# ថ្ងៃទី 03 ខែ កុម្ភៈ ឆ្នាំ២០២០

## លោក អ៊ិត សំហេង៖ បច្ចុប្បន្នពលករកម្ពុជានៅថៃស្ទើរតែ ១00% ទទួលបានសិទ្ធិស្របច្បាប់

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 03 February 2020 | 10:59 ICT

**ភ្នំពេញ៖** លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានថ្លែងថា បច្ចុប្បន្នពលករកម្ពុជាដែលធ្វើការនៅប្រទេសថៃស្ទើរតែ ១០០ ភាគរយ ទទួលបានសិទ្ធិស្របច្បាប់ក្នុងការបំពេញការងារនៅក្នុងប្រទេសនេះស្របពេលដែលប្រទេសថៃជាប្រទេសទទួលពលករពីកម្ពុជាច្រើនជាងគេ។

លោក អ៊ិត សំហេង បានថ្លែងក្នុងពិធីដាក់ឲ្យប្រើប្រាស់នូវក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសពលករឯកជនកម្ពុជាកាលពីថ្ងៃទី ២៩ ខែមករានៅសណ្ឋាគារភ្នំពេញថា មកដល់ពេលនេះកម្ពុជា ពិតជាមានមោទនភាពចំពោះភាពជោគជ័យក្នុងការអនុវត្តគោលនយោបាយទេសន្តប្រវេសន៍។ លោកបន្តថា ក្នុងរយៈពេល ៤ ឆ្នាំកន្លងមកនេះកម្ពុជាបានបញ្ចប់យុទ្ធនាការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជានៅក្នុងប្រទេសថៃដោយជោគជ័យ ហើយមកដល់ពេលនេះពលករកម្ពុជាស្ទើរតែ ១០០ ភាគរយទៅប្រទេសថៃគឺទទួលបាននូវភាពស្របច្បាប់។ លោកបន្តថា៖ «ប្រហែលជា ៦ ទៅ ៧ ឆ្នាំកន្លងមកនេះអ្នកទាំងអស់គ្នាឃើញថា យើងមានបញ្ហាប្រឈមធំ ដោយសារថាពលករទេសន្តប្រវេសន៍របស់យើងចេញទៅធ្វើការខុសច្បាប់ជាច្រើនក្នុងប្រទេសថៃក្នុងចំណោមពលកររបស់យើងនោះគឺមាន ៦០ ភាគរយដែលទៅមិនមានឯកសារគ្រប់គ្រាន់។ ផ្តើមពីបញ្ហានេះរដ្ឋាភិបាលបានបង្កើតកិច្ចសហប្រតិបត្តិការជាមួយប្រទេសដៃគូ»។

ទោះយ៉ាងណាលោក សំហេង ក៏បានទទួលស្គាល់ផងដែរ ចំពោះការខ្វះចន្លោះដែលនៅតែមានដោយពលករកម្ពុជាមួយចំនួនតូចនៅតែបន្តរស់នៅក្នុងប្រទេសថៃដោយខុសច្បាប់ដែលលោកថាក្រសួងនឹងជំរុញបន្ថែមទៀត។ លោកបញ្ជាក់ថា៖ អ្នកមិនស្របច្បាប់ហ្នឹងគឺមានតែមួយចំនួនដែលបន្តធ្វើការនៅពេលដល់ពេលកំណត់នៃកិច្ចសន្យាហើយព្យាយាមរស់នៅបន្តទៀត ដើម្បីចង់បានឱកាសរស់នៅទីនោះ ដោយមិនព្រមវិលត្រឡប់មកវិញ ដោយមិនព្រមធ្វើតាមបែបបទនីតិវិធីថ្មី។ យើងព្យាយាមសហប្រតិបត្តិការជាមួយប្រទេសទទួលដើម្បីដោះស្រាយបញ្ហានេះ។

បើតាមក្រសួងការងារគិតត្រឹមដើមឆ្នាំ ២០២០ នេះកម្ពុជាបានបញ្ជូនពលករទៅបម្រើការងារនៅបរទេសចំនួន ៦ ប្រទេសគឺប្រទេសថៃ សាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី ជប៉ុន សិង្ហបុរី និងហុងកុងដែលមានពលករសរុបចំនួនប្រមាណ ១ លាន ២ សែននាក់ហើយក្នុង ១ ឆ្នាំៗ ពួកគេទាំងនោះបានផ្ញើថវិកាមកកម្ពុជា ដើម្បីជួយទ្រទ្រង់ជីវភាពក្រុមគ្រួសារប្រមាណជាង ២ ពាន់លានដុល្លារ។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារបានប្រាប់ភ្នំពេញ-ប៉ុស្តិ៍ពីម្សិលមិញថា ក្នុងចំណោមប្រទេសទាំង ៦ ដែលកម្ពុជាបានបញ្ជូនពលករទៅធ្វើការនោះ ប្រទេសថៃស្ថិតក្នុងចំណាត់ថ្នាក់ខ្ពស់ជាងគេគឺមានជិត ១ លាន ២ សែន ខណៈប្រទេសផ្សេងៗទៀតគឺមានចំនួនតិចតួច។ លោកបញ្ជាក់ថា៖ «ខ្មែរនៅថៃគឺមានជិត ១ លាន ២ សែននាក់ ហើយក្រៅពីនោះគឺមាន ១ ពាន់ ២ ពាន់ ឬ ១ ម៉ឺន ២ ម៉ឺននាក់។ ៦ ប្រទេសបូកចូលគ្នាគឺមិនលើសពី ១ លាន ២ សែននាក់ដែរ ព្រោះនៅកូរ៉េមានជាង ៤ ម៉ឺននាក់ និងនៅម៉ាឡេស៊ីមានជាង ២ ម៉ឺននាក់ទេ ហើយក្រៅពីនោះមានមិនដល់ ១ ម៉ឺននាក់ទេ»។

កញ្ញា បូ រ៉ា ពលករម្នាក់កំពុងធ្វើការនៅថៃបានប្រាប់ភ្នំពេញប៉ុស្តិ៍ថា បច្ចុប្បន្នពលករកម្ពុជាដែលកំពុងធ្វើការនៅថៃភាគច្រើនពិតជាទទួលបានសិទ្ធិ និងធ្វើការដោយស្របច្បាប់ពិតមែន ខណៈអ្នកធ្វើការដោយខុសច្បាប់នៅមានចំនួនតិចតួច បើប្រៀបធៀបនឹងប៉ុន្មានឆ្នាំមុនៗ។ កញ្ញាបន្តថា៖ «ខ្ញុំបានមកធ្វើការនៅប្រទេសថៃនេះរយៈពេល ៦ ឆ្នាំមកហើយ។ ចំពោះបច្ចុប្បន្នដូចជាមិនមានបញ្ហាចោទអ្វីទេ សម្រាប់ពលករយើងគឺមានលក្ខណៈល្អប្រសើរច្រើន»។

លោកស្រី មាស សាឮអ៊ីម អនុប្រធានផ្នែកសិទ្ធិស្ត្រី និងកុមារនៃសមាគមអាដហុកបានលើកឡើងថា លោកស្រីមិនមានតួលេខ ដើម្បីធ្វើការផ្ទៀងផ្ទាត់ចំពោះតួលេខដែលបង្ហាញដោយក្រសួងការងារដែលថា ពលករកម្ពុជាស្ទើរតែ ១០០ ភាគរយនៅប្រទេសថៃមានសិទ្ធិស្របច្បាប់នោះទេ។ ប៉ុន្តែលោកស្រីនៅតែមើលឃើញមានករណីពលករចំណាកស្រុកត្រូវបានចាញ់បោកមេខ្យល់ ហើយបានទៅធ្វើការដោយខុសច្បាប់នៅតែបន្តមាននៅប្រទេស ថៃ។ ទោះយ៉ាងណាលោកស្រី សាទរ បើសិនជាពលករភាគច្រើនពិតជាទទួលបានសិទ្ធិស្របច្បាប់បែបនោះ ហើយអត្ថប្រយោជន៍នានារបស់ពលករនឹងត្រូវបានការពារ។ «ការផ្ដល់ភាពស្របច្បាប់នេះ គឺជាជំណាក់កាលដោះស្រាយដំបូង ហើយបញ្ហាបន្តបន្ទាប់គឺត្រូវតែមានក្នុងការបណ្ដុះបណ្ដាលពង្រឹងបន្ថែម សម្រាប់ពួកគាត់ឲ្យមានការយល់ដឹងពីសិទ្ធិកិច្ចសន្យាផ្សេងៗ ដែលពួកគាត់អាចនឹងត្រូវទទួលបាននៅមុនពេលពួកគាត់ទទួលបានសិទ្ធិស្របច្បាប់ទៅធ្វើការនៅថៃនេះក៏កាន់តែល្អ»៕

## ឪពុកចិត្តអប្រិយ យកកូនស្រីទៅលក់ឲ្យភ្ញៀវនៅផ្ទះសំណាក់ តម្លៃ៣០០ដុល្លារ

https://www.chnchannel.com/ Post ដោយ Lay Math Post ថ្ងៃទី Feb 3, 2020

**ភ្នំពេញ៖** ក្មេងស្រីម្នាក់ត្រូវឪពុកបង្កើតរបស់ខ្លួនលួងលោមយកទៅលក់ឲ្យភ្ញៀវនៅផ្ទះសំណាក់ ក្នុងតម្លៃ៣០០ដុល្លារ តែសំណាងល្អ ត្រូវក្មេងស្រីរងគ្រោះដឹងខ្លួនទាន់ពេល រត់ចេញមកក្រៅ និងប្រាប់ក្រុមគ្រួសារទៅដាក់ពាក្យបណ្ដឹងឲ្យសមត្ថកិច្ចជួយអន្តរាគមន៍ចាប់ខ្លួនឪពុកតិរច្ឆាននេះ យកទៅចាត់ការតាមផ្លូវច្បាប់ កាលពីវេលាម៉ោង១០ និង៣០នាទីយប់ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២០ នៅមុខសួន វត្តបុទុមវត្តី ។ ក្មេងស្រីរងគ្រោះមិនត្រូវបានស្គាល់អត្តសញ្ញាណទេ រីឯបុរសជាឪពុកចិត្តអប្រិយដែលលក់កូនស្រីបង្កើតរបស់ខ្លួននោះ ក៏សមត្ថកិច្ចមិនប្រាប់អត្តសញ្ញាណដែរ។

សមត្ថកិច្ចបានបង្ហើបឲ្យដឹងថា ការចាប់ខ្លួនបុរសជាឪពុកនេះ ធ្វើឡើយក្រោយពីមានពាក្យបណ្ដឹងពីគ្រួសារក្មេងស្រីរងគ្រោះ ដោយបានចោទប្រកាន់ថា បានលួងលោមកូនស្រីរបស់ខ្លួន ទៅផ្ទះសំណាក់ ដើម្បីលក់ខ្លួនឲ្យបុរសម្នាក់ទៀតក្នុងតម្លៃ៣០០ដុល្លារ ។ តែត្រូវក្មេងស្រីរងគ្រោះដឹងខ្លួន ហើយបានរត់ចេញ និងប្រើល្បិចតេទូរស័ព្ទណាត់ជួបម្ដងទៀត នៅមុខសួនខាងលើ ដើម្បីឲ្យសមត្ថកិច្ចឃាត់ខ្លួនតែម្ដង និងដកហូតថ្នាំញៀនពាកព្ធប់ផងដែរ។ ជនសង្ស័យត្រូវសមត្ថកិច្ចនាំខ្លួនមកសាកសួរ ដើម្បីកសាងសំណុំរឿងចាត់ការតាមច្បាប់ ៕

## ដាក់ឲ្យប្រើប្រាស់វីដេអូអប់រំស្ដីពីការបង្ការទប់ស្កាត់ការរៀបអាពាហ៍ ពិពាហ៍វ័យកុមារ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 31/01/2020

ខេត្តរតនគិរី ៖ នៅព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ នៅសាលប្រជុំសាលាខេត្តរតនគិរី បានប្រារព្ធធ្វើពិធីប្រកាសដាក់ឲ្យប្រើប្រាស់វីដេអូ ស្ដីពីការបង្ការទប់ស្កាត់ការរៀបអាពាហ៍ពិពាហ៍ វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់ ក្រោមអធិបតីភាព លោកជំទាវ ចក់ មើល ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ គ.ក.ស.ក និងជាសមាជិកក្រុមប្រឹក្សាខេត្ត។ កិច្ចប្រជុំនេះក៏មានការអញ្ជើញចូលរួមពី សំណាក់ ប្រធាន អនុប្រធានមន្ទីរអង្គភាពជុំវិញខេត្ត អង្គការដៃគូពាក់ព័ន្ធ និងសមាជិក សមាជិការ ជាច្រើនរូបទៀតផងដែរ។

មានប្រសាសន៍ក្នុងពិធីប្រកាសខាងលើ លោកជំទាវ ចក់ មើល បានលើកឡើងថា វិស័យសុខុមាលភាពកុមារតាមរយៈ ការកាត់បន្ថយអំពើហិង្សាលើកុមារ ត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់បំផុត ហើយរាជរដ្ឋាភិបាលបានប្រគល់ភារកិច្ច ដ៏ឧត្តុងឧត្តមនេះ ជូនក្រសួងពាក់ពន្ធ័នានា និងអាជ្ញាធរមានសមត្ថកិច្ចទទួលខុសត្រូវគ្រប់គ្រង និងដោះស្រាយ។ ដោយអនុវត្តតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

ថ្នាក់ដឹកនាំខេត្ត និងអង្គការដៃគូ បានធ្វើផែនការសកម្មភាពទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះវ័យជំទង់ សម្រាប់ខេត្តរតនគិរី ឆ្នាំ២០១៧-២០២១។ ផែនការនេះរួមចំណែកសម្រេចឲ្យបាននូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបញ្ឈប់អាពាហ៍ពិពាហ៍ក្នុងវ័យកុមារ និងការមានផ្ទៃពោះក្នុងវ័យជំទង់ដែលជាផ្នែកមួយនៃការអនុវត្តន៍ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយកាត់បន្ថយ ការមានផ្ទៃពោះរបស់មនុស្សវ័យជំទង់ និងការរៀបអាពាហ៍ពិពាហ៍ក្នុងវ័យកុមារ នៅសហគមន៍ជនជាតិដើមភាគតិច ខេត្តរតនគិរី។

ពិធីប្រកាសដាក់ឲ្យប្រើប្រាស់ផ្សព្វផ្សាយឧបករណ៍ និងវីដេអូនេះក្នុងគោលបំណង ១,ផ្សព្វផ្សាយពីឧបករណ៍អប់រំដែលបានផលិត ស្តីពីអាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់ និងណែនាំពីគម្រោងព្រមទាំង ផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធទាំងអស់ដែលមានតួនាទី និងកាតព្វកិច្ចក្នុងការទប់ស្កាត់ អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់។២,លើកកម្ពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងសហគមន៍ ជាពិសេសកុមារីជនជាតិដើមភាគតិចខ្លួនឯងផ្ទាល់ក្នុងការ ទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់។ ៣,ផ្សព្វផ្សាយបង្កើន ការយល់ដឹងពីហានិភ័យដែលពាក់ព័ន្ធលើអាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់។ លោកជំទាវបានបន្តថា នៅទូទាំងសកលលោកក្នុងមួយឆ្នាំៗមានកុមារីច្រើនជាង ១៤លាននាក់ បានរៀបអាពាហ៍ពិពាហ៍នៅវ័យកុមារ ក្រោមអាយុ១៨ឆ្នាំ។

យោងតាមការសិក្សាស្រាវជ្រាវបឋមស្តីពីអាពាហ៍ពិពាហ៍វ័យកុមារ និងកុមារជាមាតា ក្នុងចំណោម ក្មេងស្រីអាយុពី ១២ឆ្នាំដល់១៧ឆ្នាំ ខេត្តរតនគិរី ដែលរៀបចំដោយ គណៈកម្មាធិការពិគ្រោះ យោបល់កិច្ចការស្ត្រី និងកុមារខេត្តរតនគិរី ឆ្នាំ២០១៩ បានបង្ហាញថាក្មេងស្រីជាច្រើន នៅតែរៀបការនៅវ័យជំទង់។ ក្មេងស្រីជំទង់ម្នាក់ក្នុងចំណោមក្មេងស្រីជំទង់ ៩នាក់ដែលមានអាយុពី ១២ឆ្នាំ ដល់១៧ឆ្នាំ បានរៀបអាពាហ៍ពិពាហ៍។ ក្មេងស្រីជំទង់ក្នុងក្រុមអាយុពី១៥ឆ្នាំ ដល់១៧ឆ្នាំ បង្ហាញពីអត្រារៀបអាពាហ៍ពិពាហ៍ខ្ពស់ជាងក្រុមអាយុដែលក្មេង ជាង ១២ឆ្នាំ ដល់១៤ឆ្នាំ។ ស្រុកវើនសៃមានភាគរយខ្ពស់បំផុត នៃក្មេងស្រីដែលបានរៀបការ ហើយដែលមានអាយុ១២ឆ្នាំ ដល់១៧ឆ្នាំ មានចំនួន១៩% អាយុ ១៥ឆ្នាំ ដល់១៧ឆ្នាំ មាន៣៣%។ ស្រដៀងគ្នានេះដែរ ទិន្នន័យស្តីពីស្ថានភាពសម្រាលកូនបានបង្ហាញថា ស្ថានភាពសម្រាលកូនក្នុងចំណោមក្មេងស្រីវ័យជំទង់ នៅតែជាក្តីបារម្ភមួយក្នុងខេត្តរតនគិរី។

ក្មេងស្រីវ័យជំទង់ ៨% ដែលមានអាយុពី១២ឆ្នាំ ដល់ ១៧ឆ្នាំបានសម្រាលកូន ក្នុងខែវិច្ឆិកា ឆ្នាំ២០១៨។ ក្មេងស្រីម្នាក់ ក្នុងចំណោមក្មេងស្រី ៨នាក់ដែលមាន អាយុពី១៥ឆ្នាំ ដល់១៧ឆ្នាំ និងម្នាក់ក្នុងចំណោមក្មេងស្រី ២៥នាក់ ដែលមានអាយុ ១២ឆ្នាំ ដល់១៤ឆ្នាំ ត្រូវបានកត់ត្រាថាបានសម្រាលកូន។ លោកជំទាវបានថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះអង្គការយូនីសេហ្វ ដែលបានខិតខំជ្រោមជ្រែងគាំទ្រ និងប្រកាសដាក់ឲ្យប្រើប្រាស់វីដេអូអប់រំ ស្តីពីអាពាហ៍ពិពាហ៍ វ័យកុមារក្នុងខេត្តរតនគិរី។ ទន្ទឹមនេះដែរ លោកជំទាវសូមកោត សរសើរចំពោះ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត និងក្រុមការងារដែលបានយកចិត្តទុកដាក់មិនខ្លាចនឿយហត់ និងមានការអត់ធ្មត់រៀបចំពិធីសម្ពោធនេះ។ លោកជំទាវសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការជាតិ និងអន្តរជាតិទាំងអស់ដែលបានជួយដល់កុមារកម្ពុជា ធ្វើឲ្យកិច្ចការនានារីកចម្រើនជាលំដាប់៕

## ថៃ បានបញ្ជូនពលរដ្ឋខ្មែរចំនួន ០៣នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 03-02-2020

នៅរសៀលថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ ខាងភាគីថៃ បានបញ្ជូនពលរដ្ឋខ្មែរចំនួន ០៣នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកចាក់ប្រែង ខេត្តព្រះវិហារ៕

# ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០២០

## ប្រសាសន៍សំខាន់ៗសម្តេចតេជោ ហ៊ុន សែន ថ្លែងក្នុងឱកាសជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋ រស់នៅកូរ៉េខាងត្បូង

http://www.freshnewsasia.com/ 2020-02-03

**(ភ្នំពេញ)៖** នៅរសៀលថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០នេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានអញ្ជើញជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋ រស់នៅកូរ៉េខាងត្បូង នារសៀលថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០។

**ខាងក្រោមជាប្រសាសន៍សំខាន់ៗរបស់សម្តចតេជោ ហ៊ុន សែន៖**

* សម្តេចតេជោ ហ៊ុន សែន ក៏បានរំលឹកដល់ពីការខកខានមិនបានអញ្ជើញទៅកាន់ប្រទេសកូរ៉េកាលពីខែវិច្ឆិកា ឆ្នាំ២០១៩ ដោយសារស្ថានភាពជំងឺរបស់ម្តាយក្មេក។

* សម្តេចតេជោ ហ៊ុន សែន ក៏បានឆ្លៀតឆ្លើយតបចំពោះការលើកឡើថា សម្តេចគិតពីគ្រួសារច្រើនជាងការងារជាតិ។ សម្តេចតេជោ បានថ្លែងថា បើត្រឹមតែម្តាយមិនគិតផង តើពួកគេគេគិតពីប្រជាពលរដ្ឋរបៀបណា?

* សម្តេចតេជោ ហ៊ុន សែន ក៏បានថ្លែងចំអកដល់អ្នកធ្វើបាតុកម្មប្រឆាំងសម្តេច។ សម្តេចតេជោ បានថ្លែងថា ស្មានតែមហាបាតុកម្មនោះលិចទីក្រុងសេអ៊ូលទៅហើយ តែមានតែប៉ុន្មានគ្រាប់ប៉ុណ្ណោះ។

* សម្តេចតេជោ បានថ្លែងថា មិនថាតែនៅកូរ៉េខាងត្បូងទេ នៅឯអាមេរិក និងនៅអឺរ៉ុប អ្នកប្រឆាំងសម្តេច មានចំនួនមិនស្មើនឹងអ្នកគាំទ្រសម្តេចនោះឡើយ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា កម្ពុជា និងកូរ៉េខាងត្បូង បានក្លាយទៅជាជន្លងនឹងគ្នាហើយ។

* សម្តេចតេជោ បានថ្លែងថា ក្នុងជំនួបជាមួយប្រធានាធិបតី និងនាយករដ្ឋមន្ត្រីកូរ៉េខាងត្បូង សម្តេចនឹងលើកឡើងពីការរិះរកវិធីឱ្យកូនខ្មែរកាត់កូរ៉េ បានចេះភាសាខ្មែរ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងអំណរគុណដល់ខ្មែរនៅកូរ៉េ ដែលបានចំណាយពេលជួបទទួលសម្តេចនៅកូរ៉េ។

* សម្តេចតេជោ ហ៊ុន សែន បានចោទសួរថា ការផ្តើមដំណើរទេស្សនកិច្ចនៅកូរ៉េនាឆ្នាំ១៩៩៦ និងការសម្រេចចងចំណងការទូតជាមួយកូរ៉េ បានហុចផ្លែផ្កាយ៉ាងណាទៅហើយ?

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា រឿងរ៉ាវអតីតកាលរវាងកម្ពុជា និងកូរ៉េ បានឆ្លងកាត់នូវស្ថានភាពលិចអណ្តែត។

* សម្តេចតេជោ បានថ្លែងថា ការលិចអណ្តែតនេះ ដោយសារបញ្ហានៅឧបទ្វីបកូរ៉េ និងសង្គ្រាមត្រជាក់។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ជម្លោះរវាងកូរ៉េខាងជើង និងខាងត្បូង ធ្វើឱ្យនយោបាយការទូតរបស់កម្ពុជាមានការប្រែប្រួល។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា សម្តេចបានប្រឹងប្រែងក្នុងការធ្វើឱ្យមានតុល្យភាពរវាងកូរ៉េខាងត្បូង និងខាងជើង។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងរំលឹកពីការវិវឌ្ឍន៍នៃទំនាក់ទំនងការទូតរវាងកម្ពុជា និងកូរ៉េខាងត្បូង រហូតឈានដល់កូរ៉េខាងត្បូង ព្រមបង្កើតស្ថានទូតនៅកម្ពុជា។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា បន្ទាប់ពីការពន្យល់របស់សម្តេច កូរ៉េខាងត្បូង បានយល់ព្រមដំឡើងកម្រិតពីស្ថានបេសកកម្មទៅជាស្ថានទូត ពីតំណាងបេសកកម្ម ទៅជាឯកអគ្គរដ្ឋទូត។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ទំនាក់ទំនងរវាងកម្ពុជា និងកូរ៉េខាងត្បូង មកដល់ពេលបច្ចុប្បន្នទទួលបានជោគជ័យខ្លាំងណាស់។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា បើសិនសម្តេចមិនចុះហត្ថលេខាចងការទូតជាមួយកូរ៉េខាងត្បូងកាលពីឆ្នាំ១៩៩៦ទេ ច្បាស់ជាមិនមានវត្តមានពលរដ្ឋខ្មែរនៅកូរ៉េខាងត្បូងនាពេលនេះផងដែរ។

* សម្តេចតេជោ ហ៊ុន សែន បានរំលឹកថា ពេលកម្ពុជា សម្រេចចងការទូតជាមួយកូរ៉េខាងត្បូង គឺមានការព្រួយបារម្ភប៉ះពាល់ដល់ទំនាក់ទំនងរវាងកម្ពុជា ជាមួយកូរ៉េខាងជើង។

* សម្តេចតេជោ បានថ្លែងថា វាមិនយុត្តិធម៌ឡើយ ដែលកូរ៉េខាងជើង និងខាងត្បូង មានអាសនៈនៅអង្គការសហប្រជាជាតិ តែកម្ពុជាមិនអាចធ្វើទំនាក់ទំនងជាមួយកូរ៉េខាងត្បូង។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ព្រោះតែបញ្ហានេះហើយ ទើបសម្តេចតែងប្រាប់ទៅមន្ត្រីការទូតថា ការសម្រេចចិត្តផ្នែកនយោបាយទាំងក្នុង និងក្រៅប្រទេស គឺត្រូវយកផលប្រយោជន៍ជាតិ និងឯករាជ្យជាតិជាចម្បង។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ការបង្កើតទំនាក់ទំនងរវាងកម្ពុជា និងកូរ៉េខាងត្បូង ជាសច្ចភាពប្រវត្តិសាស្ត្រ ដែលគេមិនអាចយកដៃទៅបាំងបាននោះឡើយ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា លោក លី ម្យុងបាក់ បានបង្ហាញប្រវត្តិជាទីប្រឹក្សាសេដ្ឋកិច្ចរបស់សម្តេចក្នុងពេលធ្វើយុទ្ធនាការឃោសនារកសំឡេងឆ្នោត។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា កម្ពុជាពិតជាមានមោទនភាព ដែលបានប្រឹងប្រែងសម្របសម្រួលឱ្យមានកិច្ចប្រជុំកំពូលខួបទំនាក់ទំនងរវាងកម្ពុជា និងកូរ៉េខាងត្បូង ដែលធ្វើឡើងប៊ូសាន កាលពីឆ្នាំ២០១៩។

* សម្តេចតេជោ ហ៊ុន សែន ក៏បានថ្លែងបង្ហាញមោទនភាពផងដែរ ដែលកម្ពុជា បានសម្របសម្រួលឱ្យមានការលើកកម្រិតទំនាក់ទំនងមេគង្គ និងកូរ៉េខាងត្បូង។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា មកដល់ពេលនេះ បើនិយាយពីចំនួនពលរដ្ឋខ្មែរមកនៅកូរ៉េ មានដល់ទៅ៦៥,៥០០នាក់។

* សម្តេចតេជោ ហ៊ុន សែន បានបង្ហាញថា ពលរដ្ឋដែលរស់នៅកូរ៉េខាងត្បូង រួមមាន៖ ចិន១លាន ១សែននាក់, ថៃ២០ម៉ឺននាក់, ហ្វីលីពីន ៧៨,០០០នាក់, វៀតណាម ២២ម៉ឺននាក់។

* សម្តេចតេជោ ហ៊ុន សែន បានចោទសួរថា ថៃកំពុងខ្វះពលករយកពីកម្ពុជា មីយ៉ាន់ម៉ា និងឡាវ តែហេតុអ្វីបានជាពលរដ្ឋថៃទៅធ្វើពលករនៅកូរ៉េរហូតដល់ជាង ២ម៉ឺននាក់?

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ថៃមិនមានពលករធ្វើការនៅថៃនោះទេ តែមាននៅមជ្ឈឹមបូព៌ាជាច្រើនទៀត។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា បើមិនចង់ឱ្យពលរដ្ឋខ្មែរធ្វើការនៅកូរ៉េខាងត្បូងមិនលំបាកទេ គឺគ្រាន់តែលុបកិច្ចព្រមព្រៀងជាមួយកូរ៉េខាងត្បូងជាការស្រេចប៉ុន្តែសម្តេចមិនធ្វើតាមការលើកឡើងរបស់ក្រុមប្រឆាំងនោះទេ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ជាមួយថៃ ក៏ដូចគ្នាបើមិនចង់ឱ្យពលរដ្ឋទៅធ្វើការនៅថៃ គឺលុបកិច្ចព្រមព្រៀងជាមួយថៃជាការស្រេច។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ពលករខ្មែរដែលរស់នៅមិនស្របច្បាប់នៅកូរ៉េខាងត្បូងប្រមាណជា ៧ពាន់នាក់។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ពលករខ្មែរមិនស្របច្បាប់មួយចំនួន ដើម្បីបានរស់នៅកូរ៉េខាងត្បូង គឺប្រឹងជេររាជរដ្ឋាភិបាល។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ត្រូវមើលឱ្យឃើញពីទំនាក់ទំនងល្អរវាងកម្ពុជា និងកូរ៉េខាងត្បូង។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា សម្តេចអរគុណណាស់ដល់ថៅកែកូរ៉េ ដែលបានវាយតម្លៃខ្ពស់ចំពោះពលកម្មពលករខ្មែរ។

* សម្តេចតេជោ ហ៊ុន សែន បានស្នើសុំថៅកែកូរ៉េខាងត្បូង ជួយមើលថែទាំចំពោះពលករខ្មែរ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា រាជរដ្ឋាភិបាលមិនមែនឱ្យពលករទៅធ្វើការនៅក្រៅប្រទេស ហើយឱ្យធ្វើបាបសង្កត់សង្កិននោះទេ។

* សម្តេចតេជោ ហ៊ុន សែន សរសើរលោក ឡេង ណាវ៉ាត្រា ដែលបានប្រែខ្លួនពីពលករ ទៅជាអ្នករកស៊ីលើវិស័យអចនទ្រព្យ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ២០១៩ ទំហំពាណិជ្ជកម្ម ៧៧៨លានដុល្លារ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា កម្ពុជានាំទៅកូរ៉េខាងត្បូង មានប្រមាណ ៣៣៥លានដុល្លារ ខណៈកម្ពុជានាំពីកូរ៉េមានប្រមាណ ៦៩៦លានដុល្លារ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ទំនាក់ទំនងពាណិជ្ជកម្មនេះ បានផ្តើមចេញពីទំនាក់ទំនងល្អរវាងប្រទេសទាំងពីរ។

* សម្តេចតេជោ ហ៊ុន សែន បានសាទរចំពោះការនាំស្វាយចេញទៅលក់នៅកូរ៉េខាងត្បូង តែសម្តេចណែនាំឱ្យពិនិត្យនូវគុណភាព ដើម្បីចៀសវាងការលក់ថ្លូវ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា រិះរកវិធីពង្រីកទីផ្សារនៅកូរ៉េខាងត្បូងឱ្យកាន់តែធំថែមទៀត។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា កម្ពុជា និងកូរ៉េខាងត្បូងអាចចាប់ដៃគ្នាបាន ព្រោះតែសុចន្ទៈ និងការរកស៊ីជាមួយគ្នាបាន។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០១៨ កូរ៉េខាងត្បូង ផ្តល់ជំនួយឥតសំណងជាង ៣០០លានដុល្លារអាមេរិក។ ឆ្នាំ២០១៩កន្លងទៅ ជំនួយឥតសំណងមាន ១៧លានដុល្លារ និងឆ្នាំ២០២០ គ្រោងផ្តល់ ២៤លានដុល្លារ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៩ កូរ៉េខាងត្បូងផ្តល់កម្ចីសម្រាប់អភិវឌ្ឍន៍ប្រមាណ ៨៨៩លានដុល្លារ បើកប្រើប្រាស់ ៤៤២លានដុល្លារ។ ត្រៀមផ្តល់នៅឆ្នាំ២០១៩ ដល់២០២៣ ប្រមាណ ៧០០លានដុល្លារបន្ថែមទៀត សម្រាប់ការអភិវឌ្ឍន៍គម្រោងចំនួន១០។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ការស្តាបនាឡើងវិញផ្លូវជាតិលេខ២ លេខ២២ ដែលបើកការដ្ឋាននៅថ្ងៃទី ១១ ខែកុម្ភៈ ទទួលបានកម្ចីពីកូរ៉េខាងត្បូង។ ផ្លូវជាតិ៤៨ បំបែកពីផ្លូវជាតិលេខ៤ ទៅកោះកុង ក៏ប្រើកម្ចីរបស់កូរ៉េខាងត្បូងផងដែរ។

* សម្តេចតេជោ ហ៊ុន សែន ក៏បានថ្លែងបង្ហាញបំណងស្នើកូរ៉េខាងត្បូង ផ្តល់ជំនួយសម្រាប់សាងសង់ស្ពានឆ្លងកាត់ទន្លេនៅកម្ពុជាផងដែរ។

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា អ្នកស្រុកស្ទឹងត្រង់បានធ្វើនាយករដ្ឋមន្ត្រី៣រូបហើយ បូករួមទាំងសម្តេចផង។

* នាយករដ្ឋមន្ត្រីទាំង៣រូបនោះ រួមមាន៖ លោក អ៊ិន តាំ, លោក ហង់ ធុនហាក់ និង សម្តេចតេជោ ហ៊ុន សែន។

* សម្តេចតេជោ ហ៊ុន សែន គ្រើនរំលឹកដល់ពលករខ្មែរនៅកូរ៉េខាងត្បូង ឱ្យធ្វើការដោយគោរពច្បាប់នៅកូរ៉េ ហើយនិស្សិតខិតខំរៀនសូត្រ យកចំណេះជួយអភិវឌ្ឍន៍ប្រទេសវិញ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ក្នុងមួយសប្តាហ៍ការហោះហើរវាងកម្ពុជា និងកូរ៉េខាងត្បូង មានប្រមាណ ៥០ជើង។

* សម្តេចតេជោ ហ៊ុន សែន បានប្រកាសថា សម្តេចនឹងអញ្ជើញទៅទីក្រុងវូហាន ដើម្បីសួរសុខទុក្ខប្រជាពលរដ្ឋខ្មែរនៅទីនោះ បើរដ្ឋាភិបាលចិនអនុញ្ញាតឲ្យទៅ

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា សម្តេចហ៊ានយកជីវិតធ្វើដើមទុន ដើម្បីសង្គ្រោះជាតិ រឿងអ្វីដែលសម្តេចមិនហ៊ានទៅវូហាន សួរសុខទុក្ខនិស្សិត។

* សម្តេចតេជោ ហ៊ុន សែន បានណែនាំឱ្យទាក់ទងទៅរដ្ឋាភិបាលចិន ដើម្បីរៀបចំដំណើរទៅទីក្រុងវូហាន។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា សម្តេចបានណែនាំទៅអាកាសចរណ៍កម្ពុជា មិនឱ្យបិទការហោះហើរជាមួយចិននោះឡើយ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា មកដល់ពេលនេះមិនទាន់មានពលរដ្ឋខ្មែរណាម្នាក់កើតជំងឺផ្លូវដង្ហើម «កូរ៉ូណា» នោះឡើយ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ឱ្យតែរដ្ឋាភិបាលចិនអនុញ្ញាត សម្តេចនឹងទៅសួរសុខទុក្ខនិស្សិតខ្មែរនៅវូហាន។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងរំលឹកពីការសម្រេចចិត្តរបស់សម្តេច ដោយមិនជម្លៀសពលរដ្ឋខ្មែរនៅកូរ៉េខាងត្បូងកាលពីអំឡុងឆ្នាំ២០១៥ ពេលកូរ៉េទាំងពីរប្រឈមនឹងការផ្ទុះសង្គ្រាម។ ដោយសម្តេចចាត់ទុកការសម្រេចចិត្តនោះ ជារឿងត្រឹមត្រូវមួយ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា អ្នកមិនយល់មិនបាច់ពន្យល់ទេ ព្រោះពិបាកពន្យល់ណាស់សម្រាប់អ្នកធ្វើមិនយល់។ គ្មានអ្វីពិបាកជាងអ្នកមិនពិការក្អែកធ្វើពិការ អ្នកមិនថ្លង់ ធ្វើជាថ្លង់នោះទេ។

* សម្តេចតេជោ ហ៊ុន សែន ចង់ត្រឡប់ពីកូរ៉េខាងត្បូង ទៅសួរសុខទុក្ខនិស្សិតនៅទីក្រុងវូហាន ព្រោះត្រូវហោះកាត់ប្រទេសចិន។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា មកដល់ពេលនេះប្រទេសជាច្រើនសុទ្ធតែកើតមានជំងឺផ្លូវដង្ហើម «កូរ៉ូណា» ដូច្នេះបើបិទជើងហោះហើរត្រូវបិទទាំងអស់។ បច្ចុប្បន្នមានតែឡាវមួយប៉ុណ្ណោះ ដែលមិនទាន់មានកើតជំងឺនេះ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា សម្តេចមិនយល់ទេ ចំពោះអ្នកដែលថ្លែងផ្ទាញ់ផ្ទាលសម្តេចរឿងថា រួមសុខរួមទុក្ខជាមួយចិន។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ការកើតមេរោគថ្មីៗនេះ គឺជាការបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ ដែលពិភពលោកកំពុងរួមគ្នាដោះស្រាយ។ សម្តេចតេជោ បានថ្លែងថា បញ្ហានេះគ្មានអ្វីក្រៅពីការប្រឹងប្រែងរួមគ្នាដោះស្រាយនោះទេ។

* សម្តេចតេជោ ហ៊ុន សែន ថ្លែងរំពឹងថា ទំនាក់ទំនងរវាងកូរ៉េខាងត្បូង និងខាងជើង នៅតែល្អប្រសើរ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងប្រាប់ពលករខ្មែរនៅកូរ៉េខាងត្បូងថា បើថ្ងៃមុខនៅកូរ៉េមានបញ្ហាអ្វីសុំកុំមានការស្លន់ស្លោរ។ បើពលរដ្ឋកូរ៉េខាងត្បូង រស់យ៉ាងម៉េច ត្រូវរស់នៅដូចគេ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា កម្ពុជាទទួលបានផលប្រយោជន៍ច្រើន ក្នុងការដាក់ទំនាក់ទំនងការទូតរវាងកម្ពុជា និងកូរ៉េខាងត្បូង។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា សម្តេច ជាជនជោគជ័យម្នាក់ នៅក្នុងនយោបាយកូរ៉េ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ទំនាក់ទំនងជាមួយកូរ៉េខាងជើង នៅតែបន្ត មិនធ្វើសត្រូវជាមួយកូរ៉េខាងជើងនោះទេ។

* សម្តេចតេជោ ហ៊ុន សែន នៅតែបន្តឱ្យមានការចរចារវាងកូរ៉េខាងជើង ជាមួយភាគីពាក់ព័ន្ធ។

* សម្តេចតេជោ ហ៊ុន សែន បានស្លាយយកសៀវភៅអប់រំទូន្មានរបស់បណ្ឌិត អ៊ូ ចុង និងបណ្តាំក្រុមង៉ុយ ទៅជូនពលករខ្មែរនៅកូរ៉េខាងត្បូង។
* សម្តេចតេជោ ហ៊ុន សែន បានបញ្ចប់ការថ្លែងសំណេះសំណាលជាមួយនៅវេលាម៉ោង ១៧៖៣០នាទីម៉ោងនៅកម្ពុជា, សូមអរគុណចំពោះការទស្សនាផ្សាយផ្ទាល់៕

## ពលករខ្មែរនៅកូរ៉េជាង៣ម៉ឺននាក់ បញ្ជូនប្រាក់មកគ្រួសារនៅកម្ពុជា ជាង៤០០លានដុល្លារ ក្នុងមួយឆ្នាំ

https://thmeythmey.com/ 03, Feb 2020 , 10:59 pm ដោយ: ធឿន បញ្ញាឫទ្ធិ

ភ្នំពេញ៖ ពលករខ្មែរជាង៣ម៉ឺននាក់ ដែលបំពេញការងារនៅកូរ៉េខាងត្បូង បានបញ្ជូនប្រាក់មកជួយគ្រួសារនៅកម្ពុជា ជាង៤០០លានដុល្លារក្នុងមួយឆ្នាំ។ នេះជាការបញ្ជាក់របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋខ្មែរ នៅកូរ៉េខាងត្បូង នារសៀលថ្ងៃទី៣ កុម្ភៈនេះ។ សម្តេច ហ៊ុន សែន បានអះអាងថា រដ្ឋាភិបាលបញ្ជូនពលករខ្មែរ ទៅធ្វើការនៅក្រៅប្រទេសនេះ មិនមែនជាការធ្វើបាបពួកគេនោះទេ ប៉ុន្តែវាជួយពួកគេឱ្យមានលទ្ធភាពរកថវិកាច្រើនសម្រាប់ជួយគ្រួសារប៉ុណ្ណោះ។ ប្រមុខរដ្ឋាភិបាល ក៏បានលើកឡើងថា ពលករខ្មែរ ដែលមកធ្វើការនៅកូរ៉េជាង៣ម៉ឺននាក់នេះ អាចទទួលបានទាំងប្រាក់ខែខ្ពស់ និងជំនាញផងដែរ។

ជាមួយគ្នានេះលោកនាយករដ្ឋមន្ត្រីកម្ពុជា ក៏ផ្តាំឱ្យពលករទាំងអស់ ប្រឹងប្រែងបំពេញការងារ និងយកជំនាញរបស់ខ្លួន ទុកមកបម្រើការងារ និងរកស៊ីវិញនៅកម្ពុជាផងដែរ នៅពេលដែលចប់អាណត្តិការងារ។ ក្រៅពីពលករស្របច្បាប់នេះ ក៏មានពលរដ្ឋខ្មែរខុសច្បាប់ជាង៧ពាន់នាក់ ដែលកំពុងរស់នៅកូរ៉េខាងត្បូងផងដែរ។ រដ្ឋាភិបាលកំពុងអន្តរាគមន៍ជួយរៀបចំភាពស្របច្បាប់ឱ្យពួកគេ។ «ខ្មែររស់នៅមិនស្របច្បាប់នៅកូរ៉េខាងត្បូងជាង៧ពាន់នាក់ យើងក៏ខិតខំប្រែក្លាយអ្នកទាំងនោះឱ្យស្របច្បាប់វិញដែរ បើទោះអ្នកទាំងនោះប្រឹងគេចខ្លួន ដើម្បីរស់នៅទីនេះ»។ នេះជាការបញ្ជាក់នាយករដ្ឋមន្ត្រី ដែលបានបន្ថែមថា សម្តេចនឹងពិភាក្សាជាមួយប្រធានាធិបតីកូរ៉េ លោក មូន ចេអ៊ីន (Moon Jae-in) ដើម្បីពិភាក្សាលើកិច្ចសហប្រតិបត្តិការទ្វេភាគី ក៏ដូចជាបញ្ហាតំបន់ និងអន្តរជាតិ និងលក្ខខណ្ឌការងារពលករ។ ទំហំពាណិជ្ជកម្មកម្ពុជា-កូរ៉េ នៅឆ្នាំ២០១៩ មានចំនួន១,០៣២លានដុល្លារអាមេរិក ដោយក្នុងនោះកម្ពុជានាំចេញទៅកូរ៉េ៣៣៥លានដុល្លារ ហើយកូរ៉េនាំចូលកម្ពុជា ជិត៧០០លានដុល្លារអាមេរិក៕

## កម្ពុជា នៅប្រឈមបញ្ហាក្នុងការដោះស្រាយចំពោះពលករគ្មានច្បាប់

http://bayontv.com.kh/ 04/02/2020

ភ្នំពេញ ៖ ថ្នាក់ដឹកនាំគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ) នៃប្រទេសកម្ពុជា បានឱ្យដឹងថា ពលករខ្មែរ ដែលទៅធ្វើការប្រទេសគេ ដោយគ្មានច្បាប់ត្រឹមត្រូវ បានធ្វើឲ្យរាជរដ្ឋាភិបាល ពិបាកក្នុងការដោះស្រាយ ប៉ុន្តែអង្គការអន្តរជាតិទេសន្តប្រវេសន៍ ហៅកាត់ថា IOM បន្តលើកទឹកចិត្តជានិច្ច ចំពោះកម្ពុជា ដើម្បីស្វែងរកដំណោះស្រាយសម្រាប់ពលករ ដែលខុសច្បាប់ទាំងនោះ។ ប្រទេសកម្ពុជា នៅថ្ងៃនេះ បានធ្វើជាម្ចាស់ផ្ទះ នៃសិក្ខាសាលាសម្របសម្រួលថ្នាក់តំបន់ ស្តីពីការធ្វើ ចំណាកស្រុកដោយសុវត្ថិភាព របស់ប្រទេសបញ្ជូន (កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម) ដែលក្រោយការថ្លែងបើកសិក្ខាសាលានេះ។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន អចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ) នៃប្រទេសកម្ពុជា បានបញ្ជាក់ប្រាប់អ្នកសារព័ត៌មានថា សព្វថ្ងៃនេះ ពលករខ្មែរ ដែលបានទៅធ្វើការនៅក្រៅប្រទេស មានចំនួន រហូតដល់ជាងមួយលាននាក់ ទាំងស្របច្បាប់ និងមិន

ស្របច្បាប់ ប៉ុន្តែអ្វីដែលកម្ពុជា កំពុងមានការព្រួយ បារម្ភខ្លាំង ក្នុងការដោះស្រាយជូនពួកគេនោះ គឺបញ្ហាពួកគេទៅដោយខុសច្បាប់ ហើយជួបប្រទះ នឹងវិបត្តិ ផ្សេងៗ។

អ្នកស្រី គ្រីស្ទីន ប៉ាឡូ (Kristin Palo) ប្រធានបេសកកម្ម របស់អង្គការអន្តរជាតិទេសន្តប្រវេសន៍ IOM ប្រចាំនៅកម្ពុជា បានថ្លែងថា បញ្ហាទេសន្តប្រវេសន៍ គឺជាបញ្ហាមួយ ដែលត្រូវរួមគ្នាដោះស្រាយ មិនថា ប្រទេសដែលបញ្ជូនពលករ និងប្រទេស ដែលទទួលពលករទាំងនោះទេ ហើយអង្គការIOM បន្តគាំទ្រ និង កោតសរសើរយ៉ាងខ្លាំងចំពោះការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយរាល់បញ្ហាទេសន្តប្រវេសន៍នេះ។

សិក្ខាសាលាសម្របសម្រួលថ្នាក់តំបន់ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពរបស់ប្រទេស បញ្ជូន ដែលមានប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាមនេះ គឺដើម្បីបន្តស្វែងរកដំណោះស្រាយ បន្ថែមចំពោះប្រជាជនរបស់ខ្លួន ដែលបានបញ្ជូន និងលួចទៅធ្វើការនៅប្រទេសដទៃ ខណៈដែលពួកគេ បានជួប នឹងបញ្ហាផ្នែកច្បាប់ និងបញ្ហាផ្សេងៗនោះ។ សិក្ខាសាលានេះ គឺធ្វើឡើងចំនួនពីរថ្ងៃ គឺចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៥ ខែកុម្ភៈ នេះ ដោយប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះ៕

## កម្ពុជាធ្វើជាម្ចាស់ផ្ទះសិក្ខាសាលាសម្របសម្រួលថ្នាក់តំបន់ស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព

http://www.freshnewsasia.com/ 2020-02-04

**(ភ្នំពេញ)៖** ប្រទេសកម្ពុជា ត្រូវបានផ្តល់កិត្តិយសឲ្យធ្វើជាម្ចាស់ផ្ទះ នៃសិក្ខាសាលាសម្របសម្រួលថ្នាក់តំបន់ស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាពរបស់ប្រទេសបញ្ជូន (កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម) CLMV រយៈពេលពីរថ្ងៃ ចាប់ពីថ្ងៃទី០៤ ដល់ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០។

ពិធីបើកសិក្ខាសាលានៅព្រឹកថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០នេះ ធ្វើឡើងក្រោមអធិបតីលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធ ប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ), តំណាងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (ថ្នាក់តំបន់) IOM និងតំណាងស្ថានទូតអាមេរិក។ លោកស្រី ជូ ប៊ុនអេង បានឲ្យដឹងថា សិក្ខាសាលានេះធ្វើឡើងក្នុងគោលបំណងចែករំលែកបទពិសោធន៍ជាមួយគ្នា អំពីបញ្ហាទេសន្តរប្រវេសន៍ ដែលឈានទៅដល់ការជួញដូរ ឬកេងប្រវ័ញ្ចកម្លាំងពលកម្មរបស់ពលករ។ ក្នុងរយៈពេលពីរថ្ងៃនេះ ភាគីពាក់ព័ន្ធនឹងអាចមានព័ត៌មាន ជាមួយការផ្តួចផ្តើមថ្មីៗ ដែលប្រទេសទាំងបួន អាចចែករំលែកជាមួយគ្នាអំពីបទពិសោធន៍ និងការអនុវត្តល្អ នៅតាមប្រទេសនីមួយដើម្បីឆ្លើយតបទៅនឹងទេសន្តប្រវេសន៍។ លោកស្រីបន្ថែមថា ទាំងកម្ពុជា និងប្រទេស៣ផ្សេងទៀត សង្ឃឹមយ៉ាងជឿជាក់ថា ប្រទេសទាំងបួន នឹងមានកិច្ចសហការល្អជាមួយគ្នាបន្តទៀត ដែលត្រៀមលក្ខណៈដើម្បីឈានទៅដដែកពិភាក្សាជាមួយប្រទេសគោលដៅ ដែលអាចផ្តើមពីប្រទេសថៃ។

បើតាមលោកស្រី ជូ ប៊ុនអេង បញ្ហាប្រឈមដែលកម្ពុជា, ឡាវ , មីយ៉ាន់ម៉ា និងវៀតណាម ជួបប្រទះកន្លងទៅ គឺការដោះស្រាយបញ្ហាច្បាប់ ព្រោះដោយសារតែពលករមួយចំនួន មិនមានឯកសារច្បាប់ត្រឹមត្រូវ ហើយប្រទេសបញ្ជូន និងប្រទេសគោលដៅបានឯកភាពគ្នា ក្នុងការផ្តល់ឯកសារច្បាប់ ជូនពួកគាត់ដែលចំណាកស្រុកទាំងអស់នោះ។ អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានអះអាងទៀតថា រហូតមកដល់ពេលនេះ កម្ពុជាមានពលករនៅក្រៅប្រទេស ប្រមាណ១.២លាននាក់ ក្នុងនោះពលករដែលខុសច្បាប់ច្រើនជាងគេ គឺទៅប្រទេសថៃ ដែលក្រសួង និងស្ថាប័នពាក់ព័ន្ធកំពុងតែខិតខំរិះរក គ្រប់មធ្យោបាយទាំងឡាយណា ដើម្បីដោះស្រាយជូនពួកគាត់ឲ្យក្លាយជាពលករស្របច្បាប់។

ជាមួយគ្នានេះ លោកស្រី Kristin Parco តំណាងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (ថ្នាក់តំបន់) IOM នៅកម្ពុជា ក៏បានបង្ហាញនូវការស្ងប់ស្ងែងរបស់ចំពោះប្តេជ្ញាចិត្តខ្ពស់ របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការទប់ស្កាត់ការធ្វើចំណាក់ស្រុកដោយខុសច្បាប់។ តំណាងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (ថ្នាក់តំបន់) IOM នៅកម្ពុជា បានអះអាងថា ទាំងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងច្បាប់បទដ្ឋានគតិយុត្តផ្សេងៗ គឺរាជរដ្ឋាភិបាលកម្ពុជា បានដាក់ចូលដើម្បីពិភាក្សាដោះស្រាយបញ្ហាទេសន្តរប្រវេសន៍ដែលមិនប្រក្រតីនេះ៕

# ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០២០

## សម្តេចក្រឡាហោម ស ខេង អនុញ្ញាតឱ្យគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចូលជួបសម្តែងការគួរសម

http://cambodiapolice.com/policekh/ 5:15 pm 5 កុម្ភៈ 2020 79

**ភ្នំពេញ៖** នៅរសៀលថ្ងៃពុធ ១២កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ ២០២០នេះ សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី បានអនុញ្ញាតឱ្យគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហៅកាត់ថា គ.ជ.ប.ជ ដឹកនាំគណៈប្រតិភូ នៃក្រុមប្រទេសបញ្ជូនពលករទៅក្រៅប្រទេស រួមមាន កម្ពុជា,ឡាវ,មីយ៉ាន់ម៉ា និងវៀតណាម ចូលជួបសម្តែងការគួរសម នៅទីស្តីការក្រសួងមហាផ្ទៃ។

នៅក្នុងឱកាសចូលជួបសម្តែងការគួរសមនេះ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានប្រសាសន៍ជម្រាបប្រាប់ក្រុមអ្នកសារព័ត៌មានឱ្យដឹងថា គណៈប្រតិភូ បានគោរពរាយការណ៍ជូនសម្តេចក្រឡាហោម អំពីលទ្ធផលនៃកិច្ចប្រជុំ ដែលកម្ពុជាបានទទួលធ្វើជាម្ចាស់រយៈពេល២ថ្ងៃ ដោយមានការអញ្ជើញចូលរួមពីប្រតិភូនៃប្រទេសបញ្ជូនពលករទៅក្រៅប្រទេសទាំង៤។ លោកជំទាវបានមានប្រសាសន៍ថា ពលករនៃប្រទេសទាំង៤ កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម សុទ្ធតែមានស្ថានភាពប្រឈមដូចៗគ្នាក្នុងពេលចេញទៅធ្វើការនៅក្រៅប្រទេស ដែលជាប្រទេសគោលដៅ។ ដូច្នេះប្រទេសបញ្ជូនទាំង៤ បានផ្លាស់ប្តូរយោបល់គ្នាអំពីបទពិសោធន៍រៀងៗខ្លួន ទាំងចំណុចល្អ និងចំណុចខ្វះខាត ដើម្បីបានរៀនសូត្រពីគ្នាទៅវិញទៅមក ធ្វើយ៉ាងណាឱ្យពលករនៃប្រទេសរៀងៗខ្លួន បានចេញទៅបំពេញការងារដោយស្របច្បាប់ ទទួលបានអត្ថប្រយោជន៍ និងការការពារត្រឹមត្រូវ។

បន្ទាប់ពីបញ្ចប់កិច្ចប្រជុំនៅកម្ពុជា ប្រទេសទាំង៤ បានរួមគ្នារកឃើញនូវដំណោះស្រាយជាក់លាក់ជាច្រើន ប៉ុន្តែលោកជំទាវបានរាយការណ៍ជូនសម្តេចថា យន្តការនេះត្រូវការការគាំទ្រពីថ្នាក់ដឹកនាំប្រទេស ទាំងការទទួលស្គាល់បញ្ហាដែលមន្ត្រីបច្ចេកទេសបានរកឃើញ និងការដាក់ចេញបន្ថែមនូវដំណោះស្រាយក្នុងកម្រិតសេចក្តីសម្រេចផ្នែកនយោបាយ ពីព្រោះកន្លងមកប្រទេសបញ្ជូនទាំង៤ មានតែកិច្ចព្រមព្រៀងជាមួយប្រទេសទទួលពលករ ឬប្រទេសគោលដៅប៉ុណ្ណោះ ពោលគឺមិនមានយន្តការ ឬកិច្ចព្រមព្រៀងជាមួយគ្នាឡើយ។

បន្ទាប់ពីបានស្តាប់នូវសេចក្តីគោរពរាយការណ៍ ដូចដែលលោកជំទាវរដ្ឋលេខាធិការ បានបញ្ជាក់នេះមក សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី បានមានប្រសាសន៍ណែនាំបន្ថែមឱ្យមន្ត្រីពាក់ព័ន្ធទាំង៤ប្រទេស បន្តបង្កើនការសហការគ្នា ហើយអ្វីដែលបានរកឃើញនោះ សម្តេចបានជំរុញឱ្យបន្តការអនុវត្ត និងគួរបើកចំហរការចូលរួមពីប្រទេសក្នុងតំបន់ផ្សេងទៀត ដែលមានបញ្ហាប្រហាក់គ្នា ដើម្បីបានចូលរួមចែករំលែកបទពិសោធន៍ និងរួមវិភាគទានជាគំនិត ក្នុងការបង្កើតយន្តការសហប្រតិបត្តិការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៕

# កម្ពុជានិង៣ប្រទេសទៀត រួមគ្នាទប់ស្កាត់ការជួញដូរមនុស្ស

https://www.dap-news.com/national/ ByVNT108 Posted on February 5, 2020

ភ្នំពេញ ៖ កម្ពុជានិង៣ប្រទេសផ្សេងទៀត ក្នុងតំបន់អាស៊ាន បានរួមគ្នាផ្លាស់ប្តូរយោបល់ ដើម្បីរកដំណោះស្រាយ សម្រាប់ពលករ ដែលជួបបញ្ហាការជួញដូរមនុស្ស ទៅប្រទេសផ្សេងទៀត ព្រោះការជួញដូរមនុស្សនៅតែបន្តកើតមាន។ ប្រទេសទាំង៣នោះរួមមាន ៖ វៀតណាម ឡាវ និងមីយ៉ាន់ម៉ា។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស(គ.ជ.ប.ជ) បានឲ្យដឹងបន្ទាប់ពីបញ្ចប់ជំនួប រវាងសម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី និងតំណាងប្រទេស ដែលបានបញ្ជូនពលករចំណាកស្រុក នៅនារសៀលថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០ថា «ពួកយើងបានជួបពិភាក្សាគ្នា អំពីពលករដែលបានបញ្ជូន ទៅក្រៅប្រទេស ហើយនាំគ្នាដោះស្រាយរួម និងផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក ដើម្បីកាត់ភាពរងគ្រោះរបស់ពលករ ដែលបានទៅធ្វើការងារនៅក្រៅប្រទេស»។

កម្ពុជា វៀតណាម ឡាវ មីយ៉ាន់ម៉ា ព្រមទាំងអង្គការអន្តរជាតិទេសន្តប្រវេសន៍ (IOM) បានបើកសិក្ខាសាលាសម្របសម្រួលថ្នាក់តំបន់ ស្តីពីការធ្វើចំណាកស្រុក ដោយសុវត្ថិភាពដែលបានបញ្ជូនពលករចំណាកស្រុក។ សិក្ខាសាលានេះ ដើម្បីបន្តស្វែងរកដំណោះស្រាយបន្ថែម ចំពោះប្រជាជនរបស់ខ្លួន ដែលបានបញ្ជូននិងលួចទៅធ្វើការនៅប្រទេស។ សិក្ខាសាលានេះ ធ្វើឡើង២ថ្ងៃចាប់ពីថ្ងៃទី៤-៥ កុម្ភៈ ដោយកម្ពុជាធ្វើជាម្ចាស់ផ្ទះ ៕ ដោយ៖ អេង ប៊ូឆេង

# របាយការណ៍បង្ហាញថា ពលកម្មកុមារបន្តកើតមានក្នុងឧស្សាហកម្មឡឥដ្ឋ

https://khmer.voanews.com/ 06 កុម្ភៈ 2020 ហ៊ុល រស្មី

មន្ត្រីសិទ្ធិមនុស្សស្នើឲ្យរដ្ឋាភិបាលមានឆន្ទៈនយោបាយពិតប្រាកដដើម្បីកាត់បន្ថយពលកម្មកុមារ និងការជំពាក់បំណុលនេះដោយសន្សឹមៗ។

ភ្នំពេញ៖ ជាងពាក់កណ្តាលនៃចំនួនឡឥដ្ឋ នៅក្នុងប្រទេសកម្ពុជា បានប្រើម៉ាស៊ីនដែលប្រើដោយដៃដែលជាហានិភ័យធំបំផុតមួយនាំទៅរកគ្រោះថ្នាក់ខូចខាតទៅលើអវយវៈ របស់អ្នកដែលធ្វើការក្នុងឧស្សាហកម្មឡឥដ្ឋ។ នេះបើតាមសេចក្តីព្រាងនៃរបាយការណ៍មួយរបស់សហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើកម្ពុជា ឬហៅកាត់ថា (BWTUC) ដែលជាអង្គការមួយធ្វើការដើម្បីលើកកម្ពស់សិទ្ធការងារ ។

របាយការណ៍ ដែលបានមកពីការសិក្សាស្រាវជ្រាវចាប់ពីខែកក្កដារហូតដល់ខែសីហា ឆ្នាំ២០១៩របស់សហព័ន្ធសហជីពដដែលបានសរសេរក្នុងអត្ថន័យដើមថា៖ «៥០,៤ភាគរយនៃឡឥដ្ឋនៅក្នុងប្រទេសកម្ពុជាប្រើម៉ាស៊ីនបញ្ជាដោយដៃ ដែលមានចំនួន២៣១ឡ ធៀបនឹង ២២៧ឡ ដែលមិនមានម៉ាស៊ីននេះ»។ របាយការណ៍ជាភាសាខ្មែរដែលមានកម្រាស់ជិត៤០ទំព័ររបស់សហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើកម្ពុជា ក៏បានរកឃើញដែរថា មានកុមារប្រមាណ៦៣៨នាក់ដែលមានអាយុក្រោម១៨ឆ្នាំកំពុងធ្វើការនៅឧស្សាហកម្មផលិតឥដ្ឋ។ ចំនួននេះគឺស្ថិតក្នុងចំណោមមនុស្សចំនួន៦៨៦៣នាក់ ដែលបញ្ជាក់ថា មានការងារនៅក្នុងឧស្សាហកម្មឡឥដ្ឋ។ តាមការសិក្សានេះ ឧស្សាហកម្មផលិតឥដ្ឋ នៅតែពឹងផ្អែកខ្លាំងលើពលកម្មប្រពលវប្បកម្ម ដែលអាចបង្កគ្រោះថ្នាក់ ។ សហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើកម្ពុជាបានសរសេរនៅក្នុងរបាយការណ៍មានចំណងជើងថា «ជំរឿនឧស្សាហកម្មឥដ្ឋកម្ពុជា៖ ប្រជាជន ភូមិសាស្រ្ត ការអនុវត្ត»តាមន័យដើមបន្ថែមថា៖ «កង្វល់ចម្បងមួយចំពោះឧស្សាហកម្មឡឥដ្ឋនៅកម្ពុជាគឺជាលក្ខខណ្ឌនៅកន្លែងធ្វើការងារផ្ទាល់។ ក្នុងចំណោមគ្រោះថ្នាក់ជាច្រើនដែលកម្មករឡឥដ្ឋប្រឈមមុខ...គឺហា

និភ័យដែលបង្កឡើងដោយម៉ាស៊ីនផលិតវាយពុម្ពឥដ្ឋដែលប្រើដោយដៃ ដែលបង្កការខូចខាតទៅលើអវយវៈ ឬធ្វើឲ្យមានការកាត់អវយវៈ»។

កាលពីដើមខែមីនា ឆ្នាំ២០១៩កន្លងទៅនេះកុមារីឈ្មោះ ឆេង ស្រីភ័ក្រ អាយុ១០ ឆ្នាំ ជាកូនកម្មករឡឥដ្ឋ បានជួបគ្រោះថ្នាក់នៅសិប្បកម្មផលិតឥដ្ឋរបស់ម្ចាស់ឈ្មោះ លាង ស្រ៊ុន ស្ថិតនៅឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ គ្រោះថ្នាក់នេះបានបង្កឲ្យកុមារបាត់បង់ដៃម្ខាង។

ក្រោយហេតុការណ៍គ្រោះថ្នាក់នោះ រដ្ឋមន្ត្រីក្រសួងការងារលោក អ៊ិត សំហេងបានចេញណែនាំហាមហាមក្មេងចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្មនៃសិប្បកម្មផលិតឥដ្ឋ។ ក្រសួងបានចាត់វិធានការសំខាន់ៗប្រាំក្នុងនោះគឺម្ចាស់ ឬនាយកសិប្បកម្មផលិតឥដ្ឋនៅមូលដ្ឋានរបស់ខ្លួន ត្រូវរៀបចំដាក់ស្លាកសញ្ញាធំៗ និងងាយមើលឃើញដូចជា ហាមក្មេងចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម ឬជនណាដែលនាំក្មេងចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម អាចប្រឈមនឹងបទល្មើសព្រហ្មទណ្ឌ។ លោក អ៊ិត សំហេង ក៏ស្នើឲ្យម្ចាស់សិប្បកម្ម «ត្រូវហាមឃាត់ដាច់ខាត ការប្រើប្រាស់ទាសភាពបំណុល ដើម្បីដាក់បន្ទុកសេរីភាពការងារកម្មករ» និង «ហាមឃាត់ដាច់ខាតរាល់ទម្រង់នៃការកេងប្រវ័ញ្ចពលកម្មកុមារ និងការបង្ខំឲ្យកុមារធ្វើការដើម្បីដោះបំណុល»។

កម្មករឡឥដ្ឋជាច្រើនត្រូវបានជាប់អន្ទាក់នៅក្នុងឧស្សាហកម្មនេះ ដោយសារបំណុលនេះ។ បើតាមការរកឃើញរបស់អង្គការលីកាដូកន្លងមក។

លោក វ៉ាន់ រតនា ប្រធានការិយាល័យផ្នែកពិនិត្យ និងអធិការកិច្ចពលកម្មកុមារនៃនាយកដ្ឋានការងារកុមារនៅក្រសួងការងារ ដែលបានចូលរួមកិច្ចពិភាក្សាយោបល់លើរបាយការណ៍របស់សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជានៅទីក្រុងភ្នំពេញនាថ្ងៃពុធនេះ បានបញ្ជាក់ថា ក្រុមអធិការកិច្ចក្រសួងការងារបានបង្កើនការខិតខំក្នុងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ។ មន្ត្រីអធិការកិច្ចរូបនេះអះអាងថាតាមរយៈសកម្មភាពអធិការកិច្ចដែលធ្វើឡើងពីរដងក្នុងរយៈមួយឆ្នាំនេះ ក្រុមការងារអធិការកិច្ចរកមិនឃើញ ការជំពាក់បំណុលរវាងកម្មករឡឥដ្ឋ និងម្ចាស់សិប្បកម្មនោះទេ។ លោកបានទាត់ចោលរបាយការណ៍របស់អង្គការសិទ្ធិមនុស្សក្នុងស្រុកមួយគឺអង្គការលីកាដូ ដែលបានរកឃើញការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារ ក្នុងឧស្សាហកម្មផលិតឥដ្ឋនៅកម្ពុជាកាលពីឆ្នាំ២០១៦។ «បើតាមអង្កេតរបស់ក្រសួងការងារដែលមាននាយកដ្ឋានអធិការកិច្ចការងារ ដែលចុះទៅដល់សិប្បកម្មឡឥដ្ឋ យើងពិនិត្យឃើញថា ដូចអត់មានទាសភាពទាសករទេ អីចឹងបានក្រសួងបានចេញសេចក្ដីព័ត៌មានហ្នឹងបដិសេធមួយបាទ បដិសេធនៅក្នុងឆ្នាំ២០១៦ហ្នឹង»។

អ្នកស្រី ហន ថារី វ័យ២៤ឆ្នាំ ដែលជាកម្មករនៅសិប្បកម្មឡឥដ្ឋមួយ ក្នុងស្រុកមុខកំពូល ខេត្តកណ្ដាល និយាយថា អ្នកស្រីនៅជាប់បំណុលជាមួយថៅកែឡឥដ្ឋនៅឡើយ ហើយការសងបំណុលគឺកាត់ទៅតាមប្រាក់ឈ្នួលដែលរកបានពីការផលិតឥដ្ឋក្នុងសិប្បកម្មឡឥដ្ឋតែម្ដង។ «និយាយទៅយើង ដូចថាយើងធ្វើបាន ប៉ុន្មាន យើងបើកលុយដូចថា ក្នុងមួយខែយើងបើកលុយបាន២០ ៣០ម៉ឺនអី យើងកាត់ឲ្យគេ ប្រាំម៉ឺនអីចឹងទៅ។ ហើយយើងអត់ទាន់កាត់ក៏បានដែរ ហ្នឹងគេអត់ទាមទារចឹង តែគ្រាន់ថា តែយើងមានជំងឺ យើងខ្ចីគេទៅ វាចេះតែកើន កើន»។

លោក អំ សំអាត នាយករងទទួលបន្ទុកផ្នែកឃ្លាំមើលនិងការពារសិទ្ធិមនុស្សនៃអង្គការលីកាដូ (Licadho) យល់ថា បើរដ្ឋាភិបាលមានឆន្ទៈខាងនយោបាយនោះ ការប្រើប្រាស់ពលកម្មកុមារ និងបញ្ហាបំណុលក្នុងឧស្សាហកម្មផលិតឥដ្ឋអាចនឹងត្រូវបានកាត់បន្ថយ។ «វាអាស្រ័យទៅលើឆន្ទៈប្រាកដប្រជាណ៎ា ពីព្រោះរឿងទាំងអស់ យើងទទួលស្គាល់ហើយថាមិនមែនដោះស្រាយភ្លាមចប់ភ្លាម ប៉ុន្តែយើងធ្វើយ៉ាងណាឲ្យបានឆាប់ កាន់តែល្អ ជាពិសេសយើងចង់ដោះស្រាយបញ្ហាពលកម្ម ដែលកុមារធ្វើការនៅក្នុងឡឥដ្ឋ យើងត្រូវតែដោះស្រាយអំពីឫសគល់បានន័យថា គឺបំណុលរបស់ឪពុកម្ដាយ ជាមួយនឹងថៅកែឡឥដ្ឋហ្នឹង ជាមុន។ អាហ្នឹង បើមិនចឹងទេ អាផលប៉ះពាល់ហ្នឹងនៅតែប៉ះពាល់ទៅដល់កុមារចឹង ពីព្រោះក្រុមគ្រួសារឪពុកម្ដាយដែលធ្វើការទៅ គាត់ចង់បានកម្រៃច្រើន»។

របាយការណ៍សហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើកម្ពុជាបន្តឲ្យដឹងថា ភាគច្រើនអ្នកធ្វើការនៅក្នុងឡឥដ្ឋជាពលករចំណាកស្រុក ដែលជាង២៤ភាគរយ មកពីខេត្តកណ្ដាល និងជាង២២ភាគរយ មកពីខេត្តព្រៃវែង ដែលស្មើរតែជិតពាក់កណ្ដាលនៃចំនួនប្រជាជនធ្វើការក្នុងឡឥដ្ឋបច្ចុប្បន្ន។ របាយការណ៍ដដែលបានបង្ហាញដែរថា

ភាគច្រើនលើសលុបនៃឡឥដ្ឋដែលស្មើនឹង៨៨,៩ ភាគរយមិនមានដំបូល។ របាយការណ៍បានលើកឡើងថា៖«កង្វះខាតដំបូលធ្វើឲ្យមានបញ្ហាដល់ជីវភាពរស់នៅរបស់កម្មករដោយហេតុថា ផលិតកម្មត្រូវតែបញ្ឈប់ទាំងស្រុងនៅពេលភ្លៀង។ បញ្ហានេះធ្វើឲ្យខាតបង់ពេលវេលាសម្រាប់កម្មករដែលអាររកប្រាក់បាននិងធ្វើឲ្យពួកគេពឹងផ្អែកលើបំណុលកាន់តែច្រើនថែមទៀត»។

តាមការបញ្ជាក់របស់លោក វ៉ាន់ រតនា ប្រធានការិយាល័យផ្នែកពិនិត្យ និងអធិការកិច្ចពលកម្មកុមារនៃនាយកដ្ឋានការងារកុមារនៅក្រសួងការងារ កាលពីឆ្នាំ២០១៩ ក្រុមមន្ត្រីក្រសួងការងារបានចុះឃុំទូនាការផ្សព្វផ្សាយមិនឲ្យមានការប្រើប្រាស់ពលកម្មកុមារក្នុងសិប្បកម្មឡឥដ្ឋដល់ កម្មករចំនួន៧៥៥៨នាក់ និងក្រុមគ្រួសារកុមារ១២៥៩គ្រួសារ។ ក្រុមការងារក្រសួងក៏បានណែនាំឲ្យម្ចាស់សិប្បកម្មបង្កើនវិធានការនានាការពារមិនឲ្យកុមារចូលដល់កន្លែងនៃសង្វាក់ផលិតកម្មឥដ្ឋ។ លោកបន្ថែមថា នៅឆ្នាំ២០២០នេះ ក្រសួងនឹងបន្តការធ្វើអធិការកិច្ចដូចសព្វដង នៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីទប់ស្កាត់មិនឲ្យមានការប្រើប្រាស់ពលកម្មកុមារអាយុក្រោម១៨ឆ្នាំ ឬក្រោម១៥ឆ្នាំ។ លោកអះអាងថា ក្រុមការងាររកមិនឃើញការប្រើប្រាស់ពលកម្មកុមារដែលមានអាយុក្រោម១៥ឆ្នាំនោះទេ ដែលការណ៍នេះគឺផ្ទុយពីការរកឃើញរបស់ក្រុមការពារសិទ្ធិមនុស្សនៅប្រទេសកម្ពុជា៕

## អ្នកទោសខ្មែរ៤នាក់ត្រូវបានអាជ្ញាធរថៃដោះលែងហើយ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០២០ ម៉ោង ១៦:៤៩ ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ សេចក្តីរាយការណ៍បឋមបានឲ្យដឹងថា ក្រុមអាជ្ញាធរថៃបានធ្វើការដោះលែងអ្នកទោសខ្មែរ៤នាក់ឱ្យមានសេរីភាពវិញនាំខ្លួនយកមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជា តាមមាត់ច្រកទ្វារអន្តរជាតិជាំ (ដែលខាងថៃហៅថាឆងសាងាំ) កាលពីរសៀល ថ្ងៃទី០៤ កុម្ភៈ ២០២០ ស្ថិតនៅក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

អ្នកទោសខ្មែរដែលក្រុមអាជ្ញាធរថៃ ធ្វើការដោះលែងឈ្មោះ វ៉ែន អ៊ឹម ភេទប្រុស អាយុ៤៥ឆ្នាំ រស់នៅភូមិចំបក់សែនជ័យ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ឈ្មោះ ភាព ចិន ភេទប្រុស អាយុ៣៧ឆ្នាំ រស់នៅភូមិកោះថ្មី ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលទាំង០២នាក់ថៃចាប់ខ្លួនកាលថ្ងៃទី២៥ វិច្ឆិកា ឆ្នាំ២០១៧ ឈ្មោះ រម្យ រុណ ភេទប្រុស អាយុ៣៩ឆ្នាំ រស់នៅភូមិត្រពាំងគារ ឃុំជើងរស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ចាប់ខ្លួននៅថ្ងៃទី១១ សីហា ឆ្នាំ២០១៧ ទាំង៣នាក់ពីបទឆ្លងដែនខុសច្បាប់ ចូលកាប់ឈើក្រញូង ក្នុងទឹកដីថៃ និងម្នាក់ទៀតឈ្មោះពៅ ចាន់ធើត ភេទប្រុស អាយុ៥៥ឆ្នាំ រស់នៅភូមិថ្មីឃុំកំពុងប្រណាក ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ជាជនពិកាជើងខាងស្តាំ ថៃចាប់ខ្លួនថ្ងៃទី១៦ ធ្នូ ២០១៩ ពីបទឆ្លងដែនជួញដូរសត្វព្រៃ ទាំង៤នាក់ជាប់គុកនៅស្រុកខាន់តាឡាក់ ខេត្តស៊ីសាកេត ប្រទេសថៃ ។

ក្រុមអាជ្ញាធរកម្ពុជាដែលបម្រើការងារនៅមាត់ច្រកទ្វារអន្តរជាតិជាំបានឱ្យដឹងថា អ្នកទោសខ្មែរដែលក្រុមអាជ្ញាធរថៃដោះលែងទាំង៤នាក់នោះ ក្រោយពីបានទទួលពីថៃសមត្ថកិច្ចបានធ្វើការអប់រំនឹងធ្វើកិច្ចសន្យាបញ្ឈប់ឆ្លងដែនដោយខុសច្បាប់បន្តទៀត ហើយបានឱ្យវិលត្រឡប់ទៅជួបជុំក្រុមគ្រួសារក្នុងថ្ងៃដដែល ៕

## ពង្រឹងការទប់ស្កាត់ទំនិញខូចគុណភាព និងគេចពន្ធដែលលួចនាំចូលពីប្រទេសជិតខាង

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២០ ម៉ោង ០៩:៣៣ ប៊ុន ធឿន

បន្ទាយមានជ័យ ៖ កម្លាំងមានសមត្ថកិច្ចដែលឈរជើងតាមបន្ទាត់ព្រំដែនត្រូវពង្រឹងការទប់ស្កាត់ទំនិញខូចគុណភាព និងគេចពន្ធដែលលួចនាំចូលពីប្រទេសចិតខាងអភិបាលខេត្តលើកឡើងកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត នៅថ្ងៃទី០៥ ខែកុម្ភៈនេះ នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ ។

ក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត គឺមានការចូលរួមពីគ្រប់មន្រ្តី និងសមត្ថកិច្ចពាក់ព័ន្ធគ្រប់ស្ថាប័ន និងស្រុក- ក្រុង ក្នុងខេត្តបន្ទាយមានជ័យ នាឱកាសនោះអភិបាលខេត្តបន្ទាយមានជ័យ លោក អ៊ុំ រាត្រី បានមានប្រសាសន៍លើកឡើងថា ដើម្បីពង្រឹងសុវត្ថិភាពទំនិញគេចពន្ធ និងខូចគុណភាព ការពារសុវត្ថិភាពជូនប្រជាពលរដ្ឋតាមបន្ទាត់ព្រំដែន និងពលករចំណាកស្រុកខុសច្បាប់ ដែលតាមច្រករបៀងខុសច្បាប់ប្រឈមគ្រោះថ្នាក់ ។ លោកបានបញ្ជាក់ថា ៖ កងកម្លាំងដែលឈរជើងតាមបន្ទាត់ព្រំដែនត្រូវទប់ស្កាត់អោយបានដូចជាទំនិញខូចគុណភាព ទំនិញគេចពន្ធ រថយន្ត និងម៉ូតូគ្មានបង់ពន្ធដែលជាមុខសញ្ញាត្រូវចូលមានវិធានការទប់ស្កាត់អោយបាន និងបទល្មើសគ្រឿងញៀនចោរលួច ចោរប្លន់ ល្បែងស៊ីសងលុបបំបាត់អោយអស់ ។ លោក អ៊ុំ រាត្រី បានមានប្រសាសន៍សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយសមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នានានៅមូលដ្ឋានអោយប្រសើរឡើង ៕

## ពលករឆ្លងដែនខុសច្បាប់ កាប់ឈើគ្រញូងម្នាក់ ត្រូវបានអាជ្ញាធរថៃយកមកប្រគល់ឲ្យភាគីកម្ពុជាវិញ

---

http://kampucheathmey.com/ 6/2/2020 10:50 Am

ឧត្តរមានជ័យ ៖ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង១៦និង២០នាទី អាជ្ញាធរថៃបានបញ្ជូនប្រជាពលរដ្ឋខ្មែរ ដែលបានឆ្លងដែនខុសច្បាប់ចូលទៅកាប់ឈើគ្រញូងក្នុងទឹកដីថៃ ចំនួន០១នាក់ តាមច្រកអន្តរជាតិជាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចបានឲ្យដឹងថា ពលរដ្ឋខាងលើមាន ឈ្មោះ បាន ម៉េងហ៊ួរ ភេទប្រុស អាយុ៤៧ឆ្នាំ រស់នៅភូមិទំព័រ ឃុំតាអុង ស្រុកចំការលើ ខេត្តកំពង់ចាម។ ចាប់ខ្លួនកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨ ពីបទឆ្លងដែនកាប់ឈើគ្រញូង ចូលតាមច្រកអូរស្វាយ ឃុំអូស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ជាប់គុកនៅស្រុកខាន់តាឡាក់ ខេត្តស៊ីសាកេត ប្រទេសថៃ។ សមត្ថកិច្ចច្រកទ្វារអន្តរជាតិជាំ បានធ្វើការអប់រំរួចឲ្យវិលត្រឡប់ទៅស្រុកកំណើតវិញ៕ អត្ថបទ ៖ ចាន់ ធី

## ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ បានទទួលជួបលោក JACOB Sims ប្រធានអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ( IJM )

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok 05-02-2020

នាព្រឹកថ្ងៃពុធ ទី០៥ ខែកុម្ភៈ ឆ្នាំ២០២០ ឯកឧត្តម អ៊ុក សោភ័ណ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ បានទទួលជួបលោក JACOB Sims ប្រធានអង្គការ បេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) និងបានពិភាក្សាលើកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយស្ថានទូតលើចំណុចសំខាន់ៗដូចខាងក្រោម៖

-ជួយផ្តល់សេវាផ្នែកច្បាប់ជូនដល់ពលករ

-ផ្តល់ការអប់រំបណ្តុះបណ្តាល និងវគ្គខ្លីៗ

-សហការចុះជួបជាមួយបងប្អូនពលករនេសាទតាមបណ្តាខេត្ត

## ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០២០

## ខេត្តព្រះសីហនុ រៀបចំសិក្ខាសាលាផ្សព្វផ្សាយគម្រោងចំណាកស្រុកឆ្លងដែន

http://www.nicetvnewsoffice.com/ February 7, 2020

នៅសាលាខេត្តព្រះសីហនុ ព្រឹកថ្ងៃសុក្រ ១៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០នេះ រដ្ឋបាលខេត្តព្រះសីហនុ បានបើកសិក្ខាសាលាផ្សព្វផ្សាយគម្រោងចំណាកស្រុកឆ្លងដែន ក្រោមអធិបតីភាពលោកជំទាវ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គណៈកម្មការជាតិគ្រប់គ្រងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ) លោកស្រី ហៀក ហ៊ីមុល្លី អភិបាលរងខេត្តព្រះសីហនុ និងលោក យ៉ាន នោរឡានឌ័រ នាយករងអង្គការឃែរអន្តរជាតិប្រចាំប្រទេសកម្ពុជា ដោយមានការចូលរួមពីអស់លោក លោកស្រី ជាអភិបាលអភិបាលរងក្រុង ស្រុក ប្រធាន អនុប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធជុំវិញខេត្ត ។

លោកជំទាវ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានប្រសាសន៍ថា សិក្ខាសាលាមានគោលបំណងផ្សព្វផ្សាយទិដ្ឋភាពទូទៅ និងផែនការអនុវត្តន៍គម្រោងចំណាកស្រុកឆ្លងដែន និងធ្វើការប្រឹក្សាយោបល់កំណត់អំពីយុទ្ធសាស្រ្ត យន្តការ និងសកម្មភាពសំខាន់ៗក្នុងការសហការ និងកសាងភាពជាម្ចាស់ជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្នុងគោលបំណងពង្រឹងការអនុវត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ចូលរួមសហការអំពីទិដ្ឋភាពទូទៅយុទ្ធសាស្រ្ត យន្តការ និងសកម្មភាពសំខាន់ៗរបស់គម្រោង និងកំណត់បាននូវលទ្ធផលរំពឹងទុករបស់គម្រោងទទួលបានកិច្ចសហការល្អ និងភាពជាម្ចាស់ ក្នុងចំណោមអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជាពិសេសក្រុមសហគមន៍មូលដ្ឋាន និងអាជ្ញាធរនៅមូលដ្ឋាន ដូចជា អាជ្ញាធរក្រុង ស្រុក ឃុំ សង្កាត់ និងសហគមន៍មូលដ្ឋានកំណត់បានផែនការ អនុវត្តន៍ច្បាស់លាស់សម្រាប់ឆ្នាំ២០២០នេះ។

លោកជំទាវ បានបន្តថា ទិសដៅគម្រោង ដើម្បីលើកកម្ពស់កិច្ចការពារសម្រាប់ពលករទេសន្តរប្រវេសន៍ និងទប់ស្កាត់អំពីហិង្សាលើស្ត្រី ហានិភ័យនៃទេសន្តរប្រវេសន៍ និងការជួញដូរមនុស្ស ។ ការគាំទ្របណ្តាញក្រុមសហគមន៍ បណ្តាញមិត្តអប់រំមិត្តក្នុងប្រទេសកម្ពុជា មានឱកាសភ្ជាប់ទំនាក់ទំនងក្នុងការផ្លាស់ប្តូរព័ត៌មាន និងគាំទ្រគ្នាទៅវិញទៅមក បង្កើនភាពអង់អាចដល់សមាគមន៍ក្នុងខេត្តគោលដៅ ក្នុងការទទួលបានព័ត៌មានពីជម្រើសនៃការធ្វើចំណាកស្រុក និងអាចបង្ការទប់ស្កាត់ដែលមិនមានសុវត្ថិភាព និងការជួញដូរមនុស្ស ។ សកម្មភាពរបស់គម្រោងពង្រឹងក្រុមសហគមន៍ បណ្តាញ ឬក្រុមមិត្តអប់រំមិត្ត ដែលមានស្រាប់ក្នុងខេត្តគោលដៅនៅក្នុងប្រទេសកម្ពុជា ដោយផ្សាភ្ជាប់ទំនាក់ទំនងក្រុមសហគមន៍ បណ្តាញក្រុមមិត្តអប់រំមិត្តដែលមានស្រាប់ និងបង្កើតថ្មីក្នុងខេត្តគោលដៅក្នុងប្រទេសកម្ពុជានិងប្រទេស ថៃ ។

ការបណ្តុះបណ្តាលលើកកម្ពស់ការទប់ស្កាត់អំពើហិង្សាលើស្ត្រី ការជួញដូរមនុស្ស និងសេវាគាំទ្រជនរងគ្រោះ និងងាយរងគ្រោះដោយអំពើហិង្សា និងរងគ្រោះដោយការជួញដូរមនុស្ស ។ បណ្តុះបណ្តាលជនបង្គោលក្នុងសហគមន៍ បណ្តាញ ឬក្រុមមិត្តអប់រំមិត្ត ស្តីពីការលើកកម្ពស់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកិច្ចការពារការជួញដូរមនុស្សឱ្យកាន់តែមានប្រសិទ្ធភាព។ ជនបង្គោលត្រូវបានអនុវត្តន៍ការលើកកម្ពស់ចំណេះដឹង ដល់សមាជិកក្នុងសហគមន៍នៅក្នុងមូលដ្ឋាន ដើម្បីធានាថា ការធ្វើចំណាកស្រុក ឆ្លងដែនត្រូវបានកាត់បន្ថយ ៕

## កម្ពុជា និងប្រទេសបីទៀត ក្នុងអាស៊ាន ដែលបញ្ជូនពលករទៅក្រៅប្រទេស រួមគ្នាទប់ស្កាត់ការជួញដូរមនុស្ស

http://kampucheathmey.com/ 7/2/2020 8:50 Am

ពេញ ៖ ប្រទេសកម្ពុជា និងប្រទេសចំនួនបីទៀត ក្នុងតំបន់អាស៊ាន ដូចជា ប្រទេសវៀតណាម ឡាវ និង មីយ៉ាន់ម៉ា រួមគ្នាផ្លាស់ប្តូរយោបល់ដើម្បីរកដំណោះស្រាយជូនពលករ ដែលជួបបញ្ហា ឬការជួញដូរមនុស្សទៅប្រទេសផ្សេងទៀត ខណៈបញ្ហាការជួញដូរមនុស្សនៅតែបន្តកើតមានចំពោះប្រទេសរៀងៗខ្លួននោះ។ ថ្លែងប្រាប់អ្នកយកព័ត៌មានក្រោយពីកិច្ចជំនួបរវាង សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទីជាមួយតំណាងប្រទេសដែលបានបញ្ជូនពលករចំណាកស្រុក កាលពីរសៀលថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០នេះ។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ)បានលើកឡើងបែបនេះ ប្រាប់អ្នកយកព័ត៌មានក្រោយពីកិច្ចជំនួបរវាង សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទីជាមួយតំណាងប្រទេសដែលបានបញ្ជូនពលករចំណាកស្រុក កាលពីរសៀលថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០ នៅក្នុងកិច្ចជំនួបនេះ សម្តេចក្រឡាហោម ស ខេង បានសម្តែងការស្វាគមន៍ និងគាំទ្រចំពោះប្រទេសដែលមានពលករជួបបញ្ហា ហើយរួមគ្នារកដំណោះស្រាយជូនពួកគេនោះ។ លោកស្រីបានលើកឡើងថា «ពួកយើងបានជួបពិភាក្សាគ្នាអំពីពលករ ដែលបានបញ្ជូនទៅក្រៅប្រទេស ហើយនាំគ្នាដោះស្រាយ រួមនឹងផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក ដើម្បីកាត់ភាពរងគ្រោះរបស់ពលករដែលបានទៅធ្វើការងារនៅក្រៅប្រទេស»។

សូមបញ្ជាក់ថា ប្រទេសកម្ពុជា និងប្រទេសវៀតណាម ឡាវ មីយ៉ាន់ម៉ា និង អង្គការអន្តរជាតិទេសន្តរប្រវេសន៍ ដែលហៅកាត់ថា IOM បានបើកសិក្ខាសាលាសម្របសម្រួលថ្នាក់តំបន់ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពរបស់ខ្លួន ដែលបានបញ្ជូនពលករទៅចំណាកស្រុកគេ ហើយសិក្ខាសាលានេះ គឺដើម្បីបន្តស្វែងរកដំណោះស្រាយបន្ថែមចំពោះប្រជាជនរបស់ខ្លួន ដែលបានបញ្ជូន និងលួចទៅធ្វើការនៅប្រទេសដទៃ ខណៈដែលពួកគេបានជួបនឹងបញ្ហាផ្នែកច្បាប់ និងបញ្ហាផ្សេងៗទាក់ទងនឹងពួកគេនោះ។ សិក្ខាសាលានេះ គឺធ្វើឡើងចំនួនពីរថ្ងៃ គឺចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ ២០២០នេះ ដោយប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះ៕

## ឃាត់ខ្លួនបុរសម្នាក់ ជាជនសង្ស័យ នាំនារីក្មេងៗឲ្យរួមភេទជាមួយភ្ញៀវនៅតាមផ្ទះសំណាក់ និងសណ្ឋាគារ

https://khmernote.com.kh/news/ February 6, 2020

យោងតាមផេករបស់ស្នងការរាជធានីភ្នំពេញ បានឲ្យដឹងថា៖ ដោយមានការចង្អុលបង្ហាញពីឯកឧត្តម ឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរង និងជា ស្នងការនគរបាលរាជធានីភ្នំពេញ នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ១៥ម៉០០នាទី កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចុះអនុវត្តចំណារអនុញ្ញាតិឲ្យបង្រ្កាបជាក់ស្តែងលេខ ០១០ អ.យ.វ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០ របស់លោក សេង ហៀង ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ដោយបានធ្វីការឃាត់ខ្លួនជនសង្ស័យ ០១នាក់ និងជនរងគ្រោះចំនួន ០៦នាក់ ស្រី (អនីតិជន ០២នាក់) ករណី ប្រព្រឹត្តអំពើសញ្ជារកម្ម (នាំនារីក្មេងៗឲ្យរួមភេទជាមួយភ្ញៀវនៅតាមផ្ទះសំណាក់ និងសណ្ឋាគារ) នៅចំណុច ០២គោលដៅ ផ្សេងគ្នា ៖

១. នៅចំណុចភោជនីយ៍ដ្ឋាន ម្លប់ស្វាយមានលាភ ផ្លូវលេខ១០០៣ កែងផ្លូវលេខ១៩៥៦ ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ឃាត់ខ្លួនជនសង្ស័យ ០១នាក់ ឈ្មោះ កេត រតនៈ ហៅ អាហ្សា ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ និងជនរងគ្រោះចំនួន ០២នាក់ ស្រី (នីតិជន) ។

២. នៅចំណុចផ្ទះសំណាក់ ស្វីតប៊ូទិកម៉ូតែល (Sweet Boutique Motel) ផ្លូវលេខ១០០៣ កែងផ្លូវបេតុង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ជនរងគ្រោះ ចំនួន ០៤នាក់ ស្រី (អនីតិជន ០២នាក់) ។ មកកាន់ការិយាល័យ ដើម្បីធ្វើការសាកសួរ និងស្រាវជ្រាវ ។ បច្ចុប្បន្នការិយាល័យកំពុងកសាងសំណុំរឿង និងបញ្ជូនជនសង្ស័យទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ចំណែកជនរងគ្រោះចំនួន ០៦នាក់ (អនីតិជន ០២នាក់) ប្រគល់ជូនមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន០៣នាក់ ពីភាគីថៃ ពាក់ព័ន្ធនឹងការឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 07-02-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នារសៀលថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ បានទទួលពលករខ្មែរ ចំនួន ០៣ នាក់ ពីភាគីថៃ ពាក់ព័ន្ធនឹងការឆ្លងដែនខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៣នាក់ មាន ១. ឈ្មោះ ខែន ផាន់ណា ភេទប្រុស អាយុ ៣២ឆ្នាំ ទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងភូមិស្វាយស ឃុំខ្នាញមាស ស្រុកបវេល ខេត្តបាត់ដំបង, ២. ឈ្មោះ មិត្ត វណ្ណា ភេទប្រុស អាយុ ៤៧ឆ្នាំ ទីលំនៅស្ថិតក្នុងភូមិស្រែអំបិល ឃុំស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង និង៣. ឈ្មោះ មាស ឡាយ ភេទប្រុស អាយុ ២៧ឆ្នាំ មានលំនៅស្ថិតភូមិកំពង់ត្រាច ឃុំកំពង់ត្រាច ស្រុកកំពង់ត្រាច ខេត្តកំពត។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ចំនួន ០៣ នាក់ ពីភាគីថៃ ពាក់ព័ន្ធនឹងការស្នាក់នៅខុសច្បាប់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 07-02-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នារសៀលថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ បានទទួលពលករខ្មែរ ចំនួន ០៣ នាក់ ពីភាគីថៃ ពាក់ព័ន្ធនឹងការស្នាក់នៅខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៣នាក់ មកពីខេត្តបាត់ដំបង ០១ នាក់, ខេត្តកំពត ០១នាក់ និងខេត្តកំពង់ចាម ០១នាក់៕

## លោក នាង ផាត ដឹកនាំគណៈប្រតិភូចូលរួមប្រជុំគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ (GBC)

https://grandnewsasia.com/ 06-02-2020

នៅព្រឹកថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ នាយឧត្តមសេនីយ៍ នាង ផាត រដ្ឋលេខាធិការប្រចាំការ ក្រសួងការពារជាតិ និងជាប្រធានក្រុមលេខាធិការដ្ឋាននៃគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ(GBC) បានដឹកនាំប្រតិភូក្រុមលេខាចូលរួមកិច្ចប្រជុំក្រុមលេខាធិការដ្ឋាន គណៈកម្មាធិការ ព្រំដែនទូទៅកម្ពុជា-ថៃ (GBC) លើកទី១៥ ដែលប្រព្រឹត្តទៅនៅព្រះរាជាណាចក្រថៃឡង់ដ៏ចាប់ពីថ្ងៃទី០៤ ដល់០៦ ខែកុម្ភៈ ឆ្នាំ ២០២០ ខាងមុខនេះ។ ជូនដំណើរប្រតិភូដល់ព្រលានយន្តហោះអន្តរជាតិភ្នំពេញក្នុងឱកាសនោះមាន៖ អគ្គនាយករង ក្រសួងការពារជាតិ នាយទាហាន នាយទាហានរង ចំណុះក្រសួងការពារជាតិជាច្រើនរូប។

យោងតាមកិច្ចព្រមព្រៀងរវាងកងទ័ព នៃប្រទេសទាំង២ កម្ពុជា ថៃ គឺគណៈកម្មាធិការព្រំដែនទូទៅ កម្ពុជា-ថៃ(GBC) ត្រូវបានកំណត់កិច្ចប្រជុំជារៀងរាល់ឆ្នាំ ដោយធ្វើការផ្លាស់វេនគ្នាជាម្ចាស់ផ្ទះម្តងម្នាក់។ គោលដៅនៃកិច្ចប្រជុំ គឺដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការ រវាងកងទ័ពនៃប្រទេសទាំង២ ពិសេសការរក្សាសន្តិភាព ស្ថេរភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែននៃប្រទេសទាំង២ ដើម្បីទប់ស្កាត់ និងបង្ក្រាបរាល់សកម្មភាពខុសច្បាប់នានា នៅតំបន់ព្រំដែនរួមមាន៖ បញ្ហារត់ពន្ធគ្រឿងញៀន រត់ពន្ធមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែននានា ដែលភាគីទាំង២ និងពុះពារស្វែងរកដំណោះស្រាយ និងមានវិធានការទប់ស្កាត់ដើម្បីរក្សា និងធានាបាននូវស្ថេរភាព សន្តិសុខ និងការអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនរួមនៃប្រទេសជិតខាងទាំង២៕

## ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២០

## ដឹងតម្លៃហើយ ករណីនៅដេកជាមួយភ្ញៀវម្តងៗ នៅតាមផ្ទះសំណាក់ និងសណ្ឋាគារ គឺតម្លៃប្រមាណ

https://report-news.info/ 07-02-2020

ភ្នំពេញ ៖ កម្លាំងការិយាល័យប្រឆាំងការ ជួញដូរ មនុស្ស និង ការពារ អនីតិជន សហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះ បង្ក្រាប ជាក់ស្តែងករណី ប្រព្រឹត្តិ អំពើសញ្ញារកម្ម មានស្លានទម្ងន់ទោស ( នាំនារីក្មេងៗ ឱ្យរួមភេទជាមួយភ្ញៀវ នៅតាម ផ្ទះសំណាក់ និង សណ្ឋាគារ )ដោយបានឃាត់ខ្លួនមេខ្យល់ភេទទី៣ម្នាក់ និង នារីរងគ្រោះចំនួន ០៦នាក់ នៅវេលាម៉ោង៣ រសៀល ថ្ងៃ ទី ០៦ ខែកុម្ភៈ ឆ្នាំ ២០២០។ ប្រតិបត្តិការនេះដោយមានការចង្អុលបង្ហាញពីឯកឧត្តម ឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរងនិងជាស្នងការនគរបាលរាជធានីភ្នំពេញ សម្របសម្រួលពីលោក សេង ហៀង ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ និងដឹកនាំផ្ទាល់ដោយលោក ឧត្តមសេនីយ៍ទោ ចាន់ កិត្តិខុម ស្នងការរងទទួលដឹកនាំការងារការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជននៃស្នងការដ្ឋាននគរបាលរាជាធានីភ្នំពេញ។

តាមប្រភពព័ត៌មាពីសមត្ថកិច្ច បានឱ្យដឹងថា មេខ្យល់ ឈ្មោះ កេត រតនៈ ហៅ អាហ្វ្រា អាយុ ២៩ ឆ្នាំ ជនជាតិ ខ្មែរ ស្នាក់នៅ ផ្ទះលេខ២៣២ ផ្លូវលំ ភូមិសែនសុខទី៥ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឃាត់ខ្លួននៅចំណុចភោជនីយ៍ដ្ឋាន ម្លប់ស្បូវមានលាភ ផ្លូវលេខ១០០៣ កែងផ្លូវលេខ១៩៥៦ ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ និង ឃាត់នារីជនរង គ្រោះ ចំនួន០៦នាក់ អនីតិជន ០២នាក់ អាយុ១៦ម្នាក់ និង អាយុ១៥ម្នាក់ ) ឃាត់ខ្លួននៅ ចំណុច ផ្ទះសំណាក់ sweet boutique motel ផ្លូវ បេតុងកែងនិងផ្លូវលេខ១០០៣ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែន សុខ រាជធានីភ្នំពេញ។

យោងតាមនារីរងគ្រោះបានអោយដឹងថា ភោជនីយ៍ដ្ឋាន ម្លប់ស្បូវមានលាភ ចាប់ផ្តើមបើកដំណើរការពីម៉ោង ១១ថ្ងៃត្រង់ រហូតដល់ម៉ោង៩យប់ ដោយមាននារីៗក្មេងជាច្រើននៅបំរើភ្ញៀវនៅហាង ចំពោះភ្ញៀវ ដែលចូលមកហាង ពេលត្រូវការនារីក្មេងៗមកអង្គុយកំដរនិងទៅរួមភេទនៅខាងក្រៅ គឺមេការឈ្មោះ កេត រតនៈ ហៅអាហ្វ្រា អាចធ្វើការទំនាក់ទំនង តាមរយៈទូរស័ព្ទ បាននាំមកអោយភ្ញៀវមើលនិងសម្រាប់រួមភេទ **ដោយក្មេងៗនារី មានអាយុចន្លោះពី១៥ឆ្នាំ ដល់១៦ឆ្នាំ ឡើងទៅ ដោយក្នុងតម្លៃការរួមភេទក្នុង១ដង ចាប់ពី១០០$ដល់ ១៥០$** ចំពោះលុយបានមក គឺមេខ្យល់ជាអ្នករក្សាទុកទាំងអស់សម្រាប់ចែកពាក់កណ្តាលម្នាក់ ជាមួយនារីក្មេងៗ បន្ថែមទៀតនោះ មេខ្យល់បានសុំលុយធីបពី ភ្ញៀវចំនួនពី ៥០$ទៅ១០០$ ជាកម្រៃជើងសារដែលខ្លួនបាននាំនារី មកអោយរួមភេទជាមួយភ្ញៀវ។

បច្ចុប្បន្ន សមត្ថកិច្ច បានឃាត់ជនសង្ស័យនៅការិយាល័យប្រឆាំងការ ជួញដូរមនុស្ស និង ការពារ អនីតិជន ដើម្បីសាកសួរ និង កសាង សំណុំរឿង បញ្ជូនទៅតុលាការចាត់ការ តាមនីតិវិធី។ ចំណែកនារីរងគ្រោះត្រូវបានសមត្ថកិច្ចប្រគល់ជូនមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ធ្វើការអប់រំ៕

## បញ្ជូនបុរសម្នាក់នាំនារីក្មេងៗឲ្យរួមមេត្រីជាមួយភ្ញៀវតាមផ្ទះសំណាក់ ទៅតុលាការ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០២០ ម៉ោង ១៦:០៧ ឃីម ប៊ុនណាក់

រាជធានីភ្នំពេញ ៖ បើតាមសេចក្តីរាយការណ៍បឋមបានឱ្យដឹងថា មេខ្យល់ម្នាក់ជាប់ពាក់ព័ន្ធនាំនារីវ័យក្មេងឲ្យទៅរួមភេទជាមួយភ្ញៀវតាមផ្ទះសំណាក់ នៅព្រឹកថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២០នេះ ត្រូវបានសមត្ថកិច្ចការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានបញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញហើយ ដើម្បីចោទប្រកាន់ជាផ្លូវការ និងសម្រេចឃុំខ្លួនដាក់ពន្ធនាគារជាបណ្តោះអាសន្ន ។ សេចក្តីរាយការណ៍បន្តថា មេខ្យល់រូបនោះឈ្មោះ កេត រតនៈ ហៅអាហ្សា អាយុ២៩ឆ្នាំ ជាបុរសភេទទី៣ ស្នាក់នៅផ្ទះលេខ២៣២ ផ្លូវលំ ភូមិសែនសុខទី៥ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

សូមរម្លឹកថា កាលពីរសៀលថ្ងៃទី៦ ខែកុម្ភៈ កម្លាំងសមត្ថកិច្ចនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញ ដឹកនាំដោយលោកស្នងការរង និងមានការសម្របសម្រួលពីព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ បានចុះបង្ក្រាបបទល្មើស «អំពើសញ្ជរកម្មមួយករណី» នៅភោជនីយដ្ឋានម្លប់ស្បូវមានលាភ ផ្លូវលេខ១៩៥៦ ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ។ សូមរំលឹកទៀត ក្នុងនោះសមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនមេខ្យល់ម្នាក់ និងរំដោះនារីវ័យក្មេងៗ៦នាក់ ក្នុងនោះមាន២នាក់ជាអនីតិជន ដែលមេខ្យល់នាំទៅរួមភេទជាមួយភ្ញៀវនៅតាមផ្ទះសំណាក់ ។

នៅចំពោះមុខសមត្ថកិច្ចនារីវ័យក្មេងៗមានខ្លះអាយុក្រោម១៥ឆ្នាំ បាននិយាយថា ពួកនាងជាបំរើភ្ញៀវនៅហាងដែលត្រូវការហៅមកអង្គុយផឹកកំដរ ប៉ុន្តែបើសិនភ្ញៀវពេញចិត្ត ហើយត្រូវការចង់នាំនាងឡើងឋានសួគ៌នៅខាងក្រៅតាមផ្ទះសំណាក់ គឺអាចធ្វើការទំទាក់នាក់ទំនងមេការឈ្មោះ កេត រតនៈ ហៅអាហ្សា តាមរយៈទូរស័ព្ទទៅដេកជាមួយភ្ញៀវនៅផ្ទះសំណាក់ និងសណ្ឋាគារបាន ដោយម្នាក់ក្នុងតម្លៃការក្នុង១ដងចាប់ពី១០០ទៅ១៥០ដុល្លារអាមេរិក ក្នុងនោះមេខ្យល់ក៏បានទទួលកម្រៃជើងសារពីភ្ញៀវបន្ថែមដែរ ។

ចំណែកជនសង្ស័យបានសារភាពថា ខ្លួនជាអ្នកមើលការខុសត្រូវនារីទាំងអស់ ដែលនៅបម្រើភ្ញៀវនោះមែន ប៉ុន្តែរឿងពួកនាងៗចង់បានប្រាក់ លួចលាក់ទៅរួមមេត្រីជាមួយភ្ញៀវខាងក្រៅតាមផ្ទះសំណាក់ គេអត់បានដឹងទេ ។ ទោះជាយ៉ាងណា ជនសង្ស័យជាមេខ្យល់ ត្រូវបានតំណាងអយ្យការចោទប្រកាន់ជាផ្លូវការ ពីបទ «អំពើសញ្ជារកម្មមានស្ថានទម្ងន់ទោស» និងបានចាត់បញ្ជូនទៅខាងចៅក្រមស៊ើបសួរ ដើម្បីសម្រេចឃុំខ្លួនដាក់ពន្ធនាគារជាបណ្តោះអាសន្ន ។ (កែសម្រួលដោយ ៖ បុប្ផា)

## ប្រមុខរដ្ឋាភិបាលអំពាវនាវដល់ភាគីកូរ៉េបន្តយកចិត្តទុកដាក់លើពលករខ្មែរ កំពុងបម្រើការងារនៅកូរ៉េ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២០ ម៉ោង ០៨:១០ ឡុង សារ៉េត

រាជធានីភ្នំពេញ៖ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាសម្តេចតេជោ ហ៊ុនសែន បានអំពាវនាវទៅដល់ម្ចាស់រោងចក្រ សហគ្រាស និងក្រុមហ៊ុនទាំងអស់នៅប្រទេសកូរ៉េដែលទទួលយកពលករខ្មែរទៅបម្រើការងារនៅក្នុងផលិតកម្ម

របស់ខ្លួនឱ្យបន្តជួយយកចិត្តទុកដាក់និងថែរក្សាពួកគេឱ្យបានល្អ ខណៈពលករខ្មែរគោរពច្បាប់និងមានសិលធម៌ល្អទទួលបានការកោតសសើរពីភាគីកូរ៉េ។

សម្តេចតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបានមានប្រសាសន៍ក្នុងពិធីសំណេះសំណាលជាមួយពលករខ្មែរនិងម្ចាស់រោងចក្រកូរ៉េប្រមាណ៣៧នាក់នៅប្រទេសកូរ៉េកាលពីពេលថ្មីៗនេះថា សម្តេចបានអរគុណដែលកូរ៉េបានវាយតម្លៃខ្ពស់ទៅលើគុណភាពនៃពលកររបស់កម្ពុជា។ សម្តេចតេជោបានសង្កត់ធ្ងន់ថា «អ្វីដែលខ្ញុំសុំពីអស់លោកគឺសុំអស់លោក (ម្ចាស់រោងចក្រ) ជួយថែទាំកូនក្មួយរបស់ខ្ញុំ។មើលសុខទុកកូនក្មួយរបស់ខ្ញុំបានកំពុងធ្វើការនៅតាមរោងចក្រ ឬការដ្ឋានរបស់អស់លោកឱ្យបានល្អ។នោះហើយគឺជាបំណងប្រាថ្នារបស់ខ្ញុំ។ខ្ញុំចាត់ទុកថាពួកគេជាសាច់ឈាមរបស់ខ្ញុំ»។ សម្តេចតេជោ ហ៊ុន សែន បានបន្តថា «ខ្ញុំនូវតែអំពាវនាវឱ្យនិយោជកដែលម្ចាស់រោងចក្រ, ម្ចាស់ការដ្ឋាន,ម្ចាស់ក្រុមហ៊ុននិង សហគ្រាសកូរ៉េ ជួយបន្តការថែទាំពលករពលការិនីដែលធ្វើការនៅគ្រប់ទីកន្លែងក្នុងប្រទេសកូរ៉េ ព្រោះយើងត្រូវការឱ្យពលករយើង មិនត្រឹមតែដោះស្រាយការងារ ហើយមកឱ្យគេសង្កតសង្កិននោះទេ។ យើងបានតាមការពារពលកររបស់យើងនៅតាមប្រទេសនានា ហើយមានពេលខ្លះពលកររបស់យើងត្រូវគេបោកទៅដល់អាប៊ីសាអូឌិត យើងតាមយកមកវិញ»។ សម្តេចតេជោ ហ៊ុន សែនបានលើកឡើងថា « ប្រទេសកូរ៉េមានការខ្វះពលកម្មពិតប្រាកដ ។ ដូច្នេះកូរ៉េត្រូវនាំពលកម្មចូល ហើយជាសំណាងពលករខ្មែរធ្វើការមានការគោរពច្បាប់ មានសិលធម៌ល្អទទួលបានការកោតសសើរពីភាគីកូរ៉េ។ដូច្នេះហើយបានជាយើងស្នើសុំបង្កើនចំនួនពលករខ្មែរឱ្យបានច្រើនបន្ថែមទៀត។ម្យ៉ាងដើម្បីដោះស្រាយការងារធ្វើនិងម្យ៉ាងទៀតទទួលយកបច្ចេកវិទ្យាសម្រាប់ទៅក្នុងប្រទេសនៅពេលត្រលប់ទៅវិញ»។

លោក ឡុងឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសកូរ៉េ មានប្រសាសន៍ថា បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបានចុះអនុស្សរណៈយោគយល់ជាមួយរដ្ឋាភិបាលសាធារណៈកូរ៉េស្តីពីប្រព័ន្ធអនុញ្ញាតមុខរបរកាលពីឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្នពលករពលការិនីដែលកំពុងមានវត្តមាននៅប្រទេសកូរ៉េនេះមានជាង៤,៩ម៉ឺននាក់ ក្នុងនោះពលការិនីជាង១ម៉ឺននាក់ធ្វើការនៅក្នុងវិស័យឧស្សាហកម្ម,សំណង់និងកសិកម្ម។ លោកឯកអគ្គរាជទូតបានបញ្ជាក់ថា« ជារៀងរាល់ឆ្នាំថវិកាសរុបមានជាង៤០០លានដុល្លារអាមេរិកត្រូវបានផ្ញើរទៅប្រទេសកម្ពុជាដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារនិងសេដ្ឋកិច្ចជាតិ។ក្រៅពីនេះប្រជាពលរដ្ឋខ្មែរក៏ទទួលបានបទពិសោធន៍ការងារ ចំណេះដឹង ជំនាញបច្ចេកទេសនឹងភាសាសម្រាប់ជាយានបង្កើតមុខរបរនាពេលអនាគតនៅពេលបញ្ចប់អាណត្តិត្រលប់ទៅប្រទេសកម្ពុជាវិញ»។ បើតាមឯកអគ្គរាជទូតខ្មែរប្រចាំប្រទេសកូរ៉េ ក្នុងចំណោមពលករខ្មែរទាំងអស់ដែលធ្លាប់បានបម្រើការងារនៅកូរ៉េមួយចំនួនបានក្លាយជាពាណិជ្ជកម្មករដ៏ជោគជ័យក្នុងវិស័យអចលនទ្រព្យ ម្ចាស់ស្ថានីយ៍ប្រេងឥន្ទៈ,ភោជនីយដ្ឋាន កសិដ្ឋាននឹងបម្រើការងារនៅតាមក្រសួងស្ថាប័នរដ្ឋនិងឯកជន ។ ប្រាក់ខែអតិបរមា និងអប្បរមារបស់ពលករកម្ពុជា គឺមិនមានតួលេខច្បាស់លាស់នោះទេ គឺវាអាស្រ័យទៅលើការអនុម័តច្បាប់នៃការងារនៅក្នុងប្រទេសកូរ៉េ ។ តែគ្រាន់តែដឹងថាជាមធ្យម ពលករ កម្ពុជាទទួលបានប្រាក់ខែ ប្រហែល ២០០០ ដុល្លារអាមេរិក ៕ កែសម្រួលដោយ ៖សុឃាក់

## ស្នងការដ្ឋាននគរបាលកម្ពុជា-ថៃ ឯកភាពតាមផែនការនឹងត្រូវអនុវត្តឱ្យបាន

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០២០ ម៉ោង ០៩:៣៤ ហួត សុងហាក់

- ខេត្តបាត់ដំបង ៖ នៅព្រឹកថ្ងៃទី៧ កុម្ភៈ នៅបរិវេណស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង មានរៀបចំជំនួបពិភាក្សាពង្រឹងទំនាក់ទំនងសហប្រតិបត្តិការ រវាងស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង នៃព្រះរាជាណាចក្រកម្ពុជាជាមួយនគរបាលភូមិភាគ២ នៃព្រះរាជាណាចក្រថៃ ក្រោមអធិបតីភាពលោកឧត្តមសេនីយ៍ទោ អ៊ុច សុខុន មេ

បញ្ជាការរងនគរបាលជាតិទិសភូមិភាគទី៥ ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង និងជាសហប្រធាននៃជំនួនពិភាក្សា ដែលភាគីថៃដឹកនាំដោយ លោកឧត្តមសេនីយ៍ត្រី ថាណាស័ក្តិ រិទ្ធីដេតផៃប៊ូន មេបញ្ជាការរងនគរបាលភូមិភាគ២ នៃព្រះរាជាណាចក្រថៃ ជាសហប្រធាននៃជំនួនពិភាក្សាមកចូលរួមចំនួន២៩នាក់។ ចំណែកកម្ពុជាចំនួន៣៨នាក់ ។

- លោកឧត្តមសេនីយ៍ទោ អ៊ុច សុខុន បានលើកឡើងពង្រឹងកម្លាំងសហការជាមួយគ្នា ដោយអនុវត្តតាមខ្លឹមសារចំនួន៧ចំណុច ដែលបានជួបឯកភាពគ្នា រវាងនគរបាលខេត្តបាត់ដំបង និងខេត្តច័ន្ទបូរីនៅប្រទេសថៃកាលពីថ្ងៃទី២៤ កក្កដា ឆ្នាំ២០១៩ រួចមកនោះ យកមកអនុវត្តបន្តទៀត ហើយក៏បានសុំបន្ថែមកិច្ចសហការជាមួយនគរបាលខេត្តត្រាត និងខេត្តស្រះកែវបន្ថែមទៀត ហើយបានជំរុញឲ្យមានជំនួបគ្នារវាងថ្នាក់ស្រុក និងស្រុកដែលមានព្រំប្រទល់ជាមួយគ្នា និងជំនាញតាមគោលដៅនៅទល់មុខគ្នា សុំបន្តពង្រឹងបន្ថែមតាមខ្លឹមសារចាស់ឲ្យបានល្អបន្ថែមជាបន្តទៀត ។
- បន្ទាប់មកលោកឧត្តមសេនីយ៍ត្រី ថាណាស័ក្តិ រិទ្ធីដេតផៃប៊ូន មេបញ្ជាការរងនគរបាលភូមិភាគ២នៃព្រះរាជាណាចក្រថៃបានលើកឡើងថា សុំឯកភាពបន្តពង្រឹងជាមួយជាមួយខេត្តទាំង៣របស់ថៃ ដែលមានព្រំដែនជាប់ជាមួយខេត្តបាត់ដំបង ហើយសុំឲ្យខាងកម្ពុជាជួយជំរុញផ្សព្វផ្សាយដល់ពលករមួយចំនួនឲ្យយល់អំពីច្បាប់ដែលត្រូវចេញ-ចូល ទៅធ្វើការរស់នៅឱ្យសមស្របទៅតាមច្បាប់ផង ។ ភាគីថៃបានបន្ថែមទៀតថា បើមានករណីមានអ្នកជំងឺដែលត្រូវសង្គ្រោះបន្ទាន់ ត្រូវបញ្ជូនទៅព្យាបាលនៅប្រទេសថៃ សូមភាគីទាំងសងខាងជួយសម្រួលឲ្យបានឆាប់បំផុតចៀសវាងការខកពេលនាំឲ្យអ្នកជម្ងឺអាចស្លាប់ ក្នុងការជួយសង្គ្រោះមិនទាន់ ។ បន្ទាប់ពីបានឯកភាពគ្នារួចហើយភាគីទាំងពីរ បានចុះហត្ថលេខាលើកំណត់ហេតុរួមគ្នា ហើយបន្តយកទៅអនុវត្តឲ្យមានប្រសិទ្ធិភាពបំផុត ។

## តើការទទួលកូនសុំគ្មានលិខិតស្នាម ប្រឈមនឹងទោសឬទេ?

https://m.postkhmer.com/ គីម សារុំ 03 February 2020 | 10:39 ICT

ធម្មតាការរស់នៅរបស់មនុស្សតែងមានករណីសុំកូនពីអ្នកដទៃមកចិញ្ចឹមដោយមូលហេតុផ្សេងៗ ដែលខ្លះមកពីអ្នកទទួលគ្មានកូន។ ឯករណីខ្លះទៀតមកពីម្ដាយ-ឪពុកបង្កើតគ្មានលទ្ធភាពអាចបីបាច់ថែរក្សាបណ្ដុះបណ្ដាលកូនបានល្អដោយសារកត្តាជីវភាព ឬមានជំងឺជាដើម។ ក៏ប៉ុន្តែបើការប្រគល់ និងទទួលកូននោះមិនបានធ្វើលិខិតស្នាម ឬមានអាជ្ញាធរដឹងឮត្រឹមត្រូវតើអ្នកទទួល (ម្ដាយថ្មី) អាចប្រឈមនឹងផ្លូវច្បាប់ដែរឬទេ? ជុំវិញករណីនេះភ្នំពេញប៉ុស្តិ៍បានសម្ភាសជាមួយលោកមេធាវី ឡេ គីមហ៊្វិច នៃក្រុមមេធាវីអាស៊ានអន្តរជាតិមានអាសយដ្ឋានផ្ទះលេខ ១៦R ផ្លូវ ២៥២ សង្កាត់ចតុមុខ ដែលមានខ្លឹមសារដូចខាងក្រោម ៖

**ឧបមាថាមានស្ត្រីម្នាក់បានឲ្យកូនទៅស្ត្រីម្នាក់ទៀត ប៉ុន្តែភាគីទាំង ២ មិនបានធ្វើកិច្ចសន្យាទេ។ ក្រោយមកស្ត្រីជាម្ដាយបង្កើតបានប្ដឹងឲ្យសមត្ថកិច្ចចាប់ខ្លួនស្ត្រីជាអ្នកទទួលកូននោះ។ តើបញ្ហានេះស្ត្រីជាអ្នកទទួលកូនគេត្រូវប្រឈមនឹងទោសដែរឬទេ?**

ដើម្បីអាចបង្កើតការសុំកូនពេញលេញបានលុះត្រាតែបំពេញតាមលក្ខខណ្ឌដែលមានកំណត់ដោយច្បាប់សុំកូន។ លក្ខខណ្ឌទាំងនោះទាក់ទងនឹងអាយុរបស់ឪពុកម្ដាយចិញ្ចឹម និងកូនសុំ។ ឪពុកម្ដាយចិញ្ចឹមត្រូវមានអាយុចាប់ពី ២៥ ឆ្នាំឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច ២០ ឆ្នាំទើបអាចបង្កើតការសុំកូនពេញលេញបាន (មាត្រា ១០០៩ នៃក្រមរដ្ឋប្បវេណី)។ ជាគោលការណ៍កូនសុំត្រូវមានអាយុតិចជាង ៨ ឆ្នាំ (មាត្រា ១០១០ នៃក្រមរដ្ឋប្បវេណី)។ ករណីនេះប្រសិនបើអ្នកទទួលកូននោះគាត់មិនបានទៅប្រាប់ ឬជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានទេបានន័យថា ជាការខុសច្បាប់ហើយ បើទោះបីពេលប្រគល់ និងពេលទទួលយកកូននោះមានការព្រមព្រៀង

គ្នាផ្ទាល់មាត់ក៏ដោយ។ ករណីនេះស្ត្រីជាម្តាយបង្កើតដែលឲ្យកូនទៅគេនោះអាចចោទប្រកាន់ទៅភាគីអ្នកទទួលយកកូនបាន ដោយសារតែស្ត្រីអ្នកទទួលនោះគ្មានលិខិតស្នាមដឹងឮពីអាជ្ញាធរមូលដ្ឋាន ។

**ចុះបើស្ត្រីដែលទទួលកូនពីអ្នកប្រគល់គាត់បានប្រាប់អាជ្ញាធរមូលដ្ឋានត្រឹមមេភូមិដឹងឮតើស្របច្បាប់ដែរទេ?** ករណីនេះបើអ្នកទទួលកូនយកទៅចិញ្ចឹម ហើយប្រាប់ត្រឹមមេភូមិដឹងឮគឺជាការត្រឹមត្រូវតាមច្បាប់ហើយ ពីព្រោះអាជ្ញាធរមូលដ្ឋានបានដឹងឮ។

**ចុះបើស្ត្រីជាម្តាយប្រគល់កូនរបស់គាត់ឲ្យទៅអនីតិជនម្នាក់ទៀតដែលមិនទាន់គ្រប់អាយុតើបានទេ?** ករណីនេះមិនអាចប្រព្រឹត្តទៅបានទេបើតាមច្បាប់សុំកូនចែងថា លុះត្រាតែអ្នកសុំនោះមានអាយុលើសពី ២៥ ឆ្នាំ។ និយាយរួមឳពុក ឬម្តាយដែលចង់សុំកូនត្រូវមានអាយុលើសពីកូនសុំ ២០ ឆ្នាំឡើងទៅទើបអាចសុំកូនមកចិញ្ចឹមបាន៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ០៥នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីស្នាក់នៅខុសច្បាប់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 07-02-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នារសៀលថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ បានទទួលពលករខ្មែរ ០៥នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីស្នាក់នៅខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍បធនឲ្យដឹងថា ពលករខ្មែរទាំង ០៥នាក់ ស្រី ០៤នាក់ មកពីខេត្តបាត់ដំបង ០៣នាក់ ស្រី ០៣នាក់ និងខេត្តតាកែវ ០២នាក់ ស្រី ០១នាក់៕

## សេចក្តីជូនដំណឹងស្តីពីពលការនីទំនាក់ទំនងមិនបាន

https://www.facebook.com/mtosbcambodia/ MTOSB Cambodia 10-02-2020

គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស សូមជូនដំណឹងដល់ពលការនី ដែលមានឈ្មោះ អ៊ីន មករា (EON MAKARA) ភេទ ស្រី អាសយដ្ឋាន ភូមិពពេលពក ឃុំគោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ សូមរួសរាន់ទំនាក់ទំនងមកគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស ឱ្យបានមុនថ្ងៃសុក្រ ទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ម៉ោង០៣:០០នាទីល្ងាច ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣ ៦៥២៥ ៧៧៧, ០៨៨ ៣៥៩៨ ៨៨៨ និង ០១២ ៤៦៦ ២២២ នៅរៀងរាល់ម៉ោងធ្វើការ។

* បញ្ជាក់៖ គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស មិនអាចទំនាក់ទំនង តាមរយៈលេខទូរស័ព្ទរបស់គាត់ និងគ្រួសាររបស់គាត់បានឡើយ។ អាស្រ័យហេតុនេះ សូមបងប្អូន និងសាធារណជនមេត្តាជួយផ្សព្វផ្សាយបន្ត។ សូមអរគុណ!

## សេចក្តីជូនដំណឹងស្តីពីពលការនីទំនាក់ទំនងមិនបាន

https://www.facebook.com/mtosbcambodia/ MTOSB Cambodia 10-02-2020

សេចក្តីជូនដំណឹងស្តីពីពលការនីទំនាក់ទំនងមិនបាន គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស សូមជូនដំណឹងដល់ពលការនី ដែលមានឈ្មោះ នួន ស៊ីនីន (NUON SININ) ភេទ ស្រី អាសយដ្ឋានភូមិសន្ទិចកណ្តាល ឃុំដងក្តារ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ សូមរួសរាន់ទំនាក់ទំនងមកគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស ឱ្យបានមុនថ្ងៃសុក្រ ទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ម៉ោង០៣:០០នាទីល្ងាច ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣ ៦៥២៥ ៧៧៧, ០៨៨ ៣៥៩៨ ៨៨៨ និង ០១២ ៤៦៦ ២២២ នៅរៀងរាល់ម៉ោងធ្វើការ។

* បញ្ជាក់៖ គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស មិនអាចទំនាក់ទំនង តាមរយៈលេខ

ទូរស័ព្ទរបស់គាត់ និងគ្រួសាររបស់គាត់បានឡើយ។ អាស្រ័យហេតុនេះ សូមបងប្អូន និងសាធារណជនមេត្តាជួយផ្សព្វផ្សាយបន្ត។

## តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ សហការជាមួយ (LPN) និងក្រុមហ៊ុន CPRAM Co.,Ltd បង្កើតវេទិកាអប់រំផ្តល់ចំណេះដឹងដល់ពលករកំពុងបម្រើការងារនៅប្រទេសថៃ

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok 8 February 2020

ថ្ងៃសៅរ៍ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២០។ តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ សហការជាមួយ មូលនិធិលើកកំពស់សិទ្ធិនិងគុណភាពជីវិតពលករ(LPN) និងក្រុមហ៊ុន CPRAM Co.,Ltd ខេត្តប៉ាធុមថានី បង្កើតវេទិកាអប់រំផ្តល់ចំណេះដឹងដល់បងប្អូនពលករដែលកំពុងបម្រើការងារនៅទីនោះ ឱ្យបានយល់ដឹង អំពីច្បាប់ការងារនៅក្នុងប្រទេសថៃ សិទ្ធិនិងអត្ថប្រយោជន៍ដែលបងប្អូនពលករអាចទទួលបាន បម្រាមទោសបញ្ញត្តិ និងការស្នើសុំជំនួយពីភ្នាក់ងារពាក់ព័ន្ធ ក្នុងករណីបងប្អូនពលករជួបប្រទះបញ្ហាផ្សេងៗក្នុងការស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ។ ក្រុមហ៊ុន CPRAM Co.,Ltd មានពលករបរទេសពាសញ្ជាតិប្រមាណ៦,០០០នាក់ ក្នុងនោះមានពលករខ្មែរប្រមាណជាង១,០០០នាក់បម្រើការងារនៅទីនោះផងដែរ។

## ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០២០

## លោកជំទាវជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អញ្ជើញបើកយុទ្ធនាការ ស្តីពីការលើកកម្ពស់សុវត្ថិភាពអ៊ិនធើណេត សីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរ

http://bayontv.com.kh/ BTV Cambodia 11-02-2020

នាព្រឹកថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អញ្ជើញបើកយុទ្ធនាការ ស្តីពីការលើកកម្ពស់សុវត្ថិភាពអុ៊ីនធើណេត សីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរ កម្មវិធីនេះធ្វើឡើងនៅវិទ្យាស្ថានជាតិអប់។

## លោកជំទាវ ជូ ប៊ុនអេង អំពាវនាវ ដល់យុវតីទាំងអស់កុំយកកូលាបមួយទង ផ្លាស់ប្តូរជីវិតខ្លួនឯង

http://bayontv.com.kh/ BTV Cambodia 11/02/2020

ភ្នំពេញ ៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានធ្វើការអំពាវនាវដល់យុវតីទាំងអស់កុំយកកូលាបមួយទង ដើម្បីផ្លាស់ប្តូរជីវិតខ្លួនឯង នៅក្នុងឱកាសបុណ្យ នៃសេចក្តីស្រលាញ់ ខណៈបុណ្យនេះនៅសល់តែ៣ថ្ងៃទៀត នឹងមកដល់នោះ។

ឆ្លើយតបនឹងសំនួរអ្នកសារព័ត៌មាន បន្ទាប់ពីចូលរួមយុទ្ធនាការ ស្តីពីការលើកកម្ពស់សុវត្ថិភាពអ៊ីនធើណេត សីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរ នៅវិទ្យាស្ថានជាតិអប់រំ នាព្រឹកថ្ងៃ ទី១១ ខែកុម្ភៈ ឆ្នាំ២០២០ នេះលោកជំទាវ ជូ ប៊ុនអេង បានលើកឡើងថា យុវតីទាំងអស់គប្បីយល់ដឹងអំពីអត្ថន័យបុណ្យ នៃសេចក្តីស្រលាញ់ឲ្យបាន

ច្បាស់លាស់បន្ថែមទៀត ហើយកុំចាត់ទុកបុណ្យនេះជាបុណ្យសង្សា ហើយត្រូវចាត់ទុកថា ជាថ្ងៃបុណ្យនៃក្ដីស្រលាញ់ចំពោះឪពុកម្ដាយ និងក្រុមគ្រួសារ និងបងប្អូនយើងវិញទើបជាការល្អ។

ទាក់ទងនឹងយុទ្ធនាការ ស្ដីពីការលើកកម្ពស់សុវត្ថិភាពអ៊ីនធើណេត សីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរវិញ លោកជំទាវ ជូ ប៊ុនអេង បានលើកឡើងថា ការប្រើប្រាស់ប្រព័ន្ធអ៊ិនធើណែត គឺជាការល្អបំផុតសម្រាប់អភិវឌ្ឍនូវប្រទេសជាតិនីមួយៗ នាពេលបច្ចុប្បន្ននេះ ប៉ុន្តែការប្រើនេះ ក៏គប្បីប្រើឲ្យមានប្រយោជន៍ ខណៈប្រព័ន្ធអ៊ីនធើណែតនេះក៏មានជនខិលខូចយកមកប្រើ ដើម្បីគេងប្រវ័ញ្ចនូវលើកុមារ និងការជួញដូរមនុស្សដែរនោះ។

សូមបញ្ជាក់ថា ប្រទេសកម្ពុជា បានចាប់ផ្ដើមចូលរួមយុទ្ធនាការទិវាសុវត្ថិភាពអ៊ីនធើណែតសកល ខណៈកម្មវិធីនេះត្រូវបានធ្វើឡើងនៅទូទាំងពិភពលោក ដើម្បីផ្ដល់ជាប្រយោជន៍ដល់កុមារ ជាពិសេសសម្រាប់យុវតី និងស្រីឲ្យរួចផុតពីការកេងប្រវ័ញ្ច និងបោកបញ្ឆោតពីជនអគតិតាមប្រព័ន្ធដ៏ទំនើបមួយនេះ៕

# ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០២០

## កិច្ចប្រជុំត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិលើកទី២ ស្តីពី កតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់

https://gdlf-kh.com/ 2020/02/12/ Kim Sopha ភ្នំពេញ

រាជធានីភ្នំពេញ ៖ នៅព្រឹកថ្ងៃពុធ ៤រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០២០ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិលើកទី២ ស្តីពីកតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM) នៅសណ្ឋាគារភ្នំពេញ។

## អង្គការ និងមន្ត្រីធ្វើយុទ្ធនាការលើកកម្ពស់សុវត្ថិភាពអ៊ីនធឺណិត និងសីលធម៌សង្គម

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 12 February 2020 | 10:26 ICT

**ភ្នំពេញៈ** អង្គការសកម្មភាពដើម្បីកុមារ (APLE) គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រសួងពាក់ព័ន្ធបានសហការគ្នាធ្វើយុទ្ធនាការស្ដីពីការ «ការលើកកម្ពស់សុវត្ថិភាពអ៊ីនធឺណិត សីលធម៌សង្គម និងតម្លៃគ្រួសារ» ដើម្បីលើកកម្ពស់ការប្រើប្រាស់ អ៊ីនធឺណិតបច្ចេកវិទ្យាឌីជីថលប្រកបដោយសុវត្ថិភាពពិសេសក្នុងចំណោមកុមារ និងយុវវ័យ។

សេចក្ដីប្រកាសព័ត៌មានរបស់ (APLE) ឲ្យដឹងថាៈ «គោលគំនិតនៃយុទ្ធនាការនេះគឺមនុស្សម្នាក់ៗមានការទទួលខុសត្រូវដើម្បីធ្វើឲ្យមានភាពខុសគ្នាបែបវិជ្ជមានតាមបណ្ដាញអ៊ីនធឺណិត អនឡាញរាប់តាំងពីកុមារដែលគួរតែមានសន្ដានចិត្តល្អ និងគោរពអ្នកដទៃតាមប្រព័ន្ធអ៊ីនធឺណិត និងចេះការពារខ្លួនពីគ្រោះថ្នាក់តាមរយៈការប្រើប្រាស់អ៊ីនធឺណិតនេះ»។ សេចក្ដីប្រកាសដដែលនេះថា ឪពុកម្ដាយ អ្នកមើលថែកុមារ និងគ្រូបង្រៀនគួរតែណែនាំកុមារឲ្យឆ្ពោះទៅរកការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយសុវត្ថិភាពដោយផ្ដល់ឲ្យពួកគេនូវឧបករណ៍ និងចំណេះដឹងដើម្បីមានជម្រើសកាន់តែល្អប្រសើរជាងមុន ខណៈក្រុមហ៊ុនផ្ដល់សេវាអ៊ីនធឺណិតអាចជួយបង្កើតសុវត្ថិភាពអ៊ីនធឺណិតតាមរយៈការផ្សព្វផ្សាយនូវមាតិកាល្អៗ និងសេវាកម្មប្រកបដោយសុវត្ថិភាពនៅលើប្រព័ន្ធអ៊ីនធឺណិតដោយភាពទទួលខុសត្រូវដល់សង្គម។

លោក សំលៀង សីលា នាយកប្រតិបត្តិ APLE ថ្លែងថាៈ «អ្វីដែលយើងធ្វើរាល់ថ្ងៃដើម្បីបញ្ឈប់បទល្មើសតាមប្រព័ន្ធអ៊ីនធឺណិតប្រឆាំងនឹងកុមារយើងសូមគាំទ្រយុទ្ធនាការសកលប្រចាំឆ្នាំនៃសុវត្ថិភាពអ៊ីនធឺណិត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត។ យើងសូមអំពាវនាវដល់ស្ថាប័នរដ្ឋាភិបាល អ្នកនយោបាយ អ្នកធ្វើសេចក្ដីសម្រេចចិត្ត មន្ត្រីអនុវត្តច្បាប់ វិស័យឯកជន សង្គមស៊ីវិល គ្រូបង្រៀន ឪពុកម្ដាយ អាណាព្យាបាលកុមារ និងយុ

វជនចូលរួមទាំងអស់គ្នាដើម្បីធ្វើឲ្យការប្រើប្រាស់អ៊ីនធឺណិតកាន់តែមានសុវត្ថិភាព»។ លោកបន្ថែមថា យុទ្ធនាការនេះ អង្គការ APLE និងអ្នកពាក់ព័ន្ធមានគោលបំណងលើកកម្ពស់ការយល់ដឹងក្នុងចំណោមអ្នកពាក់ព័ន្ធនានាស្តីពីសុវត្ថិភាព ក្នុងការប្រើប្រាស់អ៊ីនធឺណិតហានិភ័យនៃអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត និងអំពីសីលធម៌សង្គម និងតម្លៃគ្រួសារផងដែរ។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៃក្រសួងមហាផ្ទៃ បានថ្លែងក្នុងពេលបើកយុទ្ធនាការនេះថា ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតបានផ្តល់ផលទាំងវិជ្ជមាន និងអវិជ្ជមានដល់កុមារ និងយុវជន ដូច្នេះមាតាបិតា អាណាព្យាបាលត្រូវណែនាំកូនឲ្យបានត្រឹមត្រូវ ពិសេសកុមារ និងយុវជនផ្ទាល់ត្រូវស្វែងយល់ពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា និងអ៊ីនធឺណិតឲ្យបានច្បាស់លាស់មុននឹងប្រើប្រាស់។ លោកស្រីថ្លែងថា៖ «កុមារនៅពេលប្រើប្រាស់ប្រព័ន្ធទូរស័ព្ទច្រើនធ្វើឲ្យខួរក្បាលដំណើរការមិនល្អ ប៉ះពាល់ដល់ភ្នែករបស់កុមារ ព្រោះទូរស័ព្ទទំនើបៗមានជាតិវិទ្យុសកម្ម។ ចំពោះកុមារីបើមិនយល់ពីការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតឲ្យបានច្បាស់លាស់មុននឹងប្រើប្រាស់ទេ អាចនាំឲ្យជនខិលខូចឆ្លៀតឱកាសប្រព្រឹត្តអំពើមិនល្អ កេងប្រវ័ញ្ចផ្លូវភេទលើកុមារបានតាមរូបភាពផ្សេងៗជាច្រើន»។

លោកស្រី ជុំ ប្រជាប្រិយ៍ អគ្គនាយិការង និងជាតំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ថ្លែងដែរថា ក្នុងការវិវឌ្ឍនៃបច្ចេកវិទ្យា អ៊ីនធឺណិតបានផ្តល់នូវកាលានុវត្តភាពជាវិជ្ជមានជាច្រើនសម្រាប់ការលូតលាស់ និងការវិវឌ្ឍរបស់កុមារ។ ទោះជាយ៉ាងនេះក្តីការវិវឌ្ឍនេះក៏បានក្លាយជាមធ្យោបាយធ្វើឲ្យកុមារងាយរងគ្រោះដោយអំពើហិង្សា និងការកេងប្រវ័ញ្ចផ្លូវភេទ។ លោកស្រីថ្លែងថា៖ «ហានិភ័យនេះមានការកើតឡើងគួរឲ្យព្រួយបារម្ភស្របពេលដែលមានការកើនឡើងនូវការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងដំណាក់កាលដែលកុមារកំពុងប្រើប្រាស់ដោយបានចូលរួមបង្កើតនូវខ្លឹមសារ និងមាតិកាអនឡាញ»។ លោកស្រី ប្រជាប្រិយ៍ បង្ហាញថាតាមទិន្នន័យនៃការវាស់ស្ទង់មតិរបស់អង្គការ unicef ជាមួយយុវជនចំនួន ១៧ ម៉ឺននាក់ក្នុងប្រទេសជាង ៣០ ក្នុងនោះមានប្រទេសក្នុងតំបន់អាស៊ីផងដែរបានបង្ហាញថា កុមារម្នាក់ក្នុងចំណោម ៣ នាក់ត្រូវបានកេងប្រវ័ញ្ច និងរំលោភបំពានតាមរយៈប្រព័ន្ធអ៊ីនធឺណិត ហើយពួកគេពុំបានដឹង និងពុំបានទទួលព័ត៌មានគ្រប់គ្រាន់ក្នុងការគាំទ្រនៃករណីនេះ។

សិស្សវិទ្យាល័យអនុវត្តន៍រាជធានីភ្នំពេញឈ្មោះ ថុន ជំនោ ដែលបានចូលរួមក្នុងយុទ្ធនាការនេះដែរបានថ្លែងថា ប្រព័ន្ធអ៊ីនធឺណិត គឺមានសារៈសំខាន់ណាស់សម្រាប់ការប្រើប្រាស់របស់មនុស្សគ្រប់គ្នា វាបានផ្តល់ព័ត៌មានជាតិ និងអន្តរជាតិ និងមេរៀនអប់រំផ្សេងៗបាននៅជុំវិញពិភពលោក។ សិស្សរូបនេះបន្តថា៖ «ប្រព័ន្ធអ៊ីនធឺណិតក៏ជាផ្នែកមួយយ៉ាងសំខាន់សម្រាប់សិស្សានុសិស្សក្នុងការសិក្សាស្រាវជ្រាវរៀនសូត្រ បន្ថែម និងការទំនាក់ទំនងដែលជាផ្នែកសំខាន់មិនអាចខ្វះបាន»។ សិស្សរូបនេះបានអំពាវនាវដល់យុវជនផ្សេងទៀត គួរគប្បីប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតឲ្យមានតម្លៃ និងប្រើក្នុងផ្លូវល្អ ដើម្បីឲ្យក្លាយខ្លួនជាពលរដ្ឋល្អ យុវជនល្អនៅក្នុងសង្គម៕

## រាជរដ្ឋាភិបាល នៅតែបន្តផ្តល់សិទ្ធិដល់ពលករស្របច្បាប់ កំពុងធ្វើការនៅប្រទេសក្រៅ

http://bayontv.com.kh/ 12/02/2020

ភ្នំពេញ ៖ អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានអះអាងថា នាពេល បច្ចុប្បន្ននេះ រាជរដ្ឋាភិបាល នៅតែបន្តផ្តល់សិទ្ធិស្របច្បាប់ដល់ពលករខ្មែរ ដែលកំពុងធ្វើការនៅក្រៅ ប្រទេស ជាដែល ជាពិសេស គឺប្រទេសថៃ បើទោះបីជាសព្វថ្ងៃ ធ្វើជូនពួកគេបានមួយលានប្រាំបីម៉ឺននាក់ ហើយនោះ។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោយពីកិច្ចប្រជុំអន្តរក្រសួង ស្តីពីកិច្ចប្រជុំត្រៀមរៀបចំសិក្ខា សាលាថ្នាក់ជាតិ លើកទី២ ស្តី

ពីកតិកាសញ្ញាពិភពលោកសម្រាប់ ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM) នៅថ្ងៃទី១២ ខែកុម្ភៈ នេះ បានប្រាប់ក្រុមអ្នកសារព័ត៌មានថា ពលករខ្មែរ សព្វ ថ្ងៃនេះ គឺភាគច្រើនមានសិទ្ធិស្របច្បាប់ បន្ទាប់ពីរាជរដ្ឋាភិបាល បានយកចិត្តទុកដាក់សហការជាមួយ ប្រទេសជាដៃគូ ហើយជាប្រទេសដែលពលករខ្មែរកំពុងធ្វើការនៅទីនោះ។

យ៉ាងណាក៏ដោយ លោកជំទាវ ជូ ប៊ុនអេង ក៏នៅតែសម្ដែងការព្រួយបារម្ភចំពោះពួកគេដដែល ជាពិសេស គឺទាក់ទងនឹងផ្នែកច្បាប់ ខណៈដែលពួកគេជួបប្រទះនឹងបញ្ហាអ្វីមួយ ដោយសារតែពួកគេ នាពេល កន្លងទៅ បានលួចទៅធ្វើការមិនស្របច្បាប់ ហើយមិនមកបំពេញបែបបទ ដែលរាជរដ្ឋាភិបាលបានកំណត់ ទីតាំង ដោយសារតែពួកគេកំពុងជាប់ដៃធ្វើការ និងមិនមានការអនុញ្ញាតពីនិយោជករបស់ពួកគេ ជាដើម នោះ។ លោកជំទាវ ជូ ប៊ុនអេង បានឲ្យដឹងផងដែរថា នាពេលបច្ចុប្បន្ន ទេសន្តរប្រវេសក៍ កម្ពុជា ប្រមាណ ១០ភាគរយ បានចំណាកស្រុកទៅក្រៅប្រទេស ដោយក្នុងនោះ ក៏មានអ្នកមិនស្របច្បាប់ផងដែរ៕

## កម្ពុជានឹងយកគោលដៅ ៣ចំណុច ក្នុងកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តប្រវេសន៍ មកអនុវត្តសំដៅឲ្យការចំណាកស្រុកមានសុវត្ថិភាព

http://www.freshnewsasia.com/ 2020-02-12

**(ភ្នំពេញ)៖** កម្ពុជា នឹងយកគោលដៅ ៣ចំណុច ក្នុងចំណោមគោលដៅទាំង២៣ចំណុច ដែលកំណត់ក្នុងកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM) ដើម្បីមកអនុវត្តសំដៅធ្វើយ៉ាងណាឲ្យការធ្វើទេសន្តប្រវេសន៍របស់ពលរដ្ឋខ្មែរទៅក្រៅប្រទេស ប្រកបដោយសុវត្ថិភាព និងត្រឹមត្រូវតាមផ្លូវច្បាប់របស់ប្រទេសគោលដៅ។

កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM) គឺជាសេចក្ដីថ្លែងការណ៍រួមមួយ ដែលប្រទេសចំនួន១៩៣ នៅលើពិភពលោក រួមទាំងកម្ពុជាផងដែរ បានទទួលស្គាល់រួមគ្នាថា មានបញ្ហាដូចគ្នាពាក់ព័ន្ធទៅនឹងទេសន្តប្រវេសន៍។ កតិកាសញ្ញានេះ បានដាក់បញ្ចូននូវគ្រប់កង្វល់ទាំងឡាយ ជុំវិញការធ្វើទេសន្តប្រវេសន៍ ដែលធ្វើឲ្យមនុស្សរាប់សិបលាននាក់ ទទួលផលវិបាកពីការធ្វើទេសន្តប្រវេសន៍។

ដើម្បីជ្រើសរើសយកគោលដៅ៣ចំណុច ដែលមាននៅក្នុងកតិកាសញ្ញា GCM នៅព្រឹកថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០នេះ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ) បានដឹកនាំកិច្ចប្រជុំអន្តរក្រសួងមួយ ដើម្បីត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិលើកទី២ នៅខែមីនាខាងមុខ ពាក់ព័ន្ធនឹងការជ្រើសរើសគោលដៅនេះ។

ថ្លែងប្រាប់ក្រុមអ្នកសារព័ត៌មាន លោកស្រី ជូ ប៊ុនអេង បានអះអាងថា ក្នុងកតិកាសញ្ញា GCM បានបែងចែកជា២៣ចំណុចសំខាន់ៗ ដែលសុទ្ធសឹងតែផ្ដោតសំខាន់ ទៅលើការធ្វើទេសន្តប្រវេសន៍ ដើម្បីឲ្យត្រឹមត្រូវទៅតាមផ្លូវច្បាប់ ប៉ុន្តែក្នុងនោះកម្ពុជា បានជ្រើសរើសយកតែ៣ចំណុចប៉ុណ្ណោះ ដើម្បីមកអនុវត្តឲ្យចំអ្វីដែលកំពុងជួបប្រទះ និងជាការងារអាទិភាព។ ឆ្លើយនឹងសំណួរថា តើការជ្រើសរើសត្រឹមតែ៣ចំណុចនេះ ជាការកំណត់របស់ភាគីរដ្ឋពាក់ព័ន្ធឬយ៉ាងណា? លោកស្រី បានលើកឡើងថា ការដែលកម្ពុជាជ្រើសរើសត្រឹមតែ៣ចំណុចមកអនុវត្ត ព្រោះនោះគឺសុទ្ធតែពាក់ព័ន្ធទៅនឹងអ្វីដែលកម្ពុជាកំពុងជួបប្រទះនាពេលបច្ចុប្បន្ន ប៉ុន្តែមិនមែនមានន័យថា គោលដៅផ្សេងទៀតត្រូវបានបោះចោលនោះទេ ពោលនឹងអនុវត្តជាបន្តបន្ទាប់គ្នា។ លោកស្រី បានគូសបញ្ជាក់យ៉ាងដូច្នេះថា «**ក្នុងកតិកាសញ្ញា គោលបំណងទាំង២៣ បែកទិសទាំងអស់ មានរឿងខ្លះអត់ទាក់ទងជាមួយយើងទេ តែវាទាក់ទងទៅនឹង បញ្ហាទេសន្តប្រវេសន៍របស់ប្រទេសផ្សេង ចឹងកម្ពុជាត្រូវសំឡឹងមើលការងារអាទិភាពត្រឹមតែ ២-៣ចំណុចណានោះ ដែលយើងអាចធ្វើបានហើយជាការចាប់ផ្ដើម**

**នៅក្នុងការធ្វើ មិនមែនមានន័យថាយើងបោះបង់គោលបំណង៣ទៀតនោះទេ។ គោលបំណងណាពាក់ព័ន្ធសំខាន់មកកម្ពុជា យើងចាប់ផ្តើមធ្វើ»។**

បើតាមលោកស្រី ជូ ប៊ុនអេង បន្ទាប់ពីរដ្ឋភាគីព្រមទទួលយកនូវកតិកាសញ្ញាពិភពលោក GCM នេះកាលពីឆ្នាំ២០១៨ បានកំណត់ថា នៅរៀងរាល់៤ឆ្នាំម្តង នឹងជួបប្រជុំគ្នា ដើម្បីនិយាយអំពីប្រទេសណាជ្រើសរើសយកគោលបំណងអ្វី ហើយបានសម្រេចអ្វីខ្លះ ដើម្បីចែករំលែកបទពិសោធន៍ឲ្យគ្នាទៅវិញទៅមក។ កម្ពុជា ក៏នឹងយកគោលដៅ៣ចំណុច ដែលបានជ្រើសរើសនេះ ទៅចែករំលែកនៅលើឆាកអន្តរជាតិផងដែរ។ សម្រាប់ការសម្រេចយ៉ាងណានោះ នឹងត្រូវធ្វើឡើងម្តងទៀតនៅអំឡុងខែមីនា ដោយកិច្ចប្រជុំនោះនឹងដឹកនាំដោយសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ នេះជាអ្វីដែលលោកស្រី ជូ ប៊ុនអេង បានគូសបញ្ជាក់៕

## កម្ពុជា និងបារាំង បង្ហាញជំហរថានឹងនៅតែបន្តធ្វើកិច្ចការសុំកូនអន្តរប្រទេសជាមួយគ្នា ក្នុងគោលដៅមនុស្សធម៌

http://www.freshnewsasia.com/ 2020-02

**(ភ្នំពេញ)៖** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងប្រទេសបារាំង នៅតែបន្តចាប់ដៃគ្នា និងបង្ហាញជំហររួមគ្នា ធ្វើកិច្ចការសុំកូនអន្តរប្រទេសជាមួយគ្នាដដែល ក្នុងគោលដៅមនុស្សធម៌ ទប់ស្កាត់អំពើជួញដូរមនុស្ស និងដើម្បីស្វែងរកគ្រួសារល្អឲ្យកុមារកំព្រា។

គោលជំហររបស់ភាគីទាំង២ខាងលើ បានធ្វើឡើងខណៈដែលលោក នឹម ថូត រដ្ឋលេខាធិការប្រចាំការ និងជាតំណាង លោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា បានទទួលជួបសម្តែងការគួរសម និងពិភាក្សា ការងារជាមួយប្រតិភូបារាំង ដឹកនាំដោយ លោក Denis Babet ឯកអគ្គរដ្ឋទទួលបន្ទុកកិច្ចការសុំកូន អន្តរប្រទេសបារាំង នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ នាទីស្តីការក្រសួងសង្គមកិច្ច។ នៅក្នុងឱកាសនោះ លោក នឹម ថូត បានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជា អនុវត្តគោលនយោបាយការពារសិទ្ធិកុមារ ស្របតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារ ដែលបានដាក់បញ្ចូលក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ លោក នឹម ថូត បានបន្ថែមឲ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកការងារសុំកូនអន្តរប្រទេស ជាគោលនយោបាយមួយ ក្នុងគោលដៅមនុស្សធម៌ ផ្សារភ្ជាប់ទៅនឹងការគោរព អនុវត្តសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ ទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការសុំកូនអន្តរប្រទេស និងស្វែងរកគ្រួសារល្អឲ្យកុមារកំព្រា ដែលមិនអាចទុកដាក់ជាកូនចិញ្ចឹម នៅក្នុងប្រទេសបាន។

បន្ថែមពីលើនេះ លោក Denis Babet ឯកអគ្គរដ្ឋទទួលបន្ទុកកិច្ចការសុំកូនអន្តរប្រទេសបារាំង បានលើកឡើងថា ប្រទេសបារាំងនៅតែបន្ត សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងកិច្ចការសុំកូនអន្តរប្រទេសដដែល ដើម្បីជួយដល់កុមារកំព្រានៅកម្ពុជា ឲ្យពួកគាត់មានជីវិតរស់នៅប្រសើរជាងមុន។ លោក Denis Babet បានបន្តថា ការសហការជាមួយកម្ពុជា នាពេលនេះ គ្មានគោលបំណងអ្វីផ្សេងក្រៅតែពីការជួយក្នុងគោលដៅមនុស្សធម៌ និងដើម្បីទប់ស្កាត់អំពើជួញដូរមនុស្សឡើយ។ ក្នុងជំនួបនាថ្ងៃនេះ ទាំងភាគីកម្ពុជា និងភាគីបារាំង បានសម្តែងការពាក់ទាក់គ្នា និងភាពស្និទស្នាលគ្នាទៅវិញទៅមក ក្នុងនាមប្រទេសជាមិត្ត និងជាដៃគូដ៏ល្អ ក្នុងការបម្រើលើការងារសុំកូនអន្តរប្រទេសនៅកម្ពុជា។

គួរបញ្ជាក់ថា នៅក្នុងប្រទេសកម្ពុជាការសុំកូនអន្តរប្រទេស បានអនុវត្តចាប់តាំងពីឆ្នាំ១៩៨៧ រហូតដល់ខែមេសាឆ្នាំ២០១១។ ប្រទេសដែលមានកិច្ចសហការជាមួយកម្ពុជា រួមមាន ប្រទេសបារាំង អាមេរិក បែលហ្ស៊ិក កាណាដា អ៊ីតាលី អង់គ្លេស សាន់សូស៊ីយ៉ា ប៉ូឡូញ ស៊ីសែល ម៉ាល់តា ហ្វាំងឡង់ អេស្ប៉ាញ ក្រិក អាហ្វ្រិកខាងត្បូងជាដើម៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ០៧នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងការស្នាក់នៅខុសច្បាប់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 11-02-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នារសៀល ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ បានទទួលពលករខ្មែរ ០៧នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងការស្នាក់នៅខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៧នាក់ ស្រី ០៤នាក់ មានស្រុកកំណើតនៅខេត្តបាត់ដំបង ០៤នាក់ ស្រី ០២នាក់ និងខេត្តសៀមរាប ០៣ នាក់ ស្រី ០២នាក់៕

## ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០២០

## បង្ក្រាបទីតាំងសញ្ចារកម្ម ហាងម៉ាស្សាយីហោ "ស្រីប៉ាត់" ក្នុងបុរីវិរីណា ឃាត់ខ្លួនម្ចាស់ និងនារីម៉ាស្សាសរុប៨នាក់

http://nokorwatnews.com/ 12-02-2020

ភ្នំពេញ៖ ជនសង្ស័យ២នាក់ប្តីប្រពន្ធ រួមនឹងនារីម៉ាស្សាបម្រើសេវាផ្លូវភេទ៦នាក់ ត្រូវបានកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្សក្នុងប្រទេស នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ធ្វើការស្រាវជ្រាវបង្ក្រាប និងឃាត់ខ្លួនដាក់ស្តែង ក្រោយស៊ើបដឹងថាលួចបើកទីតាំងហាងម៉ាស្សាយីហោ "ស្រីប៉ាត់" ក្នុងបុរីវិរីណា បង្កប់សេវាផ្លូវភេទ ។

ករណីបង្ក្រាបករណីសញ្ចារកម្មខាងលើនេះ បានធ្វើឡើងកាលពីវេលាម៉ោង៧ និង៥០នាទីយប់ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ដឹកនាំដោយលោកឧត្តមសេនីយ៍ទោ សំបូរ មាណ្ណារិទ្ធ អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សក្នុងប្រទេស នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយ តំណាងចៅសង្កាត់គោកឃ្លាង នគរបាលប៉ុស្តិ៍គោកឃ្លាង និងអនុប្រធានភូមិ ដោយមានការសម្របសម្រួលពីលោក ចែ សុង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ស្ថិតនៅផ្ទះតែលេខ២៣(បុរីវិរីណា) ផ្លូវបេតុង ភូមិគោកឃ្លាង សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយនាំខ្លួនជនសង្ស័យប្តីប្រពន្ធ២នាក់ជាម្ចាស់ទីតាំង និងជនរងគ្រោះចំនួន០៦នាក់ មកកាន់នាយកដ្ឋាន ដើម្បីធ្វើការសាកសួរ និងស្រាវជ្រាវបន្តតាមនីតិវិធី ។

លោកឧត្តមសេនីយ៍ទោ សំបូរ មាណ្ណារិទ្ធ អនុប្រធាននាយកដ្ឋាន បានឲ្យដឹងនៅព្រឹកថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០នេះថា កម្លាំងជំនាញបានឃាត់ខ្លួនជនសង្ស័យប្តីប្រពន្ធ២នាក់ជាម្ចាស់ទីតាំងមាន៖ ឈ្មោះ វន់ ដា (ប្តី) និងឈ្មោះ សារ៉ែន ស្រីផាត់ ហៅ ស្រីប៉ាត់(ប្រពន្ធ) ។ ចំណែកជនរងគ្រោះចំនួន០៦នាក់៖ ទី១-ឈ្មោះ ឡាង សុខអែម ភេទស្រី អាយុ១៥ឆ្នាំ ជនជាតិខ្មែរ ស្រុកកំណើតភូមិឈើទាល ឃុំឈើទាល ស្រុកសណ្តាន់ ខេត្តកំពង់ធំ បច្ចុប្បន្នស្នាក់នៅក្នុងទីតាំងហាងម៉ាស្សាស្រីប៉ាត់ ។ ទី២-ឈ្មោះ សេង សុខម៉េង ហៅ យី ភេទស្រី អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ស្រុកកំណើតភូមិឈើទាល ឃុំឈើទាល ស្រុកសណ្តាន់ ខេត្តកំពង់ធំ បច្ចុប្បន្នស្នាក់នៅក្នុងទីតាំងហាងម៉ាស្សាស្រីប៉ាត់ ។ ទី៣-ឈ្មោះ ស៊្រុន ស្រីអយ ហៅ ស្រីអូន ភេទស្រី អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ស្រុកកំណើតភូមិស្ទឹងត្រង់ ខេត្តកំពង់ចាម ស្នាក់នៅក្នុងទីតាំងហាងម៉ាស្សាស្រីប៉ាត់ ។ ទី៤-ឈ្មោះ ម៉ាប់ ស្រីលិ ភេទស្រី អាយុ១៨ឆ្នាំ ជនជាតិខ្មែរ ស្រុកកំណើតឃុំកោះតាស៊ុយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ស្នាក់នៅផ្ទះជួលម្តុំទួលគោក ។ ទី៥-ឈ្មោះ ម៉ុន ពិសី ភេទស្រី អាយុ២០ឆ្នាំ ជនជាតិខ្មែរ ស្រុកកំណើតខេត្តត្បូងឃ្មុំ ស្នាក់នៅក្នុងទីតាំងហាងម៉ាស្សាស្រីប៉ាត់ និងទី៦-ឈ្មោះ រ៉ា កញ្ញា ភេទស្រី អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ស្រុកកំណើតភូមិព្រែកស្លែង ឃុំតាលុន ស្រុកស្អាង ខេត្តកណ្តាល ស្នាក់នៅក្នុងទីតាំងហាងម៉ាស្សាស្រីប៉ាត់ ។

លោកអនុប្រធាននាយកដ្ឋានបន្តថា៖ វត្ថុតាងដកហូតរួមមាន៖ ១.ជាន់ទ្បៀតឿបន្ទប់ទី១ ស្រោមអនាម័យប្រើរួចចំនួន៣ និងមិនទាន់ប្រើចំនួន២ ។ ២.ជាន់ទ្បៀតឿបន្ទប់ទី២ ឯកសារជួលផ្ទះ និងសៀវភៅកត់ម៉ោង ។ ៣.ជាន់ទី១បន្ទប់ទី៣ ស្រោមអនាម័យមិនទាន់ប្រើចំនួន១ ។ ៤. ជាន់ផ្ទាល់ដីផ្ទះបាយខាងក្រោយ កន្សែងជូតទឹកកាមបុរសមួយចំនួនធំ ។ ៥.ជាន់ផ្ទាល់ដីថតតុខាងមុខ ប្រាក់រៀលចំនួន១៤០០០០៛(ដប់បួនម៉ឺនរៀល) និងប្រាក់ដុល្លា១៥$(ដប់ប្រាំដុល្លាអាមេរិក) ។ ៦.ជាន់ផ្ទាល់ដីថតតុខាងមុខ ក្រដាស់កិច្ចសន្យា២សន្លឹក សៀវភៅកត់ត្រាម៉ោងភ្ញៀវចេញ-ចូល និងលើជញ្ជាំងលិខិតអនុញ្ញាតិបើកអាជីវកម្ម ។ ប្រភពដដែលបន្តទៀតថា ផ្អែកតាមការបំភ្លឺរបស់ជនរងគ្រោះទាំង០៦នាក់ និងចម្លើយរបស់ជនសង្ស័យឈ្មោះ វន់ ដា(ប្តី) និងឈ្មោះ សារ៉ន ស្រីផាត់ ហៅ ស្រីប៉ាត់(ប្រពន្ធ) ព្រមទាំងការស៊ើបអង្កេតរបស់សមត្ថកិច្ចបានរកឃើញ៖ នារីម៉ាស្សាបំរើសេវាផ្លូវភេទ មានចំនួន០៦នាក់ មានអនីតិជនក្រោមអាយុ១៨ឆ្នាំចំនួន០៣នាក់ ។

ដោយឡែកជនសង្ស័យឈ្មោះ វន់ ដា (ប្តី) និងឈ្មោះ សារ៉ន ស្រីផាត់ ហៅ ស្រីប៉ាត់(ប្រពន្ធ) បានដាក់កាំមេរ៉ាសុវត្ថិភាពដើម្បីគ្រប់គ្រងហាងម៉ាស្សា ស្រីប៉ាត់ និងដើម្បីដឹងថានារីម៉ាស្សា បានបំរើសេវា ម៉ាស្សាក្រលៀន ឬ រួមភេទ ឲ្យភ្ញៀវរឺទេ ។ ចំណែកប្រាក់ដែលបាននោះ ថៅកែបានដកយកប្រាក់ ចំនួន៥$(ប្រាំដុល្លាអាមេរិក)ពីការបំរើសេវាម៉ាស្សាក្រលៀន ឬ រួមភេទ មួយលើក ។ ជាពិសេសនោះជនសង្ស័យឈ្មោះ វន់ ដា ជាអ្នកបង្ហាត់បង្រៀននារីម៉ាស្សាទាំងអស់ឲ្យចេះម៉ាស្សាក្រលៀន (រួមភេទដោយដៃ) ដោយឲ្យនារីម៉ាស្សាអនុវត្តដោយផ្ទាល់ជាមួយខ្លួន ។

បច្ចុប្បន្ន ជនសង្ស័យ២នាក់ប្តីប្រពន្ធឈ្មោះ វន់ ដា និងឈ្មោះ សារ៉ន ស្រីផាត់ ហៅ ស្រីប៉ាត់ ពិតជាបើកហាងម៉ាស្សាកោសជប់ ប្រព្រឹត្តអំពើសញ្ញាកម្ម ដើម្បីកេងប្រវ័ញ្ចលើស្ត្រី និងកុមារ ប្រាកដមែន ត្រូវបានកម្លាំងសមត្ថកិច្ចកសាងសុំរឿងបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីដាក់ទោសតាមច្បាប់ ។ ចំណែកជនរងគ្រោះ៦នាក់នោះ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ដើម្បីធ្វើការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមជំនាញ ៕ ចន្ទ លីហ្សា

## លោកឧត្តមសេនីយ៍ត្រី បែន តារា ដឹកនាំមន្ត្រីពាក់ព័ន្ធជួបប្រជុំ ជាមួយអង្គភាពការពារកុមារ (CPU)

http://cambodiapolice.com/policekh/ 4:06 pm 12 កុម្ភៈ 2020

ខេត្តកែប៖ នារសៀលថ្ងៃពុធ ៤រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ លោកឧត្តមសេនីយ៍ត្រី បែន តារា ស្នងការនគរបាលខេត្តកែប បានដឹកនាំលោក លោកស្រីប្រធានផែនការងារព្រហ្មទណ្ឌ ផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន រួមជាមួយមន្ត្រីពាក់ព័ន្ធ ដើម្បីជួបប្រជុំជាមួយអង្គភាពការពារកុមារ(CPU) នៅសាលប្រជុំតូចស្នងការដ្ឋាននគរបាលខេត្ត ស្តីពីកិច្ចការ និងកិច្ចសហប្រតិបត្តិជាមួយកងកម្លាំងនគរបាលជាតិកម្ពុជាសម្រាប់ឆ្នាំ២០២០ កិច្ចប្រជុំបានផ្តោតសំខាន់ទៅលើការស៊ើបអង្កេត និងស្វែងរកភ័ស្តុតាងដើម្បីដាក់បន្ទុកលើជនសង្ស័យ ៕

## ប៉ូលីសថៃបានបើកប្រតិបត្តិការបង្ក្រាបករណីពពោះជំនួស ឃាត់ខ្លួនជនជាតិចិនម្នាក់ និងស្ត្រី៧នាក់ទៀត ដែលខ្លះកំពុងពពោះ

https://www.facebook.com/ Thai PBS News 13-02-2020

ព័ត៌មានពីស្រុកថៃ ថ្ងៃទី១៣ ខែកុម្ភៈនេះ ខាងប៉ូលីសថៃ បានបើកប្រតិបត្តិការបង្ក្រាបករណីពពោះជំនួស ឃាត់ខ្លួនជនជាតិចិនម្នាក់ និងស្ត្រី៧នាក់ទៀត ដែលខ្លះកំពុងពពោះ និងស្ត្រីម្នាក់ទៀតដែលមើលថែក្មេង និងសង្គ្រោះបានទារកភេទប្រុសម្នាក់ដែលមានអាយុបានប្រហែលជា ២០ថ្ងៃ។ ជនជាតិចិនម្នាក់នេះប្រកបមុខរបរនេះមក ១៣ឆ្នាំហើយ។ ការពពោះជំនួស មាន៣ដំណាក់កាល ជាដំបូង ពួកគេឆ្លងទៅឡាវ ដើម្បីបណ្តុះមេជីវិតនៅទីនោះ ពេលបានផលហើយ

ពួកគេត្រលប់មកវិញ ថៃរក្សាគត់នៅប្រទេសថៃ។ ពេលដែលផ្ទៃពោះមានអាយុ ៧ខែ គេនិងបញ្ជូនស្ត្រីពពោះទៅឆ្លងទន្លេនៅចិន តែដោយសារមានការផ្ទុះវីរុសក្លូរូណាថ្មីៗនេះ ទើបពួកគេសម្រេចឆ្លងទន្លេក្នុងស្រុក។ ក្នុងផ្ទះនោះមានសម្ភារៈសង្គ្រោះបន្ទាន់ទារកទៀតផង។ កន្លងមកទារកដែលកើតមកគឺត្រូវបានលក់ដូរនៅប្រទេសចិន ហើយក៏មិនបានដឹងថាតើគេយកទារកទៅចិញ្ចឹមឬក៏ធ្វើអ្វីផ្សេងទៀតឡើយ។

## ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០២០

## ឃាត់ខ្លួនស្ត្រីសង្ស័យម្នាក់ អនុវត្តតាមដីកាបង្គាប់អោយចាប់ខ្លួន ចំនួន០២ដីកា ពីបទការនាំចេញដោយមិនស្របច្បាប់

http://cambodiapolice.com/policekh/ 11:50 pm 13 កុម្ភៈ 2020

ខេត្តកំពង់ចាម៖ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ កាលពីវេលាម៉ោង១៣និង៣០នាទី កំលាំងអធិការដ្ឋាននរបាលស្រុកកងមាស បានអនុវត្តតាមដីកាបង្គាប់អោយចាប់ខ្លួន ចំនួន០២ដីកា មានដីកាលេខ១៣៩៦ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨ របស់លោកស្រី គឹម លុយ ចៅក្រមស៊ើបសួរ និង ដីកាលេខ ៩៧៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ របស់លោកស្រី ហៃ ណៃហេង ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកំពង់ចាម ។

មន្ត្រីនរបាលស្រុកកងមាសបានឲ្យដឹងថា៖ ជនសង្ស័យដែត្រូវបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ ហ័ត សុខហ័ង ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ រស់នៅភូមិល្វាលើ ឃុំស្ដៅ ស្រុកកងមាស ខេត្តកំពង់ចាម ។ ពីបទការនាំចេញដោយមិនស្របច្បាប់ ដោយមានគោលដៅ ប្រព្រឹត្តនៅ ភូមិខ្ពបលើ ឃុំស្ដៅ ស្រុកកងមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០១៣ និងនៅភូមិល្វាលើ ឃុំស្ដៅ ស្រុកកងមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ ៕ បច្ចុប្បន្នជនសង្ស័យ ត្រូវបានសមត្ថកិច្ចបញ្ជូនខ្លួនមកកាន់សាលាដំបូងខេត្តកំពង់ចាម ដើម្បីអនុវត្តតាមនីតិវិធី ៕

## ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០២០

## សម្តេចតេជោ អញ្ជើញបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកផែនការសកម្មភាពការងារឆ្នាំ២០២០ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

http://nokorwatnews.com/ 17-02-2020

ភ្នំពេញ៖ នៅវិមានសន្តិភាពព្រឹកថ្ងៃទី ១៧កុម្ភៈនេះក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីបានបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកផែនការសកម្មភាពការងារឆ្នាំ២០២០ របស់ខ្លួនក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាអនុប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ។

បើតាមរបាយការណ៍របស់លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារីនិងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រីបានវាយតម្លៃថា.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីសូមគោរពថ្លែងអំណរគុណសម្តេចតេជោនាយករដ្ឋមន្ត្រី ដែលតែងតែអញ្ជើញ ជាអធិបតីដ៏ខ្ពង់ខ្ពស់ ក.ជ.ក.ស. និងបានបង្កលក្ខណៈងាយស្រួលឲ្យស្ថាប័ន បានដំណើរការយ៉ាងសកម្មក្នុងការអនុវត្តយេនឌ័រដែលជាអាទិភាពរបស់បានកែប្រែ និងជីវភាពរស់នៅរបស់ការរីកចម្រើនល្អប្រសើរ ។ យន្តការនៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមបានខិតខំបំពេញភារកិច្ចរបស់ខ្លួនសម្រេច បានតាមរយៈការអនុវត្តគោលនយោបាយ ជាពិសេស អនុសាសន៍សម្តេចតេជោ នាយករដ្ឋមន្ត្រី និងជាអនុប្រធានកិត្តិយសជាតិកម្ពុជាដែលបាន ដាក់ចេញឲ្យអនុវត្តន៍ទៅតាមផែនការប្រកបដោយការទទួលខុសចំណុច

ខ្លាំង នៃឆន្ទៈ និង ការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល តួនាទី និងសុខមាលភាពស្ត្រីដោយ បានកសាង និងដាក់ចេញនូវគោលនយោបាយលិខិតបទដ្ឋានយន្តការ និងសេវាចាំបាច់សំដៅដោះស្រាយ និងភាពប្រឈមទាំងឡាយស្ត្រី ក្នុងនោះការពង្រឹង និងផ្ដល់ភាពអង់អាចដល់ស្ត្រីចូលរួមកាត់បន្ថយពង្រឹងអភិបាលកិច្ចអភិវឌ្ឍន៍ និងកំណើនសេដ្ឋកិច្ច។

អនុសាសន៍គន្លឹះ១១សម្ដេចតេជោនាយករដ្ឋមន្ត្រី បានដាក់ចេញនូវសំខាន់ៗ ជារៀងរាល់ឆ្នាំដែលក.ជ.ក.ស ក្នុងនាមជាយន្តការសម្រួល និងផ្ដល់យោបល់ដល់រាជរដ្ឋាភិបាលអំពីបញ្ហាតួនាទី និងសុខមាលភាព ដើម្បីធានា ឲ្យមានការ និងសមភាពយេនឌ័រ ។ គ្រប់ស្ថាប័ន បានជំរុញការផ្សព្វផ្សាយកាន់តែទូលំទូលាយគោលនយោបាយ វិធានការអនុសាសន៍គន្លឹះសម្ដេចតេជោ និងអនុសញ្ញាCEDAW រួមទាំងការពង្រឹងការអនុវត្តដែលជាមូលដ្ឋានបង្កើនដល់ថ្នាក់មន្ត្រីរាជការ និងថ្នាក់យុវជន និងប្រជាពលរដ្ឋសហគមន៍ ។ ក្រសួងស្ថាប័នអង្គភាព អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ បានរួមគ្នាជាកម្លាំង និងបានបង្កើនសមត្ថភាពបំពេញភារកិច្ចយ៉ាងសកម្មក្នុងកិច្ចការពារផ្នែកច្បាប់ដល់ស្ត្រី និងក្មេងស្រីរងគ្រោះដោយអំពើហិង្សា និងអំពើរំលោភផ្លូវភេទតាមរយៈកិច្ចសហការអន្តរាគមន៍ការផ្ដល់សេវាផ្នែកច្បាប់ឆាប់រហ័សជាងមុន ដូចជា សេវាមេធាវីនិងការប្រឹក្សាផ្លូវច្បាប់ក្នុងនោះការបញ្ជាក់កោសល្យវិច័យ ដោយមិនគិតថ្លៃការព្យាបាលបន្ទាន់ និងការថែទាំសុខភាពបឋម និងផ្ដល់សេវាសង្គមផ្សេងៗទៀត ។

ជាមួយនិងសកម្មភាពជាវិជ្ជមានជាច្រើននៃការខិតខំរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីនេះ របាយការណ៍ក៏បានបង្ហាញអំពីចំណុចប្រឈម និងផលប៉ះពាល់មួយចំនួនលើស្ត្រី និងកុមារផងដែរ ដូចជាការធ្វើចំណាកស្រុកដែលជាក្ដីកង្វល់មួយ ទោះបីជាកុមារទាំងនោះត្រូវបានឪពុក ម្ដាយទុកឲ្យនៅជាមួយអ្នកជិតខាង ឬសាច់ញាតិឬទៅតាមឪពុក ម្ដាយដែលធ្វើចំណាកស្រុកក៏ដោយ ក៏ក្មេងទាំងនោះជួបបញ្ហាប្រឈមក្នុងការទទួលបានការរៀនសូត្រថែទាំសុខភាពនិងសុវត្ថិភាព ។ កិច្ចប្រជុំនៅថ្ងៃនេះ និងពិភាក្សារិះរកវិធានការថ្មីៗថែមទៀត ដើម្បីដាក់ឲ្យអនុវត្តសម្រេចបានលទ្ធផលយ៉ាងល្អប្រសើរថែមទៀតសម្រាប់ឆ្នាំ២០២០៕

## សម្ដេចតេជោ ឲ្យតាគីពាក់ព័ន្ធពន្លឿន ការកាត់ក្ដី លើស្ត្រីកំពុងជាប់ឃុំ និងឲ្យជួលសណ្ឋាគារបន្ថែម ដើម្បីកាត់ក្ដី

https://www.dap-news.com/ ByPH104 Posted on February 17, 2020

ភ្នំពេញ ៖ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានជំរុញឲ្យក្រុមប្រឹក្សាជាតិដើម្បីស្ត្រី និងក្រសួងកិច្ចការនារី បន្តសហការ ជាមួយ ក្រសួងមហាផ្ទៃ ក្នុងការតាមដានរឿង ស្ត្រីជាទណ្ឌិត ឬជាពិរុទ្ធជន ដើម្បីពន្លឿនការងារ កាត់ក្ដីឲ្យឆាប់ រួមទាំងការស្វែងរកមេធាវី សម្រាប់ការពារស្ត្រី ដែលជាពិរុទ្ធជននោះផងដែរ ជាពិសេស សម្ដេច ក៏អនុញ្ញាតឲ្យជួល សណ្ឋាគារបន្ថែម បើសិនជាខ្វះសាលសវនាការកាត់ក្ដី ។

ក្នុងឱកាសអញ្ជើញជាអធិបតី បើកកិច្ចប្រជុំបូក សរុបលទ្ធផល ការងារឆ្នាំ២០១៩ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០២០ របស់ «ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី» នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០នេះ សម្ដេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា «ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី» មានព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ជាព្រះប្រធានកិត្តិយស និងមានសម្ដេចតេជោ ជាអនុប្រធានកិត្តិយស ។ ចាប់តាំងពីឆ្នាំ២០០៦មក ថ្នាក់ដឹកនាំនៃ «ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី» ដែលមានលោកស្រី អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួង កិច្ចការនារី ជាប្រធាន តែងតែបើកកិច្ចប្រជុំជាទៀងទាត់ រៀងរាល់មួយឆ្នាំម្ដង ក្រោមអធិបតីភាពសម្ដេចតេជោ ហ៊ុន សែន ។ កិច្ចប្រជុំធ្វើឡើងដើម្បីតាមដាន និងត្រួតពិនិត្យរាល់សកម្មភាពការងារ និងការអនុវត្តរាល់អនុសាសន៍ លើការងារមួយចំនួនរបស់ «ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី» ក្នុងការចូលរួមចំណែក ជាមួយរាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់សិទ្ធិសេរីភាពឋានៈតួនាទី ពិសេសការចូលរួមដោះស្រាយ រាល់ការងារជាអាទិភាពនានារបស់ស្ត្រី ។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែង របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការកសាង និងអភិវឌ្ឍសង្គមជាតិ ។ សម្តេចថា បច្ចុប្បន្ន ស្ត្រីបានចូលរួមចំណែកក្នុង កិច្ចការងារជាច្រើនក្នុងវិស័យផ្សេងៗ ដូចជាវិស័យសុខាភិបាល , វិស័យសេវាកម្ម ដូចជាធនាគា សណ្ឋាគារ, ភោជនីដ្ឋាន និងគ្រូបង្រៀន រួមទាំងវិស័យយោធាផងដែរ ។ សម្តេចតេជោ ក៏បានកោតសរសើរ តួនាទីស្ត្រីក្នុងវិស័យយោធា ដែលថ្មីៗនេះមានមានស្ត្រីមួយចំនួន ដែលបានចូលរួមក្នុងកម្លាំង ប្រត្តិការជួយសង្គ្រោះក្នុងហេតុការណ៍ បាក់អគារកាលពីពេលថ្មីៗកន្លងទៅនេះ ពីព្រោះគេបានចូលរួមយ៉ាងសកម្ម ដែលបង្ហាញនូវភាពក្លាហាន ក្នុងការជួយសង្គ្រោះមិនចាញ់បុរសនោះឡើយ។ សម្តេចតេជោ ក៏បានអរគុណផងដែរចំពោះស្ត្រី ដែលបានចូលរួមក្នុងកម្លាំងកងរក្សាសន្តិភាពមួកខៀវ នៃអង្គការសហប្រជាជាតិ ដែលបានចូលរួមក្នុង ប្រទេសមួយចំនួនដូចជា ប្រទេសអៀរ៉ាក់, សៀរី, យេម៉ែន, ម៉ាលី និងអាហ្វ្រិកកណ្តាលជាដើម។

សម្តេចតេជោ ហ៊ុន សែន បញ្ជាក់ថា «ជំរុញឲ្យក្រុមប្រឹក្សាជាតិដើម្បីស្ត្រី និងក្រសួងកិច្ចការនារីត្រូវបន្ត នូវកិច្ចសហការបន្ថែមទៀត ជាមួយក្រសួងមហាផ្ទៃ ក្នុងការតាមដានរឿង ស្ត្រីដែលជាទណ្ឌិត ឬជាពិរុទ្ធជន ដើម្បីធ្វើយ៉ាងណាពន្លឿន ការងារកាត់ក្តីអោយឆាប់ រួមទាំងការស្វែងរកមេធាវី សំរាប់ការពារស្ត្រី ដែលជាពិរុទ្ធជននោះផងដែរ ។ សុំឲ្យក្រសួងយុត្តិធម៌ត្រូវពន្លឿនការងារនេះ ដែលបច្ចុប្បន្ននេះលឺថា មានជាង ២មុឺនសំណុំរឿង ដែលមិនទាន់បានកាត់ក្តី ចូច្នេះត្រូវពន្លឿនសំណុំរឿងនេះអោយបានឆាប់ ហើយបើខ្វះសាលសវនាការកាត់ក្តី អាចជួលសណ្ឋាគារកាត់ក្តីតែម្តងទៅ ។ សុំឲ្យក្រសួងការងារ ត្រូវតាមដានពលការិនី ដែលទៅធ្វើការងារនៅក្រៅប្រទេស ដោយត្រូវយកចិត្តទុកដាក់ ទៅលើសុវត្ថិភាពរបស់ពួកគេ និងការពារការរំលោភបំពានផ្សេងៗ» ។ សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានបញ្ជាឲ្យក្រសួងមហាផ្ទៃ ធ្វើការងារក្នុងបទល្មើសបច្ចេកវិទ្យា ដើម្បីពិនិត្យមើល និងចាត់វិធានការរាល់វីដេអូអាសអាភាស របស់ស្ត្រីខ្មែរមួយចំនួន ដែលបានថត និងបែកធ្លាយដោយខ្លួនឯង ដែលមានតាមវេបសាយមួយចំនួន ព្រោះនេះពិតជាមានការប៉ះពាល់ យ៉ាងខ្លាំងដល់កិត្តយស និងសីលធម៌របស់ស្ត្រីខ្មែរ ហើយណាមួយកម្ពុជា ក៏គ្មានច្បាប់អោយធ្វើបែបនោះឡើយ។ ជាមួយគ្នានោះ សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានបានព្រមានចាត់វិធានការអ្នក ដែលផ្សព្វផ្សាយលក់ ផលិតផលតាមអនឡាញមួយចំនួន ដែលមានការស្លៀកពាក់សុិចសុី ជ្រុលនិយម ហើយធ្វើការផ្សព្វផ្សាយ (Live) លក់ផលិតផលរបស់ខ្លួន លើបណ្តាញសង្គមផ្សេងៗ ដែលនេះក៏ជាការប៉ះពាល់ដល់តម្លៃ សីលធម៌ និងកិត្តិយសស្ត្រីខ្មែរយើងផងដែរ ។

សម្តេចតេជោ បានជំរុញឲ្យមានការបង្កើន សមត្ថភាពមន្ត្រីរាជការស៊ីវិល ជាស្ត្រីតាមការបណ្តុះបណ្តាលសមត្ថភាព ដើម្បីអោយស្ត្រីបានកាន់តួនាទីផ្សេងៗ ក្នុងក្រសួងស្ថាប័ន ដើម្បីអោយចំនួនស្ត្រីមានការ កើនឡើងជាបន្តបន្ទាប់ទៀត។ សម្តេចតេជោបន្ថែមថា កម្ពុជាកំពុងអនុវត្តគោល នយោបាយគាំពារសង្គម ដែលបានចាប់ផ្តើមអនុវត្តមុនគេ ចំពោះស្ត្រីដែលជាកម្មការិនីមានផ្ទៃពោះ ហើយគិតតាំងពីឆ្នាំ២០១៨មក មានស្ត្រីជាង ១៥មុឺននាក់ ដែលបានឆ្លងទន្លេ ។ រាជរដ្ឋាភិបាលកម្ពុជា បានគិតគូចំពោះម៉ោងចេញ-ចូល និងម៉ោងសម្រាកចំពោះកម្មការនី ដែលទទួលបានការ ពិនិត្យផ្ទៃពោះ ដោយមិនគិតថ្លៃ នៅតាមមន្ទីរពេទ្យរដ្ឋ ព្រមទាំងទទួលបានថវិកា ក្នុងពេលសម្រាលកូនទៀតផង ។ ជាពិសេសទៀតនោះ គឺក្នុងពេលសម្រាលកូន គឺបានឈប់សម្រាករយៈពេល ៣ខែ ហើយទទួលបានប្រាក់ខែ១២០%ទៀតផង ។ ដោយឡែក ស្ត្រីក្រក្រី គឺទទួលបានការឧបត្ថម្ភ តាំងពីមានផ្ទះពោះ, ពេលសម្រាល រហូតដល់កូនមានអាយុ ២ឆ្នាំ ៕

## អាជ្ញាធរថៃបានបញ្ជូនជាពលរដ្ឋខ្មែរចំនួន ២នាក់ មកស្រុកវិញ បន្ទាប់ពីដោះលែងពីពន្ធនាគារពីបទកាប់ឈើគ្រញូង

http://www.rasmeinews.com/ February 14, 2020, 3:31 PM

ដោយៈបាយ័ន/ឧត្តរមានជ័យ ៖ អាជ្ញាធរថៃបានបញ្ជូនជាពលរដ្ឋខ្មែរចំនួន ២នាក់ មកស្រុកវិញ បន្ទាប់ពីដោះលែងពីពន្ធនាគារពីបទកាប់ឈើគ្រញូងដោយខុសច្បាប់ ក្នុងទឹកដីថៃ ។ពិធីប្រគល់និងទទួល បានធ្វើឡើងកាលវេលាម៉ោង១៣និង ៥០នាទី ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០នេះ ស្ថិតនៅ អន្តរជាតិជាតិជាំស្រងាំ ក្នុងទឹកដី។

សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំស្រងាំ បាននិយាយថា ប្រជាពលរដ្ឋខ្មែរចំនួន ២នាក់ ដែលត្រូវបានថៃបញ្ជូនមកស្រុកវិញគឺមានឈ្មោះ សួន សុ ភេទប្រុស អាយុ ៥៥ឆ្នាំ រស់នៅភូមិរស្មី ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និងម្នាក់ ឈ្មោះ រ៉ន ស្រួច ភេទប្រុស អាយុ ២០ ឆ្នាំរស់នៅភូមិថ្មី ឃុំសង្កែសន្ទប់ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ សមត្ថកិច្ចបានបន្តថា ជនទាំង២នាក់ត្រូវបាន អាជ្ញាធរថៃបានបញ្ជូនជាចាប់ខ្លួននៅថ្ងៃទី ២៤ កុម្ភៈ ឆ្នាំ ២០១៨ កន្លងមកម្លេះ ពីបទឆ្លងដែនកាប់ឈើក្រញូង ចូលតាមច្រកចាក់ច្រែង ជាប់គុកនៅស្រុកខាន់តាឡាក់ ខេត្តស៊ីសាកេតប្រទេសថៃ៕B/

## ប៉ូលិសថៃចាប់ក្រុមមេខ្លោង“ពពោះជំនួស”សម្រាប់ជនបរទេស

http://www.rasmeinews.com/ February 14, 2020, 3:49 PM

ប៉ូលិសថៃបាននិយាយថាប្ដីប្រពន្ធជនជាតិចិនមួយគូនិងជនជាតិថៃ៧ នាក់ត្រូវបានចាប់ខ្លួននៅប្រទេសថៃកាលពីថ្ងៃព្រហស្បតិ៍ទី ១៣ខែកុម្ភៈពីបទរំលោភច្បាប់ហាមឃាត់ការពពោះជំនួសសម្រាប់ជនបរទេស។ របបអតីតយោធាថៃ បានដាក់សកម្មភាពនៃការពពោះជំនួសនេះនៅក្រៅច្បាប់កាលពីឆ្នាំ២០១៥បន្ទាប់ពីមានរឿងអាស្រូវជាបន្តបន្ទាប់នៅក្នុងប្រទេសមួយដែលធ្លាប់ជាកន្លែងសម្រាប់ការពពោះជំនួសអន្តរជាតិ។

ប៉ូលិសបានប្រាប់ក្រុមអ្នកយកព័ត៌មាននៅសន្និសីទកាសែតមួយនៅទីក្រុងបាងកកថា ប៉ូលិសថៃបានធ្វើការចាប់ខ្លួននៅក្នុងការឆ្មក់ចូលផ្ទះនិងការិយាល័យជាច្រើននៅទីក្រុងបាងកកនិងនៅខេត្តផាធូមថានីនិងខេត្តសុខោតៃ។ ប៉ូលិសបាននិយាយថាពួកគេបានរកឃើញម្ដាយពពោះជំនួសចំនួន ៨ នាក់ដោយក្នុងនោះមានម្នាក់មានផ្ទៃពោះ៨ខែនិងបានសង្គ្រោះក្មេងប្រុសអាយុ២២ថ្ងៃម្នាក់និងក្មេងស្រីអាយុ៤ ខែម្នាក់ផងដែរ។ ពួកគេសង្ស័យថាក្មេង១៤ នាក់ទៀត ត្រូវបានគេជួញដូរទៅប្រទេសចិន រួចហើយ ។

ឧត្ដមសេនីយ៍ប៉ូលិសថៃ បាននិយាយថា“នេះជាបទឧក្រិដ្ឋពពោះជំនួសបរទេស”។លោកបាននិយាយថាពួកគេបានចិញ្ចឹមទឹកកាមមេជីវិត( sperm )នៅក្នុងប្រទេសជិតខាងដោយផ្ដល់ការមើលទាំមុនកំណើតនៅប្រទេសថៃ ហើយបន្ទាប់មក ម្ដាយទាំងនោះបានផ្ដល់កំណើតនៅប្រទេសចិន៕ដោយ៖ *សុខា/sn*

# ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០២០

## កម្ពុជាកំពុងតែរៀបចំគោលនយោបាយ ដើម្បីជួយដល់ពលករបស់ខ្លួន ដែលវិលត្រឡប់ពីប្រទេសគេ

http://bayontv.com.kh/ 18/02/2020

ភ្នំពេញ ៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស បានដឹកនាំក្រុមការងារប្រជុំមួយ ដើម្បីស្វែងរកដំណោះស្រាយ ជួយ

ដល់ពលករខ្មែរ ដែលពួកគេត្រូវបានវិលត្រឡប់ពីក្រៅប្រទេសវិញ ខណៈ ដែលកម្ពុជាធ្លាប់ជួបបញ្ហានេះម្តង ហើយកាលពីឆ្នាំ២០១៤ កន្លងទៅ ។

ថ្លែងប្រាប់អ្នកសារព័ត៌មានក្រោយពីសិក្ខាសាលាពិគ្រោះយោបល់ និងវិធីប្រតិបត្តិស្តង់ ដារួមគ្នា និងផែនការត្រៀមស្តីពីកិច្ចសហប្រតិបត្តិមនុស្សធម៌ សម្រាប់ការឆ្លងព្រំដែន ការត្រៀម ខ្លួននិងការឆ្លើយតប នាព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០នេះ នៅភោជនីយដ្ឋាន ទន្លេបាសាក់២ លោក ជំទាវជូ ប៊ុនអេង បានលើកឡើងថា កម្ពុជាធ្លាប់ជួបប្រទះមួយដងរួចទៅហើយ ដោយ អាជ្ញាធរថៃ បានចាប់បញ្ជូនពលករខ្មែរ ដែលខុសច្បាប់ ឲ្យត្រឡប់មកកម្ពុជាវិញ ដោយគ្មានការ ព្រៀងទុករាប់សែននាក់។ ដូច្នេះ ដើម្បីកុំឲ្យពលករខ្មែរយើងជួបបញ្ហាបន្តទៀត ខណៈដែលពួកគេវិលត្រឡប់មកវិញស្រដៀងនឹងករណីខាងលើនេះ ក្រុមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង ការជួញដូរមនុស្សត្រូវរិះរកមធ្យោបាយ ទុកឲ្យហើយសម្រាប់ពួកគេនិងជួយពួកគេនោះ។

សូមបញ្ជាក់ថា នាពេលបច្ចុប្បន្ននេះ ពលករ ខ្មែរដែលកំពុងធ្វើការនៅក្រៅប្រទេសជាង ១លាននាក់ ទាំងស្របច្បាប់ និងមិនស្របច្បាប់ ក្នុងនោះប្រទេសថៃ ដែលជាប្រទេសជាប់នឹង កម្ពុជាមានច្រើនជាងគេបន្ទាប់ប្រទេសកូរ៉េខាងត្បូង និងម៉ាឡេស៊ី៕

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រជុំត្រៀមលក្ខណៈទទួលពលករចំណាកស្រុក ពេលមកកម្ពុជាវិញ

http://www.freshnewsasia.com/ 2020-02-18

**(ភ្នំពេញ)៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០នេះ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដារួមគ្នា និងផែនការត្រៀម ស្តីពីកិច្ចសហប្រតិបត្តិការមនុស្សធម៌ សម្រាប់ការឆ្លងព្រំដែន ការត្រៀមខ្លួន និងការឆ្លើយតប។ កិច្ចប្រជុំនេះ ដឹកនាំដោយលោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងមានការចូលរួម ពីស្ថាប័នពាក់ព័ន្ធជាច្រើនទៀតផងដែរ។ កិច្ចប្រជុំត្រៀមលក្ខណៈទទួលយកពលករចំណាកស្រុក ដែលកំពុងធ្វើការនៅក្រៅប្រទេស ពេលត្រូវត្រឡប់ ឬបញ្ជូនមកប្រទេសកម្ពុជា ជៀសវាងស្ថានភាពភ្លាមៗ ដូចកាលពីឆ្នាំ២០១៤កន្លងទៅ។

កាលពីឆ្នាំ២០១៤កន្លងទៅ អាជ្ញាធរថៃ បានធ្វើការចាប់បញ្ជូនពលករកម្ពុជា ដែលធ្វើការមិនស្របច្បាប់នៅទីនោះ រាប់ម៉ឺននាក់ មកប្រទេសកម្ពុជាវិញ ដូច្នេះហើយ ដើម្បីជៀសវាងស្ថានភាពដូចនេះ ទើបគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រៀបចំកិច្ចប្រជុំត្រៀមលក្ខណៈ និងរៀបចំផែនការទុកជាមុន ដើម្បីមានវិធានការដោះស្រាយ។

ថ្លែងក្នុងឱកាសនោះ លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានលើកឡើងថា ក្រៅពីការត្រៀម លក្ខណៈជៀសវាងស្ថានភាពកើតឡើងភ្លាមៗ ដូចឆ្នាំ២០១៤កន្លងទៅ កិច្ចប្រជុំនេះគឺផ្តោតសំខាន់លើការរួមគិត រួមធ្វើ ដើម្បីត្រៀមលក្ខណៈទុកជាមុន និងរំពឹងទុកអំពីផលប៉ះពាល់ទៅលើពលករទេសន្តរប្រវេសន៍នៅក្រៅប្រទេស។ លោកស្រី ជូ ប៊ុនអេង បានអះអាងថា បច្ចុប្បន្ននេះប្រទេសនៅលើពិភពលោកទាំងអស់ បាននិងកំពុងប្រឈមជាមួយដំណើរការសេដ្ឋកិច្ចផលិតកម្ម ក្នុងនោះក៏អាចមានពលករកម្ពុជាមួយចំនួនអាចនឹងត្រឡប់មកវិញ នៅក្នុងដំណាក់ដែលពេងចក្រ សហគ្រាសនោះ ដំណើរការមិនល្អ។ លោកស្រីបានគូសបញ្ជាក់ទៀតថា ការគិតរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺការត្រៀមខ្លួនដើម្បីត្រៀមលក្ខណៈថា ប្រសិនបើពលករប្រឈមជាមួយនឹងការវិលត្រឡប់ ឬបញ្ជូនត្រឡប់ តើអាជ្ញាធរពាក់ព័ន្ធត្រូវ

ត្រៀមលក្ខណៈយ៉ាងដូច្នេះ ព្រោះថាកម្ពុជាមិនចង់ឲ្យការវិលត្រឡប់នេះ ប្រឈមជាមួយបញ្ហាដូចកាលពីឆ្នាំ២០១៤ នោះទេ។

អ្វីដែលអាជ្ញាធរកម្ពុជា កំពុងគិតនៅពេលនេះ គឺត្រូវធ្វើយ៉ាងណាដើម្បីឲ្យពលករចំណាកស្រុកដែលអាចនឹងត្រឡប់មកវិញ មានសុវត្ថិភាពតាំងពីចេញដំណើរមក រហូតទៅរស់នៅក្នុងសហគមន៍វិញ។ នេះជាអ្វីដែលលោកស្រី ជូ ប៊ុនអេង បានគូសបញ្ជាក់។ យ៉ាងណាក៏ដោយ លោកស្រី ជូ ប៊ុនអេង បានគូសបញ្ជាក់ថា បើទោះរោងចក្រ សហគ្រាស នៅបរទេសមិនផ្អាក់ដំណើរការ ប៉ុន្តែពលករចំណាកស្រុកដែលទៅពីកម្ពុជា ក៏មិនអាចធ្វើការអស់មួយជីវិតនៅទីនោះដែរ ច្បាស់ជាថ្ងៃណាមួយគាត់នឹងវិលត្រឡប់មកស្រុកកំណើតវិញដដែល ដូច្នេះអាជ្ញាធរត្រូវតែត្រៀមដើម្បីទទួលពួកគាត់។

សូមជម្រាបថា បច្ចុប្បន្នប្រទេសកម្ពុជា បានបញ្ជូនពលករទៅបម្រើការងារនៅប្រទេសចំនួន៦ រួមមានប្រទេសថៃ សាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី ជប៉ុន សិង្ហបុរី និងហុងកុង ដែលមានពលករសរុបចំនួនប្រមាណ ១លាន២សែននាក់។ ពួកគាត់បានផ្ញើថវិកាមកកម្ពុជា ដើម្បីជួយទ្រទ្រង់ជីវភាពក្រុមគ្រួសាររបស់ពួកគាត់ ប្រមាណជាង២ពាន់លានដុល្លារក្នុង១ឆ្នាំៗ៕

## ដើម្បីកាត់បន្ថយចំនួនពលករចំណាកស្រុក គឺយុវជនម្នាក់ ត្រូវមានជំនាញមួយយ៉ាងតិច

http://bayontv.com.kh/ 17/02/2020

រតនគិរី ៖ លោក ជឹម ឈឿន អនុប្រធានផ្នែកផែនការ រដ្ឋបាល ហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិ កម្ពុជាដើម្បីអភិវឌ្ឍយុវជន បានថ្លែងថា ការឈានជើងចូលប្រឡូកក្នុងទីផ្សារការងារ ធ្វើយ៉ាងណាដើម្បីទទួលបានជោគជ័យ និងសម្រេចតាមបំណងប្រាថ្នារបស់ខ្លួន និងដើម្បីកាត់បន្ថយចំនួនពលករចំណាកស្រុក គឺយុវជនម្នាក់ ត្រូវមានជំនាញមួយយ៉ាងតិច ។

នៅក្នុងសិក្ខាសាលា ស្ដីពីការតម្រង់ទិសការសិក្សា និងការងារសម្រាប់យុវជន នៅខេត្តរតនគិរី នៅព្រឹកថ្ងៃទី១៧ ខែកុម្ភៈ នេះ លោក ជឹម ឈឿន អនុប្រធានផ្នែកផែនការ រដ្ឋបាល ហិរញ្ញវត្ថុ នៃអគ្គលេខា ធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន បានជំរុញយុវជន ជាពិសេស សិស្សានុសិស្ស នៅ កម្រិតមធ្យមសិក្សា ឱ្យមានផែនការកាន់តែច្បាស់ ក្នុងការកំណត់អំពីផែនការសិក្សា ការរៀបចំខ្លួនចូលថ្នាក់ ឧត្តមសិក្សា និងរៀនវិជ្ជាជីវៈ ដើម្បីចាប់យកជំនាញ មុននឹងឈានជើងចូលប្រឡូកក្នុងទីផ្សារការងារ។ លោក ជឹម ឈឿន បានឱ្យដឹងទៀតថា កន្លងមក អគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ បាន សហការរៀបចំសិក្ខាសាលាបែបនេះ ចំនួន១២ខេត្តរួចមកហើយ ក្នុងគោលបំណង ដើម្បីផ្សព្វផ្សាយព័ត៌មានសំខាន់ៗដល់យុវជន ជាពិសេសសិស្សានុសិស្ស សំដៅធ្វើយ៉ាងណាឱ្យពួកគេអាចកំណត់ឱ្យបាន ច្បាស់ អំពីផែនការសិក្សា៕

## លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប បានចុះអប់រំផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស

https://www.facebook.com/deputygovernoryousophear/ គ.ខ.ប.ជ សៀមរាប 17-02-2020

ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ក្រុមការងារបង្ការទប់ស្កាត់ ដឹកនាំដោយមន្ទីរអប់រំយុវជន និងកីឡាខេត្ត នៃលេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពីជួញដូរមនុស្ស ខេត្តសៀមរាប បានចុះអប់រំផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវលើកុមារនៅតាមសហគមន៍ ដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅវិទ្យាល័យបន្ទាយស្រី ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ ការ

អប់រំផ្សព្វផ្សាយនេះ រៀបចំឡើង ដើម្បីលោក អ្នកគ្រូ និងសិស្សានុសិស្ស បានយល់ដឹងអំពីរូបភាព និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការរំលោភបំពានផ្លូវភេទលើកុមារ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។

## បទល្មើសព្រហ្មទណ្ឌ ថយចុះជាង២០០លើក បើប្រៀបធៀបទៅឆ្នាំមុន

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០២០ ម៉ោង ១១:៣២ ចន ណារិទ្ធ

រាជធានីភ្នំពេញ ៖ យោងតាមរបាយការណ៍របស់រដ្ឋបាលរាជធានីភ្នំពេញ បានឱ្យដឹងថា ក្នុងរយៈពេលមួយឆ្នាំ សម្រាប់ឆ្នាំ២០១៩កន្លងមកនេះ បទល្មើសព្រហ្មទណ្ឌ កើតមាន ៨៣៨លើក/១.០៤៦លើក ថយចុះចំនួន ២០៨លើក (ស្លាប់៣៣នាក់/ ៤៥នាក់, របួស១១៧នាក់/២៣២នាក់) ក្នុងនោះ បទល្មើសឧក្រិដ្ឋ ១០៨លើក/ ១៣៩លើក ថយចុះ៣១លើក និងបទល្មើសមជ្ឈិម ៧៣០លើក/៩០៧លើក ថយចុះ ១៧៧លើក បើធ្វើការប្រៀបធៀបទៅឆ្នាំ២០១៨កន្លងមក ។ របាយការណ៍ បានបន្តថា មួយឆ្នាំកន្លងមកនេះ សមត្ថកិច្ចបានខិតខំបង្ក្រាបបទល្មើសព្រហ្មទណ្ឌបានចំនួន ៧៤៩ករណី ស្មើនឹង ៨៩,៣៧% នៃបទល្មើសរួម ឃាត់ខ្លួន ១.០៨៩នាក់ (បង្ក្រាបជាក់ស្តែង ៥៩៨ករណី ឃាត់ខ្លួន ៨១៨នាក់ និងបង្ក្រាបដោយស៊ើបអង្កេត ១៥១ករណី ឃាត់ខ្លួន ២៧១នាក់) ក្នុងនោះបទល្មើសឧក្រិដ្ឋ៨៩ករណី ឃាត់ខ្លួន១៦២នាក់ និង បទល្មើសមជ្ឈិម ៦៦០ករណី ឃាត់ខ្លួន ៩២៧នាក់។ ក្រៅពីនេះបង្ក្រាបតាមដីកា ១៧ដីកា ឃាត់ខ្លួន ១៨នាក់ (បទល្មើសឧក្រិដ្ឋ ១ករណី ១នាក់ និងបទល្មើសមជ្ឈិម ១៦ករណី ១៧នាក់) ជនសង្ស័យ និងវត្ថុតាង កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមផ្លូវច្បាប់។

របាយការណ៍របស់រដ្ឋបាលរាជធានីភ្នំពេញបានឱ្យដឹងទៀតថា សម្រាប់បទល្មើសគ្រឿងញៀនបង្ក្រាប បាន ២.២៧៧ករណី/២.០២៣ករណី កើន ២៥៤ករណី ឃាត់ខ្លួន ៤.៧៦១នាក់/៣.៦៧០នាក់ (ស្រី ២៦៤នាក់) កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ភ្នំពេញ ក្នុងនោះ ករណីជួញដូរគ្រឿងញៀន ១.២២៣ករណី ឃាត់ខ្លួន ២.០៤៥នាក់(ស្រី ៩៩នាក់), ករណីប្រើប្រាស់គ្រឿងញៀន ១.០៥៤ករណី ឃាត់ខ្លួន ២.៧១៦នាក់ ( ស្រី ១៦៥នាក់) និងឃាត់ តាមដីកា ៧ដីកា ឃាត់ខ្លួន ៧នាក់។ ក្រៅពីនោះ បានបើកកិច្ចប្រតិបត្តិការបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅតាមក្លឹបកំសាន្តធំៗចំនួន៣គឺ៖ នៅមជ្ឈមណ្ឌល កំសាន្តរ៉ក់ ឃាត់ខ្លួន ចំនួន ៣១១នាក់ (ស្រី ៥៥នាក់), ក្លឹបកំសាន្តម៉ៃអាមី ឃាត់ខ្លួន ចំនួន ៥០នាក់ (ស្រី ១២នាក់) និងក្លឹបលុចសារី ឃាត់ខ្លួន ចំនួន ៤០៨នាក់ (ស្រី ១៨២នាក់) កសាងសំណុំរឿង បញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ សរុបចំនួន ៤១នាក់ និងបណ្តេញចេញពីព្រះរាជាណាចក្រ កម្ពុជា ចំនួន ៤៥នាក់។ ចំណែក ល្បែងស៊ីសងខុសច្បាប់ បង្ក្រាបបាន៩៤ករណី ឃាត់ខ្លួន៤៨៦នាក់ (ស្រី ១១០នាក់) កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ ចំនួន ៨៥នាក់ និងធ្វើកិច្ចសន្យាអប់រំ ៤០១នាក់។

ការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ៖ បង្ក្រាបបាន ៤៧ករណី ឃាត់ខ្លួន ១០៤នាក់ ស្រី ៣៨នាក់ (ជនបរទេស ៥នាក់) រួមមាន ករណីរួមភេទជាមួយអនីតិជន ២៨ករណី ឃាត់ខ្លួន ២៩នាក់, ករណីអាជីវកម្មផ្លូវភេទ ២ករណី ឃាត់ខ្លួន ២នាក់, ករណីសញ្ជារកម្ម ៧ករណី ឃាត់ខ្លួន ៦១នាក់ (ស្រី ៣៥នាក់), ប្រព្រឹត្តអំពើអាស ៦ករណី ឃាត់ខ្លួន ៦នាក់, ករណីនាំចេញដោយមិន ស្របច្បាប់សម្រាប់ឆ្លងដែន ៣ករណី ឃាត់ខ្លួន ៥នាក់ (ស្រី ៣នាក់) និងករណីផលិតរូបភាពអាស អាភាស ១ករណី ឃាត់ខ្លួន ១នាក់។ ជនសង្ស័យ និងវត្ថុតាង កសាងសំណុំរឿងបញ្ជូនទៅសាលា ដំបូងរាជធានីភ្នំពេញ និងរំដោះនារីរងគ្រោះ ចំនួន ៦០នាក់ បញ្ជូនទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ៣៣នាក់ និងប្រគល់ជូនក្រុមគ្រួសារ២៧នាក់។ ក្រៅពីនេះបានសហការបង្ក្រាប

ករណីសញ្ចារកម្ម ៤ករណី ឃាត់ខ្លួន ៨នាក់ (ស្រី ៦នាក់) ប្រគល់ជូននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារ អនីតិជន ចាត់ការតាមនីតិវិធី។

សូមបញ្ជាក់ថា រដ្ឋបាលរាជធានីភ្នំពេញ គ្រោងធ្វើពិធីសន្និបាតបូកសរុបលទ្ធផលការងារ របស់ខ្លួនប្រចាំឆ្នាំ ២០១៩ និងលើកទិសដៅបន្តឆ្នាំ២០២០ មានរយៈពេលពីរថ្ងៃ គឺថ្ងៃទី២៦ និង២៧ ខែកុម្ភៈនេះ និងគ្រោងអញ្ជើញ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃផងដែរ ៕ (កែសម្រួលដោយ ៖ បុប្ផា)

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០១នាក់ ពីសមត្ថកិច្ច ថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 17-02-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៦និង៤០នាទី ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០២០ បានទទួលពលករខ្មែរចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ កម្លាំង នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរនេះ មានឈ្មោះ រី ភារម្យ ភេទប្រុស អាយុ ២៥ឆ្នាំ មានទីលំ នៅបច្ចុប្បន្ន ស្ថិតក្នុងភូមិអូយ៉ាដាវ ឃុំអូយ៉ាដាវ ស្រុកសង្គមថ្មី ខេត្តរតនគិរី និងបានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅ ផ្ទះវិញ៕

## ពលករខ្មែរ ធ្វើការនៅលើទូកនេសាទត្រី ម្នាក់សម្រេចចិត្តលោតពីលើទូកដើម្បីទៅផ្ទះបន្ទាប់ពី ទំនាស់ជាមួយកម្មករម្នាក់ និងនឹកស្រុកកំណើត

https://www.facebook.com/officialworker/ 16-02-2020

យោងតាមប្រភពព័ត៌មានពីខេត្តត្រាត ប្រទេសថៃ នៅថ្ងៃអាទិត្យទី១៦ ខែកុម្ភៈ ឆ្នាំ២០២០ នេះបានអោយ ដឹងថា មានករណីបុរសពលករខ្មែរម្នាក់ ឈ្មោះ Phanna Nginn ភេទប្រុស អាយុ២៤ឆ្នាំ សញ្ជាតិខ្មែរ បានលោតពី លើទូកនេសាទត្រីមួយគ្រឿង ឈ្មោះ (ស.សែងសំប៊ូណ២) កាលពីវេលាម៉ោង០៩យប់ ត្រូវនឹងថ្ងៃសៅរ៍ ទី១៥ ខែ កុម្ភៈ ឆ្នាំ២០២០ នៅត្រង់ចំណុចកើតហេតុនៅម្តុំសមុទ្រកោះគូត ស្ថិតនៅក្នុងស្រុកកោះគូត ខេត្តត្រាត ប្រទេសថៃ។ បន្ទាប់ពីមានហេតុការណ៍នេះកើតឡើង ម្ចាស់ទូកនេសាទត្រីខាងលើ បានហៅទូរស័ព្ទរាយការណ៍ជូនដំណឹងដល់ សមត្ថកិច្ចថៃដែលពាក់ព័ន្ធ អោយជួយអន្តរាគមន៍ស្វែងរកពលករខ្មែររូបនេះភ្លាមៗផងដែរ ។ នៅវេលាម៉ោង ១២ថ្ងៃ ត្រង់ ត្រូវនឹងថ្ងៃអាទិត្យ ទី១៦ ខែកុម្ភៈ ឆ្នាំ២០២០នេះ កម្លាំងសមត្ថកិច្ចជំនាញដែនសមុទ្រថៃបាន រកឃើញជនរង គ្រោះកំពុងអណ្តែតខ្លួននៅក្នុងសមុទ្រក្នុងស្រុកកើតហេតុ។

## ឧបទ្ទវហេតុផ្ទុះធុងហ្គាស់ នៅកន្លែងធ្វើការបណ្តាលអោយពលករខ្មែរម្នាក់រងគ្រោះរបួស យ៉ាងធ្ងន់នៅថៃ

https://www.facebook.com/officialworker/ 17-02-2020

ដំណឹងប្រកាសតាមសាចញាតិ បុរសពលករខ្មែរ ម្នាក់ ឈ្មោះ ស៊ុំ ប៉ា ភេទប្រុស អាយុ ៣៥ឆ្នាំ ស្រុកកំណើត រស់នៅ ភូមិប្រជាតុ ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល បច្ចុប្បន្នជនរងគ្រោះបានចំណាកស្រុកខុសច្បាប់ចូលមក ធ្វើការនៅក្នុងប្រទេសថៃ បានរយៈពេល០២ថ្ងៃ បន្ទាប់មកបានកើតហេតុឧបទ្ទវហេតុផ្ទុះធុងហ្គាស់ នៅកន្លែងធ្វើការ បណ្តាលអោយជនរងគ្រោះរង់របួសយ៉ាងធ្ងន់ធ្ងរ។ បច្ចុប្បន្នជនរងគ្រោះត្រូវបានអ្នកធ្វើការជាមួយដឹកយកមកទុក

ចោលនៅ(មន្ទីរពេទ្យ PHYETHAI3 )ក្នុងទីក្រុងបាងកក ប្រទេសថៃ ដូច្នេះហើយប្រសិនមានបងប្អូនណាស្គាល់សាចញាតិជនរងគ្រោះ សូមមេត្តាទំនាក់ទំនងមកកាន់លេខទូរស័ព្ទ0636655300 ជាបន្ទាន់ សូមអរគុណ។

UPDATE៖បន្ថែមបន្ទាប់ពីមានបងប្អូននៅក្នុងបណ្តាញសង្គមហ្វេសប៊ុកស៊ែរបន្តច្រើន ខណៈពេលនេះមានបងប្អូនខាងសាច់ញាតិជនរងគ្រោះបានទំនាក់ទំនងមកខាងមន្ទីរពេទ្យបាយ៉ាថៃ៣ហើយ យើងខ្ញុំសូមអរគុណដល់បងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់ ដែលជួលស៊ែរហូតសាចញាតិជនរងគ្រោះបានទទួលដំណឹង។

## ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០២០

### សម្តេច ស ខេង សរសើរការចូលរួមរបស់ពលរដ្ឋ តាមរយៈគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព

https://www.dap-news.com/national/ ByKD102 Posted on February 19, 2020

ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងកោតសរសើរចំពោះ កម្លាំងនគរបាល និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន នាំគ្នាអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដោយបានរួមគ្នាយ៉ាងសកម្ម ក្នុងការបង្ការ ទប់ស្កាត់ បទល្មើសផ្សេងៗ ក្នុងសង្គមកម្ពុជា។

ក្នុងពិធីបើកសន្និបាតត្រួតពិនិត្យការងារ ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃនៅថ្ងៃ ទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ សម្តេចក្រឡាហោម ស ខេង មានប្រសាសន៍ថា "កម្លាំងនគរបាល ដោយមានកិច្ចសហការចូលរួម ពីកម្លាំងអនុវត្តច្បាប់នានា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងការគាំទ្រ ការចូលពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន តាមរយៈការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព បានរួមគ្នាយ៉ាងសកម្មក្នុងការបង្ការ ទប់ស្កាត់ បង្ក្រាបបទល្មើសនានាក្នុងសង្គមកាន់តែមានប្រសិទ្ធភាពថែមទៀត"។ សម្តេចក្រឡាហោមបន្តថា ជាក់ស្តែងទោះបីបទល្មើសព្រហ្មទណ្ឌ ឆ្នាំ២០១៩ កើនឡើងបន្តិច (កើន៨%) ដោយសារការហូរចូលយ៉ាងគំហុក នៃជនបរទេសនាំមកជាមួយ នូវបទល្មើសដែលប្រព្រឹត្តឡើង ក្នុងចំណោមជនបរទេសមួយចំនួនក៏ដោយ ក៏កម្លាំងនគរបាលជាតិបាន ប្រឹងប្រែងបង្ក្រាបបានរហូតដល់ ៨៩% នៃបទល្មើសដែលកើតមានឡើង ក៏មានអត្រាខ្ពស់ជាងឆ្នាំ២០១៨។ សម្តេចបន្ថែមថា ព្រមជាមួយនេះ បទល្មើសមួយចំនួនដែលប៉ះពាល់ ដល់ចិត្តសាស្ត្រសង្គមដូចជា លួច មានស្ថានទម្ងន់ រំលោភសម្លាប់ អំពើហិង្សាដោយចេតនា ឆបោក និងការប្រើប្រាស់អាវុធខុសច្បាប់ មានការថយចុះ គួរឲ្យកត់សម្គាល់។

ឆ្លៀតឱកាសនោះ សម្តេចលើកឡើងទៀតថា វិធានការបង្ការ បង្ក្រាបបទល្មើសគ្រឿងញៀន ត្រូវបានបន្តជំរុញយ៉ាងសកម្មផុលផុស ស្របតាមផែនការនៃការអនុវត្ត យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន ខុសច្បាប់លើកទី៤ របស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះ ការងារបង្ក្រាបបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ សកម្មភាពក្មេងទំនើង ល្បែងស៊ីសងខុសច្បាប់ បទល្មើសសេដ្ឋកិច្ចគ្រប់ប្រភេទ ការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ក៏ដូចជា វិធានការបង្ការ ទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ គ្រោះអគ្គិភ័យ អាវុធជាតិផ្ទុះ ក៏បានខិតខំប្រឹងប្រែង អនុវត្តយ៉ាងសស្រាក់ស្រាំ គឺទទួលបានការគាំទ្រ និងការចូលរួមកាន់តែច្រើនពីសាធារណជន ៕ ដោយ៖ អេង ប៊ូឆេង

## កម្លាំងនគរបាល នាយកដ្ឋានប្រឆាំងការ ជួញដូរ មនុស្ស និង ការពារ អនីតិជន ឃាត់ខ្លួនមេខ្យល់ ចំនួន២ និងនារីរងគ្រោះ៥នាក់ ករណី នាំក្មេងៗ ឱ្យរួមភេទ នៅតាមផ្ទះសំណាក់ និងសណ្ឋាគារ

https://www.dap-news.com/ ByPH104 Posted on February 19, 2020

ភ្នំពេញ:កម្លាំងនាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ បានធ្វើការធ្មក់បង្រ្កាប ហាងផឹកស៊ីមួយកន្លែង ដែលបង្កប់អោយមាន ការជួញដូរផ្លូវភេទជាមួយភ្ញៀវ ។ រង្វង់ប្រតិបត្តិការនេះ បានធ្វើឡើងនៅវេលាម៉ោង ៨និង៣០នាទីយប់ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ នៅហាងមួយកន្លែង យីហោ លីហួរស្មើពន្លឺសាច់អាំង ( ៩៩៩ )ផ្ទះលេខ២៣A ផ្លូវ៣៧១ ភូមិឬស្សី២ សង្កាត់ស្ទឹងមានជ័យ៣ ខណ្ឌមានជ័យ។

មន្ត្រីនគរបាលដែលចុះប្រតិបត្តិការនេះ បានឲ្យដឹងថា ការធ្មក់បង្រ្កាបហាងខាងលើ មន្ត្រីជំនាញបានឃើញមនុស្សចំនួន៧នាក់ ក្នុងនោះមាន មេការហាង ប្រុសស្រីចំនួន២នាក់ និងនារីរងគ្រោះចំនួន៥នាក់ ព្រមទាំងដកហូតស្រោមអនាម័យប្រើប្រាស់រួចចំនួន១ ដែលសមត្ថកិច្ចរកឃើញ នៅក្នុងបន្ទប់ផ្ទះសំណាក់ ឈ្មោះ វិរៈមហាសាល។ ជនសង្ស័យជាមេការ ម្ចាស់ហាងមានឈ្មោះ សឹក សុភាព ភេទប្រុស អាយុ៣៨ឆ្នាំ និងប្រពន្ធ ឈ្មោះ តត សុផាត អាយុ៣៦ឆ្នាំ ។ មន្ត្រីនគរបាលដដែលបានអោយដឹងថា មុននឹងកម្លាំង នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ ដោយមាន សម្របសម្រួល ពី លោក សុខ កែវបណ្ឌិត ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងលោក ឧត្តមសេនីយ៍ទោ សំបូរ មាណ្ណារិទ្ធ អនុប្រធាននាយកដ្ឋានប្រឆាំងជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ បានចុះបង្រ្កាបជាក់ស្តែង ករណី (សញ្ចារកម្ម )នៅក្នុង ហាង យីហោ លីហួរស្មើពន្លឺសាច់អាំង ៩៩៩ ដោយ ឃាត់មនុស្សប្រុសស្រី ចំនួន៧នាក់ ក្នុងនោះមាន នារីរងគ្រោះ ចំនួន៥នាក់ និងម្ចាស់ហាង ជាមេខ្យល់ប្តីប្រពន្ធចំនួន២នាក់ ព្រមទាំងឆែកឆេរ រកឃើញ ស្រោមអនាម័យប្រើប្រាស់រួចចំនួន១ នៅក្នុងបន្ទប់ផ្ទះសំណាក់ ឈ្មោះ វិរៈមហាសាល ដែលជាបន្ទប់ សំរាប់ណាត់ភ្ញៀវទៅរួមភេទ ។

ក្រោយពេលកើតហេតុ បន្ទាប់ពីឃាត់ខ្លួននិងត្រួតពិនិត្យរួចហើយ នារីរងគ្រោះចំនួន៥នាក់ ព្រមទាំងជនសង្ស័យ មេខ្យល់ប្តីប្រពន្ធចំនួន២នាក់ រួមទាំងវត្ថុតាំង ត្រូវបានសមត្ថកិច្ច នាំខ្លួនយកទៅសាកសួរនៅ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បន្តទៀត ចំណែកទីតាំងខាងលើ មិនបានបិទទ្វារនោះទេ ដោយសារតែមានឪពុកម្តាយនិង កូនតូច២នាក់ របស់ម្ចាស់ទីតាំងគ្មានកន្លែងស្នាក់នៅ ៕

## ការបញ្ជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេសនៅឆ្នាំ 2019 មានការធ្លាក់ចុះជាង៨0ភាគរយ

---

http://kampucheathmey.com/ 19/2/2020 9:56 Am

ភ្នំពេញ៖ យោងតាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានឲ្យដឹងថាការបញ្ជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេសនៅឆ្នាំ 2019 មានចំនួនជិត7ម៉ឺន នាក់ថយចុះជាង 80 ភាគរយបើប្រៀបធៀបទៅឆ្នាំ 2018 កន្លងទៅមានចំនួនជាង 34 ម៉ឺននាក់នាក់។ ក្នុងចំណោមពលករទាំងនោះទៅធ្វើការនៅថៃច្រើនជាងគេមានរហូតដល់ទៅជាង5ម៉ឺន 7ពាន់នាក់ និងប្រទេសដែលបញ្ជូនតិចជាងគេគឺប្រទេសម៉ាឡេស៊ី ដែលមានចំនួនតែ 33នាក់ប៉ុណ្ណោះ។

គួរបញ្ជាក់ថា បច្ចុប្បន្ននេះកម្ពុជាបានបញ្ជូនពលករទៅធ្វើការនៅតាមបណ្តាប្រទេសចំនួន7 រួមមានប្រទេថៃ កូរ៉េ ជប៉ុន សឹង្ហបុរី ម៉ាឡេស៊ី តំបន់រដ្ឋបាលពិសេសហុងកុង និងប្រទេសអារ៉ាប៊ីសាអូឌីត ដោយបានផ្ញើប្រាក់មកក្រុមគ្រួសារវិញប្រមាណជាង2ពាន់លានដុល្លារអាមេរិក៕ អត្ថបទ៖ សំអឿន

# ឆ្នាំ២០១៩ កម្ពុជា បញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសជិត៧ម៉ឺននាក់ ថយចុះជាង៨០ភាគរយ

http://kampucheathmey.com/ 19/2/2020 2:09 Pm

ភ្នំពេញ ៖ យោងតាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានឲ្យដឹងថា កាលពីឆ្នាំ២០១៩កន្លងទៅថ្មីៗនេះ កម្ពុជា បានបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសចំនួន ៦៨ ០៤០ នាក់ ថយចុះចំនួន ៨០,១ ភាគរយ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៨ កន្លងទៅ ដែលបានបញ្ជូនរហូតដល់ ៣៤២ ១៥៤ នាក់។ ការថយចុះចំនួនពលករដ៏ច្រើនសន្ធឹកសន្ធាប់នេះ គឺភាគច្រើននៅប្រទេសថៃដែលកាលពីឆ្នាំ២០១៨កន្លងទៅ កម្ពុជា បានបញ្ជូនពលករទៅធ្វើការនៅថៃចំនួន ៣៣៣ ៨៧២ នាក់ ខណៈឆ្នាំ២០១៩ បានបញ្ជូនត្រឹមតែ ៥៧ ៨២៣ នាក់ ថយចុះ៨២,៦ភាគរយ។ ក្រៅពីនេះឆ្នាំ២០១៩នេះដែរ ការបញ្ជូនពលករទៅធ្វើប្រទេសសិង្ហបុរីក៏មានការធ្លាក់ចុះចំនួន៥២,៩ភាគរយដែរ ដោយឆ្នាំ២០១៨ បញ្ជូនចំនួន២៨៧នាក់ ខណៈឆ្នាំ២០១៩ បញ្ជូនត្រឹមតែ១៣៥នាក់ប៉ុណ្ណោះ។

តាមរបាយការណ៍ដែលបានបង្ហាញនៅក្នុងសន្និបាតបូកសរុបការងារឆ្នាំ២០១៩ និងលើកទិសដៅសម្រាប់ឆ្នាំ២០២០ កាលពីព្រឹកថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ នៅទីស្តីការក្រសួងបានឲ្យដឹងទៀតថា ផ្ទុយពីប្រទេសថៃ និងសិង្ហបុរី កម្ពុជា បានបង្កើនការបញ្ជូនពលករទៅធ្វើការនៅតាមបណ្តាប្រទេសចំនួន៥ទៀតផងដែរដូចជា សាធារណរដ្ឋកូរ៉េ ឆ្នាំ២០១៩ បានបញ្ជូន៥៩៣៨នាក់ កើនឡើង២១,៩ភាគរយ ធៀបនឹងឆ្នាំ២០១៨ មានចំនួន៤៨៧០នាក់ ប្រទេសជប៉ុនបញ្ជូន៣៩៤៥នាក់ នៅឆ្នាំ២០១៩កើនឡើង៣១,៤ភាគរយ ធៀបឆ្នាំ២០១៨ មានចំនួន ៣ ០០២ នាក់ ប្រទេសម៉ាឡេស៊ីបញ្ជូន៣៣នាក់នៅឆ្នាំ២០១៩ កើនឡើង៦៥ភាគរយ ធៀបនឹងឆ្នាំ២០១៨ មានចំនួន២០នាក់ ប្រទេសអារ៉ាប៊ីសាអ៊ូឌីតបញ្ជូនចំនួន៥៨នាក់ នៅឆ្នាំ២០១៩ កើនឡើង២៦២,៥ភាគរយ ធៀបនឹងឆ្នាំ២០១៨ មានចំនួន១៦នាក់ និងតំបន់រដ្ឋបាលពិសេសហុងកុងបញ្ជូនចំនួន៧២នាក់ នៅឆ្នាំ២០១៩ កើនឡើង៣៣,៣ភាគរយ ធៀបនឹងឆ្នាំ២០១៨ មានចំនួន៥៤នាក់។

លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានមានប្រសាសន៍ថាពលករដែលបញ្ជូនទៅធ្វើការនៅក្រៅប្រទេសធ្វើឡើង តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជនធ្វើការជ្រើសរើសបណ្តុះបណ្តាលបញ្ជូន និងគ្រប់គ្រងពលករទៅធ្វើការនៅបរទេសចំនួន១០៤ក្រុមហ៊ុន និងតាមប្រព័ន្ធរដ្ឋ និងរដ្ឋចំនួន១។ លោករដ្ឋមន្ត្រីបានបន្តថា រាជរដ្ឋាភិបាលកម្ពុជា បានផ្តោតការយកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការគាំពារ ការការពារសិទ្ធ និងផលប្រយោជន៍ពលករខ្មែរយើងនៅបរទេស តាមរយៈកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាល នៃប្រទេសទទួល និងការពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋាននានា ដោយប្រើប្រាស់គោលការណ៍ យន្តការ និងនីតិវិធីនានាផងដែរ។ លោករដ្ឋមន្ត្រីបានបន្ថែមទៀតថា ចំណែកក្រសួង បានបន្តខិតខំយកចិត្តទុកដាក់ដល់ពលករដែលធ្វើការនៅក្រៅប្រទេស និងពង្រីកទីផ្សារនៅក្រៅប្រទេស ដោយបន្តផ្តល់សេវា៥យ៉ាង ជូនពលករកម្ពុជា នៅឯបរទេស ៖

ទី១-អនុវត្តសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពី ការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៏។ បាននិងកំពុងខិតខំជួយពលករដែលធ្វើការនៅបរទេស ដើម្បីធានានូវផលប្រយោជន៍ស្របច្បាប់។ ជួយផ្តល់ភាពស្របច្បាប់ដល់ពលករដែលមិនស្របច្បាប់។ ចាត់តាំងទីប្រឹក្សាការងារនៅតាមស្ថានទូតនៃ ប្រទេសដែលមានពលករ ដូចជាថៃ កូរ៉េ ម៉ាឡេស៊ី និងជប៉ុន។

ទី២-សហការជាមួយប្រទេសដៃគូ ក្នុងការទទួលស្គាល់ជំនាញទៅវិញទៅមក ដូចជាកម្ពុជា-ថៃ បានទទួលស្គាល់ជំនាញផ្នែកសំណង់ ដូចជា ជាងកំបោរ និង តបណ្តាញអគ្គិសនី។ នៅសាធារណរដ្ឋកូរ៉េ ផ្តល់ឱកាសឲ្យពលករ

ទៅរៀនបន្ថែមនៅតាមសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្តល់វិញ្ញាបនបត្រទទួលស្គាល់។ បន្ទាប់ពី ត្រឡប់មកប្រទេសកម្ពុជាវិញ អាចមានជំនាញច្បាស់លាស់។

ទី៣-កំពុងសហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងកិច្ចសហប្រតិបត្តិការលើវិស័យរបបសន្តិសុខសង្គម។

ទី៤-កំពុងសហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងការអនុវត្តរបបសោធនិវត្តដោយពលករអាចផ្ទេរសមាជិកភាព អតីតភាពការងារ និងការបង់ភាគទានបេឡាសន្តិសុខសង្គម ពីប្រទេសមួយទៅប្រទេសមួយ បន្ទាប់ពីចប់កិច្ចសន្យាការងារ និងដើម្បីធ្វើជាមូលដ្ឋានក្នុងការគិតប្រាក់សោធនិវត្ត។

និងទី៥-បានសម្រួលបែបបទជូនពលករធ្វើការនៅបរទេសអាចផ្ទេរសិទ្ធិជូនគ្រួសារនៅក្នុងប្រទេស ធ្វើជាតំណាង សម្រាប់ស្នើសុំធ្វើលិខិតថ្កោលទោស ឬលិខិតរដ្ឋបាល ឬលិខិតបញ្ជាក់អត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួន ដោយមិនចាំបាច់សាមីខ្លួនវិលត្រឡប់មកស្រុកកំណើតវិញ។

គួរបញ្ជាក់ថា បច្ចុប្បន្ននេះកម្ពុជា បានបញ្ជូនពលករទៅធ្វើការនៅតាមបណ្តាប្រទេសចំនួន៧ រួមមានប្រទេសថៃ កូរ៉េ ជប៉ុន សិង្ហបុរី ម៉ាឡេស៊ី តំបន់រដ្ឋបាលពិសេសហុងកុង និងប្រទេសអារ៉ាប៊ីសាអ៊ូឌីតដោយបានផ្ញើប្រាក់មកប្រទេសវិញប្រមាណជាង២ពាន់លានដុល្លារអាមេរិក ដែលបានជួយលើកស្ទួយដល់ជីវភាព ក៏ដូចជាសេដ្ឋកិច្ចជាតិកាន់តែរីកចម្រើនថែមទៀត៕

## ក្រសួងការងារបញ្ជាក់ថា កំពុងខិតខំបន្តគ្រប់គ្រងទីផ្សារការងារជូនពលរដ្ឋ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២០ ម៉ោង ១៣:០៤ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារបណ្តុះបណ្តាល និងវិជ្ជាជីវៈបានអះអាងថា ក្រសួងបាននឹងកំពុងបន្តខិតខំបន្តគ្រប់គ្រងទីផ្សារការងារ និងកម្លាំងពលកម្មដែលរាជរដ្ឋាភិបាលបានខិតខំបង្កើតការងារជូនប្រជាពលរដ្ឋ ។ ការបញ្ជាក់នេះធ្វើឡើងក្នុងឱកាសអញ្ជើញជាអធិបតីភាពក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០នាទីស្តីការក្រសួង។ លោករដ្ឋមន្ត្រី អ៊ិត សំហេង បានថ្លែងថា សមិទ្ធផលដែលសម្រេចបានពេញ១ឆ្នាំនេះបានធ្វើឱ្យវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាកាន់តែដើរតួរនាទីយ៉ាងសំខាន់ដល់ការគាំទ្រនូវគោលនយោបាយ របស់រាជរដ្ឋាភិបាលក្នុងបន្តជម្រុញកំណើនសេដ្ឋកិច្ច ការបន្តភាពប្រកួតប្រជែងរបស់កម្ពុជាការបន្តនិរន្តភាពពាណិជ្ជកម្ម អាជីវកម្ម ផលិតកម្ម និងវិនិយោគ ។ លោកបានគូសបញ្ជាក់ថា ៖«ក្រសួងបានខិតខំបន្តគ្រប់គ្រងទីផ្សារការងារ និងកម្លាំងពលកម្មដែលរាជរដ្ឋាភិបាលខិតខំបង្កើតការងារជូនបងប្អូនជាពលរដ្ឋរហូតមានកម្លាំងពលកម្មសរុបប្រមាណ១០លាននាក់ ក្នុងនោះនៅក្នុងប្រទេសប្រមាណ៣,៦៩លាននាក់ (ផ្នែកសេដ្ឋកិច្ចក្នុងប្រព័ន្ធមានចំនួនជាង ១,៥០លាននាក់ និងផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធប្រមាណ២,២០លាននាក់) វិស័យកសិកម្មប្រមាណ៤លាននាក់ មន្ត្រីសាធារណៈ៥០ម៉ឺននាក់ និងពលករដែលធ្វើការនៅក្រៅប្រទេសមានចំនួនប្រមាណជាង១,២៨លាននាក់» ។

លោកបន្តទៀតថា ដែលកត្តានេះបានធ្វើឱ្យប្រជាពលរដ្ឋជាង៩៩,៣% មានការងារធ្វើ ។ សហគ្រាស គ្រឹះស្ថាន សេដ្ឋកិច្ចក្នុងប្រព័ន្ធ ដែលមានការចុះបញ្ជីនៅក្រសួងសរុបចំនួន ១៤ ០៦០ សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតចំនួន ១,៥០ លាននាក់ ដោយបានទទួលប្រាក់ឈ្នួល ជាមធ្យមជាង ៣,៧០ ពាន់លានដុល្លារក្នុងមួយឆ្នាំ បើគិតបូកប្រាក់បញ្ញើ ដែលពលករមកពីក្រៅប្រទេសក្នុង១ឆ្នាំ ជាង ២,៨០ពាន់លានដុល្លារទៀត សរុបទៅជាង ៦,៥០ ពាន់លានដុល្លារក្នុងមួយឆ្នាំ ។ លោករដ្ឋមន្ត្រីសង្កត់ធ្ងន់ថា តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីការងារមន្ត្រីអធិការកិច្ចការងារបានចុះអធិការកិច្ចចំនួន៤៩២២លើក, បានដាក់កំហិតចំនួន៩៧៧សហគ្រាស, បានចេញលិខិតផាកពិន័យ ៥៥សហគ្រាស និងប្តឹងទៅតុលាការ ៦សហគ្រាស ជាលទ្ធផលរោងចក្រសហគ្រាសដែល

មិនគោរពច្បាប់ស្តីពីការងារ បានធ្លាក់ចុះគួរកត់សម្គាល់ ។ ទន្ទឹមនឹងនេះការពង្រឹងការអនុវត្តច្បាប់ស្តីពីសហជីព បានធ្វើឲ្យចំនួនអង្គការវិជ្ជាជីវៈចុះបញ្ជិការកើនឡើងដល់ ៥២០៩ ក្នុងនោះ សហជីពមូលដ្ឋានចំនួន ៤ ៩៤៩, សហព័ន្ធសហជីពចំនួន ២១៦,សហភាពសហជីពចំនួន៣៣ និងសមាគមនិយោជកចំនួន១១ ៕

## ពលករខ្មែរជួបគ្រោះថ្នាក់ចរាចរ នៅខេត្តសុខខ្លា បាត់បង់ជីវិតម្នាក់ និងរបួស ១១ នាក់

---

http://kampucheathmey.com/ 19/2/2020 8:05 Am

ប្រទេសថៃ ៖ ក្នុងចំណោមពលករខ្មែរចំនួន ១២ នាក់ ដែលបានធ្វើដំណើរតាមរថយន្តដឹកអ្នកដំណើរមួយគ្រឿងបានស្លាប់បាត់បង់ជីវិតម្នាក់នៅលើរថយន្ត និង ១១ នាក់ទៀត រងរបួសធ្ងន់ ស្រាល ខណៈដែលពួកគេទាំងអស់គ្នា បានម៉ៅរថយន្តនេះចេញដំណើរពីស្រុកអារញ្ញប្រាថេត ក្នុងខេត្តស្រះកែវ ទៅកាន់រោងចក្រមួយន្លែង ក្នុងខេត្តសុងខ្លា ហើយក៏បានជួបនឹងឧប្បទ្ទវហេតុ គ្រោះថ្នាក់ចរាចរណ៍នៅតាមផ្លូវ ដោយសភាពផ្លូវរអិល ។

យោងតាមរបាយការណ៍របស់ក្រុមហ៊ុនមូលនិធិ មិត្តភាព សាមគ្គី ហាតយៃ៉ បានបញ្ជាក់ថា ហេតុការណ៍ដ៏រន្ធត់នេះ បានកើតឡើងនៅវេលាម៉ោង ៧ និង ៣០ នាទី ព្រឹក ថ្ងៃទី១៨ ខែកុម្ភះ ឆ្នាំ២០២០ ដោយ រថយន្តម៉ាកតួរីស ដឹកពលករខ្មែរ ចំនួន ១២ នាក់ ពីព្រំដែនអារញ្ញប្រាថេត ទៅខេត្តសុងខ្លា ជួបគ្រោះថ្នាក់ចរាចរណ៍ តាមផ្លូវបណ្តាលឲ្យពលការិនីខ្មែរស្លាប់បាត់បង់ជីវិត ០១នាក់ របួស ១១នាក់ ។ ហេតុការណ៍នេះបានកើតឡើងនៅម្តុំផ្លូវជាតិអេសៀរ៉ាត់តៈភូមិ ស្ថិតនៅក្នុងភូមិ៤ សង្កាត់ថាឆាង ស្រុកបាងក្លាំ ខេត្តសង់ក្លា ប្រទេសថៃ។ យោងតាមប្រភពព័ត៌មានបានឲ្យដឹងថា រថយន្តឈ្នួលខាងលើបានធ្វើដំណើរទៅទទួលពលករខ្មែរចំនួន១២នាក់ ពីព្រំដែនស្រុកអារញ្ញប្រាថេត ក្នុងខេត្តស្រះកែវ ដើម្បីបន្តដំណើរទៅខេត្ត សុងខ្លា ប៉ុន្តែអកុសលរថយន្តឈ្នួលខាងលើបានជ្រុលទៅបុកគូទរថយន្តសណ្តោងតាមផ្លូវ ដែលឈប់សំចតបណ្តាលឲ្យមានមនុស្សស្លាប់ និងរងរបួសជាច្រើននាក់ បច្ចុប្បន្នជនរងគ្រោះត្រូវបានសមត្ថកិច្ចថៃបញ្ជូនយកទៅព្យាបាលនៅមន្ទីរពេទ្យបាងក្លាំ និងមន្ទីរពេទ្យហាតយៃ៉ ខេត្តសង់ក្លា ។

នៅកន្លែងកើតហេតុនោះដែរ គេសង្កេតឃើញអ្នកបើកបររថយន្តធំឈ្មោះ ផុងសាក់ ច័ន្ទថន កំពុងឈររេរារង់ចាំសមត្ថកិច្ចហៅទៅសាកសួរ ដោយលោកមិនបានគេចខ្លួនទៅណានោះទេ ។ ដោយឡែក អ្នកបើកបររថយន្តតួរីសឈ្មោះ វ៉ាត់រិន ផៈកៈម៉ា អាយុ ៥៣ ឆ្នាំ ដែលបានរងរបួសស្រាល បាននិយាយថា រថយន្តរបស់លោកត្រូវបានគេជួលអោយដឹកពលករខ្មែរស្របច្បាប់ ពីព្រំដែនថៃ កម្ពុជា ក្នុងស្រុកអារញ្ញប្រាថេត ទៅកាន់រោងចក្រផលិតអាហារសមុទ្រ មួយកន្លែង ក្នុងខេត្តសុងខ្លា ។ លោកបានបន្តថា លុះមកដល់ត្រង់ចំណុចកើតហេតុ គឺលោកក៏បានឃើញដែរ ចំពោះរថយន្តធំដែលកំពុងឈប់នៅលើផ្លូវផ្នែកខាងឆ្វេងដៃ ( ថៃប្រកាន់ឆ្វេង ) ដោយលោកបានប្តូងចង្កូតងាកទៅខាងស្តាំដើម្បីឡើងជែងរថយន្តនោះ ប៉ុន្តែដោយសារផ្លូវទើបភ្លៀងរួច ហាក់បីដូចជាមានសភាពរអិល គឺរថយន្តរបស់លោកមិនអាចគេចផុតពីរថយន្តធំ ទើបធ្វើអោយជញ្ជាំងមួយចំហៀងផ្នែកខាងឆ្វេង ត្រូវច្រៀកខ្ទេចគ្មានសល់ ទើបបង្កអោយមានបញ្ហាបែបនេះ ។

បច្ចុប្បន្នតម្រួតថៃកំពុងធ្វើការយ៉ាងសស្រាក់សស្រាំហើយចំពោះបញ្ហាខាងលើនេះ ក្នុងការដោះស្រាយទៅលើអាយុជីវិតពលករខ្មែរទាំងស្លាប់ និង របួស ដោយសារតែពួកគេសុទ្ធតែជាពលករដែលចូលទៅបម្រើការងារស្របច្បាប់ទាំងអស់ ៕

## មានគ្រប់សព្វ! អ្នករកកូនប្រើ អាចទិញកូនតាម Online អត់ហត់បង្កើត តម្លៃចន្លោះពី ១៤០០ ដុល្លារឡើងទៅ

https://www.knongsrok.com/ 2020-02-17

ពិភពលោកកាន់តែអភិវឌ្ឍធ្វើឲ្យរបស់របរគ្រប់សព្វ បច្ចុប្បន្នរមែងដាក់ឲ្យបញ្ជាទិញតាម Online ជាជាងធ្វើដំណើរទៅទិញដោយផ្ទាល់នៅឯហាងឬផ្សារទំនើប។ ក្រឡេកទៅប្រទេសម៉ាឡេស៊ីឯណោះវិញ កំពុងមានការការពេញនិយមពាក់ព័ន្ធនឹងការទិញយកទារកឬទិញកូនតាម Online ដោយតម្លៃយ៉ាងទាបបំផុតពី ១០០០០ រីងហ្គីតឬជាង ១៤០០ ដុល្លារអាមេរិកឡើងទៅ។ ដំណើរការនៃការបញ្ជាទិញអ្នកអាចចូលទៅកាន់បណ្ដាញសង្គមហើយវាយពាក្យ 'Anak Angkat' ឬជាភាសាអង់គ្លេសមានន័យថា 'adopted child' នោះអ្នកនឹងឃើញមានការការបង្ហោះពាក់ព័ន្ធការលក់ទិញទារក ដែលមានតម្លៃជាមធ្យមចន្លោះពី ១០០០០០ ទៅ ២០០០០ រីងហ្គីតឬប្រហែល ១៤០០ ទៅ ២៨០០ ដុល្លារ។ ប្រសិនអ្នកសម្រេចចិត្តទិញចាំបាច់ត្រូវធ្វើការកក់លុយប្រមាណ ២០០០ ទៅ ៧០០០ រីងហ្គីតបន្ថែមទៀត ដើម្បីរត់ការសំបុត្រចេញពីមន្ទីរពេទ្យដែលម្ដាយរបស់ទារកបានផ្ដល់កំណើតឲ្យកូន។ ប៉ុន្តែក៏មានបញ្ហារកាំរកូសខ្លះ សោតយ៉ាងដូចជាស្ត្រីធ្លាប់មានបទពិសោធន៍លើការទិញទារក Online មួយរូប និយាយថាកន្លងទៅអ្នកស្រីបានចរចាតម្លៃគ្នារួចរាល់ហើយ ដោយថែមទាំងទៅទិញសម្ភារៈទារកទុកនៅផ្ទះថែមទៀត លុះចុះឡើងម្ដាយដែលជាអ្នកត្រូវបង្កើតបែរជាថាមិនប្រគល់ឲ្យព្រោះអីមានគេដេញថ្លៃដាក់ឲ្យតម្លៃកល់ជាងហ្នឹងទៅវិញ៕

## ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០២០

## ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌកើន ៨% ដោយសារការហូរចូលយ៉ាងគំហុកនៃជនបរទេស

https://www.postkhmer.com/ ម៉ិច ដារ៉ា | Publication date 20 February 2020 | 09:33 ICT

**ភ្នំពេញៈ** លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានថ្លែងថា បទល្មើសព្រហ្មទណ្ឌនៅឆ្នាំ ២០១៩ គឺមានការកើនឡើងចំនួន ៨ ភាគរយ ដែលបានបណ្ដាលឲ្យមនុស្សស្លាប់ចំនួន ២១១ នាក់ ដោយសារតែមានការហូរចូលយ៉ាងគំហុកនៃជនបរទេស ខណៈដែលក្រុមប្រឆាំង ប៉ុនប៉ងបង្កភាពចលាចលក្នុងសង្គម និងរៀបចំផែនការប៉ុនប៉ងធ្វើរដ្ឋប្រហារផ្ដួលរំលំរាជរដ្ឋាភិបាលស្របច្បាប់។ លោក ស ខេង បានថ្លែងបែបនេះនៅក្នុងពិធីបើកសន្និបាត ត្រួតពិនិត្យការងារឆ្នាំ ២០១៩ និងលើកទិសដៅឆ្នាំ ២០២០ របស់ក្រសួងមហាផ្ទៃនៅព្រឹកថ្ងៃពុធម្សិលមិញដែលមានការចូលរួមពីថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ថ្នាក់ដឹកនាំស្ថាប័នចំណុះក្រសួងមហាផ្ទៃ និងស្ថាប័នពាក់ព័ន្ធជាច្រើនទៀតប្រមាណ ៧០០ នាក់។ លោកបញ្ជាក់ថា៖ «ជាក់ស្ដែងទោះបីបទល្មើសព្រហ្មទណ្ឌនៅឆ្នាំ ២០១៩ មានការឡើងបន្តិចគឺ ៨ ភាគរយ ដោយសារការហូរចូលយ៉ាងគំហុកនៃជនបរទេស ដែលនាំមកជាមួយនូវបទល្មើសដែលប្រព្រឹត្តនៅក្នុងចំណោមជនបរទេសមួយចំនួនក៏ដោយក៏កម្លាំងនគរបាលជាតិប្រឹងប្រែងបង្ក្រាបរហូតដល់ទៅ ៨៩ ភាគរយនៃបទល្មើសដែលកើតមានឡើងគឺមានអត្រាខ្ពស់ជាងឆ្នាំ ២០១៨»។ លោកបន្តថា៖ «ព្រមជាមួយនេះបទល្មើសមួយចំនួនដែលប៉ះពាល់ចិត្តសាស្ត្រសង្គមដូចជា លួចមានស្ថានទម្ងន់ទោស រំលោភសម្លាប់អំពើហិង្សាដោយចេតនាឆបោក និងការប្រើប្រាស់អាវុធខុសច្បាប់ មានការថយចុះគួរឲ្យកត់សម្គាល់។ វិធានការបង្ការ និងបង្ក្រាបបទល្មើសគ្រឿងញៀនត្រូវបានបន្ត ជំរុញយ៉ាងសកម្ម និងផុលផុសស្របតាមផែនការនៃការអនុវត្តនៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន»។ លោកបន្តថា កម្លាំងនគរបាលជាតិដោយមានកិច្ចសហការចូលរួមកម្លាំងអនុវត្តច្បាប់នានាអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងការគាំទ្រ និងការចូលរួមពីប្រជាពលរដ្ឋពីគ្រប់មជ្ឈដ្ឋានតាមរយៈការអនុវត្តគោលនយោបាយ

ភូមិឃុំមានសុវត្ថិភាពបានរួមគ្នាយ៉ាងសកម្មក្នុងការបង្ការនិងទប់ស្កាត់បង្ក្រាបបទល្មើសនានាក្នុងសង្គមកាន់តែមានប្រសិទ្ធភាពថែមទៀត។

បើយោងតាមរបាយការណ៍របស់ក្រសួងមហាផ្ទៃដែលបានផ្សព្វផ្សាយនៅក្នុងពិធីបើកសន្និបាតឲ្យដឹងថា បទល្មើសព្រហ្មទណ្ឌកើតឡើងចំនួន ៣១៩៦ ករណីបើធៀបកាលពីឆ្នាំ ២០១៨ មានចំនួន ២៩៦៩ ករណី កើនឡើង ២២៨ លើកដែលបានបណ្តាលឲ្យមនុស្សស្លាប់ ២១១ នាក់ របួស ៨២៩ នាក់ និងរងគ្រោះ ១៤១២ នាក់ បាត់រថយន្ត ៥៥ គ្រឿង ម៉ូតូ ៣៤១ គ្រឿង និងសម្ភារទ្រព្យសម្បត្តិមួយចំនួន។ របាយការណ៍បន្ថែមថា កម្លាំងសមត្ថកិច្ចបានបើកកិច្ចប្រតិបត្តិការបង្ក្រាបបាន ២៨៤២ ករណីស្មើនឹង ៨៩ ភាគរយនៃបទល្មើស ដែលកើតមានឡើងឃាត់ខ្លួនជនល្មើសបាន ៤១១៩ នាក់ ហើយនៅក្នុងចំណោមជនសង្ស័យនេះមាន ១០៧៤ នាក់ជាប់ពាក់ព័ន្ធប្រើប្រាស់សារធាតុញៀន ហើយបទល្មើសដែលទាញតួលេខឲ្យមានកំណើនរួមមានលួចបង្ខាំងមនុស្សខុសច្បាប់ រំលោភសេពសន្ថវៈ បំពានផ្លូវភេទ ហិង្សាដោយចេតនា ឃាតកម្ម មនុស្សឃាតដោយអចេតនា និងបង្ខាំងមនុស្សជំរិតទារប្រាក់។ ជាមួយគ្នានេះបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ សមត្ថកិច្ចបង្ក្រាបបាន ១៦៣ ករណីឃាត់ខ្លួនបាន ២១៩ នាក់ក្នុងនោះមានជនបរទេស ៣៤ នាក់កសាងសំណុំរឿងបញ្ជូនទៅតុលាការ និងរំដោះជនរងគ្រោះបាន ៤៣៨ នាក់បញ្ជូនទៅមន្ទីរសង្គមកិច្ច ១៦៥ នាក់ និងបញ្ជូនទៅព្យាបាលចំនួន ២៧៣ នាក់។

ជាមួយគ្នានេះលោក ស ខេង បានលើកឡើងថាកាលពីឆ្នាំ ២០១៩ កម្ពុជាបានទទួលរងឥទ្ធិពលមួយចំនួនពីក្រុមប្រឆាំងជ្រុលនិយមទាំងពីក្រៅប្រទេសទាំងនៅផ្ទៃក្នុងប្រទេសដោយលោកបញ្ជាក់ថា៖ «ពួកប្រឆាំងជ្រុលនិយម ព្យាយាមធ្វើសកម្មភាព ប៉ុនប៉ងបង្កភាពចលាចលក្នុងសង្គម និងរៀបចំផែនការធ្វើរដ្ឋប្រហារប៉ុនប៉ង ផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់»។ លោកបន្ថែមថា របបរាជានិយមនៅកម្ពុជាក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលដោយមានការគាំទ្រ និងការចូលរួមពីកងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការស៊ីវិល អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាជនទាំងមូលបានរួមគ្នាបំផ្លាញឲ្យបរាជ័យទាំងស្រុងនូវឧបាយកល និងផែនការប្រេកបដោយគ្រោះថ្នាក់ទាំងនេះហើយបន្តរួមគ្នាការពារប្រព័ន្ធគ្រប់គ្រងប្រទេសតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សការពារព្រះមហាក្សត្រការពាររបបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ។

លោក អំ សំអាត ប្រធានគ្រប់គ្រងផ្នែកឃ្លាំមើលសិទ្ធិមនុស្សនៃអង្គការលីកាដូ បានថ្លែងពីម្សិលមិញថា ការរីករាលដាល និងការកើនឡើងនៃការប្រើប្រាស់និងការជួញដូរគ្រឿងញៀន សមត្ថកិច្ចអនុវត្តច្បាប់នៅមានកម្រិត ការខ្វះខាតនិងការអប់រំផ្សព្វផ្សាយផ្នែកច្បាប់ជាកត្តាបណ្តាលឲ្យបទល្មើសព្រហ្មទណ្ឌនៅឆ្នាំ ២០១៩ មានការកើនឡើងយ៉ាងគំហុក។ លោកបញ្ជាក់ថា៖ «ខ្ញុំមើលឃើញកត្តាគ្រឿងញៀនជាកត្តាមួយធំចំពោះការកើនឡើងនូវបទល្មើសហ្នឹងហើយកត្តាសីលធម៌នៅក្នុងសង្គម ធ្លាក់ចុះ និងការខ្វះខាតការអប់រំផ្សព្វផ្សាយឲ្យបានទូលំទូលាយពាក់ព័ន្ធនឹងបញ្ហាច្បាប់ដែលបានអនុម័តកន្លងមកហើយឲ្យប្រជាពលរដ្ឋយល់ដឹងបានជ្រាបពីបញ្ហាច្បាប់ទាំងនោះ និងការធេកលែ្វងនៃការអនុវត្តច្បាប់»។ លោកបន្ថែមថា ដើម្បីកាត់បន្ថយបទល្មើសព្រហ្មទណ្ឌកម្លាំងសមត្ថកិច្ចត្រូវធ្វើយ៉ាងណា ទប់ស្កាត់ និងបង្ក្រាបការចរាចរ ការផលិត ឬការចែកចាយគ្រឿងញៀនកុំឲ្យរីករាលដាលកាន់តែខ្លាំង៕

## ស្ត្រីភាគច្រើននៅភូមិឡពាងចាប់យករបរដេរស្លឹកលក់ ខណៈប្តីពួកគេទៅធ្វើការតាមទូកនេសាទថៃ

https://www.rfa.org/khmer/ ដោយ សុជីវី 2020-02-19

ស្ត្រីនៅភូមិឡពាង ខេត្តកំពង់ឆ្នាំង នាំគ្នាចាប់យករបរដេរស្លឹកត្នោតលក់ ដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃខណៈប្តីនិងកូនប្រុសពួកគេ ចំណាកស្រុកទៅធ្វើការតាមទូកនេសាទនៅប្រទេសថៃ។ អ្នកភូមិឱ្យដឹងថា ពួកគាត់ប្រកបរបរនេះ ជាច្រើនឆ្នាំមកហើយ ក្រោយពីបាត់បង់ដីធ្វើស្រែចម្ការ ដោយសារកេរិយារបស់រដ្ឋមន្ត្រីមួយរូបក្នុងរដ្ឋបា

លលោក ហ៊ុន សែន រំលោភយក។ ភូមិឡពាង ដែលស្ថិតក្នុងឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ត្រូវបានគេស្គាល់ថា ជាភូមិមួយដែលមានជម្លោះដីធ្លីអូសបន្លាយយូរឆ្នាំមកនេះ រវាងថៅកែក្រុមហ៊ុនខេ.ឌី.ស៊ី (KDC) អ្នកស្រី ជា ខេង ត្រូវជាភរិយាលោក ស៊ុយ សែម រដ្ឋមន្ត្រីរ៉ែនិងថាមពល ជាមួយនឹងពលរដ្ឋរាប់សិបគ្រួសារ។ វិវាទដីធ្លីមួយនេះ បង្កឲ្យមានបញ្ហាប្រឈមជាច្រើនដល់ជីវភាពរស់នៅរបស់អ្នកឡពាង ដោយឪពុកនិងកូនប្រុសក្នុងគ្រួសារសម្រេចចិត្តចេញទៅធ្វើការតាមទូកនេសាទនៅប្រទេសថៃ ដើម្បីរកប្រាក់ផ្គត់ផ្គង់គ្រួសារ។ ចំណែក ភរិយានៅចាំផ្ទះ និងដេរស្លឹកត្នោតលក់ ដើម្បីដោះស្រាយជីវភាព ពីមួយថ្ងៃទៅមួយថ្ងៃ។

លោកស្រី ប៊ិន ចាន់នី រស់នៅក្នុងភូមិឡពាងតាំងពីកំណើត។ សព្វថ្ងៃលោកស្រី មានកូនស្រី២នាក់ និងកូនប្រុស១នាក់ ដែលកំពុងរៀនសូត្រ។ លោកស្រី រៀបរាប់ថា មុនពេលមានក្រុមហ៊ុនចូលមកចាប់ដីពួកគាត់ គ្រួសារលោកស្រី និងអ្នកភូមិឯទៀត រស់នៅជួបជុំគ្នាយ៉ាងសុខសប្បាយ។ ពួកគាត់អាចធ្វើស្រែបានស្រូវទុកហូបគ្រប់គ្រាន់ពីមួយឆ្នាំទៅមួយឆ្នាំ និងគ្មានជំពាក់បំណុលមីក្រូហិរញ្ញវត្ថុនោះទេ។ លោកស្រី បន្តថា ក្រោយមានវត្តមានក្រុមហ៊ុន ខេ.ឌី.ស៊ី ចូលទៅហ៊ុំព័ទ្ធដីធ្លីអ្នកភូមិ នៅឆ្នាំ២០០៨ ជីវភាពគ្រួសារគាត់ ក៏ដូចជាអ្នកភូមិដទៃទៀត ចាប់ផ្តើមជួបប្រទះបញ្ហាជីវភាពខ្វះមុខខ្វះក្រោយ ដោយសារគ្មានដីធ្វើស្រែដូចពីមុន៖ « ពីមុនជួបជុំគ្រួសាររស់នៅស្រួលអត់ខ្វះខាត។ ដល់ឥលូវប្ដីខ្ញុំទៅឆ្ងាយ ពិបាកចិញ្ចឹមកូនផង។ ពិបាកណាស់ធ្វើការងារក៏ខ្លួនឯង អត់មានប្តីនៅជិតអ៊ីចឹង។ ចង់ដើរទៅណាក៏ពិបាកដែរ អត់មានអ្នកណាជួយមើលកូនចៅ។ ដល់ប្ដីនៅជួបជុំគ្នា ពេលខ្វះខាតអី យើងចេះតែទៅជួយរកគ្នាទៅ ដល់ឥលូវអង្ករក៏ឡើងថ្លៃទៀត»។

ក្នុងរយៈពេលជាង១០ឆ្នាំមកនេះ លោកស្រីត្រូវរស់នៅជាមួយកូន៣នាក់ និងដេរស្លឹកត្នោតលក់ ដើម្បីដូរយកប្រាក់ខ្លះចិញ្ចឹមគ្រួសារ ព្រោះប្ដីរបស់គាត់ត្រូវចេញទៅធ្វើជាកម្មករនៅតាមទូកនេសាទថៃ ដោយ ១ឆ្នាំទើបវិលមកជួបគ្រួសារម្តង។ ក្នុងមួយថ្ងៃ ស្ត្រីវ័យ ៣៣ឆ្នាំរូបនេះ អាចអាចដេរស្លឹកត្នោតបានពី ២០ ទៅ ៣០ កណ្តប ដោយមួយ ១កណ្តប លក់បានតម្លៃ ១៨០រៀល ហើយចំណូលដែលបានពីមុខរបរនេះគឺចន្លោះពី ៣ពាន់រៀល ទៅ ៥ពាន់រៀល៖ « ជីវភាពរាល់ថ្ងៃហ្នឹង ខ្ញុំលំបាកណាស់ ខ្ញុំនៅចិញ្ចឹមកូនតែឯង។ ប្ដីខ្ញុំទៅថៃ មួយខែៗ គាត់ផ្ញើឲ្យតែ៣ពាន់ លុយបាត ហើយទូទាត់ទៅលើអង្ករ ម្ហូប កូនចាយរៀន មិនចង់គ្រប់ផង មួយខែហ្នឹងនោះ។ ខ្ញុំដេកស្លឹកផង»។

ស្ត្រីម្នាក់ទៀត ដែលចាប់យករបរដេរស្លឹកត្នោតនេះដែរ គឺលោកស្រី សួន ញ៉ែន ប្រាប់ថា ប្ដីលោកស្រី និងកូនប្រុសវ័យ ១៧ឆ្នាំ បានចេញទៅធ្វើការតាមទូកនេសាទថៃជាង ១០ឆ្នាំមកហើយ ដើម្បីរកប្រាក់ជួយគ្រួសារ។ សព្វថ្ងៃលោកស្រីរស់នៅជាមួយកូនស្រី២នាក់ ហើយតែងតែបារម្ភពីសុវត្ថិភាពប្ដីនិងកូនប្រុសដែលចេញទៅធ្វើការឆ្ងាយ។ ទន្ទឹមគ្នានេះ ស្ត្រីវ័យជិត៥០ឆ្នាំប្លាយរូបនេះ ក៏បារម្ភពីសុវត្ថិភាពគ្រួសាររស់នៅក្នុងភូមិដែរ៖ « ពេលដែលប្តីទៅអស់អ៊ីចឹង មានភាពភ័យខ្លាច ដូចខ្លាចមានគេធ្វើបាប ខ្លាចអ៊ីចឹងដែរ ហើយនៅជាមួយកូន ពិបាកដែរអត់មានស្រួលទេ ព្រោះអីយើងគិតច្រើន មិនដឹងថាប្ដីទៅនោះ មិនដឹងម៉េចអីអ៊ីចឹង។ ហើយណាមួយនៅផ្ទះហ្នឹង ក៏ពិបាក សូម្បីតែយើងនៅដេកស្លឹកអ៊ីចឹង ដេកទៅ ឥលូវអត់មានទឹកត្រាំទៀត ក៏ពិបាកទៀតហើយ។ សូម្បីតែកូនទៅរៀនម្នាក់ហ្នឹង ក៏ខ្ញុំពិបាកដែរ រកលុយឲ្យកូនចាយ មិនសឹងចង់បានទេ។ មានមាន់អីបន្តិចបន្តួចលួចអស់ហើយ»។ លោក ស្រី សួន ញ៉ែន ស្នើដល់រដ្ឋាភិបាលឲ្យជួយដោះស្រាយបញ្ចប់វិវាទដីធ្លីឲ្យអ្នកភូមិឡពាងដើម្បីឲ្យគ្រួសារពួកគេបានរស់នៅជួបជុំគ្នា ដោយទទួលស្គាល់និងប្រគល់សងដីធ្លីឲ្យអ្នកភូមិវិញ៖ « ចុងក្រោយ ខ្ញុំចង់បានប្តីឲ្យបានមកជួបជុំគ្រួសារ។ ខ្ញុំចង់បានដីមកវិញ។ បើបានដីមកវិញ ហើយបានជុំគ្រួសារ ពួកខ្ញុំនឹងសប្បាយរីករាយ។ ពួកខ្ញុំអត់មានទុក្ខលំបាកដល់ថ្ងៃមុខទៀតទេ ឲ្យតែបានដីបានអីមែន។ ហើយប្តីមកជួបជុំគ្នា ពួកខ្ញុំមានភាពកក់ក្តៅវិញ»។

មេឃុំតាជេស លោក នួន ស៊ន ថ្លែងថា ការធ្វើចំណាកចេញពីភូមិទៅធ្វើការតាមទូកនេសាទ នៅប្រទេសថៃ គឺមិនមានតែអ្នកភូមិឡពាងមួយទេ ប៉ុន្តែក៏មានអ្នកភូមិដទៃទៀតចេញទៅដូចគ្នាដែរ។ លោកបន្តថា ក្នុងមួយភូមិ

អាចមានកម្លាំងមនុស្សប្រុស ចេញទៅធ្វើការនៅថៃចាប់៤ដល់១០នាក់ ព្រោះការងារក្រៅស្រុក បានចំណូលច្រើនជាងក្នុងស្រុក៖ «ខាងគាតមានបញ្ហាខ្លះអ៊ីចឹងក៏មិនដឹង គាត់ធ្លាប់ទៅអ៊ីចឹងដែរ ឃើញតែទៅមកៗ ខ្លះគេកកប់ គេធាប់មកអ៊ីចឹងទៅ ខ្លះរកលុយអត់សូវបាន ក៏នៅយូរ។ បញ្ហាដីក៏លែងមានហើយ បញ្ហាដីហ្នឹងនោះ។ រឿងជំទាវ ជាខេង នៅភូមិឡពាង ភូមិបឹងកក់ មានអ៊ីចឹងមែន រឿងទៅថៃភូមិផ្សេងទៀត ក៏តែដេរ។ គេថា គេធ្លាប់រកស៊ីមានបានអ៊ីចឹង។ ខ្ញុំពិបាកនិយាយប្រាប់ដែរ។ រឿងបញ្ហាវាមានមែនពីមុនមក។ ពីមុនក៏មានដែរ ក្រោយមកមានរឿងរ៉ាវហើយក៏មានទៅថៃអ៊ីចឹងដែរ។ គេមកធ្វើផ្ទះសម្បែងអ៊ីចឹងទៅ»។ លោក នួន ស៊ន ឲ្យដឹងថា មានគ្រួសារមួយស្ថិតក្នុងឃុំតាដេស បាត់បង់ជីវិតកូនប្រុស២នាក់រួចមកហើយ ដោយសារតែឲ្យពួកគេចេញទៅធ្វើការតាមទូកនេសាទថៃ។ មេឃុំរូបនេះ បញ្ជាក់ថា រូបលោក ខំពន្យល់ប្រាប់អ្នកភូមិឲ្យឈប់ធ្វើចំណាកទៅប្រទេសថៃ ព្រោះខ្លាចមានគ្រោះថ្នាក់ដល់អាយុជីវិត ប៉ុន្តែមិនមានអ្នកណាទទួលការណែនាំនេះឡើយ៖ «ពិបាកនិយាយប្រាប់គេណាស់ គេថាធ្វើនៅខ្មែរ លុយបានតិច ទៅថៃធ្វើហត់មែន ដឹងតែបានលុយច្រើនតែម្តង។ គេនិយាយតែអ៊ីចឹង។ ខ្ញុំចេះតែឲ្យដែរ បងប្អូនជីដូនមួយគេរកនៅស៊ីនៅស្រុកខ្មែរគេគោក គេដាំបន្លែ គេធ្វើផ្ទះធ្វើអី គេធ្វើកម្មករ មានការងារច្រើនដែរ។ ឯងចេះតែទៅអ៊ីចឹងខ្លះធ្លាក់ទឹកស្លាប់អ៊ីចឹងទៅ។ គេថាធ្វើនៅស្រុកខ្មែរ មិនដឹងថាថ្ងៃណាបានលុយទេ។ គេចូលចិត្តនិយាយអ៊ីចឹងណាស់។ ខ្ញុំធុញដែរ គេធ្វើនៅស្រុកខ្មែរគេគោកដែរ តែនិយាយអ៊ីចឹង គាត់ថា អត់ចេះនៅទេ សំបូរណាស់អ្នកនិយាយអ៊ីចឹង»។

នាយករងទទួលបន្ទុកផ្នែកឃ្លាំមើលសិទ្ធិមនុស្សនៃអង្គការ លីកាដូ លោក អំ សំអាត លើកឡើងថា បញ្ហាដីធ្លីនៅក្នុងប្រទេសកម្ពុជា គឺជាដើមចម ដែលធ្វើឲ្យពលរដ្ឋបាត់ដីធ្លី ត្រូវបង្ខំចិត្តចាកចេញពីតំបន់ដែលខ្លួនរស់នៅ ទៅរកការងារធ្វើនៅខេត្តផ្សេង ឬនៅទីក្រុង ហើយភាគច្រើននោះ គឺចេញទៅធ្វើការនៅប្រទេសថៃ។ លោកបន្តថា បញ្ហានេះទៀតសោតក៏ធ្វើឲ្យពលរដ្ឋត្រូវជំពាក់បំណុលធនាគារ ឬមីក្រូហិរញ្ញវត្ថុ ដោយសារតែដាក់បញ្ចាំ ដីនិងផ្ទះបន្តិចបន្តួចដែលនៅសល់ក្រោយពីការរំលោភយកពីក្រុមអ្នកមានអំណាច និងក្រុមហ៊ុន។ បន្ថែមលើនេះ លោកថា ក្មេងៗដែលគ្រប់វ័យរៀនសូត្រ ត្រូវបោះបង់ចោលការសិក្សា ក៏ដោយសារតែបញ្ហាដីធ្លីនេះដែរ៖ «ជាការពិត ការធ្វើការចំណាកស្រុករកមុខរបរ វាមានជាទូទៅ ប៉ុន្តែបើយើងមើលទៅលើបញ្ហាដីធ្លីនេះ វាឃើញភាគច្រើនដែលកើតឡើងសម្រាប់ពួកគាត់។ ហើយមួយទៀតក្រៅពីធ្វើការចំណាកស្រុក អ្នកខ្លះ យើងឃើញមានការកាត់សក់លក់ ឬក៏អីអ៊ីចឹងទៅ បានន័យថា ជាការមួយប៉ះពាល់ដល់ការរំលោភសិទ្ធិរបស់គាត់ទៅទៀត ដោយសារតែបញ្ហាជីវភាព»។

ក្រុមអង្គការសង្គមស៊ីវិលដែលឃ្លាំមើលសិទ្ធិមនុស្សនិងសិទ្ធិដីធ្លី ស្នើដល់រដ្ឋាភិបាលកម្ពុជា បញ្ឈប់ការបណ្តេញពលរដ្ឋចេញពីលំនៅឋាន និងពន្លឿនដំណោះស្រាយបញ្ចប់វិវាទដីធ្លីប្រកបឲ្យមានប្រសិទ្ធិភាព ដើម្បីផ្តល់លំនឹងជីវភាពរស់នៅដល់ពលរដ្ឋនៅទូទាំងប្រទេស និងដើម្បីកាត់បន្ថយការធ្វើចំណាកស្រុកតទៅទៀត៕

## ក្រសួងសង្គមកិច្ច និងស្ថាប័នពាក់ព័ន្ធ បើកយុទ្ធនាការបញ្ចប់អំពើហិង្សាលើកុមារ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 20 February 2020 | 10:56 ICT

**ភ្នំពេញ៖** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដោយមានការគាំទ្រពីមូលនិធិសហប្រជាជាតិដើម្បីកុមារ (យូនីសេហ្វ) និងមានការចូលរួមពីក្រសួង ស្ថាប័ន និងអង្គការដៃគូបានប្រកាសបើកយុទ្ធនាការ «គ្រួសាររឹងមាំ» ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ និងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់។

សេចក្តីប្រកាសព័ត៌មានរួមស្តីពីយុទ្ធនាការនេះដែលធ្វើឡើងពីម្សិលមិញនៅសណ្ឋាគារកាំបូឌីយ៉ាណាបានបង្ហាញថា យុទ្ធនាការនេះគឺជាព្រឹត្តិការណ៍ដ៏សំខាន់មានគោលដៅរួមគ្នាក្នុងការលុបបំបាត់អំពើហិង្សាលើកុមារដែលជាការបោះជំហានទៅមុខដ៏វិជ្ជមានមួយផ្សេងទៀតក្នុងកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីបញ្ចប់រាល់ទម្រង់នៃអំពើហិង្សាលើកុមារ និងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់។ យុទ្ធនាការនេះមានគោលបំណងដោះ

ស្រាយនូវបញ្ហាសង្គម និងវប្បធម៌ដែលធ្វើឲ្យមានអំពើហិង្សាលើកុមារ និងធ្វើឲ្យមានជំនឿថា មណ្ឌលថែទាំជាទីកន្លែងដែលផ្តល់អត្ថប្រយោជន៍ជាច្រើនដល់កុមារ។ សេចក្តីប្រកាសព័ត៌មាននេះបញ្ជាក់ថា៖ «អំពើហិង្សាគឺជាកង្វល់ដ៏ធំមួយដែលមានកុមារជាងពាក់កណ្តាលក្នុងប្រទេសធ្លាប់ទទួលរងអំពើហិង្សាយ៉ាងហោចណាស់ក៏មាន ១ ទម្រង់ដែរ មុនពេលពួកគេអាយុ ១៨ ឆ្នាំ។ អំពើហិង្សាលើកុមារជះឥទ្ធិពលអវិជ្ជមានយូរអង្វែងដល់សុខុមាលភាពកុមារក្នុងទិដ្ឋភាពផ្សេងៗទាក់ទងនឹងអាកប្បកិរិយា ផ្លូវចិត្ត និងរាងកាយនៅក្នុងវ័យជំទង់ និងនៅពេលពេញវ័យ»។ សេចក្តីប្រកាសបន្តថា ខណៈពេលដែលមានភាពក្រីក្រ កង្វះខាតការទទួលបានការអប់រំ និងការគាំទ្រសុខុមាលភាពសង្គម ជំរុញឲ្យក្រុមគ្រួសារមួយចំនួនបានយកកុមារទៅដាក់នៅមណ្ឌលថែទាំ។ កត្តាជំរុញមួយទៀតអាចបណ្តាលមកពីជំនឿដែលយល់ថា កុមារនឹងទទួលបានការថែទាំ និងការអប់រំល្អប្រសើរពីមណ្ឌលថែទាំផងដែរ។

ប៉ុន្តែក្រសួង និងអង្គការពាក់ព័ន្ធបញ្ជាក់ថា៖ «ការដាក់កុមារនៅមណ្ឌលថែទាំធ្វើឲ្យកុមារប្រឈមមុខនឹងហានិភ័យនៃអំពើហិង្សា ការកេងប្រវ័ញ្ច និងការមិនអើពើដែលអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ការអភិវឌ្ឍកុមារ»។ ដោយមើលឃើញបញ្ហាខាងលើនេះក្រសួងសង្គមកិច្ចបានគាំទ្រយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់នៅកម្ពុជា ឬហៅថា (យុទ្ធសាស្ត្រប្រាស្រ័យទាក់ទង Cambodia PROTECT) ហើយយុទ្ធនាការគ្រួសាររឹងមាំគឺបង្កើតឡើងដោយផ្អែកលើយុទ្ធសាស្ត្រ Cambodia PROTECT នេះ។

លោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ថ្លែងថាយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងបានសហការរៀបចំដោយក្រសួងសង្គមកិច្ច ជាមួយយូនីសេហ្វក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ និងធានាឲ្យប្រជាជនយល់ដឹងថា បរិយាកាសគ្រួសារមានសុវត្ថិភាពគឺជាទីកន្លែងដ៏ល្អប្រសើរបំផុតសម្រាប់កុមារលូតលាស់ និងអភិវឌ្ឍ។ លោកថ្លែងថា៖ «តាមរយៈយុទ្ធនាការគ្រួសាររឹងមាំ សារអប់រំសំខាន់ៗនឹងផ្សព្វផ្សាយទៅដល់ទូទាំងប្រទេសតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ប្រព័ន្ធឆ្លើយតបតាមបច្ចេកវិទ្យា ព័ត៌មានវិទ្យា សកម្មភាពផ្សព្វផ្សាយនៅតាមសហគមន៍ និងការស្វែងរកមតិគាំទ្រជាដើម។ យុទ្ធនាការនេះគឺផ្តោតលើកុមារ ឪពុកម្តាយ អាណាព្យាបាល អ្នកថែទាំកុមារ ប្រជាពលរដ្ឋនៅក្នុងសហគមន៍ អ្នកផ្តល់សេវា អ្នកធ្វើគោលនយោបាយ អ្នកធ្វើការលើវិស័យយុត្តិធម៌ និងអ្នកសារព័ត៌មានជាដើម»។

លោកស្រី គ្រីស្សៀន ម៉ុនឌ័រតេ នាយិកាយូនីសេហ្វប្រចាំកម្ពុជាបានថ្លែងថា យុទ្ធនាការនេះគឺជាឱកាសដើម្បីកៀរគរប្រជាពលរដ្ឋកម្ពុជាទាំងអស់ឲ្យនិយាយថាទេចំពោះអំពើហិង្សា និងថែរក្សាបរិស្ថានឲ្យមានសុវត្ថិភាព និងសុខភាពល្អសម្រាប់កូនៗ និងគ្រួសាររបស់ពួកគេ។ លោកស្រីបានថ្លែងថា៖ «យើងត្រូវធ្វើយុទ្ធនាការនេះឲ្យដល់ប្រជាពលរដ្ឋគ្រប់ក្រុមគ្រួសារ គ្រប់សាលារៀន គ្រប់សហគមន៍ គ្រប់បណ្តាញផ្សព្វផ្សាយព័ត៌មាន។ អំពើហិង្សាប៉ះពាល់យើងគ្រប់គ្នា»៕

## ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០២០

## សម្តេចតេជោ ហ៊ុន សែន ណែនាំការងារអាទិភាព៨ចំណុចដល់ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ខិតខំអនុវត្តន៍ឲ្យមានប្រសិទ្ធភាព

http://www.freshnewsasia.com/ 2020-02-20

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០នេះ បានដាក់ចេញនូវការងារអាទិភាពចំនួន៨ចំណុចដល់ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ យកចិត្តទុកដាក់ខិតខំយកចិត្តទុកដាក់ឲ្យមានប្រសិទ្ធភាព នៅឆ្នាំ២០២០នេះ និងឆ្នាំបន្តបន្ទាប់ទៀត។ ការដាក់ចេញ

ការងារអាទិភាពនេះ ធ្វើឡើងក្នុងឱកាសដែលសម្តេចតេជោ ហ៊ុន សែន បានអញ្ជើញបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។

**សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ដើម្បីកម្ពុជាដោះស្រាយបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព នូវបញ្ហាប្រឈមទាំងឡាយ នៅឆ្នាំ២០២០ និង បណ្តាឆ្នាំខាងមុខទៀត ក្នុងនាមរាជរដ្ឋាភិបាល សម្តេចសូមផ្តល់នូវគោលការណ៍ណែនាំ លើការងារសំខាន់ៗមួយចំនួន ដែលក្រសួងមហាផ្ទៃ និង រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ត្រូវយកចិត្តទុកដាក់ខិតខំសម្រេចឱ្យបានដូចខាងក្រោម៖**

**ទី១៖** ត្រូវបន្តថែរក្សាសុខសន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម, ពង្រឹងជំនឿទុកចិត្តដល់ធុរជន ក្នុងការបណ្តាក់ទុនវិនិយោគ និងការប្រកប អាជីវកម្មនៅកម្ពុជា, ធានាសុវត្ថិភាពទាំងស្រុងសម្រាប់រាល់ព្រឹត្តិការណ៍ជាតិ-អន្តរជាតិ ដែលរៀបចំនៅកម្ពុជាទប់ស្កាត់មិនឱ្យមានអំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**ទី២៖** គណៈបញ្ជាការឯកភាពគ្រប់ថ្នាក់ ត្រូវបន្តជំរុញការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ឱ្យកាន់តែសកម្មផុសផុល ដើម្បីជំរុញចលនាប្រជាជន ចូលរួមជាមួយអាជ្ញាធរ កងកម្លាំងមានសមត្ថកិច្ច ក្នុងការបង្ការទប់ស្កាត់ បង្ក្រាបគ្រឿងញៀនខុសច្បាប់ ចោរកម្ម ឃាតកម្ម អំពើប្លន់ប្រដាប់អាវុធ ល្បែងស៊ីសង ការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ ការកាប់ឈើ និងការទន្ទ្រានកាន់កាប់ដីធ្លីខុសច្បាប់, បទល្មើសនេសាទ អាជីវកម្មរ៉ែ និងអាជីវកម្មខ្សាច់ខុសច្បាប់ និងប៉ុស្តិ៍ត្រួតពិនិត្យខុសច្បាប់។ល។

**ទី៣៖** អំពីបញ្ហាចរាចរណ៍ដោយសារឆ្នាំ ២០១៩ កន្លងទៅនេះ គ្រោះថ្នាក់ចរាចរណ៍មានការកើនឡើងយ៉ាងខ្លាំង ទាំងចំនួនអ្នកស្លាប់ និងអ្នករងរបួស ។ ដូច្នេះ, កងកម្លាំងនគរបាលជាតិ អាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចនានា ត្រូវរួមគ្នាពង្រឹងឱ្យមានប្រសិទ្ធភាព ជាមួយនឹងស្មារតីទទួលខុសត្រូវខ្ពស់ នូវយុទ្ធនាការលើកកម្ពស់ ការគោរពអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកឱ្យបានម៉ឺងម៉ាត់, អប់រំផ្សព្វផ្សាយច្បាប់ចរាចរណ៍ ឱ្យបានកាន់តែទូលំទូលាយ នៅទូទាំងប្រទេស សំដៅកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ឱ្យបានជាអតិបរមា។

**ទី៤៖** ត្រូវបន្តលើកកម្ពស់វិធានការគ្រប់គ្រងមុខសញ្ញានានា ទាក់ទងនឹងកិច្ចការអន្តោប្រវេស្ត ដើម្បីចូលរួមបង្ការ ទប់ស្កាត់បណ្តាញភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន សំដៅពង្រឹងសន្តិសុខជាតិ និងសណ្តាប់ធ្នាប់ក្នុងសង្គម តាមរយៈការបង្កើនការគ្រប់គ្រងឱ្យបានហ្មត់ចត់ និងមានប្រសិទ្ធភាពនូវជនបរទេស អន្តោប្រវេសន្តស្របតាមច្បាប់។

**ទី៥៖** ត្រូវបន្តអនុវត្តប្រកបដោយប្រសិទ្ធភាព នូវកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃ តាមរយៈកិច្ចសហការសម្របសម្រួលជាមួយ កម្មវិធីកែទម្រង់នានា និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ ធ្វើការផ្ទេរធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ ស្របតាមប្រព័ន្ធវិមជ្ឈការ សំដៅធានាឱ្យរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក ខណ្ឌដំណើរការ ដោយរលូន និងមានប្រសិទ្ធភាព ។ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវលើកកម្ពស់ភាពជាម្ចាស់ ប្រកបដោយភាពច្នៃប្រឌិត ក្នុងការចាត់ចែងប្រើប្រាស់មុខងារ និងធនធានដែលបានផ្ទេរ ដើម្បីឆ្លើយតបតាមតម្រូវការរបស់ប្រជាជន នៅតាមមូលដ្ឋាន សំដៅជំរុញលើកទឹកចិត្តការចូលរួម របស់ប្រជាជនក្នុងការអភិវឌ្ឍតាមមូលដ្ឋានរៀងៗខ្លួន។

**ទី៦៖** ត្រូវបន្តខិតខំយកចិត្តទុកដាក់ធ្វើការបណ្តុះបណ្តាល, កសាងសមត្ថភាពដល់មន្ត្រីរាជការស៊ីវិល, កងកម្លាំង នគរបាលជាតិ និងមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់នូវជំនាញវិជ្ជាជីវៈ ចំណេះដឹង និងចំណេះធ្វើជាក់ស្តែងថ្មីៗ ជាពិសេសសេវាសង្គមសេវារដ្ឋបាល សេវាសន្តិសុខ និងសេវាសាធារណៈចាំបាច់ជាមូលដ្ឋាន ដែលពាក់ព័ន្ធជីវភាព ប្រចាំថ្ងៃរបស់ប្រជាជន ប្រកបដោយតម្លាភាព គណនេយ្យភាព និងមានប្រសិទ្ធភាពខ្ពស់។

**ទី៧៖** តាមការព្យាករណ៍ឆ្នាំនេះ ប្រទេសយើងនឹងមានអាកាសធាតុក្តៅហួតហែង ហើយការមកដល់នៃរដូវវស្សា នឹងមានសភាពយឺតយ៉ាវជាងសព្វដង។ ដូច្នេះ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ

ត្រូវធ្វើការត្រួតពិនិត្យ វាយតម្លៃអំពីប្រភពទឹកសម្រាប់ប្រើប្រាស់ ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន តាមមូលដ្ឋាននីមួយៗ ដោយផ្អែកតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាល ស្តីពីការចាត់វិធានការថែរក្សាទឹកទុក ដើម្បីត្រៀមលក្ខណៈជួយអន្តរាគមន៍ ដោះស្រាយទឹកប្រើប្រាស់ប្រចាំថ្ងៃរបស់ ប្រជាពលរដ្ឋនៅមូលដ្ឋាន ដែលខ្វះខាតទឹកប្រើប្រាស់ឱ្យបានទាន់ពេលវេលា, ត្រូវអប់រំប្រជាពលរដ្ឋឱ្យយកចិត្តទុកដាក់ ចូលរួមបង្ការអគ្គិភ័យ មកលើផ្ទះសម្បែង, ចម្ការដំណាំនានា និងចូលរួមបង្ការទប់ស្កាត់ ភ្លើងឆេះព្រៃ ព្រមទាំងការបង្ការជំងឺដម្កាត់នានា នៅរដូវប្រាំងក្តៅហួតហែងនេះ។

**ទី៨៖** ត្រូវបន្តចូលរួមពង្រឹងទំនាក់ទំនង, ផ្សារភ្ជាប់រវាងរាជរដ្ឋាភិបាលជាមួយ ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ត្រូវបង្កើនសកម្មភាពចុះមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាប្រឈម និង សំណូមពរទាំងឡាយរបស់ប្រជាជន ឱ្យបានសមស្រប និងទាន់ពេលវេលា។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងទៀតថា «ខ្ញុំសូមថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ, កងកម្លាំងនគរបាលជាតិ, មន្ត្រីរាជការស៊ីវិល និង រដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ ដែលបានរួមគ្នាអនុវត្តសម្រេចបានសមិទ្ធផលនានាជាច្រើន គួរជាទីមោទនៈកាលពីឆ្នាំ ២០១៩កន្លងមក។ ខ្ញុំជឿជាក់ថា ក្រសួងមហាផ្ទៃនឹងបន្តពុះពារសម្រេចបាននូវ សមិទ្ធផលថ្មីៗបន្ថែមទៀត ក្នុងឆ្នាំ២០២០នេះ និង បណ្តាឆ្នាំខាងមុខទៀត»។ សម្តេចនាយករដ្ឋមន្ត្រីបានលើកឡើងថា បញ្ហាប្រឈមសកលនៅឆ្នាំ២០២០នេះ មានភាពស្មុគ្រស្មាញ ទាំងការប្រែប្រួលអាកាសធាតុ, អំពើភេរវកម្ម, បញ្ហាជនភៀសខ្លួន, ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងថ្មីៗនេះ គឺការផ្ទុះឡើងនៃមេរោគ COVID-19 បាននិងកំពុងជះឥទ្ធិពល, ទាំងការឆ្លងមេរោគ និងជំងឺភ័យខ្លាច ដល់តំបន់ជាច្រើន នៅក្នុងពិភពលោក រួមទាំងកម្ពុជាផងដែរ។ ទន្ទឹមនេះក៏មានការឆ្លៀតឱកាសប៉ុនប៉ងធ្វើបដិវត្តពណ៌ និងផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់ បំផ្លាញសុខសន្តិភាព ដែលកំពុងមាន និង ដែលរកបានមកដោយលំបាក។

**ដោយសារបញ្ហាប្រឈមទាំងនេះ ក្នុងនាមរាជរដ្ឋាភិបាល សម្តេចតេជោ ហ៊ុន សែន បានដាក់ចេញនូវទិសដៅជាយុទ្ធសាស្ត្រ សំខាន់១៤ ដែលត្រូវពុះពារសម្រេចឱ្យបានគឺ៖**

**ទី១៖** បន្តប្តូរផ្តាច់ការពារ និងថែរក្សាឱ្យបាននូវសុខសន្តិភាព ឯករាជ្យ អធិបតេយ្យជាតិ និងបូរណភាពទឹកដី សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងលើកស្ទួយនូវសិទ្ធិ សេរីភាពគ្រប់យ៉ាងរបស់ប្រជាពលរដ្ឋ ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានាជាធរមាននៅកម្ពុជា។

**ទី២៖** បន្តជំរុញលើកកម្ពស់ដំណើរការលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស តាមរយៈការធានាឱ្យបាននូវសុខសន្តិភាព និងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព អត្តសញ្ញាណជាតិ សេចក្តីថ្លៃថ្នូរ ប្រពៃណីទំនៀមទំលាប់ដ៏ល្អរបស់ជាតិ និងការកសាងភាពសុខដុមរមនា ជាមួយគ្រប់ជាតិសាសន៍ នៅក្នុងសង្គមជាតិយើង។

**ទី៣៖** បន្តអប់រំប្រជាជនឱ្យយល់ដឹងច្បាស់ពីការអនុវត្ត និងការប្រើប្រាស់សិទ្ធិសេរីភាព តាមរយៈការរួមគ្នាការពាររដ្ឋធម្មនុញ្ញ ការពារព្រះមហាក្សត្រ ការពាររបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងប្រព័ន្ធនយោបាយនៅកម្ពុជា ត្រូវពង្រឹង និងជំរុញការអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់ និងស្មើភាពគ្នា។

**ទី៤៖** លើកកម្ពស់ប្រសិទ្ធភាពនូវការកែទម្រង់ លើគ្រប់វិស័យឱ្យកាន់តែស៊ីជម្រៅ ស្របតាមបាវចនា «កែទម្រង់ខាង ក្នុងបង្កើនមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ» និង អភិក្រម «ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់»។

សម្តេចតេជោ ហ៊ុន សែន បានបង្ហាញមោទនភាព និងសូមថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ, កងកម្លាំងនគរបាលជាតិ, មន្ត្រីរាជការស៊ីវិល និងរដ្ឋបាលគ្រប់លំដាប់ថ្នាក់ នៅ

ថ្នាក់ ក្រោមជាតិ ដែលបានខិតខំបំពេញតួនាទីភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម រួមគ្នាពុះពារសម្រេចបាននូវសមិទ្ធផលនានាជាច្រើន ជូនជាតិមាតុភូមិ និងប្រជាជន៕

## សម្តេចតេជោ៖ ពលរដ្ឋលែងត្រូវការក្រមា សារុង និងអង្ករទៀតហើយ គឺត្រូវការសុខសុវត្ថិភាពក្នុងការរស់នៅ

https://khmerpress.news/ cily sok February 21, 2020 at 10:57 am

(ភ្នំពេញ)៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានថ្លែងការចែកក្រមា សារុង និងអង្ករហួសសម័យកាលហើយ ពោលប្រជាពលរដ្ឋបច្ចុប្បន្នលែងត្រូវការអំណោយជាក្រមា សារុង និងអង្ករទៀតហើយ។ បើតាមសម្តេចតេជោនាយករដ្ឋមន្ត្រី អ្វីដែលប្រជាពលរដ្ឋត្រូវការនាពេលបច្ចុប្បន្ននេះ គឺការរស់នៅប្រកបដោយសុខសុវត្ថិភាព។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានលើកឡើងបែបនេះក្នុងពិធីបិទសន្និបាតបូកសរុបការងាររបស់ក្រសួងមហាផ្ទៃ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០។ ដើម្បីផ្តល់សុខសុវត្ថិភាពសម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋ សម្តេចតេជោ ហ៊ុន សែន បានក្រើនរំលឹកដល់មន្ត្រីអាជ្ញាធរ និងកងកម្លាំងនគរបាលជាតិ រួមគ្នាពង្រឹងការអនុវត្តន៍គោលនយោបាយ «ភូមិឃុំមានសុវត្ថិភាព» ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

ដើម្បីពង្រឹងសន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាព និងលុបបំបាត់រាល់បទល្មើសទាំងឡាយនោះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយ «ភូមិឃុំសុវត្ថិភាព»។ គោលនយោបាយភូមិឃុំមានសុវត្ថិភាពនេះ មានលក្ខណៈសម្បត្តិចំនួន ៩យ៉ាង រួមមាន៖ គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ, គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់ គ្រឿងញៀនខុសច្បាប់, គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ, គ្មានក្មេងទំនើង, គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ, គ្មានគ្រោះថ្នាក់ចរាចរណ៍, គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ, មានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតប ចំពោះគ្រោះមហន្តរាយ ប្រកបដោយប្រសិទ្ធិភាព និងគ្មានការត្រួតពិនិត្យខុសច្បាប់។

សម្តេចតេជោ ហ៊ុន សែន បានលើកឡើងថា ការដាក់ចេញគោលនយោបាយ «ភូមិឃុំមានសុវត្ថិភាព» នេះជារឿងត្រឹមត្រូវមួយ តែការអនុវត្តន៍មិនទាន់បានល្អប្រសើរ។ «យើងដាក់ចេញនូវគោលនយោបាយភូមិឃុំមានសុវត្ថិភាពត្រឹមត្រូវហើយ ឥឡូវអ្វីដែលជាការនៅខ្វះត្រង់ថាយើងមិនបានដាក់ភ្ជាប់នូវគន្លឹះ នូវកូនសោរនេះ ហើយយើងងាកទៅឆ្វេងបន្តិច ងាយកទៅស្តាំបន្តិច»។ សម្តេចតេជោ បញ្ជាក់បន្ថែម។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានសង្កត់ធ្ងន់ថា ការរួមគ្នាពង្រឹងគោលនយោបាយភូមិឃុំមានសុវត្ថិភាព និងនាំមកនូវសន្តិសុខសុវត្ថិភាពសម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋ នឹងនាំដល់ការជឿទុកចិត្តលើការដឹកនាំរបស់រាជរដ្ឋាភិបាលផងដែរ៕

## ខ្លាំងមែន! នារីម្នាក់នេះឡាយលក់ខ្លួនតាមហ្វេសប៊ុក តម្លៃចាប់៣០ ដល់១០០ដុល្លារ

https://kbn.news/ February 21, 2020

រាជធានីភ្នំពេញ៖ នារីម្នាក់នេះ មានចិត្តក្លាហានណាស់ ហ៊ានឡាយប្រកាសលក់ខ្លួនឲ្យភ្ញៀវតាមហ្វេសប៊ុក ក្នុងតម្លៃចាប់ពី៣០ដុល្លារ ដល់១០០ដុល្លារ ស៊ីសងតាមការចរចាគ្នា លុះពេលកម្លាំងសមត្ថកិច្ចបានឃើញ ក៏ទៅចាប់នាំខ្លួនមកចាត់ការតាមច្បាប់តែម្តង។ យោងតាម Pheng Vannak News ដែលបានបង្ហោះ កាលពី10ម៉ោងមុនមានខ្លឹមសារថា« សមត្ថកិច្ចឃាត់ខ្លួនស្ត្រីម្នាក់ ដែលបានឡាយតាមបណ្តាញសង្គម ប្រកាសលក់ខ្លួនថា មកដល់ផ្ទះ៣០ដុល្លារ, ចេញក្រៅ៥០ដុល្លារ និងមួយយប់ដល់ព្រឹក១០០ដុល្លារ! ចំពោះចំណាត់ការ មិនទាន់ដឹងនៅឡើយតើគួរ

អប់រំ ឬដាក់ទោសតាមច្បាប់?»។ ជុំវិញនឹងករណីនេះ «KBN» មិនទាន់សុំការបញ្ជាក់បន្ថែមពីសាមីខ្លួនខាងលើបានទេ តែយ៉ាងណា យើងរង់ចាំការបកស្រាយពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់៕

## ចាប់ពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ចូលទៅធ្វើការសំណង់នៅប្រទេសថៃ

https://www.facebook.com/officialworker/ 20.02.2020

យោងតាមប្រភពព័ត៌មានពីស្រះកែវ ប្រទេសថៃ នៅថ្ងៃព្រហស្បតិ៍ ទី២០ ខែកុម្ភៈ ឆ្នាំ២០២០នេះ បានឲ្យដឹងថា កម្លាំងសមត្ថកិច្ចថៃ ប្រចាំកុងត្រួលភូមិអាងសិលា ស្ថិតក្នុងស្រុកគោកស៊ូង ខេត្តស្រះកែវ ប្រទេសថៃ បានធ្វើការឃាត់ខ្លួនពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ ចំនួន០៥នាក់ ក្នុងនោះមាន បុរស០៤នាក់ និងស្ត្រី ០១នាក់ ខណៈពេលដែលគេកំពុងជិះក្នុងរថយន្តមួយគ្រឿងម៉ាកHonda Civic ពាក់ស្លាក់លេខ( ក ថ-8990 ប៉ាធុមថានី) ដោយមានបុរសជនជាតិជាតិថៃម្នាក់ជាអ្នកបើកបររថយន្តដឹកពលរដ្ឋខ្មែរខាងលើ។

យោងតាមការត្រួតពិនិត្យរបស់សមត្ថកិច្ចថៃ បានបញ្ជាក់ថាពលរដ្ឋខ្មែរទាំង ០៥នាក់ មិនមានលិខិតឆ្លងបង្ហាញសមត្ថកិច្ចថៃដើម្បីត្រួតពិនិត្យនោះទេ សមត្ថកិច្ចថៃបាននាំខ្លួនពលរដ្ឋខ្មែរនិងជនជាតិថៃទាំងនោះទៅធ្វើការសាកសួរនៅអធិការដ្ឋានតម្រួតស្រុកគោកស៊ូងនៅវេលាបន្តបន្ទាប់។

តាមចម្លើយសារភាពរបស់ពលរដ្ឋខ្មែរទាំងអស់បានប្រាប់អ្នកបកប្រែភាសាខ្មែរ ចំពោះមុខសមត្ថកិច្ចថៃ បានអោយដឹងថា ពួកគាត់បានចំណាក់ស្រុកខុសច្បាប់ចូលប្រទេសថៃតាមរយៈច្រកព្រំដែនរបៀងកម្ពុជា-ថៃ ស្ថិតក្នុងភូមិអាងសិលា ដោយគោលដៅត្រូវទៅធ្វើការសំណង់នៅឯទីក្រុងបាងកក ប្រទេសថៃ ដោយមានមេខ្យល់ជាជនជាតិខ្មែរជាអ្នកទំនាក់ទំនងរថយន្តខាងថៃសម្រាប់ដឹកពួកគាត់ទៅកន្លែងធ្វើការនៅទីក្រុងបាងកក ដោយពួកគាត់ត្រូវចំណាយសារហុយថ្លៃឡានក្នុងម្នាក់ ២៥០០បាត អោយមេខ្យល់។

បច្ចុប្បន្នជនជាតិថៃជាអ្នកបើករថយន្តដឹកពលរដ្ឋខ្មែរខាងលត្រូវបានសមត្ថកិច្ចថៃកសាងសំណុំរឿង ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០២០

## ស្ត្រីលក់ផលិតផលអនឡាញត្រូវបានតុលាការចោទប្រកាន់ក្រោមច្បាប់ជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ

https://khmer.voanews.com/ 21 កុម្ភៈ 2020 ទុំ ម្ជិះ

ភ្នំពេញ៖ នៅថ្ងៃសុក្រនេះ ស្ត្រីលក់ផលិតផលលើបណ្ដាញសង្គមម្នាក់ត្រូវបានតុលាការចោទប្រកាន់ក្រោមច្បាប់ជួញដូរមនុស្សនិងធ្វើអាជីវកម្មផ្លូវភេទ បន្ទាប់ពីស្ត្រីរូបនេះបានបង្ហាញផលិតផលដោយស្លៀកពាក់ស៊ិចស៊ីបង្ហាញរាងកាយ។ នាងថៃ ស្រីនាង ម្ចាស់ទំព័រហ្វេសប៊ុកឈ្មោះថៃ ស្រីនាង Onlineshop ដែលតែងតែថតរូបបែបស៊ិចស៊ីជាមួយផលិតផលរបស់ខ្លួន ដូចជាគ្រឿងសម្អាង ឈុតគេងនារីៗ ហើយបង្ហោះលក់លើបណ្ដាញសង្គមរបស់នាងនោះ ត្រូវបានអាជ្ញាធរចាប់ខ្លួនពីរលើកក្នុងសប្ដាហ៍នេះ។

VOA បានទាក់ទងសុំការបកស្រាយពីលោក គុជ គីមឡុង ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញនៅព្រឹកថ្ងៃសុក្រនេះ តែលោកថា លោកនឹងជម្រាបជូនតាមក្រោយនៅពេលដែលមានសេចក្ដីសម្រេចពីតុលាការ។ លោកនិយាយយ៉ាងខ្លីថា៖ «ទៅមើលព័ត៌មានផ្សេងគេប្រាប់ហើយ តើហី»។ នៅពេល VOA សួរថា តើមានសេចក្ដីសម្រេចជាផ្លូវការហើយឬនៅ? លោក បានឆ្លើយថា៖ «អត់ទាន់ទេ ព្រោះអត់ទាន់មានសេចក្ដីសម្រេចរបស់តុលាការ

នៅឡើយទេ»។ សារព័ត៌មានក្នុងស្រុកមួយបានឲ្យដឹងថា នាងថៃ ស្រីនាងត្រូវបានតុលាការក្រុងភ្នំពេញសម្រេចចោទប្រកាន់រួចទៅហើយ។

លោក ខៀវ សុភ័គ អ្នកនាំពាក្យរបស់ក្រសួងមហាផ្ទៃ បានប្រាប់ VOA នៅរសៀលថ្ងៃសុក្រនេះថា៖ «តុលាការបានចោទប្រកាន់ហើយតាមពូដឹង»។ លោកថា លោកក៏កំពុងរង់ចាំដីកាពីតុលាការដូចគ្នា៖ «យើងបញ្ជូនទៅដល់តុលាការហើយក្មួយ! ពូក៏មិនទាន់បន្តទៅទៀតដែរ។ សុំបន្តសួរទៅតុលាការណ៎ា ហើយបើតុលាការបន្តឃុំខ្លួន យើងក៏ឃុំ»។

លោក ជិន ម៉ាលីន អ្នកនាំពាក្យគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាល និងក្រសួងយុត្តិធម៌បានប្រាប់ VOA ថា កញ្ញា ថៃ ស្រីនាង ត្រូវបានតុលាការរកឃើញថា ល្មើសនឹងមាត្រា៤៩នៃក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីអាជីវកម្មផ្លូវភេទ មាត្រា៣៨និងមាត្រា៣៩។ លោកបាននិយាយថា៖ «បាទទង្វើរបស់គាត់មិនមែនជាការអនុវត្តសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ឬសិទ្ធិសេរីភាពរូបកាយទេណ៎ា។ ប៉ុន្តែជាការប្រព្រឹត្តបទល្មើស ដោយការបង្ហាញនូវរូបភាពអាសអាភាស ហើយដែលព្រះរាជអាជ្ញាគាត់បានរកឃើញថា សកម្មភាពហ្នឹងបំពានទៅលើបញ្ញត្តិនៃក្រមព្រហ្មទណ្ឌមាត្រា៤៩និងបញ្ញត្តិច្បាប់ស្តីពីអាជីវកម្មផ្លូវភេទហ្នឹង មាត្រា៣៨ហើយនឹងមាត្រា៣៩ បាទ!»។

នាង ថៃ ស្រីនាង ឬវ៉ែន រចនាត្រូវបានអាជ្ញាធរចាប់ខ្លួនលើកទី១នៅថ្ងៃពុធទី១៨ កុម្ភៈដោយស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដើម្បីធ្វើការណែនាំ និងចុះកិច្ចសន្យាលើករណីដែល នាងបានបង្ហោះរូបភាព«សិចស៊ីជ្រុលហួសហេតុ ដែលធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់ទំនៀមទម្លាប់ប្រពៃណី និងកិត្តិយសរបស់ស្ត្រីខ្មែរ»។ បើយោងតាមគេហទំព័ររបស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។ មួយថ្ងៃបន្ទាប់ កញ្ញាថៃ ស្រីនាងត្រូវបានសមត្ថកិច្ចចាប់ខ្លួនម្តង និងត្រូវបានបញ្ជូនទៅតុលាការដើម្បីបន្តនីតិវិធី ក្រោយពីនាងនៅតែបន្តបង្ហោះរូបភាពនិងសម្ភារៈ«អាសអាភាស»។ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញឲ្យដឹងថា ជនសង្ស័យឈ្មោះថៃ ស្រីនាងត្រូវចាប់ខ្លួន និងបញ្ជូនទៅតុលាការ នៅវេលាម៉ោង៣:៣០នាទី ថ្ងៃទី២០ ខែកុម្ភៈ ដើម្បីបន្តនីតិវិធី។ ការចាប់ខ្លួននេះបានកើតមានឡើងតែប៉ុន្មានថ្ងៃក្រោយការព្រមានរបស់លោកនាយករដ្ឋមន្ត្រីហ៊ុន សែនថា នឹងចាត់វិធានការចំពោះស្ត្រីរូបណាដែលផ្សព្វផ្សាយលក់ផលិតផលលើកសម្ពស្ស ដោយមានការស្លៀកពាក់បែប«ស៊ិចស៊ីជ្រុល»នៅតាមគេហទំព័រ ឬបណ្តាញសង្គមហ្វេសប៊ុក។

អ្នកស្រីជឹម ចាន់នី អគ្គលេខាធិការរងរបស់គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីអនុសញ្ញា CEDAW និយាយថា អ្នកស្រីមិនគាំទ្រចំណាត់ការរបស់រដ្ឋាភិបាលមួយនេះឡើយ ដែលអ្នកស្រីថា វាជាចំណាត់ការបែប«ការពារ»ដែលវានឹងប៉ះពាល់ដល់ស្ត្រីផ្សេងទៀតទូទៅ។ អ្នកស្រីបាននិយាយប្រាប់វីអូអេថា៖ «ព្រោះបើសិនជាយើងដាក់ចេញគោលការណ៍អ៊ីចឹងមួយមកបានន័យថា គោលការណ៍ហ្នឹងវាជាស្តង់ដាររបស់បុរស។ អ៊ីចឹងបានន័យថា កំហុសនៅស្ត្រីស្លៀកពាក់។ ឃើញស្ត្រីស្លៀកពាក់ស៊ិចស៊ីធ្វើឲ្យបុរសហ្នឹងមានចំណង់។ អ៊ីចឹងដើម្បីតម្រូវចិត្តបុរស ដើម្បីធ្វើម៉េចកុំឲ្យបុរសហ្នឹងមានចំណង់ កុំឲ្យទៅចាប់គេ ទៅជាឃាត់ស្ត្រីវិញ»។ អ្នកស្រីបានបន្តថា ជាជាងប្រើវិធានការនេះ រដ្ឋាភិបាលកម្ពុជាគួរតែមានវិធានការកែតម្រូវដូចជាពង្រឹងការអនុវត្តច្បាប់ និងកម្មវិធីអប់រំ បណ្តុះបណ្តាលទាក់ទិននឹងការគោរពសិទ្ធិមនុស្សចំពោះស្ត្រីជាដើម៕

## ៤ចំណុចសំខាន់ៗ ដើម្បីជម្រុញដល់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឱ្យកាន់តែមានប្រសិទ្ធភាព

https://grandnewsasia.com/ 24-02-2020

ស្វាយរៀង៖ នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០នេះ នៅសាលប្រជុំអាគារ «ឃ» សាលាខេត្ត លោកស្រី ឯក សុវណ្ណការៈ អភិបាលរងខេត្តស្វាយរៀង តំណាងលោក ម៉ែន វិបុល អភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្តឆ្នាំ២០២០។

នៅក្នុងកិច្ចប្រជុំនោះក៏មានការចូលរួមពីប្រធាន អនុប្រធាន និងសមាជិក លេខាធិការដ្ឋានខេត្ត ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោក លោកស្រី នាយករងរដ្ឋបាលសាលាខេត្ត កងកម្លាំងទាំងបី តំណាងអយ្យការអមសាលាដំបូងខេត្ត នាយកទីចាត់ការ/អង្គភាពទាំង៨ ចំណុះសាលាខេត្ត អភិបាល-អភិបាលរងក្រុង ស្រុកទាំង០៨ អធិការនគរបាលក្រុង ស្រុកទាំង០៨ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ទាំង៨០ លោកមេឃុំ ចៅសង្កាត់ លោក លោកស្រីតំណាងអង្គការដៃគូរជាច្រើនរូបទៀតសរុបវត្តមានចំនួន២៤៣នាក់។

មានប្រសាសន៍នៅក្នុងកិច្ចប្រជុំនេះ លោកស្រីអភិបាលរងខេត្ត បានលើកឡើងនូវចំណុចសំខាន់ៗ ដែលជម្រុញដល់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផ្តល់នូវមតិណែនាំបន្ថែមទៅកាន់កិច្ចប្រជុំនេះដូចជា៖
១. អាជ្ញាធរពាក់ព័ន្ធទាំងអស់ត្រូវបន្តពិនិត្យមើលទៅលើយន្តការ នៃរចនាសម្ព័ន្ធគ្រប់ថ្នាក់ទៅលើប្រព័ន្ធ នីតិវីធីនៃការអនុវត្តគោលនយោបាយប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ត្រូវមានផែនការសកម្មភាព ស្របតាមបរិបទសង្គមនៅតាមមូលដ្ឋាន។

២. ត្រូវប្រើគ្រប់មធ្យាបាយសរុប កម្លាំងសរុប វិធានការសរុប ដែលជំរុញឱ្យផែនការសកម្មភាពអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។

៣. ត្រូវបន្តជំរុញការគាំទ្រគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដឹកនាំប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រោះថាអំពើនេះ គឺជាការគំរាមកំហែងដោយផ្ទាល់ទៅលើវប្បធម៌ និងប្រពៃណីគ្រួសារតម្លៃសង្គមនៅកម្ពុជា។

៤. ត្រូវបន្តពង្រឹង គោលនយោបាយ ភូមិឃុំមានសុវត្ថិភាព និងត្រូវអនុវត្តជាប្រចាំបន្ថែមទៀត ដើម្បីតាមដាននូវ សកម្មភាពបទល្មើសជួញដូរមនុស្ស និងត្រូវដាក់ផែនការតាមដានគ្រប់ ក្រុង ស្រុក និងតាមច្រកទ្វាព្រំដែននានាជាប់ប្រទេសជិតខាង ក្នុងការទប់ស្កាត់ ការបង្ក្រាបឱ្យមានប្រសិទ្ធភាពខ្ពស់៕

## ពលករធ្វើការនៅក្រៅប្រទេសផ្ញើប្រាក់ជិត $៣ ពាន់លាន មកផ្ទះក្នុង ១ ឆ្នាំៗ

https://www.postkhmer.com/ ជួ វីរៈ | Publication date 24 February 2020 | 10:59 ICT

**ភ្នំពេញ:** ពលករកម្ពុជាបម្រើការងារនៅក្រៅប្រទេសទាំងអស់បានផ្ញើប្រាក់មកស្រុកកំណើតជិត ៣ ពាន់លានដុល្លារ ក្នុង ១ ឆ្នាំៗ ដែលប្រាក់បញ្ញើទាំងនេះបានជួយឲ្យជីវភាពគ្រួសាររបស់ពួកគេធូរជារជាងមុន។ នេះបើតាមរបាយការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ របាយការណ៍បានបង្ហាញថា ពលករកម្ពុជាបម្រើការងារនៅបរទេសបានផ្ញើប្រាក់មកឲ្យក្រុមគ្រួសារនៅស្រុកកំណើតប្រមាណ ២,៨០ ពាន់លានដុល្លារក្នុង ១ ឆ្នាំៗ។ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានថ្លែងក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៩ និងលើកទិសដៅការងារឆ្នាំ ២០២០ កាលពីសប្តាហ៍មុនថា ដើម្បីរក្សា និងបង្កើតមុខរបរនៅក្នុង និងក្រៅប្រទេសក្រសួងបានបន្តខិតខំគ្រប់គ្រងទីផ្សារការងារ និងកម្លាំងពលកម្មសរុបប្រមាណ ១០ លាននាក់។

ក្នុងនោះពលករកម្ពុជានៅក្រៅប្រទេសមានជាង ១,២៨ លាននាក់។ លោកបានបន្តថា៖ «កត្តានេះបានធ្វើឲ្យប្រជាពលរដ្ឋមានការងារធ្វើ ៩៩,៣ ភាគរយ»។

លោក ស្រ៊ុន ជារាជ្យ ពលករខ្មែរ ១ រូបកំពុងបម្រើការងារនៅប្រទេសជប៉ុនក្នុងរោងចក្រឧស្សាហកម្មបានប្រាប់ភ្នំពេញ-ប៉ុស្តិ៍កាលពីថ្ងៃអាទិត្យថា លោកបានផ្ញើប្រាក់មកឲ្យឪពុកម្ដាយជាមធ្យម ៥០០ ដុល្លារក្នុង ១ ខែ ដើម្បីជួយសម្រួលជីវភាពគ្រួសាររបស់លោកដែលរស់នៅខេត្តស្ទឹងត្រែង។ លោកបន្តថា បច្ចុប្បន្នឪពុកម្ដាយរបស់លោកកំពុងប្រកបរបរដាំដំណាំកសិកម្ម។ យុវជនវ័យ ៣២ ឆ្នាំរូបនេះប្រាប់ទៀតថា លោកបម្រើការងារនៅជប៉ុនអស់រយៈពេលជាង ២ ឆ្នាំមកហើយ ដោយទទួលបានប្រាក់ខែប្រមាណ ១ ៣០០ ដុល្លារ ១ ខែ។ លោកបានបន្តថា៖ «ចាប់តាំងពីមកធ្វើការនៅប្រទេស ជប៉ុនកាលពីឆ្នាំ ២០១៨ គ្រួសារខ្ញុំមានជីវភាពល្អជាងមុន ដោយខ្ញុំមានលទ្ធភាពពង្រីកផ្ទះបានធំជាងមុន។ ខ្ញុំគិតថាប្រទេសជប៉ុនបានផ្ដល់ជំនាញវិជ្ជាជីវៈឲ្យខ្ញុំ ហើយខ្ញុំសង្ឃឹមថា ខ្ញុំនឹងយកចំណេះនេះមកបន្តការងារនៅស្រុកកំណើតនៅពេលចប់អាណត្តិនៅប្រទេសជប៉ុន»។

របាយការណ៍ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានឲ្យដឹងថា ក្នុងចំណោមពលករទាំងនោះក្រសួងបានបញ្ជូនទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារឯកជន និងតាមរយៈរដ្ឋសរុប ៦៨ ០៤០ នាក់កាលពីឆ្នាំ ២០១៩ រួមមានប្រទេសថៃ កូរ៉េ ជប៉ុន សិង្ហបុរី ម៉ាឡេស៊ី ហុងកុង និងអារ៉ាប៊ីសាអ៊ូឌីត។

លោក អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិធនាគារអេស៊ីលីដាបានឲ្យដឹងថា ពលករកូរ៉េខាងត្បូងភាគច្រើនផ្ញើប្រាក់មកស្រុកកំណើតតាមរយៈធនាគារអេស៊ីលីដា។ លោកបន្ថែមថា ការផ្ញើប្រាក់មកស្រុកកំណើតរបស់ពលករខ្មែរទៅធ្វើការក្រៅប្រទេសបានជួយដល់ការពង្រីកការធ្វើអាជីវកម្មរបស់ពួកគេ។ លោកថ្លែងថា៖ «ខ្ញុំឃើញថា ក្រុមគ្រួសារគាត់នៅឯស្រុកកំណើតភាគច្រើនបានយកប្រាក់ពីកូនៗផ្ញើមកពីក្រៅប្រទេស ដើម្បីមកបង្កើត និងពង្រីកមុខរបរខ្នាតតូច និងមធ្យមរបស់ពួកគេ»។

លោក ហុង វណ្ណៈ អ្នកស្រាវជ្រាវសេដ្ឋកិច្ចនៃរាជបណ្ឌិត្យសភាកម្ពុជាបាននិយាយថា ពលករខ្មែរនៅក្រៅប្រទេសភាគច្រើនបានទទួលបានចំណេះដឹង និងជំនាញវិជ្ជាជីវៈច្បាស់លាស់នៅពេលត្រឡប់មកស្រុកកំណើតវិញ។ លោកបន្តថា៖«ពលករខ្មែរភាគច្រើននៅកូរ៉េខាងត្បូង និងប្រទេសជប៉ុន ទទួលបានប្រាក់ខែល្អជាងគេ។ ខ្ញុំសង្កេតឃើញថា ប្រាក់របស់ពួកគេផ្ញើមកស្រុក ដើម្បីធ្វើផ្ទះថ្មីឬកែលម្អផ្ទះ បង្កើតមុខរបរ ពិសេសពង្រីកការដាំដុះជាដើម។

ទោះបីយ៉ាងនេះក្ដី បើយោងតាមរបាយការណ៍ធនាគារជាតិនៃកម្ពុជាកាលពីឆ្នាំ ២០១៨ ពលករខ្មែរបានផ្ញើប្រាក់មកអ្នកផ្ទះប្រមាណ ១,៤ ពាន់ដុល្លារ ក្នុងនោះការផ្ញើប្រាក់ត្រឡប់មកផ្ទះវិញរបស់ពលករនៅកូរ៉េមានជាង ៥៣ លានដុល្លារ ដែលជាចំណែកធំជាងគេ៕LA

## ថៃចាប់ពលករខ្មែរ5នាក់ចោទឆ្លងដែនខុសច្បាប់ មន្ត្រីបដិសេធថាមិនដឹង

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២០ ម៉ោង ២០:៣០ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរចំនួន៥នាក់ បានត្រូវសមត្ថកិច្ចថៃចាប់ខ្លួនកាលពីល្ងាចថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ នៅលើទឹកដីថៃក្នុងភូមិអាងសិលា ឃុំណូនម៉ាក់មុន ស្រុកគោកធ្យូង ខេត្តស្រះកែវ ឈមនឹងទឹកដីកម្ពុជា ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខណៈពួកគេកំពុងជិះរថយន្ត១គ្រឿងរបស់ជនជាតិថៃប្រុងទៅរកការងារធ្វើ ។ នេះបើតាមប្រភពមួយពីទឹកដីថៃបានទម្លាយឱ្យដឹង ។

ប្រភពខាងលើបានប្រាប់ថា ពលករទាំង៥នាក់(ប្រុស៤នាក់ស្រីម្នាក់) មានទីលំនៅក្នុងស្រុក មង្គលបុរី ខេត្តបន្ទាយមានជ័យ ។ យោងតាមការសាកសួរ ពលករទាំងនេះប្រាប់សមត្ថកិច្ចថៃថា ពួកគេចេញពីកម្ពុជាតាមច្រករបៀងមួយក្នុងស្រុកអូរជ្រៅ ប្រុងទៅរកការងារធ្វើលើទឹកដីថៃ តែខណៈកំពុងជិះរថយន្តរបស់ជនជាតិថៃ១ គ្រឿង

ដល់ចំណុចប៉ុស្តិ៍ត្រួតពិនិត្យមួយនៅបន្ទាត់ព្រំដែនក្នុងភូមិ ឃុំខាងលើ ក៏ត្រូវសមត្ថកិច្ចថៃចាប់ឃាត់ខ្លួនតែម្តង ។ ក្រៅពីពលករខ្មែរទាំង៥នាក់ បុរសជាអ្នកបើកបរជនជាតិថៃអាយុ៣៣ឆ្នាំ រួមជាមួយរថយន្ត១គ្រឿង ក៏ត្រូវសមត្ថកិច្ចថៃឃាត់ខ្លួននិងរឹបអូសដែរដើម្បីបន្តនីតិវិធី ។

ប្រភពព័ត៌មានថា ពលករខ្មែរទាំ៥នាក់ត្រូវបានគេបញ្ជូនទៅសាកសួរនៅស្ថានីយតម្រួតក្នុង ស្រុកខាងលើ ។ ជុំវិញករណីនេះ លោកឧត្តមសេនីយ៍ត្រី យួន ជឿន មេបញ្ជាការយោធាកង ការពារព្រំដែនគោកលេខ៥០៣ បានធ្វើការបដិសេធថា ពុំមានករណីខាងលើកើតឡើងនៅចំណុចភូមិសាស្រ្តលោកគ្រប់គ្រងឡើយ ។

ចំណែកមន្រ្តីការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃមួយរូបប្រចាំនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែតក៏បានបដិសេធដែរថា មិនបានដឹងរឿងនេះដូចគ្នា ខណៈអគ្គកុងស៊ុលខ្មែរប្រចាំស្រុក អារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ មិនអាចទាក់ទងសុំការអត្ថាធិប្បាយបាន ព្រោះមិនស្គាល់លេខទូរស័ព្ទ។

មន្រ្តីនគរបាលការិយាល័យប្រឆាំងកាជួញដូរមនុស្ស និងការពារអនីតិជនខេត្តមួយរូប បម្រើការងារនៅទីតាំងទទួលពលករបញ្ជូនពីថៃនៅក្រុងប៉ោយប៉ែត ប្រាប់តាមទូរស័ព្ទថា ពលករទាំង៥នាក់ខាងលើមិនទាន់ឃើញភាគីថៃបញ្ជូនត្រឡប់នៅឡើយទេ ។ ពួកគេអាចប្រឈមនឹង ផ្លូវច្បាប់ប្រទេសគេ៤៩ថ្ងៃ ឬយ៉ាងតិច៧ថ្ងៃ ទើបគេបញ្ជូនត្រឡប់ ប្រសិនបើជាប់ចោទឆ្លងដែនខុសច្បាប់មែននោះ ។

បើពិតដូចប្រភពខាងលើមែន គេពុំដឹងថាវាសនាពលករទាំង៥នាក់បានវិលមកកម្ពុជាវិញ ឆាប់ៗនេះ ឬត្រូវទទួលទោសរបស់ប្រទេសថៃប៉ុន្មានខែនោះទេ ។ បញ្ហានេះ មន្រ្តីនិងសមត្ថកិច្ចពាក់ព័ន្ធគួរតែបើកការស៊ើបអង្កេតរកអ្នកនៅពីក្រោយខ្នងនៃការនាំមនុស្សឆ្លងដែនខុសច្បាប់យកមកផ្តន្ទាទោសផង ៕ (កែសម្រួលដោយ ៖ បុប្ផា)

## ចាញ់បោកមេខ្យល់ ! ពេលនេះភាគីថៃដោះលែងពលករខ្មែរ៥នាក់វិញហើយ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០២០ ម៉ោង ១៣:៤០ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ សេចក្តីរាយការណ៍បមបបានឲ្យដឹងថា ពលករខ្មែរដែលសមត្ថកិច្ចថៃចាប់ខ្លួនចោទឆ្លងដែនខុសច្បាប់ កាលពីល្ងាចថ្ងៃទី១៩ កុម្ភៈ ២០២០ នៅស្រុកគោកធ្យូង ខេត្តស្រះកែវ ប្រទេសថៃ ត្រូវបានដោះលែងវិញហើយៗ ពួកគេបានមកដល់កម្ពុជា កាលពីវេលាម៉ោងជាង៩យប់ ថ្ងៃទី២១ដោយភាគីថៃដឹកតាមរថយន្តទ្រុង តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ។

សេចក្តីរាយការណ៍បានបន្តថា ពលករទាំងនេះ សមត្ថកិច្ចអះអាងថា ស្គាល់អត្តសញ្ញាណតែ៤នាក់ទេ រួមមាន ១-ឈ្មោះ សាយ ចាន់ថន ភេទប្រុស អាយុ២៧ឆ្នាំ ២-ឈ្មោះ វុន ចាន់ធី ភេទស្រី អាយុ២៥ឆ្នាំទាំង២នាក់ ខាងលើរស់នៅភូមិចំណោមឃុំរៀងកើត ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ៣- ឈ្មោះថៃ សុខា ភេទប្រុស អាយុ៣៤ឆ្នាំ រស់នៅភូមិ និងឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ៤-ឈ្មោះចាន់ សុមាន ភេទប្រុស អាយុ៦០ឆ្នាំ រស់នៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ និងម្នាក់ទៀតមិនស្គាល់អត្តសញ្ញាណ ព្រោះក្រោយចុះពីរថយន្តទ្រុងរបស់ថៃ នៅទីតាំងទទួលពលករក្នុងក្រុងប៉ោយប៉ែតពលកររូបនេះកុហកថា សុំចូលបន្ទប់ទឹករួចគេចទៅបាត់ ។

យោងការសាកសួរពលករ៤នាក់ខាងលើប្រាប់ថា ពួកគេចេញពីកម្ពុជាតាមច្រករបៀងមួយក្នុងឃុំអូរបីជាន់ ស្រុកអូរជ្រៅ តាមរយៈមេខ្យល់ តែមិនស្គាល់ឈ្មោះ ។ ពួកគេបន្តថា ក្នុងការធ្វើដំណើរចូលទៅរកការងារធ្វើលើដីថៃត្រូវចំណាយម្នាក់ៗ២០០០បាត តែមិនទាន់ឲ្យប្រាក់គេទេ ព្រោះមិនទាន់ដល់គោលដៅក៏ត្រូវគេចាប់តែម្តង ។ យ៉ាងណាក៏ដោយ ពលករទាំង៤នាក់ ក្រោយទទួលការអប់រំពីសមត្ថកិច្ចជំនាញក៏អនុញ្ញាតឲ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញរៀងខ្លួនៗ ៕

## ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០២០

## កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្តឆ្នាំ២០២០

https://gdlf-kh.com/ 2020/02/25 Kao sophy ខេត្តស្វាយរៀង

ខេត្តស្វាយរៀង៖ នាព្រឹកថ្ងៃចន្ទ ២កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០នេះ នៅសាលប្រជុំអាគារ"ឃ"សាលាខេត្ត លោកជំទាវ ឯក សុវណ្ណភារៈ អភិបាលរងខេត្តស្វាយរៀង តំណាងឯកឧត្តម ម៉ែន វិបុល អភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្តឆ្នាំ២០២០ ។

អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមានលោក លោកស្រី ប្រធាន អនុប្រធាន និងសមាជិក លេខាធិការដ្ឋានខេត្ត ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោក លោកស្រី នាយករងរដ្ឋបាលសាលាខេត្ត លោក លោកស្រី កងកម្លាំងទាំងបី តំណាងអយ្យការអមសាលាដំបូងខេត្ត លោក លោកស្រី នាយកទីចាត់ការ/អង្គភាពទាំង៨ ចំណុះសាលាខេត្ត លោក លោកស្រីអភិបាល-អភិបាលរងក្រុង ស្រុកទាំង០៨ លោកអធិការនគរបាលក្រុង ស្រុកទាំង០៨ លោលនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ទាំង៨០ លោកមេឃុំ ចៅសង្កាត់ លោក លោកស្រីតំណាងអង្គការដៃគូរជាច្រើនរូបទៀតសរុបវត្តមានចំនួន ២៤៣នាក់។ មានប្រសាសន៍នៅក្នុងកិច្ចប្រជុំនេះ លោកជំទាវអភិបាលរងខេត្ត បានលើកឡើងពីចំណុចសំខាន់ៗ ដែលជម្រុញដល់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផ្តល់នូវមតិណែនាំបន្ថែម ទៅកាន់កិច្ចប្រជុំនេះដូចជា៖

១. អាជ្ញាធរពាក់ព័ន្ធទាំងអស់ត្រូវបន្តពិនិត្យមើលទៅលើយន្តការ នៃរចនាសម្ព័ន្ធគ្រប់ថ្នាក់ទៅលើប្រព័ន្ធ នីតិវិធីនៃការអនុវត្តគោលនយោបាយប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ត្រូវមានផែនការសកម្មភាព ស្របតាមបរិបទសង្គមនៅតាមមូលដ្ឋាន។

២.ត្រូវប្រើគ្រប់មធ្យោបាយសរុប កម្លាំងសរុប វិធានការសរុប ដែលជំរុញឱ្យផែនការសកម្មភាពអនុវត្តការងារនេះ ឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។

៣.ត្រូវបន្តជំរុញការគាំទ្រគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដឹកនាំប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រោះថាអំពើនេះ គឺជាការគំរាមកំហែង ដោយផ្ទាល់ទៅលើវប្បធម៌ និងប្រពៃណី គ្រួសារ តម្លៃសង្គមនៅកម្ពុជា។

៤.ត្រូវបន្តពង្រឹង គោលនយោបាយ ភូមិឃុំមានសុវត្ថិភាព និងត្រូវអនុវត្តជាប្រចាំបន្ថែមទៀត ដើម្បីតាមដាននូវ សកម្មភាពបទល្មើសជួញដូរមនុស្ស និងត្រូវដាក់ផែនការតាមដានគ្រប់ ក្រុង ស្រុក និងតាមច្រកទ្វាព្រំដែននានាជាប់ប្រទេសជិតខាង ក្នុងការទប់ស្កាត់ ការបង្ក្រាបឱ្យមានប្រសិទ្ធភាពខ្ពស់៕

## បុរសខ្មែរម្នាក់ និងស្ត្រីថៃម្នាក់ ត្រូវបានឃាត់ខ្លួននៅក្នុងប្រទេសថៃ ពីបទជួញដូរកុមារ និងធ្វើពលកម្មលើកុមារ

https://khmerpress.news/ cily sok February 24, 2020 at 3:59 pm

បុរសខ្មែរម្នាក់ និងស្ត្រីថៃម្នាក់ ត្រូវបានឃាត់ខ្លួន ខណៈអនីតិជនចំនួន ១៧នាក់ ដែលត្រូវបានគេជឿជាក់ថាជាជនជាតិខ្មែរ និងវៀតណាមត្រូវបានគេជួយសង្គ្រោះ នៅក្នុងការវាយឆ្មក់ប្រឆាំងការជួញដូរមនុស្ស ដែលធ្វើឡើងនៅទីតាំងចំនួន ៤ ក្នុងតំបន់ផាតុង (Patong) នៃស្រុកក្រធូ (Krathu) កាលពីថ្ងៃអាទិត្យ។ បុរសនោះឈ្មោះថា ង៉ូ ស៊ុន (Ngo Sun) អាយុ ៣៣ឆ្នាំ ជាជនជាតិខ្មែរ និងឈ្មោះ ស៊ូផាតត្រា ចារឹនស៊ុក អាយុ ២២ឆ្នាំ ជាជនជាតិថៃ ត្រូវ

បានចោទប្រកាន់ពីបទជួញដូរមនុស្ស និងធ្វើពលកម្មលើកុមារដោយបង្ខំ។ ប្រភពបាននិយាយថា អនីតិជនត្រូវបានគេនាំយកទៅភូកេត ហើយអាជ្ញាធរនឹងត្រួតពិនិត្យពួកគេ ដើម្បីកំណត់ថាតើអ្នកណាដែលបានស្ម័គ្រចិត្តធ្វើចំណាកស្រុកខុសច្បាប់ និងអ្នកដែលត្រូវបានគេជួញដូរចូលមក។

លោកវរសេនីយ៍ទោ Jaruwat Waisaya ជំនួយការអគ្គស្នងការនគរបាលជាតិបានមានប្រសាសន៍ថា ការវាយឆ្មក់នេះបានកើតឡើង បន្ទាប់ពីជនរងគ្រោះ បានរត់គេចខ្លួនទៅកាន់ទីក្រុងបាងកកកាលពីប៉ុន្មានខែមុន ហើយបានស្វែងរកជំនួយពីអង្គភាពប្រឆាំងការជួញដូរមនុស្ស។ យោងតាមសម្តីរបស់ឧត្តមសេនីយ៍ឯក Jaruwat ជនរងគ្រោះខ្លះត្រូវបានបង្ខំឱ្យធ្វើពលកម្មនៅភូកេត ខណៈដែលមួយចំនួនទៀតបានធ្វើការដោយស្ម័គ្រចិត្តជាមួយក្រុមក្មេងទំនើងជួញដូរមនុស្ស ដែលមានគ្នាយ៉ាងតិចចំនួន ៤នាក់ ដែលបានបញ្ជាពួកគេឱ្យដើរសុំលុយពីភ្ញៀវទេសចរ ឬលក់វ៉ែនតា ឬភួងផ្កានៅតាមផ្លូវ។ លោកនិយាយថា៖ «ក្មេងៗទាំងនេះ ដែលខ្លះមានអាយុតិចជាង ១៥ឆ្នាំ ត្រូវបានបង្ខំឱ្យធ្វើការតាំងពីពេលថ្ងៃត្រង់រហូតដល់ពាក់កណ្តាលអធ្រាត្រ ជារាល់ថ្ងៃ ដោយគ្មានថ្ងៃឈប់សម្រាកទេ»។ លោកបន្តថា៖ «ពួកគេមួយចំនួនមិនបានទទួលប្រាក់ឈ្នួលទាល់តែសោះ ហើយអ្វីទាំងអស់ដែលពួកគេទទួលបានគឺអាហារ និងកន្លែងសម្រាប់គេងនៅក្នុងផ្ទះជួល។ អ្នកដែលខកខានមិនអាចរកប្រាក់បានចំនួន ៣,០០០បាត/ក្នុងមួយថ្ងៃ ត្រូវបានគេវាយដំ ឬវាយនឹងស្ទូខោអាវ»។

យោងតាមអ្នកស៊ើបអង្កេតឱ្យដឹងថា ឪពុកម្តាយរបស់កុមារបានទទួលលុយដោយពួកឈ្មួញ ដែលពួកនោះ «បានទិញសិទ្ធិ» ដើម្បីជួលកុមារធ្វើជាអ្នករែកលក់អីវ៉ាន់នៅភូកេត។ មនុស្សជាច្រើនត្រូវបានគេប្រាប់ថា កូនៗរបស់ពួកគេនឹងមានការងារងាយស្រួលនៅក្នុងប្រទេសថៃ ដែលត្រូវចំណាយប្រហែល ៥,០០០បាត/ខែ។ ប៉ូលីសបាននិយាយថា ក្រុមអ្នកជួញដូរទាំងនេះបាននាំកុមារទាំងនោះចូលទៅក្នុងប្រទេសថៃ តាមច្រកព្រំដែនដែលមិនមានឈ្មោះច្បាស់លាស់៕ ប្រភព៖ Khmer Note

## ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០២០

## កិច្ចប្រជុំរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://www.facebook.com/deputygovernoryousophear/ 25-02-2020

នៅថ្ងៃទី២៥ខែកុម្ភៈឆ្នាំ២០២០ លេខាធិការដ្ឋាននៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (គ.ខ.ប.ជ សរ)បានរៀបចំប្រជុំរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការខេត្តបរយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ប្រចាំខែកុម្ភៈឆ្នាំ២០២០ក្រោមកិច្ចដឹកនាំប្រជុំពីសំណាក់ លោកស្រី យូ សុភា អភិបាលរងខេត្តនិងជាប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ ខេត្តសៀមរាប និងមានការអញ្ជើញចូលរួមពីលោក លោកស្រី សមាជិក សមាជិកាលេខាធិការដ្ឋាន គ.ខ.ប.ជ និងក្រុមការងារបច្ចេកទេសទាំង៦(ក្រុមការងារទប់ស្កាត់ ក្រុមការងារអនុវត្តន៍ច្បាប់ ក្រុមការងារការពារជនរងគ្រោះ ក្រុមការងារកិច្ចការយុត្តិធម៌ ក្រុមការងារកិច្ចការអន្តប្រវេសន៍ និង ការងារពង្រឹងកិច្ចសហប្រតិបត្តិការ ) តំណាងអង្គការ ដៃគូពាក់ព័ន្ធសរុបប្រមាណ ៥៦នាក់។

អង្គប្រជុំបានពិនិត្យទៅលើកំណត់ហេតុ និងបញ្ហាដែលនៅសេសសល់កាលពីកិច្ចប្រជុំប្រចាំឆ្នាំ២០១៩ និងពិនិត្យលើរបាយការណ៍និងបញ្ហាប្រឈមរបស់ក្រុមការងារទាំង៦ប្រចាំខែមករានិងខែកុម្ភៈឆ្នាំ២០២០ ព្រមទាំងបានពិនិត្យនិងពិភាក្សាលើការរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំ ឆ្នាំ២០១៩ និងលើកទិសដៅអនុវត្តឆ្នាំ២០២០ និងការរៀបចំកិច្ចប្រជុំយុត្តិធម៌ព្រហ្មទណ្ឌ និងយុត្តិធម៌អនីតិជន។ ក្នុងរបាយការណ៍របស់លេខាធិការដ្ឋាននៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (គ.ខ.ប.ជ សរ)បានបង្ហាញអំពីស្ថានភាពទូទៅក្នុងខេត្តសៀមរាប ពាក់ព័ន្ធទៅនឹងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការរត់ពន្ធមនុស្សនិងការជួញដូរមនុស្សឆ្លង

ដែននៅតែមានភាពស្មុគ្រស្មាញ បត់បែន និងជ្រកក្រោមរូបភាពស្របច្បាប់ផ្សេងៗដែលជនល្មើសអាចប្រើប្រាស់ដើម្បីកេងប្រវ័ញ្ចលើប្រជាពលរដ្ឋបានយ៉ាងងាយស្រួលដូចជា ការធ្វើអាជីវកម្មផ្លូវភេទតាមរូបភាពជា សេវាកំសាន្ត ខារ៉ាអូខេ ម៉ាស្សា ធ្វើការងារតាមហាងបៀរហ្គាដិន រូបភាពភ្ជាប់ពាក្យឬអាពាហ៍ពិពាហ៍ នាំស្រីចេញទៅក្រៅប្រទេសតាមទិដ្ឋាការទេសចរតែក្នុងគោលដៅរកគូរស្រករឬលក់កម្លាំងពលកម្ម កេងប្រវ័ញ្ចផ្លូវភេទឬសុំទាន ជាដើម។

លោកស្រីយូ សុភា អភិបាលរងខេត្តនិងជាប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ ខេត្ត បានលើកឡើងពីចំណុចខ្លាំងនិងចំណុចខ្សោយជាច្រើនដែលក្រុមការងារបានអនុវត្តក្នុងរយៈពេលកន្លងមក ព្រមទាំងបានកំណត់ទិសដៅសម្រាប់អនុវត្តបន្តផងដែរ។លោកស្រីអភិបាលរងខេត្តមានប្រសាសន៍ថា៖ អាជ្ញាធរខេត្តដោយមាន លេខាធិការដ្ឋាន គ.ខ.ប.ជ ជាសេនាធិការ បានបំពេញតួនាទី ជាយន្តការថ្នាក់ខេត្ត ដើម្បីប្រឆាំងនឹងបង្ក្រាបនូវអំពើជួញដូរមនុស្សនៅក្នុងខេត្ត ដោយទទួលបានកិច្ចសហការល្អជាមួយអង្គការដៃគូ ក្នុងការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់និងអ្នកពាក់ព័ន្ធ ក្នុងការជួយអប់រំផ្សព្វផ្សាយតាមគ្រប់រូបភាពដល់ប្រជាពលរដ្ឋអំពីលិខិតបទដ្ឋានគតិយុត្តិ ឧបាយកលជនល្មើសការចំណាកស្រុកដោយសុវត្ថិភាព កិច្ចការពារជនរងគ្រោះ ព្រមទាំងផ្សព្វផ្សាយពីគោលនយោបាយភូមិឃុំមានសុវត្ថិភាព ជូនដល់ប្រជាពលរដ្ឋ និងសកម្មភាពចេញអនុវត្តច្បាប់របស់កម្លាំងសមត្ថកិច្ចក្នុងការបង្ក្រាបបទល្មើសពាក់ព័ន្ធទៅនឹងអំពើជួញដូរមនុស្ស ការជួយដល់ជនរងគ្រោះ និងការផ្តន្ទាទោសជនល្មើស មានភាពល្អប្រសើរនិងមានកិច្ចសហការល្អ ។ លោកស្រីបន្តថា៖យ៉ាងណាក្តីយើងនៅមានចំណុចសេសសល់និងបញ្ហាមួយចំនួនដែលត្រូវយកចិត្តទុកដាក់និងបន្តអនុវត្ត ដូចជា៖ការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋមិនស្របច្បាប់នៅមានច្រើនដដែល ។

មន្ទីរ-អង្គភាព ក្នុងក្រុមការងារមួយចំនួន នៅមានការប្រឈមលើបញ្ហាធនធានមនុស្ស ថវិកា សម្ភារៈ និងមធ្យោបាយសម្រាប់ការអនុវត្តភារៈកិច្ចឱ្យមានប្រសិទ្ធិភាព ។ មន្ទីរ-អង្គភាព ពាក់ព័ន្ធក្រុងស្រុក មួយចំនួន ផ្តល់របាយការណ៍មកក្រុមការងារ មានការយឺតយ៉ាវ មួយចំនួនមិនបានផ្តល់របាយការណ៍មកក្រុម គ.ខ.ប.ជ ខេត្ត។ ជាទិសដៅ យើងនឹងបន្តធ្វើការផ្សព្វផ្សាយ ទប់ស្កាត់ បង្ការ និងបង្ក្រាបឱ្យបានទាន់ពេលវេលា រាល់បទល្មើសដែលកើតឡើង ។បន្តតាមដាន និងត្រួតពិនិត្យ បទល្មើសជួញដូរធ្វើអាជីកម្មផ្លូវភេទ ក្មេងទំនើង អ្នកប្រើប្រាស់គ្រឿងញៀន ដើម្បីឲ្យអាណាព្យាបាលអប់រំបន្ត។ ត្រួតពិនិត្យប្រជាពលរដ្ឋ ធ្វើចំណាកស្រុកទៅធ្វើពលករ និងសហការជាមួយដៃគូ ផ្សព្វផ្សាយអំពីច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ និងការទប់ស្កាត់អំពើជួញដូរមនុស្សតាមរយៈវិទ្យុ និងនៅតាមមូលដ្ឋានផ្ទាល់។បន្ត ចុះជំរុញនិងតាមដានពលកម្មកុមារនៅតាមឡឥដ្ឋ ។ ធ្វើការទំនាក់ទំនងជាមួយអង្គការសង្គមស៊ីវិល ដែលធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងខេត្ត ដើម្បីសហការផ្តល់ព័ត៌មាន និងផ្តល់កន្លែងមានសុវត្ថិភាពជូនជនរងគ្រោះ និងបន្តពិនិត្យតាមដាន និងធ្វើបច្ចុប្បន្នភាពប្រជាពលរដ្ឋចំណាកស្រុក ទាំងក្នុងនិងក្រៅប្រទេសឲ្យបានច្បាស់លាស់ និងបញ្ជូនរបាយការណ៍មកលេខាធិការដ្ឋាន ឲ្យបានទាន់ពេលវេលា។

## កិច្ចជំនួបពិភាក្សាការងាររវាងលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប ជាមួយអង្គការមូលនិធិអេ21

https://www.facebook.com/deputygovernoryousophear/ February 19 at 9:55 PM

នៅថ្ងៃពុធ ទី19 ខែកុម្ភៈ ឆ្នាំ2020 លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួដូរមនុស្សខេត្តសៀមរាប បានទទួលជួបពិភាក្សាការងារ ជាមួយអង្គការមូលនិធិអេ21 នៅរដ្ឋបាលសាលាខេត្ត ដឹកនាំដោយលោកស្រី យូ សុភា អភិបាលរងខេត្តជាប្រធានលេខាធិការដ្ឋាន និងមានការអញ្ជើញចូលរួមពី ក្រុមការងារបច្ចេកទេស រួមមាន ១, ប្រធានក្រុមការងារទប់ស្កាត់ (មន្ទីរអប់រំ) ២, ប្រធានក្រុមការងារកិច្ចការពារជនរងគ្រោះ (មន្ទីរសង្គមកិច្ច) ៣, ប្រធានក្រុមការងារកិច្ចការអនុវត្តច្បាប់ (ស្នងការនគរបាលខេត្ត) ៤,ប្រធានក្រុមការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ (មន្ទីរកិច្ចការនារី) និង៥, ប្រធានក្រុមការងារកិច្ចការទេសន្តប្រវេសន៍ (មន្ទីរការងារ) ផងដែរ។ កិច្ចជំនួប

នេះ បានពិភាក្សាផ្តោតសំខាន់ទៅលើកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូ ក្នុងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ពិសេសជនរងគ្រោះជាកុមារ ។

មានប្រសាសន៍ក្នុងកិច្ចជំនួបខាងលើ លោកស្រីប្រធានលេខាធិការដ្ឋាន បានស្នើសុំឲ្យអង្គការមានកិច្ចសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ពិសេសក្រុមការងាររបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំជួញដូរមនុស្សខេត្ត ដែលមានក្រុមការងារបច្ចេកទេសស្រាប់មកពីមន្ទីរអង្គភាព ជំនាញ។ បន្ថែមពីនោះ លោកស្រីបានស្នើសុំឲ្យមានការចូលរួមសហការពង្រឹងសមត្ថភាពទៅដល់មន្ត្រីនគរបាលយុត្តិធម៌ និងអ្នកពាក់ព័ន្ធដែលជាអ្នកផ្តល់សេវាជួយជនរងគ្រោះ ពិសេសកុមារដែលរងគ្រោះពីការរំលោភបំពាន ឬកុមារជាសាក្សី នៅក្នុងខេត្តសៀមរាប ឲ្យបានកាន់តែល្អប្រសើរឡើងថែមទៀត និងមានប្រសិទ្ធិភាព។

## គ.ខ.ប.ជ ខេត្តសៀមរាប បានចុះអប់រំផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ

https://www.facebook.com/deputygovernoryousophear/ February 18 at 10:11 AM

ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ក្រុមការងារបង្ការទប់ស្កាត់ ដឹកនាំដោយមន្ទីរអប់រំយុវជន និងកីឡាខេត្ត នៃលេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពីជួញដូរមនុស្ស ខេត្តសៀមរាប បានចុះអប់រំផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវលើកុមារនៅតាមសហគមន៍ ដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅវិទ្យាល័យបន្ទាយស្រី ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ ការអប់រំផ្សព្វផ្សាយនេះ រៀបចំឡើង ដើម្បីលោក អ្នកគ្រូ និងសិស្សានុសិស្ស បានយល់ដឹងអំពីរូបភាព និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការរំលោភបំពានផ្លូវភេទលើកុមារ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។

# ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២០

## អ្នកនាំពាក្យ ហេង សួរ៖ គិតត្រឹមឆ្នាំ២០១៩ ពលករខ្មែរនៅក្រៅប្រទេសមានជាង១.២៨លាននាក់ បានផ្ញើប្រាក់មកកម្ពុជាជិត២,៨០០លានដុល្លារ ក្នុងមួយឆ្នាំ

https://grandnewsasia.com/ 27-02-2020

លោក ហេង សួរ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០នេះ បានឲ្យដឹងថា គិតត្រឹមឆ្នាំ២០១៩នេះ ពលករខ្មែរដែលកំពុងធ្វើការនៅក្រៅប្រទេសមាន ចំនួន១,២៨៨,០០០នាក់។ ក្នុងចំណោមពលករទាំងអស់ភាគច្រើន គឺបម្រើការងារនៅប្រទេសថៃ។

ក្នុងសន្និសីទសារព័ត៌មានស្តីពី វឌ្ឍនភាព និងទិសដៅបន្តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលរៀបចំដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា លោក ហេង សួរ បានបញ្ជាក់ថា ចំនួនពលករនៅក្នុងឆ្នាំ២០១៩នេះ មានការកើនឡើងប្រមាណ៥ម៉ឺននាក់ បើធៀបនឹងឆ្នាំ២០១៨។ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រូបនេះបានអះអាងទៀតថា ការចេញទៅធ្វើការនៅក្រៅប្រទេសរបស់ពលករកម្ពុជា បានផ្ញើប្រាក់មកក្រុមគ្រួសារនៅក្នុងប្រទេស ជិត២,៨០០លានដុល្លារ ជារៀងរាល់ឆ្នាំ ដែលធ្វើឲ្យកម្រិតជីវភាពរបស់ពួកគេកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃផងដែរ។

លោក ហេង សួរ បានបញ្ជាក់យ៉ាងដូច្នេះថា «ពាក់ព័ន្ធពលករយើងទៅធ្វើការនៅក្រៅប្រទេសនេះ ក្នុងឆ្នាំ២០១៩យើងមានសរុប ចំនួន១,២៨៨,០០០នាក់ ហើយធៀបនឹងឆ្នាំ២០១៨ គឺយើងមាន១,២៣០,០០០នាក់ ចឹងនៅក្នុងឆ្នាំ២០១៩នេះ យើងមានការកើនឡើងប្រមាណជាង៥ម៉ឺននាក់។ តាមរយៈបងប្អូន ដែលធ្វើការនៅក្រៅប្រទេសនេះ យើងឃើញបងប្អូនបានផ្ញើប្រាក់ដែលសល់ពីការចាយវាយជាក់ស្តែង នៅប្រទេសនោះ មកស្រុកយើង

វិញ ប្រហែលជិត២,៨០០លានដុល្លារក្នុងមួយឆ្នាំ»។ លោក ហេង សួរ បានឲ្យដឹងទៀតថា រហូតមកដល់ពេលនេះ ពលករខ្មែរភាគតិចណាស់ ដែលចង់ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ក៏ព្រោះតែលុយនៅប្រទេសនោះ បានចុះថោក ខណៈការងារកាន់តែសម្បូរបែបនៅប្រទេសកម្ពុជា។ លើសពីនេះ រយៈពេល៤ឆ្នាំចុងក្រោយនេះ ប្រាក់បៀវត្សអប្បបរមា នៅប្រទេសកម្ពុជា ខ្ពស់ប្រហាក់ប្រហែលនឹងប្រទេសជិតខាងផងដែរ៕

## ក្រុមការងារអន្តរក្រសួង នឹងត្រូវបង្កើត ដើម្បីតាមដានការផ្សាយ រូបអាសអាភាស

https://www.postkhmer.com/ សុទ្ធ គឹមសឿន | Publication date 27 February 2020 | 09:24 ICT

**ភ្នំពេញៈ** ក្រសួងកិច្ចការនារី គ្រោងផ្ដួចផ្ដើមបង្កើតក្រុមការងារមកពីអន្តរក្រសួងឆាប់ៗនេះ ដើម្បីតាមដាន ផ្សព្វផ្សាយ អប់រំ និងចាត់វិធានការលើអ្នកធ្វើសកម្មភាព ផ្សព្វផ្សាយ និងចែកចាយរូបភាព ឬវីដេអូ អាសអាភាស តាមបណ្ដាញសង្គម ប្រព័ន្ធអនឡាញ បន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសឲ្យអប់រំអ្នកទាំងនោះ ប៉ុន្តែសង្គមស៊ីវិលថា ជា ការបំបិទសិទ្ធិសេរីភាពលើស្ត្រី។

លោកស្រី ប៉ែន គន្ធា អនុប្រធាននាយកដ្ឋានព័ត៌មាននៃក្រសួងកិច្ចការនារី ថ្លែងកាលពីថ្ងៃទី ២៥ កុម្ភៈ ថា បន្ទាប់ពីមានអនុសាសន៍ពីលោកនាយករដ្ឋមន្ត្រីហ៊ុន សែន ក្រុមការងារក្រសួងកិច្ចការនារី ក៏ដូចជាក្រសួងពាក់ព័ន្ធផ្សេងៗទៀតបានជជែកគ្នារកវិធីទប់ស្កាត់ អប់រំ ផ្សព្វផ្សាយទៅលើសកម្មភាពរបស់អ្នកលក់ផលិតផលតាមអនឡាញ ដែលបញ្ចេញ និងប្រើប្រាស់រូបភាពអាសអាភាស សិចស៊ី ហួសហេតុ។ ក្រោយពិភាក្សា ក្រសួងកិច្ចការនារីគ្រោងផ្ដួចផ្ដើមបង្កើតក្រុមការងារមួយដែលមានសមាសភាព មកពីអន្តរក្រសួង រួមមាន ក្រសួងកិច្ចការនារី ក្រសួង ព័ត៌មាន ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ក្រសួងមហាផ្ទៃ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ក្រុមការងារ រួមគ្នាធ្វើការតាមដានផ្សព្វផ្សាយ អប់រំ ឬណែនាំ និងចាត់វិធានការរាល់សកម្មភាពទាំងឡាយដែលបញ្ចេញ និងប្រើប្រាស់ វីដេអូ រូបភាពអាសអាភាសលើបណ្ដាញសង្គមប្រព័ន្ធអនឡាញនានា។

លោកស្រី បញ្ជាក់ថា៖ «ប៉ុន្តែមិនមែនជាគណៈកម្មការទេ។ អ៊ីចឹងក្រុមការងារនេះយើងបង្កើតឡើងដើម្បីពិនិត្យទៅលើបញ្ហាទាក់ទងការបង្ហាញភាពសិចស៊ីខ្លាំងពេកតាមអនឡាញ ឬដែលធ្វើឲ្យប្រតិកម្មពីមហាជន ដើម្បីកុំឲ្យប៉ះពាល់សង្គម វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងតម្លៃស្ត្រីខ្មែរ»។ លោកស្រី គន្ធា បន្ថែមថា ជាជំហានដំបូង ក្រសួងកិច្ចការនារីស្នើឲ្យសមត្ថកិច្ចពាក់ព័ន្ធធ្វើការអប់រំ ផ្សព្វផ្សាយ និងណែនាំក្រុមស្ត្រីដែលធ្លាប់បង្ហាញភាពសិចស៊ីតាមអនឡាញ ឬ បណ្ដាញសង្គមនានាជាមុនសិន។ ប៉ុន្តែប្រសិនបើពួកគាត់មិនអនុវត្តតាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ចទេ នឹងអនុវត្តតាមច្បាប់។

លោក ឡុង ប៊ុណ្ណាស៊ីរីវត្ថ អ្នកនាំពាក្យ និងជារដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈថ្លែងថា លោកមិនទាន់បានទទួល ដំណឹងជុំវិញគម្រោងបង្កើតក្រុមការងារនេះទេ។ ប៉ុន្តែក្រុមការងារក្រសួងវប្បធម៌បានប្រជុំគ្នាពីបញ្ហា នេះម្ដងរួចហើយ។ ទោះយ៉ាងណា លោកស្វាគមន៍ចូលរួមជាមួយក្រុមការងារជាអន្តរក្រសួងនេះ។ ទោះបីជាអ្នកលក់ផលិតផល តាមអនឡាញបង្ហាញភាពសិចស៊ី មិនមែនជាអ្នកសិល្បៈក៏ដោយ ប៉ុន្តែវាក៏ពាក់ព័ន្ធជាមួយវប្បធម៌ដែរ។ ដូច្នេះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈក៏មានចំណែកចូលរួមដោះស្រាយជាមួយអាជ្ញាធរផ្សេងៗដែរ។ លោកបញ្ជាក់ថា៖ «ប្រសិនបើក្រុមការងារនេះបង្កើតបានមែន គឺជាការល្អណាស់ ដើម្បីរក្សាសណ្ដាប់ធ្នាប់សង្គម រក្សាវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ខ្មែរយើង។ ម្យ៉ាងទៀត យើងក៏ចង់រក្សា តម្លៃលើស្ត្រីខ្មែរយើងដែរ។ ការដែលបង្ហាញភាពសិចស៊ីខ្លាំងពេក អាចធ្វើឲ្យមនុស្សប្រុសមួយចំនួនប្រព្រឹត្តអំពើផ្ដេសផ្ដាសមិនល្អ»។

កញ្ញា បុណ្យ រចនា នាយិកាប្រតិបត្តិនៃអង្គការភ្លាហាន និងជាអ្នកស្រាវជ្រាវ និងចងក្រងឯកសារពាក់ព័ន្ធការរើសអើងលើស្ត្រីថ្លែងថា ការរឹតត្បិតសិទ្ធិសេរីភាពការបញ្ចេញមតិ ក៏ដូចជា ការបង្ហាញពីអារម្មណ៍ផ្នែករាងកាយ

របស់អាជ្ញាធរ នឹងមិនជួយឲ្យសង្គមមានសន្តិភាពពេញលេញ ឬមានការអភិវឌ្ឍប្រកបដោយស្ថិរភាពនោះទេ។ នេះអាចជាការហាមឃាត់ស្ត្រីពីការស្លៀកពាក់តាមជម្រើសចិត្តពួកគាត់។ កញ្ញាបន្តថា ប្រសិនមិនមានការបញ្ជ្រាបទស្សនទានយេនឌ័រនៅក្នុងកម្មវិធីអប់រំតាំងពីបឋមសិក្សាមកទេ វានឹងធ្វើឲ្យមានផ្នត់គំនិតសង្គមមួយដែលគិតថាបុរស មានតម្លៃលើសលប់ទៅលើខ្លួនប្រាណស្ត្រីដដែល។ ការគិតបែបនេះ វាគ្មានអ្វីក្រៅពីចង់ស្តីបន្ទោស ឲ្យជនរងគ្រោះជាស្ត្រីទេ ខណៈអ្នកប្រព្រឹត្តបទល្មើសនានាភាគច្រើនជាបុរស។ កញ្ញារចនាថ្លែងថា៖ «ខ្ញុំមិនអាចបញ្ជាក់ថា ខ្ញុំចាប់អារម្មណ៍ ឬមិនចាប់អារម្មណ៍ចំពោះក្រុមការងារ ដែលអន្តរក្រសួងគ្រោងបង្កើតនេះទេ។ ប៉ុន្តែបើក្រុមការងារនេះបង្កើតឡើងក្នុងន័យរឹតត្បិតសេរីភាពស្ត្រី ខ្ញុំថាមិនចាំបាច់បង្កើតទេ ប៉ុន្តែការបង្កើតឡើងក្នុងន័យអប់រំ ផ្សព្វផ្សាយលើកកម្ពស់ស្ត្រី និងបង្កើនសិទ្ធិសេរីភាពស្ត្រី ទើបជារឿងចាំបាច់»។

ក្រសួងកិច្ចការនារី នៅថ្ងៃទី ២៥ កុម្ភៈ បានចេញសេចក្តីថ្លែងការណ៍មួយឲ្យដឹងថាវិធានការនេះ បាននិងកំពុងទទួលការសាទរពីមហាជន ព្រោះជាវិធានការ ដើម្បីទប់ស្កាត់សកម្មភាពផ្សព្វផ្សាយ និង ចែកចាយរូបភាពអាសអាភាស តាមបណ្តាញសង្គមក្នុងចំណោមអ្នកប្រើប្រាស់ប្រព័ន្ធអនឡាញ ដែលភាគច្រើនជាក្រុមមនុស្សវ័យក្មេង។ វិធានការនេះ សំដៅការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាពិសេសស្ត្រី បង្កើនសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងរក្សាការពារ លើកកម្ពស់ទំនៀមទម្លាប់ប្រពៃណី ដ៏ល្អរបស់ជាតិ។ វិធានការនេះសំដៅលើករណីលក់ផលិតផលអនឡាញមួយចំនួនតូច ដែលប្រើប្រាស់រូបភាពអាសអាភាស ដែលជាទង្វើផ្ទុយនឹងច្បាប់ដែលមានចែងជាធរមាននិងមិនសំដៅរឹតបន្តឹងសិទ្ធិសេរីភាពរបស់ស្ត្រីខ្មែរនោះទេ។

ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ ២០១៩ និងលើកទិសដៅបន្តរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី កាលពីថ្ងៃទី ១៧ កុម្ភៈ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានណែនាំឲ្យអាជ្ញាធរមានសមត្ថកិច្ច ធ្វើការអប់រំដល់អ្នកលក់ផលិតផលតាមអនឡាញ ដែលប្រើប្រាស់រូបភាពអាសអាភាស ឬអាក្រាតកាយ មុននឹងឈានទៅចាត់វិធានការជាក់លាក់ណាមួយ។ រហូតមកដល់ពេលនេះ សមត្ថកិច្ចបានឃាត់ខ្លួនស្ត្រីលក់អនឡាញម្នាក់ស្លៀកពាក់សិចស៊ី ដែលធ្វើឲ្យមានការរិះគន់តាមបណ្តាញសង្គមបញ្ជូនទៅតុលាការ ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ក្រោយធ្វើការអប់រំ និងណែនាំនៅតែមិនអនុវត្តតាម៕

## ទស្សនៈមិត្តអ្នកអានះ សូមបែងចែកឱ្យដាច់រវាងការលក់ទំនិញ Online និងអាក្រាតកាយក្នុងគោលបំណងផ្សេង

https://grandnewsasia.com/ 27-02-2020

ដោយសារប្រទេសជាតិកំពុងមានការរីកចំរើនលើគ្រប់វិស័យ ជាពិសេសគឺបច្ចេកវិទ្យាតែម្តង ដូច្នេះហើយមិនថាតែយុវវ័យនោះទេ សូម្បីតែប្រជាពលរដ្ឋទូទៅស្ទើរតែគ្រប់វ័យទៅហើយ គឺកំពុងតែជក់ចិត្តនឹងការវិវត្តថ្មីៗនៃបច្ចេកវិទ្យា ជាពិសេសគឺទូរស័ព្ទដៃស្មាតហ្វូនតែម្តង។ មិនខុសពីពលរដ្ឋរស់នៅប្រទេសជឿនលឿនប៉ុន្មានដែរ ពលរដ្ឋខ្មែរបាននិយមប្រើប្រាស់ទូរស័ព្ទស្មាតហ្វូនគ្រប់ៗគ្នា។ អ្នកខ្លះប្រើរហូតដល់ទៅ២-៣គ្រឿងទៀតផងក៏មាន។ បច្ចេកវិទ្យាបានជួយឱ្យមនុស្សកាន់តែងាយស្រួលក្នុងការរស់នៅ ការទំនាក់ទំនង ការប្រកបការងារ ការជួញដូ និងការធ្វើពាណិជ្ជកម្មជាដើម គឺងាយស្រួលជាងមុនឆ្ងាយណាស់។ ប៉ុន្តែបើទោះជាបែបនេះក្តីបច្ចេកវិទ្យា ក៏បានផ្តល់នូវគុណវិបត្តិមួយចំនួនផងដែរក្នុងសង្គម។ ជាក់ស្តែងអ្វីដែលជាទីចាប់អារម្មណ៍ក្នុងប្រទេសកម្ពុជានាពេលថ្មីៗនេះ គឺការប្រើប្រាស់ប្រព័ន្ធ Social Media (Facebook) ដើម្បីធ្វើអាជីវកម្ម Online ហើយអ្នកខ្លះទៀតហេតុតែចង់ទាក់ទាញអតិថិជនបានបំពានទៅលើក្រមសីលធម៌ និងតម្លៃស្ត្រីខ្មែរ។

អ្នកលក់ផលិតផល Online កំពុងតែកើនឡើងយ៉ាងគំហុក ហើយរីកដុះដាលដូចផ្សិតត្រូវទឹក ខណៈអ្នករកស៊ីដែល Update មិនទាន់ រឺមិនចេះប្រើវាខ្លះ កំពុងតែរអ៊ូរទាំ ពីការថយចុះអតិថិជននៅតាមទីផ្សារ និងហាងទំនិញ

នានា។ ទាំងយុវវ័យ និងមនុស្សវ័យកណ្ដាល បានងាកទៅទិញផលិតផល Online យ៉ាងគគ្រឹកគគ្រេង។ ដោយសារទីផ្សារលក់ផលិតផល Online កំពុងតែត្រូវប៉ាន់ក្នុងប្រទេសកម្ពុជា ដូច្នេះហើយគេសង្កេតឃើញមុខទំនិញស្ទើរតែគ្រប់មុខ បានប្រជ្រៀតគ្នាដាក់លក់លើ Online ឬ Facebook ព្រោងព្រាត។ ដើម្បីទាក់ទាញអតិថិជន អ្នកលក់ដូរ Online មួយចំនួន បានចាប់ផ្ដើមធ្វើអ្វីប្លែកៗហួសពីការស្មាន។ ចំណុចអវិជ្ជមានដែលលេចចេញមកនាពេលបច្ចុប្បន្ននេះ គឺអ្នកលក់ Online ខ្លះបាន Live លក់ទំនិញប្រើប្រាស់សំដីអសុរស អាសអាភាស តុបតែងខ្លួនស៊ិចស៊ីហួសហេតុ និងខ្លះទៀតស្លៀកពាក់លេចលើលេចក្រោម បញ្ចេញកេរ្តិ៍ភេទកណ្ដាលវាលក៏មាន។

ដើម្បីប្រជែងគ្នាដណ្ដើមចំណាប់អារម្មណ៍ពីអ្នក View ឬអ្នកទិញ អ្នកលក់ផលិតផល តាម Online ឬ Facebook ខ្លះបានបំពានទៅលើក្រមសីលធម៌ និងតំលៃស្ត្រីខ្មែរយ៉ាងធ្ងន់ធ្ងរ។ Video Live តាម Facebook បច្ចុប្បន្នខ្លះ បានធ្វើឱ្យអាប់ឱនដល់តំលៃ និងកត្តិយសស្ត្រីខ្មែរទូទៅ ដែលបញ្ហានេះមិនគួរត្រូវបានបណ្ដែតបណ្ដោយតទៅទៀតឡើយ។ ការរីករាលដាលកាន់តែអាក្រក់ឡើងៗនៃវីដេអូ Live ស្ទើរតែអាក្រាតកាយរបស់អ្នកលក់ Online នាពេលបច្ចុប្បន្ន ក៏ជាចំណែកមួយ ដែលនាំទៅដល់អំពើរំលោភបំពានលើស្ត្រី និងកុមារីផងដែរ។ ដោយមើលឃើញពីចំណុចអវិជ្ជមាន និងគុណវិបត្តិដូចនេះហើយ ទើបប្រមុខរាជរដ្ឋាភិបាលខ្មែរ ក៏ដូចជាស្ថាប័នពាក់ព័ន្ធនានា ដែលធ្វើការងារលើការការពារសិទ្ធិ និងលើកកម្ពស់តំលៃស្ត្រី បានជំរុញឱ្យមានការយកចិត្តទុកដាក់ អប់រំ និងចាត់វិធានការមួយចំនួន ដើម្បីព្រមានកុំឱ្យអ្នកលក់ទំនិញទាំងនោះប្រព្រឹត្តខុសឆ្គងបន្តទៀត។ ក្រៅពីធ្វើឱ្យប៉ះពាល់ដល់តំលៃ និងសីលធម៌ខ្មែរ ការLive លក់បែបអាក្រាតទាំងនោះ បានបណ្ដាលឱ្យប៉ះពាល់ដល់កិត្តិយស និងមុខមាត់ប្រទេសកម្ពុជាថែមទៀតផង។ នាយករដ្ឋមន្ត្រីកម្ពុជា លោក ហ៊ុន សែន បានលើកឡើងកាលពីពេលថ្មីៗនេះ ដោយអំពាវនាវឱ្យស្ថាប័នពាក់ព័ន្ធ និងមានសមត្ថកិច្ចទាំងអស់ ត្រួតពិនិត្យឡើងវិញចំពោះបញ្ហានេះ។

ទោះជាបែបនេះក្ដី រដ្ឋាភិបាលនៅមិនទាន់បានចាត់វិធានការក្ដៅ ទៅលើអ្នកលក់ផលិតផល Online ស៊ិចស៊ីហួសហេតុនោះទេ ក្រៅពីស្ត្រីម្នាក់ដែលមានឈ្មោះ ថៃ ស្រីនាង ត្រូវបានសមត្ថកិច្ចហៅទៅអប់រំ និងធ្វើកិច្ចសន្យា។ វិធានការរបស់រដ្ឋាភិបាល ត្រូវបានសាទរពីមហាជនទូទៅ ដោយចាត់ទុកថា នេះគឺជាការកែលម្អស្ថានភាពអាក្រក់លើបណ្ដាញសង្គមដែលនាំទៅដល់ការធ្លាក់ចុះនូវតំលៃសីលធម៌ខ្មែរមកវិញ។ ផ្ទុយពីការគិតគូរនេះ មានមជ្ឈដ្ឋានមួយចំនួន បានរិះគន់ចំពោះចំណាត់ការរបស់រដ្ឋាភិបាល និងសមត្ថកិច្ច ដោយយកលេសថាវិធានការនេះ គឺជាការបំបិទសិទ្ធិសេរីភាព និងរើសអើងស្ត្រីទៅវិញ។ ក្រោមហេតុផលការពារសិទ្ធិសេរីភាព និងប្រឆាំងការរើសអើងលើស្ត្រី ក្រុមអង្គការសង្គមស៊ីវិល និងក្រុមអ្នកប្រឆាំងផ្កាប់មុខមួយក្ដាប់តូច បានរិះគន់វិធានការរបស់រាជរដ្ឋាភិបាល។ ពួកគេបានអំពាវនាវឱ្យភាគីពាក់ព័ន្ធ រួមគ្នាលើកកម្ពស់យុត្តិធម៌តាមរយៈការប្រយុទ្ធប្រឆាំងនឹងការរើសអើងផ្អែកលើអត្តសញ្ញាណយេនឌ័រ។ ជាមួយគ្នានេះក៏មានទស្សនៈខុសឆ្គងខ្លះបានលើកឡើងថា ស្ត្រីខ្មែរពីសម័យបុរាណក៏មិនមានស្លៀកពាក់ជិតកាយដែរ។ ពួកគេបានលើកយកនូវរូបភាពអប្សរាលើជញ្ជាំងប្រាសាទ មកធ្វើការប្រៀបធៀបដោយបញ្ចេញទស្សនៈថា ការស្លៀកពាក់គ្មានដែនកំណត់ គ្មានច្បាប់ហាមប្រាមនោះទេ ហើយទោះបីអ្នកណាចង់ស្លៀកពាក់អាក្រាតបែបណាគឺជាសិទ្ធិរបស់គេ។

ជាការពិតការប្រកបរបររកស៊ីតាម Online ដែលស្របច្បាប់ និងមានក្រមសីលធម៌ គឺត្រូវបានលើកទឹកចិត្តពីរាជរដ្ឋាភិបាល ហើយពលរដ្ឋខ្មែរមានសិទ្ធិពេញលេញក្នុងការប្រកបរបរចិញ្ចឹមជីវិតតាមចំណង់ចំណូលចិត្ត និងជំនាញរបស់ខ្លួន។ ប៉ុន្តែវិធីលក់ដូរដែលបង្ហាញកេរ្តិ៍ភេទ អាក្រាត ឬស៊ិចស៊ីហួសហេតុពេក គឺបានធ្វើឱ្យធ្លាក់ចុះនូវតំលៃសីលធម៌ និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់វប្បធម៌ប្រពៃណីដ៏ផូរផង់របស់ខ្មែរ ដែលប្រការនេះគឺ ត្រូវបានមហាជនរិះគន់ជារឿយៗ និងស្នើសុំឱ្យរាជរដ្ឋាភិបាលចាត់វិធានការ។ ចំណាត់ការមួយក្នុងចំណោមចំណាត់ការផ្សេងៗទៀត ក៏នឹងត្រូវបានធ្វើឡើងផងដែរ ដោយក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍ នឹងបិទរាល់គណនី Facebook ផ្សាយ

លក់ផលិតផល ដែលបញ្ចេញអស់កេរ្តិ៍ខ្មាសទាំងនេះ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានកត់សំគាល់ផងដែរថា ការ Live ស្លៀកពាក់អាក្រាតកេរ្តិ៍បែបនេះ នាំឱ្យមានការបំពានផ្លូវភេទស្ត្រី ក្នុងសង្គមនាពេលបច្ចុប្បន្ន ហើយអាចនាំឲ្យកើតមានករណីចាប់រំលោភផងដែរ។ ក្នុងនាមជាពលរដ្ឋខ្មែរ យើងគួរតែនាំគ្នាគាំទ្រវិធានការរបស់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់តំលៃសីលធម៌នារីខ្មែរ និងទប់ស្កាត់នូវអំពើរំលោភបំពានលើស្ត្រី ៕ ដោយៈ ស រដ្ឋា

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរចំនួន ២៨នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងការស្នាក់នៅខុសច្បាប់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 26-02-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នារសៀលថ្ងៃទី ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ បានទទួលពលករខ្មែរចំនួន ២៨នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងការស្នាក់នៅខុសច្បាប់។ នគរបាលអន្តោប្រវេសន៍ប៉ុស្តិ៍ បានឲ្យដឹងថា ពលករខ្មែរទាំង ២៨ នាក់ ស្រី ០៩នាក់ មកពីខេត្តបាត់ដំបង ១១នាក់ ស្រី ០៤នាក់, ខេត្តប៉ៃលិន ០៧នាក់ ស្រី ០២នាក់, ខេត្តពោធិ៍សាត់ ០១នាក់ ស្រី ០១នាក់, ខេត្តកំពង់ឆ្នាំង ០២នាក់, ខេត្តកំពង់ស្ពឺ ០២នាក់, ខេត្តព្រៃវែង ០២នាក់ ស្រី ០១នាក់ និងខេត្តកំពង់ចាម ០៣នាក់ ស្រី ០១នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ បានទទួលពលករខ្មែរ ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែនទៅធ្វើការខុសច្បាប់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 26-02-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ នារសៀលថ្ងៃទី ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ បានទទួលពលករខ្មែរចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទ ឆ្លងដែនទៅធ្វើការខុសច្បាប់ នៅប្រទេសថៃ ដែលចេញតាមច្រកដូង ខេត្តបាត់ដំបង៕

## តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ សហការជាមួយមេភូមិ៤ ឃុំធុងហ្លួង និងការិយាល័យសុខមាលភាព និងគាំពារពលករ អន្តរាគមន៍ទាមទារប្រាក់ឈ្នួលដល់ពលករ

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 26-02-2020

ថ្ងៃពុធ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះមកខេត្តសុយោថៃ សហការជាមួយមេភូមិ៤ ឃុំធុងហ្លួង និងការិយាល័យសុខមាលភាពនិងគាំពារពលករ ដើម្បីអន្តរាគមន៍ទាមទារប្រាក់ឈ្នួលដល់ពលករខ្មែរឈ្មោះ មុត ឆៃដែន ភេទស្រី អាយុ៣៤ឆ្នាំ តំណាងឱ្យពលករ៣នាក់ មានស្រុកកំណើតនៅខេត្តបាត់ដំបង ករណីត្រូវនិយោជកមិនបើក ប្រាក់ឈ្នួលរយៈពេល៣ខែ សរុបជាទឹកប្រាក់ប្រមាណជាង៩ម៉ឺនបាត។ បន្ទាប់ពីមានការអន្តរាគមន៍ ពីស្ថានទូតនិងអាជ្ញាធរពាក់ព័ន្ធ និយោជកយល់ព្រមចាយប្រាក់ឈ្នួលចំនួន៥ម៉ឺនបាតដល់ពលករ ចំណែកប្រាក់ឈ្នួលដែលនៅសល់ អាជ្ញាធរនឹងបង្គាប់ឱ្យនិយោជកមកបំភ្លឺនិងបង់ប្រាក់ឈ្នួលក្នុងរយៈពេល៦០ថ្ងៃបន្ទាប់ពីពលករបានដាក់ពាក្យបណ្ដឹង។ ក្នុងករណីនិយោជកមិនអនុវត្តតាម អាជ្ញាធរនឹងចាត់វិធានការតាមផ្លូវច្បាប់។

# ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០២០

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ផ្ញើលិខិតថ្លែងអំណរគុណសម្តេចតេជោ ហ៊ុន សែន ដែលណែនាំលុបបំបាត់ អ្នកលក់ផលិតផលអនឡាញ ស្លៀកពាក់សិចស៊ីហួសហេតុ

http://www.freshnewsasia.com/ 2020-02-27

**(ភ្នំពេញ)៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃក្រសួងមហាផ្ទៃ ដែលមានលោកស្រី ជូ ប៊ុនអេង ជាប្រធាន បានផ្ញើសារលិខិត ថ្លែងអំណរគុណជូនសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ដែលបានណែនាំឲ្យលុបបំបាត់ ទង្វើអសីលធម៌មួយចំនួន របស់អ្នកលក់ផលិតផលតាមអនឡាញ ដោយស្លៀកពាក់សិចស៊ីហួសហេតុ។

លិខិតថ្លែងអំណរគុណដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅរសៀលថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០២០នេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស បានប្រកាសគាំទ្រ ទាំងស្រុងចំពោះវិធានការដ៏មុតស្រួច ម៉ឺងម៉ាត់របស់សម្តេចតេជោ ហ៊ុន សែន ដែលជំរុញលើកទឹកចិត្តឲ្យប្រឹងប្រែង រឹងតែសកម្ម ក្នុងការលុបបំបាត់អំពើអសីលធម៌ក្នុងសង្គម លើកកម្ពស់តម្លៃអត្ត សញ្ញាណជាតិ តម្លៃស្ត្រីខ្មែរ ការពារភាពសុខដុមរម្យនា និងសន្តិភាពផ្លូវកាយ ផ្លូវចិត្តរបស់ប្រជាជន។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏បានចាត់ទុកដែរថា ឥរិយាបថរបស់អ្នកលក់ផលិតផលអនឡាញ មួយចំនួនដែលបង្ហាញរូបភាពសិចស៊ី អាសអាភាស ជាកត្តាអូសទាញ និងរុញច្រានឲ្យមានការកើនឡើងនូវអំពើឆបោក និងកេងប្រវ័ញ្ចផ្លូវភេទ តាមប្រព័ន្ធអនឡាញ ដែលក្នុងនោះ ស្ត្រី យុវវ័យ និងកុមារ គឺជាអ្នករងគ្រោះ៕

## របាយការណ៍របស់ CPU បង្ហាញពីការធ្លាក់ចុះករណីឃាតកម្មលើកុមារកម្ពុជា

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 28 February 2020 | 10:39 ICT

**ភ្នំពេញៈ** របាយការណ៍ប្រចាំឆ្នាំរបស់អង្គភាពការពារកុមារ (CPU) បានឲ្យដឹងថា ក្នុងឆ្នាំ ២០១៩ កន្លងទៅ CPU បានសហការជាមួយនគរបាលជាតិកម្ពុជា ធ្វើការស៊ើបអង្កេតបទល្មើសដែលកើតមានលើកុមារចំនួន ២៧៤ ករណីនៅទូទាំងប្រទេសក្នុងនោះករណីឃាតកម្មមានការថយចុះពីឆ្នាំ ២០១៨ ខណៈអត្រាឃាត់ខ្លួនជនល្មើសមានកម្រិតខ្ពស់ដល់ ៨៧%។អង្គភាពការពារកុមារបានចាត់ទុកថា ឆ្នាំ ២០១៩ កន្លងទៅនេះគឺជាឆ្នាំដ៏មមាញឹកមួយក្នុងការបង្ក្រាបបទល្មើសទៅលើកុមារ ហើយក៏ជាការបង្ក្រាបមួយដែលឈានដល់មានការចាប់ខ្លួនជនដៃដល់បានខ្ពស់បំផុតរហូតដល់ទៅ ៨៧ ភាគរយ ដែលនេះជាលទ្ធផលមួយគួរឲ្យមោទនភាព។ នេះបើតាមរបាយការណ៍របស់អង្គការនេះដែលបានបង្ហោះនៅទំព័រហ្វេសប៊ុកកាលពីថ្ងៃទី ២៤ កុម្ភៈ។

CPU បានអះអាងបន្ថែមថាចំនួនបទល្មើសឃាតកម្មទៅលើកុមារបានធ្លាក់ចុះដល់ ២៤ ករណី ក្នុងឆ្នាំ ២០១៩ បើប្រៀបធៀបទៅនឹងឆ្នាំ ២០១៨ ដែលមានដល់ទៅ ៣៣ ករណី។ ជាងនេះទៀតក្រុមការងារស៊ើបអង្កេតបទល្មើសមនុស្សឃាតក៏បានស៊ើបអង្កេតលើគ្រប់ករណីឃាតកម្មទៅលើអនីតិជនក្រោមអាយុ ១៥ ឆ្នាំទូទាំងកម្ពុជាផងដែរ។ តាមរបាយការណ៍នេះ CPU ក៏បានថ្លែងអំណរគុណដល់អ្នកផ្តល់ជំនួយដល់អង្គភាពការពារកុមារផងដែរ ក្នុងនោះរាប់ទាំងអ្នកឧបត្ថម្ភ អ្នកគាំទ្រ ក្រុមការងារស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងនគរបាលជាដៃគូនៅក្រៅប្រទេសជាដើម។ «យើងមិនអាចទទួលលទ្ធផលដ៏ល្អនេះបានទេប្រសិនបើគ្មានការគាំទ្រ ការប្តេជ្ញា និងការខិតខំប្រឹងប្រែងពីអ្នកទាំងអស់គ្នា»។ បើតាមរបាយការណ៍ដដែលក្នុងឆ្នាំ ២០១៩ CPU បានកសាងក្រុមការងារជំនាញបច្ចេកទេសវិទ្យាសាស្ត្រដែលមានលោក Ray KIRWAN មន្ត្រីជំនាញកោសល្យវិច័យមកពីអូស្ត្រាលីជាប្រធានក្រុម។

បន្ថែមពីនេះក៏បានបង្កើតក្រុមការងារស៊ើបអង្កេតបទល្មើសទៅលើកុមារតាមបណ្តាញអ៊ីនធឺណិត (ICAC) ដែលជាក្រុមការងារដំបូងប្រភេទនេះក្នុងប្រទេសកម្ពុជាផងដែរ។

លោក James McCabe Director of Operations CPU បានលើកឡើងនៅលើទំព័រហ្វេសប៊ុកកន្លងទៅថា លោកបានបង្កើតអង្គភាពការពារកុមារដោយចាប់ដៃគូជាមួយអង្គការ Cambodian Children's Fund និងនគរបាលជាតិកម្ពុជា តាំងពីឆ្នាំ ២០១៣ មក។ លោក បន្តថាការបង្កើតអង្គការនេះឡើងក៏ដើម្បីការពារកុមារកម្ពុជាដែលមិនអាចការពារខ្លួនរបស់ពួកគេបានខ្លួនឯងក្នុងន័យជានាបានថា ជនល្មើសដែលប្រព្រឹត្តសកម្មភាពរំលោភបំពានលើកុមារ ត្រូវបានទទួលទោសទៅតាមច្បាប់។ លោកបញ្ជាក់ថា៖ «ខ្ញុំនឹងមិនបង្ហាញរូបភាព (កុមារ) ដែលធ្វើឲ្យតក់ស្លុតដែលខ្ញុំបានជួបប្រទះនៅពេលចុះបំពេញការងារជារៀងរាល់ថ្ងៃនោះទេ។ ស្ថានភាពទាំងនោះគឺជាសោកនាដកម្មដែលមិនត្រូវបន្តធ្វើការចែករំលែក បើទោះជារូបភាពសោកនាដកម្មទាំងនេះបានផ្តល់ចំណេះដឹងខ្លះ នាំឲ្យមានការភ័យខ្លាចទៅនឹងការរំលោភបំពានទាំងនោះក៏ដោយ»។

លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សកម្ពុជាបានប្រាប់ភ្នំពេញប៉ុស្តិ៍ថា រដ្ឋាភិបាលស្វាគមន៍ចំពោះកិច្ចសហការដោយស្មោះត្រង់របស់អង្គការសង្គមស៊ីវិលទាំងអស់ ដូចជា អង្គភាពការពារកុមារនេះជាដើម។ លោកស្រីក៏បានលើកឡើងដែរថា ការសហការបង្ក្រាបបទល្មើសដែលកើតមានលើកុមារនេះគឺអាទិភាពបំផុតដែលរដ្ឋាភិបាលតែងតែដាក់គោលដៅ និងផ្តល់ការសហការជាមួយអង្គការជាដៃគូ ខណៈបទល្មើសកើតមានលើកុមារទាំងនេះកំពុងបន្តកើតមាននៅឡើយមិនថាតែនៅកម្ពុជានោះទេ។ លោកស្រីបន្ថែមថា៖ «ចាប់ផ្តើមមានកត្តាជាច្រើនដែលក្នុងនោះក៏មានការទាក់ទាញតាមប្រព័ន្ធអនឡាញដែលធ្វើឲ្យកុមារ មានភាពរងគ្រោះច្រើនជាងមុន។ តាមពិតទៅរដ្ឋាភិបាលកម្ពុជាយើងមិនអាចធ្វើបានតែម្នាក់ឯងទេ គឺត្រូវការការចូលរួមពីពលរដ្ឋ គ្រប់ទីកន្លែង និងអង្គការជាដៃគូ»។ ជាមួយនឹងការលើកឡើងនេះលោកស្រី ជូ ប៊ុនអេង បានប្រកាសទទួលការសហការជាមួយបណ្តាអង្គការសង្គមស៊ីវិលដទៃទៀតដែលមានគោលដៅរួមគ្នា ដើម្បីទប់ស្កាត់អំពើហិង្សា ការរំលោភបំពានលើកុមារ ជាពិសេសឃាតកម្មមកលើកុមារកម្ពុជាដែលនៅតែបន្តកើតមានក្នុងពេលបច្ចុប្បន្ន៕

## ប្រតិភូក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ចូលរួមសន្និសីទថ្នាក់តំបន់ ក្រោមប្រធានបទ «ការពារការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រពន្ធ័អនឡាញ» នៅទីក្រុងបាងកក

http://www.freshnewsasia.com/ 2020-02-27

**(ភ្នំពេញ)៖** លោកស្រី សម្បត្តិ សុគន្ធា អគ្គលេខាធិការរង តំណាងលោកស្រី ញ៉េប សុភាព អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានអញ្ជើញទៅចូលរួមសន្និសិទថ្នាក់តំបន់ ប្រព្រឹត្តទៅនៅទីក្រុងបាងកក ប្រទេសថៃ ចាប់ពីថ្ងៃទី២៥ ខែកុម្ភៈ ដល់ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០។ នៅព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០នេះ លោកស្រី សម្បត្តិ សុគន្ធា បានធ្វើបទបង្ហាញជូនដល់អង្គសន្និសិទ លើការអនុវត្តការងារ ការលើកកម្ពស់ ទប់ស្កាត់ និងការពារការកេងប្រវ័ញ្ចលើកុមារតាមប្រព័ន្ធអនឡាញ ឆ្លើយតបនឹងផែនការទប់ស្កាត់អំពើហិង្សាលើកុមារ២០១៧-២០២១ នៅក្នុងសន្និសីទថ្នាក់តំបន់ ASEAN ស្តីពីការពារការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។

គួរជម្រាបថា កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសទាំង១៤ ដែលនឹងត្រូវចូលរួមការសិក្សាស្រាវជ្រាវថ្នាក់ពិភពលោកលើការបញ្ឈប់គ្រោះថ្នាក់ នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ៕

## ក្រសួងមុខងារសាធារណៈនិងស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់ ប្រជុំពិភាក្សាករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី

http://cambodiapolice.com/policekh/ 5:15 pm 27 កុម្ភៈ 2020 70

ពោធិ៍សាត់ ៖ នៅព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០នេះ ក្រសួងមុខងារសាធារណៈបានបើកកិច្ចប្រជុំពិភាក្សាករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាមួយស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់ ក្រោមអធិបតីភាពឯកឧត្តម ជុក មុន្នី រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ និងជាសមាជិកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលមានវត្តមានលោកជំទាវ ម៉ែន ផល្លី អភិបាលរងខេត្តពោធិ៍សាត់ លោកជំទាវ ប៊ុន ឈិតវាសនា អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងប្រតិភូអមដំណើរ ព្រមទាំងមន្ទីរកិច្ចការនារី លោក-លោកស្រីស្នងការរងផែនការងារជំនាញពាក់ព័ន្ធ ព្រមទាំងលោកនាយ នាយរងការិយាពាក់ព័ន្ធ និងលោកមេបញ្ជាការ បញ្ជាការរងនៃកងរាជអាវុធហត្ថខេត្តអញ្ជើញចូលរួមផងដែរ ។

ឯកឧត្តម ជុក មុន្នី បានមានប្រសាសន៍ថា កិច្ចប្រជុំនេះក្នុងគោលបំណងដើម្បីប្រមូលព័ត៌មាន និងលទ្ធផលនៃការអនុវត្តច្បាប់ជាតិ គោលនយោបាយរបស់រាជរដ្ឋាភិបាល និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទហើយស្វែងយលពីបញ្ហាប្រឈម និងដំណោះស្រាយពាក់ព័ន្ធ និងការលើកកម្ពស់ស្ថានភាព ជីវភាព ឋានៈ តួនាទីនិងសុខមាលភាពស្ត្រី ។ ឯកឧត្តមបានបន្តថា ដើម្បីការពារបាននូវបញ្ហាប្រឈមទាក់ទងការប្រើប្រាស់អំពើហិង្សា និងការរំលោភបំពានផ្លូវភេទលើអនីតិជនជាស្ត្រី សមត្ថកិច្ចត្រូវសហការជាមួយអាជ្ញាធរធ្វើការផ្សព្វផ្សាយអំពីច្បាប់ បទប្បញ្ញត្តិនានាដែលច្បាប់បានចែង និងធ្វើការអប់រំដល់ពួកគាត់ឲ្យបានយល់ដឹងទើបការប្រើប្រាស់អំពើហិង្សា និងការរំលោភបំពានផ្លូវភេទលើអនីតិជនជាស្ត្រីមានការថមថយនៅតាមមូលដ្ឋានរបស់ពួកគាត់ ៕

## យូនីសេហ្វៈ បណ្ដាញសង្គមផ្ដល់ឱកាសដល់កុមារ ប៉ុន្ដែវាក៏ផ្ដល់នូវហានិភ័យដែរ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 28 February 2020 | 10:12 ICT

**ភ្នំពេញៈ** អង្គការយូនីសេហ្វបានរកឃើញថា កុមារអាយុចាប់ពី ១១ ដល់ ១៨ ឆ្នាំ ដែលបានប្រើប្រាស់បណ្ដាញសង្គមដូចជា Instagram, Facebook, YouTube, WhatsApp, PubG និង Mobile Legends ទាំងក្មេងប្រុស និងក្មេងស្រីត្រូវបានរាយការណ៍ថា ពួកគេបានផ្ញើ និងត្រូវបានស្នើសុំឲ្យផ្ញើរូបភាពអាក្រាត ខណៈនាយិកាអង្គការនេះមើលឃើញថា បណ្ដាញសង្គមផ្ដល់នូវឱកាសធំធេងដល់កុមារ ប៉ុន្ដែវាក៏ផ្ដល់ឱ្យពួកគេនូវហានិភ័យផងដែរ ហើយហានិភ័យទាំងនេះកំពុងកើនឡើង។

យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់ការិយាល័យអង្គការយូនីសេហ្វដែលដាក់នៅលើរបាយការណ៍របស់អង្គការនេះប្រចាំតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ស្ដីអំពីឧក្រិដ្ឋកម្មលើការសិក្សាពីការប្រើប្រាស់បណ្ដាញសង្គមនៅក្នុងតំបន់អាស៊ីបូព៌ាក្នុងប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងថៃ ដោយបានប្រមូលព័ត៌មានពីការយល់ឃើញរបស់កុមារអាយុចាប់ពី ១១ ដល់ ១៨ ឆ្នាំចំនួន ៣០១ នាក់ និងការពិនិត្យលើឯកសារស្រាវជ្រាវដែលមានស្រាប់ និងការប្រមូលទិន្នន័យក្នុងប្រទេសទាំង ៤ នេះ។ សេចក្ដីប្រកាសព័ត៌មាននេះដាក់ចំណងជើងធំៗថា៖ «កសាងភាពធន់សម្រាប់កុមារ ដើម្បីជួយពួកគេឲ្យមានសុវត្ថិភាពនៅលើបណ្ដាញសង្គម» និងចំណងជើងទី ២ សរសេរថា «ជីវិតយើងនៅលើអ៊ីនធឺណិត៖ ការប្រើប្រាស់បណ្ដាញសង្គមរបស់កុមារ និងមនុស្សវ័យជំទង់នៅអាស៊ីបូព៌ា៖ ឱកាសហានិភ័យ និងគ្រោះថ្នាក់»។

ការសិក្សានេះក៏ប្រមូលទស្សនៈយល់ឃើញរបស់ក្រុមកុមារដែលជាធម្មតាមិនត្រូវបានគេបញ្ចូលនៅក្នុងការសិក្សាប្រភេទនេះ ដូចជាកុមារមកពីគ្រួសារមានប្រាក់ចំណូលទាប កុមារជួបការលំបាក កុមារមានពិការភាព កុមារអនាថា និងកុមារជាជនភៀសខ្លួនជាដើម។ ក្នុងប្រទេសដែលត្រូវបានសិក្សាទាំងនេះ ប្រធានបទចំនួន ៣ បានលេចឡើងក្នុងនោះរួមមានការខ្វះខាតចំណេះដឹងឌីជីថលក្នុងចំណោមឪពុក ម្ដាយ និងអ្នកថែទាំកុមារ ការឆ្លើយតបបែបរឹតត្បិតពីសំណាក់មនុស្សពេញវ័យ ចំពោះការយល់ឃើញពីការប្រព្រឹត្តអំពើផ្ដាំផ្ដងរបស់កុមារពេលប្រើប្រាស់បណ្ដាញសង្គម និងការខ្វះវិធីសាស្ត្រ

ផ្អែកលើភ័ស្តុតាងសម្រាប់ជួយឲ្យកុមារមានសុវត្ថិភាពនៅលើអ៊ីនធឺណិត។ របាយការណ៍នេះបានផ្តោតលើហានិភ័យនៃការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារនៅលើអ៊ីនធឺណិត ហើយបានផ្តល់វិធីសាស្ត្រការពារកុមារឲ្យទៅយូនីសេហ្វ និងដៃគូផងដែរ។

លោកស្រី ខារិន ហ៊ុលហ្សប នាយិកាយូនីសេហ្វ ប្រចាំតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិកបានថ្លែងថា បណ្តាញសង្គមផ្តល់នូវឱកាសធំធេងដល់កុមារ ប៉ុន្តែវាក៏ផ្តល់ឱ្យពួកគេនូវហានិភ័យផងដែរ ហើយហានិភ័យទាំងនេះកំពុងកើនឡើង។ ការហាមមិនឱ្យពួកគេប្រើបណ្តាញសង្គម មិនមែនជាការឆ្លើយតបដើម្បីការពារកុមារពីហានិភ័យ និងគ្រោះថ្នាក់នោះទេ។ លោកស្រីបន្តថា៖ «យើងចាំបាច់ត្រូវស្វែងយល់ពីហានិភ័យដែលកុមារកំពុងប្រឈមលើអ៊ីនធឺណិត របៀបដែលពួកគេប្រើបណ្តាញសង្គមរបៀបដែលពួកគេយល់ពីហានិភ័យដែលពួកគេប្រឈម និងជំហាន (ប្រសិនបើមាន) ដែលពួកគេអាចអនុវត្តដើម្បីការពារខ្លួន។ ខ្ញុំជឿជាក់ថា របាយការណ៍នេះនឹងចូលរួមចំណែកក្នុងការសម្រួចការពិភាក្សា និងរៀបចំកម្មវិធីផ្តោតលើការការពារកុមារតាមអ៊ីនធឺណិតក្នុងតំបន់ និងរក្សាសុវត្ថិភាពកុមារ»។

របាយការណ៍ខ្លីនេះបានរកឃើញថា កុមារនៅតំបន់អាស៊ីបូព៌ាប្រើវិធីសាស្ត្រដូចគ្នាទៅនឹងអ្វីដែលគេបានឃើញនៅទូទាំងពិភពលោក ដើម្បីការពារខ្លួននៅតាមអ៊ីនធឺណិតដូចជា ការកំណត់គណនី និងព័ត៌មានផ្ទាល់ខ្លួន (Profile) ជាឯកជន និងបិទមិនឲ្យផ្ញើសារ និងរូបភាពចូលដោយមិនបានស្នើសុំពីមនុស្សចម្លែកៗ ដែលធ្វើឱ្យពួកគេមានអារម្មណ៍មិនស្រួលក្នុងចិត្ត។ ប៉ុន្តែកុមារព្រមទទួលយកសំណើសុំជជែក (chat) និងសំណើសុំធ្វើមិត្តភក្តិ (friend request) ពីមនុស្សចម្លែកៗ ជាពិសេសអ្នកដែលអះអាងថា ខ្លួនជាមនុស្សស្រី ព្រោះកុមារមិនសូវចាត់ទុកមនុស្សស្រីជាជនចម្លែកនៅក្នុងបរិបទអ៊ីនធឺណិតឡើយ។ កុមារនឹងបិទទំនាក់ទំនងជាមួយអ្នកទាំងនោះ នៅពេលណាដែលការសន្ទនាខុសពីចិត្តរបស់ពួកគេតែប៉ុណ្ណោះ។

របាយការណ៍នេះបញ្ជាក់ថា៖ «ទាំងក្មេងប្រុស និងក្មេងស្រីត្រូវបានរាយការណ៍ថា ពួកគេបានផ្ញើ និងត្រូវបានស្នើសុំឲ្យផ្ញើរូបភាពអាក្រាត។ កុមារ ២ នាក់ក្នុងចំណោម ៥ នាក់នៅក្នុងក្រុមពិភាក្សា (focus group) សម្រាប់ការស្រាវជ្រាវនេះបានរាយការណ៍ថា ពួកគេមានបទពិសោធមិនល្អទាល់តែសោះ ហើយពួកគេមិនចង់ប្រាប់នរណាម្នាក់អំពីរឿងនោះឡើយ។ ជាងពាក់កណ្តាលនៃចំនួនកុមារបានជួបអ្នកដែលគេស្គាល់តាមអ៊ីនធឺណិតជាលើកដំបូងក្នុងជីវិតពិត ហើយភាគច្រើននៃកុមារសង្ឃឹមថាពួកគេអាចបង្កើតទំនាក់ទំនងស្នេហា។ ក្នុងករណីភាគច្រើនពួកគេមិនបានរាយការណ៍អំពីគ្រោះថ្នាក់ពីការជួបគ្នានោះទេ ប៉ុន្តែបែរជាលើកឡើងពីការខកចិត្តទៅវិញ»។ របាយការណ៍នេះបានផ្តល់អនុសាសន៍ជាច្រើនសម្រាប់ក្រុមគ្រួសារ សាលារៀន សហគមន៍ និងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិតដែលក្នុងនោះមានធ្វើឱ្យប្រសើរឡើងនូវការគាំទ្រសម្រាប់ការចិញ្ចឹមកូនតាមប្រព័ន្ធឌីជីថល និងការចិញ្ចឹមកូនក្នុងយុគសម័យឌីជីថលដូចជាការគ្រប់គ្រងកូនតាមបែបឌីជីថលគួរតែត្រូវបានបញ្ចូលទៅក្នុងកម្មវិធីចិញ្ចឹមកូនដែលផ្អែកលើភ័ស្តុតាង ហើយគួរពិចារណាបែងចែកកម្រិតខុសគ្នានៃចំណេះដឹងឌីជីថលក្នុងចំណោមអ្នកមើលថែទាំកុមារដែលជាស្ត្រី និងបុរសក៏ដូចជាកំណត់ពីកម្រិតនៃការប្រើប្រាស់បច្ចេកវិទ្យាជាដើម។

កាលពីថ្ងៃទី ១១ ខែកុម្ភៈនេះអង្គការសកម្មភាពដើម្បីកុមារ (APLE) គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រសួងពាក់ព័ន្ធបានសហការគ្នាធ្វើយុទ្ធនាការស្តីពីការ «ការលើកកម្ពស់សុវត្ថិភាពអ៊ីនធឺណិតសីលធម៌សង្គម និងតម្លៃគ្រួសារ» ដើម្បីលើកកម្ពស់ការប្រើប្រាស់អ៊ីនធឺណិតបច្ចេកវិទ្យាឌីជីថលប្រកបដោយសុវត្ថិភាពពិសេសក្នុងចំណោមកុមារ និងយុវវ័យនៅកម្ពុជាផងដែរក្នុងនោះមានកុមារប្រមាណ ៦០០ នាក់បានចូលរួម។

អង្គការសកម្មភាពដើម្បីកុមារបានចេញសេចក្តីប្រកាសព័ត៌មានថា ឪពុកម្តាយ អ្នកមើលថែកុមារ និងគ្រូបង្រៀនគួរតែណែនាំកុមារឲ្យឆ្ពោះទៅរកការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយសុវត្ថិភាព ដោយផ្តល់ឲ្យពួកគេនូវឧបករណ៍ និងចំណេះដឹង ដើម្បីមានជម្រើសកាន់តែល្អប្រសើរជាងមុន ខណៈក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតអាចជួយបង្កើតសុវត្ថិភាពអ៊ីនធឺណិតតាមរយៈការផ្សព្វផ្សាយនូវមាតិកាល្អៗ និងសេវាកម្មប្រកបដោយសុវត្ថិភាពនៅលើប្រព័ន្ធអ៊ីនធឺណិតដោយភាពទទួលខុសត្រូវដល់សង្គម៕

# របាយការណ៍ថ្មី៖ កុមាររាប់រយនាក់ធ្វើការក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា

https://khmer.voanews.com/ 26 កុម្ភៈ 2020

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារបានបដិសេធលើការរកឃើញនេះដោយអន្លើ។ លោកនិយាយថា ការរកឃើញនេះផ្អែកទៅលើស្រាវជ្រាវរបស់ «ក្រុមអ្នកស្រាវជ្រាវដែលមិនមានវិជ្ជាជីវៈត្រឹមត្រូវ»។

ភ្នំពេញៈ កុមាររាប់រយនាក់ធ្វើការនៅក្នុងសិប្បកម្មផលិតឥដ្ឋក្នុងប្រទេសកម្ពុជា នេះបើយោងតាមលទ្ធផលនៃការស្ទង់មតិមួយទៅលើសិប្បកម្មផលិតឥដ្ឋទាំងអស់នៅកម្ពុជារបស់មជ្ឈមណ្ឌលសាមគ្គីភាព(Solidarity Center)។ ការស្ទង់មតិនេះត្រូវបានគេរំពឹងថា នឹងចេញផ្សាយនៅពេលឆាប់ៗនេះ បើទោះបីជាអ្នកនាំពាក្យរាជរដ្ឋាភិបាលបដិសេធការរកឃើញនៃរបាយការណ៍នេះក្តី។ កាលពីឆ្នាំមុន ក្រសួងការងារបានធ្វើយុទ្ធនាការមួយដើម្បីបញ្ចប់ពលកម្មកុមារនៅតាមសិប្បកម្មផលិតឥដ្ឋ និងបានប្រកាសថា ក្រសួងនឹងបង្ក្រាបលើម្ចាស់ឡឥដ្ឋណាដែលនៅតែយកកុមារមកធ្វើការ។

ការស្ទង់មតិនោះត្រូវបានធ្វើឡើងភាគច្រើននៅក្នុងខែកក្កដាដោយមជ្ឈមណ្ឌលសាមគ្គីភាព(SolidarityCenter) ដែលជាអង្គការសិទ្ធិការងារមួយមានមូលដ្ឋាននៅសហរដ្ឋអាមេរិក និងបានសហការជាមួយនឹងអង្គការ AFL-CIO ដែលជាសហព័ន្ធពលកម្មអាមេរិកាំង និងសហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើកម្ពុជា ហៅកាត់ថា BWTUC។ ការស្ទង់មតិនោះបានរកឃើញថា អនីតិជនជិត៤ពាន់នាក់រស់នៅក្នុងបរិវេណសិប្បកម្មផលិតឥដ្ឋដែលកំពុងមានប្រតិបត្តិការចំនួន៤៦៤នៅទូទាំងប្រទេស ហើយកុមារចំនួន៦៣៨នាក់ត្រូវបានគេជួលឱ្យធ្វើការនៅតាមឡឥដ្ឋទាំងនោះ។

លោក យុន ថារូ ដែលជាអ្នកសម្របសម្រួលកម្មវិធីរបស់មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្សក្នុងរាជធានីភ្នំពេញហៅកាត់ថា សង់ត្រាល់ បាននិយាយថា ការអង្កេតនេះបង្ហាញថា យុទ្ធនាការរបស់រដ្ឋាភិបាលមិនមានប្រសិទ្ធភាពនោះទេមកដល់ពេលនេះ និងថាយុទ្ធនាការនោះមិនបានកែប្រែស្ថានភាពច្រើននោះទេ។ ទោះជាយ៉ាងនេះក្តី ច្បាប់ចម្លងនៃរបាយការណ៍នោះដែល VOA ទទួលបានសរសេរថា ចំនួនកុមារពិតប្រាកដដែលកំពុងធ្វើការនៅតាមឡឥដ្ឋអាចនឹងមានច្រើនជាងនេះ ដោយសារតែគេមិនអាចបែងចែករវាងចំនួនកុមាររស់នៅក្នុងបរិវេណឡឥដ្ឋ និងកុមារដែលធ្វើការនៅទីនោះ។

លោក Laurie Parsons ដែលជាសហនិពន្ធនៃរបាយការណ៍ខាងលើបាននិយាយនៅក្នុងបទសម្ភាសន៍មួយថា៖ «ខ្ញុំគិតថា មិនមានការបែងចែកច្បាស់លាស់រវាងកុមារចំនួន៦០០នាក់ ឬលើសពីនេះ និងកុមារជាង៣ពាន់នាក់ផ្សេងទៀត ដែលរស់នៅទីនោះទេ។ ក្នុងករណីភាគច្រើន កុមារទាំងនោះយ៉ាងហោចណាស់ក៏ធ្វើការតិចតួចដែរ។ ខ្ញុំគិតថា មានកុមារតិចណាស់ ដែលមិនបានធ្វើការផលិតឥដ្ឋទាល់តែសោះ។ វាច្បាស់ជាមានពេលដែលគ្រួសាររបស់ពួកគេរវល់ ហើយមានការបញ្ជាទិញច្រើន ឬនៅពេលដែលម្ចាស់ឡឥដ្ឋដាក់សម្ពាធ ឬគ្រួសារទទួលបានប្រាក់ឈ្នួលទៅតាមចំនួនឥដ្ឋ ឬពួកគេត្រូវការប្រាក់បន្ថែមទៀត។ ពួកគេទទួលបានប្រាក់កាន់តែច្រើន នៅពេលពួកគេអាចផលិតឥដ្ឋបានកាន់តែច្រើន ដូច្នេះពួកគេនឹងឱ្យកូនៗរបស់ពួកគេជួយ»។ លោកនិយាយថា ជាឧទាហរណ៍ ការងារភាគច្រើនសម្រាប់កុមារនៅសិប្បកម្មផលិតឥដ្ឋគឺជញ្ជូនឥដ្ឋពីឡឥដ្ឋទៅដាក់នៅលើរថយន្តដឹកឥដ្ឋ ឬក៏អាចដាក់ដីឥដ្ឋចូលទៅក្នុងម៉ាស៊ីនកិនដីឥដ្ឋផងដែរ។ លោកបន្ថែមថា៖ «ច្បាស់ណាស់ នេះគឺជាការងារដ៏គ្រោះថ្នាក់»។ កាលពីខែមីនា ឆ្នាំមុន កុមារីអាយុ១០ឆ្នាំម្នាក់បានបាត់បង់ដៃរបស់នាង នៅពេលដាក់ដីឥដ្ឋចូលទៅក្នុងម៉ាស៊ីនកិនដីឥដ្ឋ។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារបានបដិសេធលើការរកឃើញនេះដោយអន្លើ។ លោកនិយាយថា ការរកឃើញនេះផ្អែកទៅលើស្រាវជ្រាវរបស់ «ក្រុមអ្នកស្រាវជ្រាវដែលមិនមានវិជ្ជាជីវៈត្រឹមត្រូវ»។ លោក ហេង សួរ បាននិយាយថា៖ «មិនមានពលកម្មកុមារនៅក្នុងសិប្បកម្មផលិតឥដ្ឋនោះទេ»។ លោក ហេង សួរ បាននិយាយថា ក្រុមមន្ត្រីអធិការកិច្ចរបស់ក្រសួងបានចុះពិនិត្យគ្រប់សិប្បកម្មផលិតឥដ្ឋទាំងអស់នៅទូទាំងប្រទេស ប៉ុន្តែមិនបានរកឃើញថា មានពលកម្មកុមារនោះទេ។ លោកបាននិយាយថា ក្នុងពេលចុះត្រួតពិនិត្យ ម្ចាស់សិប្បកម្មផលិតឥដ្ឋ អ្នកគ្រប់គ្រង និងឪពុកម្តាយបានចុះហត្ថលេខាលើលិខិតយល់ព្រម ដោយអះអាងថា ពួកគេនឹងមានទោសព្រហ្មទណ្ឌ ប្រសិនបើគេរកឃើញថា មានកុមារចូលទៅក្នុងកន្លែងផលិតឥដ្ឋ។

ទោះជាយ៉ាងនេះក្តី លោក Parsons បាននិយាយថា សូម្បីតែកុមារដែលមិនធ្វើការនៅឡតដ្ឋក៏ប្រឈមនឹងហានិភ័យជាច្រើនដែរ។ លោក Parsons បាននិយាយថា គ្រោះថ្នាក់ដែលអាចកើតមាន រួមមានដូចជាការលោកភ្លើងកម្តៅរាប់រយអង់ស្សាសេដែលគេប្រើដើម្បីដុតឥដ្ឋ ផ្សែងពុលចេញពីភ្លើងដុតឥដ្ឋ និងឧស្ម័នពុលផ្សេងៗទៀត។ នេះមានន័យថា កុមារដែលរស់នៅតាមសិប្បកម្មផលិតឥដ្ឋជារឿយៗខ្វះជាតិទឹកធ្ងន់ធ្ងរ។ លោក Parsons បានលើកឡើងថា៖ «ទោះជាអ្នកមិនធ្វើការនៅទីនោះក៏ដោយ ក៏វាជាបរិស្ថានមិនល្អខ្លាំងសម្រាប់សុខភាព។ នេះជាមូលហេតុដែលធ្វើឲ្យគ្រប់គ្នាឈឺ»។

លោក ហេង សួរ បានទទួលស្គាល់ថា ពិតជាមានកុមាររស់នៅក្នុងបរិវេណសិប្បកម្មផលិតឥដ្ឋមែន ប៉ុន្តែលោកនៅតែអះអាងថា ពួកគេមិនបានធ្វើការនោះទេ។ ក៏ប៉ុន្តែ លោក យុន ថារូ បាននិយាយថា តាមរយៈការសង្កេតផ្ទាល់ខ្លួនរបស់លោក កុមារជាច្រើនបានជួយឪពុកម្តាយរបស់ពួកគេនៅក្នុងសិប្បកម្មទាំងនោះ។

លោក យុន ថារូ បាននិយាយថា «ពលកម្មកុមារនៅតែបន្តកើតមាន ពីមួយជំនាន់ទៅមួយជំនាន់»។ លោក យុន ថារូ បានបន្ថែមទៀតថា ត្រូវមានវិធីសាស្ត្រមួយដើម្បីដោះស្រាយនូវវិបត្តិបំណុល ដែលឪពុកម្តាយពួកគេយកប្រាក់កម្ចីពីម្ចាស់សិប្បកម្មផលិតឥដ្ឋដើម្បីផ្តាច់បំណុលចាស់ ហើយត្រូវផ្ទេរបំណុលទាំងនោះពីមួយជំនាន់ទៅមួយជំនាន់។ លោក យុន ថារូ ក៏បានលើកឡើងពីតម្រូវការក្នុងការធានាឱ្យបានថា កុមារនៅតាមសិប្បកម្មផលិតឥដ្ឋទាំងអស់បានទៅសាលារៀន ត្រូវអនុវត្តច្បាប់ឱ្យបានតឹងរ៉ឹងជាងមុន និងធានាថា សិប្បកម្មផលិតឥដ្ឋគោរពតាមស្តង់ដារសុវត្ថិភាពនិងសុខភាព និងត្រូវផ្តល់ធានារ៉ាប់រងសុខភាពដល់កម្មករផងដែរ៕

## គ្រោះថ្នាក់ចរាចរណ៍រថយន្តដឹកពលករខ្មែរ ចំនួន ៣២នាក់ ដើម្បីធ្វើដំណើរទៅតវីសា

https://www.facebook.com/officialworker/ 28.02.2020

ករណីគ្រោះថ្នាក់ចរាចរណ៍រថយន្តដឹកពលករខ្មែរ ចំនួន ៣២នាក់ ដើម្បីធ្វើដំណើរទៅតវីសា ប៉ុន្តែថៃជន្សកើតគ្រោះថ្នាក់តាមផ្លូវបណ្តាលឲ្យមានពលករខ្មែរ ០៤នាក់រងរបួសធ្ងន់ និងស្រាល ហេតុការណ៍គ្រោះថ្នាក់នេះបានកើតឡើងកាលពីវេលាម៉ោង០៨យប់ពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ កន្លងទៅ ចំណុចកើតហេតុនៅផ្លូវជាតិ តេតបុរី-ភេតកាសេមម្ពុំគីឡូម៉ែត្រលេខ១៤០ ស្ថិតនៅក្នុងភូមិ១ សង្កាត់ថាប់ខាង ស្រុកខៅណយ ខេត្តភេតបុរី ក្នុងហេតុការណ៍នេះមានពលករខ្មែររងរបួសចំនួន ០៤នាក់ ក្រោយពេលកើតហេតុជនរងគ្រោះត្រូវបានសមត្ថកិច្ចថៃបញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យខៅណយ ខេត្តភេតបុរី។

## រថយន្តដឹកពលករខ្មែរពីទីក្រុងបាងកកទៅធ្វើការសំណង់នៅខេត្តតីជីត ជួបគ្រោះថ្នាក់ចរាចរណ៍តាមផ្លូវបណ្តាលឲ្យមានពលកររបួសចំនួន ៤២នាក់

https://www.facebook.com/officialworker/ 27.02.2020

មានករណីរថយន្តដឹកពលករខ្មែរពីទីក្រុងបាងកកទៅធ្វើការសំណង់នៅខេត្តតីជីត ជួបគ្រោះថ្នាក់ចរាចរណ៍តាមផ្លូវបណ្តាលឲ្យមានពលកររបួសចំនួន ៤២នាក់ ហេតុការណ៍នេះបានកើតឡើងកាលពីវេលាម៉ោង០៨យប់ ត្រូវនិង ថ្ងៃព្រហស្បតិ៍ ទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ករណីគ្រោះថ្នាក់ចរាចរណ៍នេះបានកើតឡើងនៅលើផ្លូវជាតិលេខ១១៧ សាយណាខនសុវណ្ណភីសុតនលោក ត្រង់ចំណុចគីឡូម៉ែត្រ៨០-៨១ ស្ថិតក្នុងភូមិ៥ សង្កាត់ណើនប៉ ស្រុកសាយងាម ខេត្តតីជីត ប្រទេសថៃ ។ បច្ចុប្បន្នជនរងគ្រោះត្រូវបានសមត្ថកិច្ចថៃបញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យខេត្តតីជីត យោងតាមប្រភពព័ត៌មានបឋម ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍នេះមិនមានពលករស្លាប់បាត់បង់ជីវិតនោះ។